# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

## សារត្ថប្បកាសិនី

## ភាគ ៣២

## និទានវគ្គ ចតុត្ថភាគ

ពុទ្ធសករាជ ២៥៥៦

អធិប្បាយ

## និទានវគ្គ ចតុត្ថភាគ

រួមមាន ៨ សំយុត្ត អដ្ឋកថាកែ ១៥០ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

# សារត្ថប្បកាសិនី

## ភាគ ៣២

## និទានវគ្គ ចតុត្ថភាគ

ពុទ្ធសករាជ ២៥៥៦

អធិប្បាយ

## និទានវគ្គ ចតុត្ថភាគ

រួមមាន ៨ សំយុត្ត អដ្ឋកថាកែ៧៥០សូត្រ

# និទានវគ្គ ចតុត្ថភាគ

## រួមមាន ៧ សំយុត្ត

| | | | |
|---|---|---|---|
| ១-ធាតុសំយុត្ត | មាន | ៣៦ | អដ្ឋកថា |
| ២-អនមតគ្គសំយុត្ត | មាន | ១៦ | អដ្ឋកថា |
| ៣-កស្សបសំយុត្ត | មាន | ១៣ | អដ្ឋកថា |
| ៤-លាភសក្ការសំយុត្ត | មាន | ២៨ | អដ្ឋកថា |
| ៥-រាហុលសំយុត្ត | មាន | ១២ | អដ្ឋកថា |
| ៦-លក្ខណសំយុត្ត | មាន | ២១ | អដ្ឋកថា |
| ៧-ឱបម្មសំយុត្ត | មាន | ១២ | អដ្ឋកថា |
| ៨-ភិក្ខុសំយុត្ត | មាន | ១២ | អដ្ឋកថា |

រួមក្នុងសំយុត្តទាំងនេះ មាន ១៣ វគ្គ ព្រះអដ្ឋកថាចានកែសេចក្តី

ដែលលំចាកចំនួន ១៥០ សូត្រ

# ស្រៈនិងស្រ័យ

# *Signes et accents:*



# ស្រះពេញតួ

# *Voyelles:*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូប Romain | a | ā | i | ī | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# *Consonnes.*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រូប<br>Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម<br>Siamois | ก | ข | ค | ฆ | ง |
| លាវ<br>Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា<br>Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា<br>Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຊ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្ដី*

រីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្ដីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាម អាចារ្យរបស់ខ្លួន ទួន្ទានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយ ច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមក ហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះ ខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយ ខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បី ខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញុំាញ់វត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថាពុទ្ធមន្ត ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនាបានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវ័ក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុឋៈ ) ខ្លះ ( សិរិកូដ្ឋៈ ) ខ្លះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្តាប់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យនាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយទមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-នឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន

ឧបាសក នាក់ ម៉ៅ

ឧបាសក ទុំ ទួន

ឧបាសក ហុក សឹងហួត

ឧបាសក ជឹម ជំនិត

ឧបាសក កើត ទិត្យ

ឧបាសក សន ម៉ារឌី

ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក សុក្រ ហ៊ត

ឧបាសក សោម រតនៈ

ឧបាសក សំ ឆាយ

ឧបាសក ម៉ៅ ផុន

ឧបាសក ជា ស៊ីបាន

ឧបាសិកា ថាប់ លឿម

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៊ុត សេដាដួង

ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នួវ ប៉ូវ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ឆុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

| | |
|---|---|
| ឧបាសក ក្អាត ហ៊ន | ឧបាសក ហាយ ចំរើន |
| ឧបាសក ហុក សឹងហួត | ឧបាសក អ៊ឹម រ៉ៃយ៉ា |
| ឧបាសក ឈួន សំណាង | ឧបាសក ឃឿម សារ៉េន |

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

ឈ្មោះធម៌ | ទំព័រ

## ធាតុសំយុត្ត

### បឋមវគ្គ


| | | |
|---|---|---|
| អដ្ឋកថា ធាតុសូត្រ | ទី ១ | ១ |
| អដ្ឋកថា សម្ផស្សសូត្រ | ទី ២ | ៣ |
| អដ្ឋកថា នោសម្ផស្សសូត្រ | ទី ៣ | ៤ |
| អដ្ឋកថា វេទនាសូត្រ | ទី ៤ | ៥ |
| អដ្ឋកថា នោវេទនាសូត្រ | ទី ៥ | ៦ |
| អដ្ឋកថា ពាហិរធាតុសូត្រ | ទី ៦ | ៧ |
| អដ្ឋកថា សញ្ញាសូត្រ | ទី ៧ | ៨ |
| អដ្ឋកថា នោបរិយេសនាសូត្រ | ទី ៨ | ១០ |
| អដ្ឋកថា ផស្សសូត្រ | ទី ៩ | ១១ |
| អដ្ឋកថា នោផស្សសូត្រ | ទី ១០ | ១៥ |


### ទុតិយវគ្គ


| | | |
|---|---|---|
| អដ្ឋកថា សត្តធាតុសូត្រ | ទី ១ | ១៦ |
| អដ្ឋកថា សនិទានសូត្រ | ទី ២ | ១៩ |
| អដ្ឋកថា គិញ្ជកាវសថសូត្រ | ទី ៣ | ២៥ |
| អដ្ឋកថា ហីនាធិមុត្តិសូត្រ | ទី ៤ | ២៨ |

| | | |
|---|---|---|
| អដ្ឋកថា ចង្កមសូត្រ | ទី ៥ | ២៩ |
| អដ្ឋកថា សតាចារទ្ធសូត្រ | ទី ៦ | ៣៦ |
| អដ្ឋកថា បឋមអស្សទ្ធសូត្រ | ទី ៧ | ៣៧ |
| អដ្ឋកថា អស្សទ្ធមូលកសូត្រ | ទី ៨ | ៣៩ |


## ទសកម្មបថវគ្គ


| | | |
|---|---|---|
| អដ្ឋកថា អសមាហិតសូត្រ | ទី ១ | ៤១ |
| អដ្ឋកថា ទុស្សីលាសូត្រ | ទី ២ | ៤១ |
| អដ្ឋកថា បញ្ចសិក្ខាបទសូត្រ | ទី ៣ | ៤២ |
| អដ្ឋកថា ទសកម្មបថសូត្រ | ទី ៥ | ៤៣ |
| អដ្ឋកថា អដ្ឋង្គិកសូត្រ | ទី ៦ | ៦៣ |
| អដ្ឋកថា ទសង្គិកសូត្រ | ទី ៧ | ៦៤ |


## ចតុទ្វាតុវគ្គ


| | | |
|---|---|---|
| អដ្ឋកថា ចតស្សសូត្រ | ទី ១ | ៦៥ |
| អដ្ឋកថា បុព្វសូត្រ | ទី ២ | ៦៦ |
| អដ្ឋកថា អចិរសូត្រ | ទី ៣ | ៧៣ |
| អដ្ឋកថា ឆោចេទសូត្រ | ទី ៤ | ៧៤ |
| អដ្ឋកថា ទុក្ខសូត្រ | ទី ៥ | ៧៦ |
| អដ្ឋកថា អភិនន្ទសូត្រ | ទី ៦ | ៧៧ |
| អដ្ឋកថា ឧប្បាទសូត្រ | ទី ៧ ជាដើម | ៧៨ |

## អនមតគ្គសំយុត្ត

### បឋមវគ្គ


| | | |
|---|---|---|
| អដ្ឋកថា តិណកដ្ឋសូត្រ | ទី ១ | ៧៩ |
| អដ្ឋកថា បឋវីសូត្រ | ទី ២ | ៨២ |
| អដ្ឋកថា អស្សុសូត្រ | ទី ៣ | ៨៣ |
| អដ្ឋកថា ខីរសូត្រ | ទី ៤ | ៨៥ |
| អដ្ឋកថា បព្វតសូត្រ | ទី ៥ | ៨៦ |
| អដ្ឋកថា សាសបសូត្រ | ទី ៦ | ៨៧ |
| អដ្ឋកថា សាវកសូត្រ | ទី ៧ | ៨៨ |
| អដ្ឋកថា គង្គាសូត្រ | ទី ៨ | ៨៩ |
| អដ្ឋកថា ទណ្ឌសូត្រ | ទី ៩ | ៩០ |
| អដ្ឋកថា បុគ្គលសូត្រ | ទី ១០ | ៩១ |


### ទុតិយវគ្គ


| | | |
|---|---|---|
| អដ្ឋកថា ទុគ្គតសូត្រ | ទី ១ | ៩៣ |
| អដ្ឋកថា សុខិតសូត្រ | ទី ២ | ៩៤ |
| អដ្ឋកថា តិង្សមត្តាសូត្រ | ទី ៣ | ៩៥ |
| អដ្ឋកថា មាតុសូត្រ | ទី៤ជាដើម | ៩៦ |
| អដ្ឋកថា វេបុល្លបព្វតសូត្រ | ទី ១០ | ៩៧ |


## កស្សបសំយុត្ត

អដ្ឋកថា សន្តុដ្ឋសូត្រ ទី ១ ១០០
អដ្ឋកថា អនោត្តបីសូត្រ ទី ២ ១០៨
អដ្ឋកថា ចន្ទូបមសូត្រ ទី ៣ ១១១
អដ្ឋកថា កុលូបកសូត្រ ទី ៤ ១២១
អដ្ឋកថា ជិណ្ណសូត្រ ទី ៥ ១២២
អដ្ឋកថា បឋមឱវាទសូត្រ ទី ៦ ១២៩
អដ្ឋកថា ទុតិយឱវាទសូត្រ ទី ៧ ១៣១
អដ្ឋកថា តតិយឱវាទសូត្រ ទី ៨ ១៣២
អដ្ឋកថា ឈានាភិញ្ញាសូត្រ ទី ៩ ១៣៤
អដ្ឋកថា ភិក្ខុនូបស្សយសូត្រ ទី ១០ ១៣៦
អដ្ឋកថា ចីវរសូត្រ ទី ១១ ១៤០
អដ្ឋកថា បរម្មរណាសូត្រ ទី ១២ ១៨៩
អដ្ឋកថា សទ្ធម្មប្បដិរូបសូត្រ ទី ១៣ ១៩០

# លាភសក្ការសំយុត្ត

## សុទ្ធកវគ្គ

អដ្ឋកថា សុទ្ធកសូត្រ ទី ១ ១៩៩
អដ្ឋកថា ពឡិសសូត្រ ទី ២ ២០០
អដ្ឋកថា កុម្មសូត្រ ទី ៣ ២០១
អដ្ឋកថា ទីឃលោមសូត្រ ទី ៤ ២០៣
អដ្ឋកថា ឯឡកសូត្រ ទី ៥ ២០៤

| | | | |
|---|---|---|---|
| អដ្ឋកថា | អសនិសូត្រ | ទី ៦ | ២០៥ |
| អដ្ឋកថា | ទិដ្ឋិសូត្រ | ទី ៧ | ២០៦ |
| អដ្ឋកថា | សិង្គាលសូត្រ | ទី ៨ | ២០៧ |
| អដ្ឋកថា | វេរម្ភសូត្រ | ទី៩ | ២០៨ |
| អដ្ឋកថា | សគយ្ហកសូត្រ | ទី ១០ | ២១០ |

## ជាតិវគ្គ

| | | | |
|---|---|---|---|
| អដ្ឋកថា | សុវណ្ណជាតិសូត្រ | ទី ១ | ២១១ |
| អដ្ឋកថា | រូបិយជាតិសូត្រ | ទី ២ | ២១២ |
| អដ្ឋកថា | សុវណ្ណនិក្ខសូត្រ | ទី ៣ | ២១៣ |

## មាតុគាមវគ្គ

| | | | |
|---|---|---|---|
| អដ្ឋកថា | មាតុគ្រាមសូត្រ | ទី ១ | ២១៤ |
| អដ្ឋកថា | បុត្តសូត្រ | ទី ៣ | ២១៦ |
| អដ្ឋកថា | សមណព្រាហ្មណសូត្រ | ទី ៧ | ២១៧ |
| អដ្ឋកថា | ជវិសូត្រ | ទី ៨ | ២១៨ |
| អដ្ឋកថា | វុឌ្ឍិសូត្រ | ទី ៩ | ២១៩ |
| អដ្ឋកថា | ភិក្ខុសូត្រ | ទី ១០ | ២២០ |

## ភេទវគ្គ

| | | | |
|---|---|---|---|
| អដ្ឋកថា | ភិន្ទិសូត្រ | ទី ១ | ២២១ |

| | | | |
|---|---|---|---|
| អដ្ឋកថា | មូលសូត្រ | ទី ២ ជាដើម | ២២២ |
| អដ្ឋកថា | បការន្តសូត្រ | ទី ៥ | ២២៣ |
| អដ្ឋកថា | រថសូត្រ | ទី ៦ | ២២៤ |
| អដ្ឋកថា | មាតុសូត្រ | ទី ៧ | ២២៥ |


## លាភសក្ការសំយុត្ត

### អប្បមានវគ្គ


| | | | |
|---|---|---|---|
| អដ្ឋកថា | ចក្ខុសូត្រ | ទី ១ | ២២៦ |
| អដ្ឋកថា | រូបសូត្រ | ទី ២ | ២២៨ |
| អដ្ឋកថា | វិញ្ញាណសូត្រ | ទី ៣ | ២២៩ |
| អដ្ឋកថា | សញ្ញាសូត្រ | ទី ៦ | ២៣០ |
| អដ្ឋកថា | តណ្ហាសូត្រ | ទី ៨ | ២៣១ |
| អដ្ឋកថា | ធាតុសូត្រ | ទី ៩ | ២៣២ |
| អដ្ឋកថា | ខន្ធសូត្រ | ទី ១០ | ២៣៣ |
| អដ្ឋកថា | ចាប់ពីសូត្រទី ១ ដល់ទី ១០ ងាយទាំងអស់ | | ២៣៤ |
| អដ្ឋកថា | អនុសយសូត្រ | ទី ១១ | ២៣៥ |
| អដ្ឋកថា | អបគតសូត្រ | ទី ១២ | ២៣៦ |


## លក្ខណសំយុត្ត

### អដ្ឋិសង្ខលិកវគ្គ


| | | | |
|---|---|---|---|
| អដ្ឋកថា | អដ្ឋិសូត្រ | ទី ១ | ២៣៧ |

| | | |
|---|---|---|
| អដ្ឋកថា បេសិសូត្រ | ទី ២ | ៣៤៣ |
| អដ្ឋកថា បិណ្ឌសូត្រ | ទី ៣ | ២៤៤ |
| អដ្ឋកថា និច្ឆវិសូត្រ | ទី ៤ | ២៤៥ |
| អដ្ឋកថា អសិសូត្រ | ទី ៥ | ២៤៦ |
| អដ្ឋកថា សត្តិសូត្រ | ទី ៦ | ២៤៧ |
| អដ្ឋកថា ឧសុសូត្រ | ទី ៧ | ២៤៨ |
| អដ្ឋកថា បឋមសូចិសូត្រ | ទី ៨ | ២៤៩ |
| អដ្ឋកថា ទុតិយសូចិសូត្រ | ទី ៩ | ២៥០ |
| អដ្ឋកថា អណ្ឌភារីសូត្រ | ទី ១០ | ២៥១ |


## ឃរាវារិកវគ្គ


| | | |
|---|---|---|
| អដ្ឋកថា កូបនិមុគ្គសូត្រ | ទី ១ | ២៥៣ |
| អដ្ឋកថា គូថខាទិសូត្រ | ទី ២ | ២៥៤ |
| អដ្ឋកថា និច្ឆវិត្ថីសូត្រ | ទី ៣ | ២៥៥ |
| អដ្ឋកថា មង្គុឡិត្ថីសូត្រ | ទី ៤ | ២៥៦ |
| អដ្ឋកថា ឱកិលិនីសូត្រ | ទី ៥ | ២៥៧ |
| អដ្ឋកថា សីសច្ឆិន្នសូត្រ | ទី ៦ | ២៥៩ |
| អដ្ឋកថា ភិក្ខុសូត្រ | ទី ៧ | ២៦០ |
| អដ្ឋកថា ភិក្ខុនីសូត្រ | ទី ៨ ជាដើម | ២៦១ |


## ឱបម្មសំយុត្ត

អដ្ឋកថា កូដាគារសូត្រ ទី ១ ២៦២  
អដ្ឋកថា នខសិខសូត្រ ទី ២ ២៦៣  
អដ្ឋកថា កុលសូត្រ ទី ៣ ២៦៤  
អដ្ឋកថា ឱក្ខាសូត្រ ទី ៤ ២៦៦  
អដ្ឋកថា សត្តិសូត្រ ទី ៥ ២៦៨  
អដ្ឋកថា ធនុគ្គហសូត្រ ទី ៦ ២៦៩  
អដ្ឋកថា អាណីសូត្រ ទី ៧ ២៧៤  
អដ្ឋកថា កលិង្គរសូត្រ ទី ៨ ២៧៩  
អដ្ឋកថា នាគសូត្រ ទី ៩ ២៨២  
អដ្ឋកថា វិឡារសូត្រ ទី ១០ ២៨៤  
អដ្ឋកថា បឋមសិគាលសូត្រ ទី ១១ ២៨៥  
អដ្ឋកថា ទុតិយសិគាលសូត្រ ទី ១២ ២៨៦

## ភិក្ខុសំយុត្ត

អដ្ឋកថា កោលិតសូត្រ ទី ១ ២៨៨  
អដ្ឋកថា ឧបតិស្សសូត្រ ទី ២ ២៩០  
អដ្ឋកថា ឃដសូត្រ ទី ៣ ២៩១  
អដ្ឋកថា នវសូត្រ ទី ៤ ២៩៥  
អដ្ឋកថា សុជាតសូត្រ ទី ៥ ២៩៦  
អដ្ឋកថា ភទ្ទិយសូត្រ ទី ៦ ២៩៧  
អដ្ឋកថា វិសាខសូត្រ ទី ៧ ៣០២

| | | |
|---|---|---|
| អដ្ឋកថា ឆន្ទសូត្រ | ទី ៨ | ៣០៣ |
| អដ្ឋកថា តិស្សសូត្រ | ទី ៩ | ៣០៥ |
| អដ្ឋកថា ធាមសូត្រ | ទី ១០ | ៣១៣ |
| អដ្ឋកថា កប្បិនសូត្រ | ទី ១១ | ៣១៥ |
| អដ្ឋកថា សាហាយសូត្រ | ទី ១២ | ៣២៥ |

# អដ្ឋកថា ព្រះសុត្តន្តបិដក

# ឈ្មោះ សារត្ថប្បកាសិនី

## អដ្ឋកថា សំយុត្តនិកាយ

### និទានវគ្គ ចតុត្ថភាគ

### លេខ ៣២

# ធាតុសំយុត្ត

## នានត្តវគ្គទី ១

## អ ដ្ឋ ក ថា

## ធាតុសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង ធាតុសូត្រទី ១ នៃនានត្តវគ្គ ដូចតទៅនេះ ៖*

[១] *ភាវៈនៃធម៌មានសភាពផ្សេងគ្នា បានឈ្មោះថា ធាតុ ព្រោះអត្ថថា ជាសភាវៈ ពោលគឺ មានអត្ថថា មិនមែនសត្វ និងអត្ថថា ជារបស់សូន្យ ដូច្នេះ ឈ្មោះថា សេចក្តីផ្សេងនៃធាតុ ។*

[២] ក្នុងបទជាដើមថា **ចក្ខុធាតុ** សេចក្តីថា ចក្ខុបសាទ ឈ្មោះថា ចក្ខុធាតុ , រូបារម្មណ៍ ឈ្មោះថា រូបធាតុ , ចិត្តដែលមានចក្ខុបសាទជាទីអាស្រ័យ ឈ្មោះថា ចក្ខុវិញ្ញាណធាតុ ។ សោតបសាទ ឈ្មោះថា សោតធាតុ, សទ្ទារម្មណ៍ ឈ្មោះថា សទ្ទធាតុ, ចិត្តដែលមានសោតបសាទជាទីអាស្រ័យ ឈ្មោះថា សោតវិញ្ញាណធាតុ, ឃានបសាទ ឈ្មោះថា ឃានធាតុ គន្ធារម្មណ៍ ឈ្មោះថា គន្ធធាតុ, ចិត្តដែលមានឃានបសាទជាទីអាស្រ័យ ឈ្មោះថា ឃានវិញ្ញាណធាតុ ។ ជិវ្ហាប្រាសាទ ឈ្មោះថា ជិវ្ហាធាតុ រសារម្មណ៍ ឈ្មោះថា រសធាតុ, ចិត្តដែលមានជិវ្ហាបសាទជាទីអាស្រ័យ ឈ្មោះថា ជិវ្ហាវិញ្ញាណធាតុ, កាយបសាទ ឈ្មោះថា កាយធាតុ, ផោដ្ឋព្វារម្មណ៍ ឈ្មោះថា ផោដ្ឋព្វធាតុ, ចិត្តដែលមានកាយបសាទជាទីអាស្រ័យ ឈ្មោះថា កាយវិញ្ញាណធាតុ ។ មនោធាតុ ៣ ឈ្មោះថា មនោធាតុ, ខន្ធ ៣ មានវេទនាជាដើម សុខុមរូប និងនិព្វាន ឈ្មោះថា ធម្មធាតុ, មនោវិញ្ញាណ សូម្បីទាំងអស់ ឈ្មោះថា មនោវិញ្ញាណធាតុ, ក៏ក្នុងសេចក្តីនេះ ធាតុ ១៦ យ៉ាង ជាកាមាវចរ ធាតុ ២ ខាងចុងប្រព្រឹត្តទៅក្នុងភូមិ ៤ ។

ចប់អដ្ឋកថា ធាតុសូត្រទី ១

# អ ដ្ឋ ក ថា

## សម្ផស្សសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង សម្ផស្សសូត្រទី ២ ដូចតទៅនេះ ៖*

[៣] *បទថា* **ឧប្បជ្ជតិ ផស្សនានត្តំ** *បានដល់ ផស្សៈមានសភាពផ្សេងៗ គ្នា រមែងកើតឡើង ។ ក្នុងផស្សៈនោះ ចក្ខុសម្ផស្សជាដើម ប្រកបនឹងចក្ខុវិញ្ញាណជាដើម មនោសម្ផស្ស ប្រកបនឹងបឋមជវនៈក្នុងមនោទ្វារ ។ ព្រោះដូច្នោះ ក្នុងសេចក្តីនេះ មានអត្ថដូច្នេះថា បទថា* **មនោធាតុំ បដិច្ច** *បានដល់ បឋមជវនសម្ផស្ស កើតឡើងព្រោះអាស្រ័យមនោទ្វារាវជ្ជនៈ ដែលជាកិរិយាមនោវិញ្ញាណធាតុ ។*

ចប់អដ្ឋកថា សម្ផស្សសូត្រទី ២

# អ ដ្ឋ ក ថា

## នោសម្ផស្សសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង នោសម្ផស្សសូត្រទី ៣ ដូចតទៅនេះ ៖*

[៦] *បទថា នោ មនោសម្ផស្សំ បដិច្ច ឧប្បជ្ជតិ មនោធាតុ គប្បីឃើញសេចក្តីយ៉ាងនេះថា អាវជ្ជនៈ កិរិយាមនោវិញ្ញាណធាតុនឹងកើតឡើងព្រោះអាស្រ័យផស្សៈដែលប្រកបនឹងបឋមជវនៈក្នុងមនោទ្វារ ក៏មិនមែន ។*

ចប់អដ្ឋកថា នោសម្ផស្សសូត្រទី ៣

# អ ដ្ឋ ក ថា

## វេទនាសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង **វេទនាសូត្រទី ៤** ដូចតទៅនេះ ៖

[៨] បទថា **ចក្ខុសម្ផស្សជាវេទនា** លោកអធិប្បាយថា តាំងពីសម្បដិច្ឆន្នមនោធាតុ វេទនាសូម្បីទាំងពួង គប្បីប្រព្រឹត្តទៅក្នុងទ្វារនោះ តែការកាន់សម្បដិច្ឆន្នវេទនាក្នុងលំដាប់ ដើម្បីងាយក្នុងការកើត ក៏គួរ ។ បទថា **មនោសម្ផស្សំ បដិច្ច** មានអធិប្បាយដូច្នេះថា បឋមជវនវេទនា កើតឡើងព្រោះអាស្រ័យអាវជ្ជនសម្ផស្សក្នុងមនោទ្វារ ទុតិយជវនវេទនា កើតឡើងព្រោះអាស្រ័យបឋមជវនសម្ផស្ស ដូច្នេះឯង ។

ចប់អដ្ឋកថា វេទនាសូត្រទី ៤

# អ ដ្ឋ ក ថា

## នោវេទនាសូត្រទី ៥

[៩] *គប្បីជ្រាបវិនិច្ឆ័យក្នុង នោវេទនាសូត្រទី ៥ ដូចតទៅនេះ ៖*

*លោកសម្តែងន័យដូចពោលទុកហើយក្នុងសូត្រទី ៣ និងសូត្រទី ៤ រួមជាមួយគ្នា ។ ក្នុង ៤ សូត្រ មានសូត្រទី ២ ជាដើម លោកមិនកាន់យក មនោធាតុថាជាមនោធាតុ តែកាន់យកមនោទ្វារាវជ្ជនៈថា មនោធាតុ ។ កាល លោកពោលយ៉ាងនោះ ក៏សូត្រទាំងអស់នោះ លោកសម្តែងតាមអធ្យាស្រ័យ របស់បុគ្គលអ្នកយល់ដឹង ។ សូម្បីក្នុងសូត្រដទៃអំពីនេះ ក៏មានន័យនេះឯង ។*

ចប់អដ្ឋកថា នោវេទនាសូត្រទី ៥

# អ ដ្ឋ ក ថា

## ពាហិរធាតុសូត្រទី ៦

[១១] *ចំណែកក្នុងសូត្រទី ៦, ធាតុ ៥ ជាកាមាវចរ ធម្មធាតុប្រព្រឹត្តទៅក្នុងភូមិ ៤ ។*

ចប់អដ្ឋកថា ពាហិរធាតុសូត្រទី ៦

# អ ដ្ឋ ក ថា

## សញ្ញាសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុង សញ្ញាសូត្រទី ៧ ដូចតទៅនេះ ៖

[១២] បទថា *រូបធាតុ* សេចក្តីថា រូបារម្មណ៍ បានដល់ សំពត់ជូតក្បាលជាដើមរបស់ខ្លួន ឬរបស់អ្នកដទៃ តាំងនៅក្នុងនៃគន្លងចក្ខុ ។

[១៣] បទថា *រូបសញ្ញា* បានដល់ រូបសញ្ញា ប្រកបទឹងចក្ខុវិញ្ញាណ ។ បទថា *រូបសង្កប្បោ* សេចក្តីថា សេចក្តីត្រិះរិះ ប្រកបដោយចិត្ត ៣ ដួងមានសម្បដិច្ឆន្នៈជាដើម ។ បទថា *រូបឆន្ទោ* បានដល់ ឈ្មោះថា ឆន្ទៈ ព្រោះអត្ថថា មានសេចក្តីពេញចិត្តក្នុងរូប ។

បទថា *រូបបរិឡាហោ* បានដល់ ឈ្មោះថា *បរិឡាហៈ* ព្រោះអត្ថថា តាមដុតរូប ។ បទថា *រូបបរិយេសនា* សេចក្តីថា កាលសេចក្តីក្តៅក្រហាយកើតឡើងក្នុងសម្មាញ់ដែលឃើញ និងសម្មាញ់ដែលធ្លាប់អាស្រ័យ គេទាំងនោះបានបែកទៅហើយ ក៏ស្វែងរកដើម្បីបានដឹងរូបនោះ ។ ចំណែកក្នុងទីនេះ សញ្ញា សង្កប្បៈ និងឆន្ទៈ (កើត) បានក្នុងជវនវារៈតែមួយជាមួយគ្នាខ្លះ

*ក្នុងជវនវារៈផ្សេងគ្នាខ្លះ ។ ចំណែក* ***បរិឡាហៈ*** *និង* ***បរិយេសនា*** *បានក្នុងជវនវារៈផ្សេងគ្នាតែម្យ៉ាង ។*

*ក្នុងបទថា* ***ឯវំ ខោ ភិក្ខវេ ធាតុនានត្តំ*** *នេះ គប្បីជ្រាបសេចក្ដីដោយន័យនេះថា សញ្ញាមានសភាពផ្សេងគ្នា មានរូបសញ្ញាជាដើម រមែងកើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា មានរូបជាដើម ។*

ចប់អដ្ឋកថា សញ្ញាសូត្រទី ៧

# អ ដ្ឋ ក ថា

## នោបរិយេសនាសូត្រទី ៨

*ក្នុងសូត្រទី ៨ មានសេចក្តីផ្សេងគ្នាត្រឹមតែបដិសេធប៉ុណ្ណោះ មកហើយយ៉ាងនេះថា* ***ធម្មបរិឡាហៈ*** *នឹងកើតឡើងព្រោះអាស្រ័យធម្មបរិយេសនា ក៏មិនមែន ។*

ចប់អដ្ឋកថា នោបរិយេសនាសូត្រទី ៨

# អ ដ្ឋ ក ថា

## ផស្សសូត្រទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុង ផស្សសូត្រទី ៩ ដូចតទៅនេះ ៖

[១៧] បទថា **ឧប្បជ្ជតិ រូបសញ្ញា** បានដល់ សញ្ញារមែងកើតឡើងក្នុងអារម្មណ៍ មានប្រការដូចពោលហើយ ។ បទថា **រូបសង្កប្បោ** បានដល់សេចក្ដីត្រិះរិះដោយចិត្ត ៣ ដួង ក្នុងអារម្មណ៍នោះឯង ។ បទថា **រូបសម្ផស្សោ** បានដល់ ផស្សៈដែលប៉ះខ្ទប់នឹងអារម្មណ៍នោះៗ ។ បទថា **វេទនា** បានដល់ វេទនាក្នុងការសោយអារម្មណ៍នោះឯង ។ **ធម៌** មានឆន្ទៈជាដើម មានន័យតាមដែលពោលហើយនោះឯង ។ បទថា **រូបលាភោ** សេចក្ដីថា អារម្មណ៍ដែលខ្លួនស្វែងរកបាន ព្រមជាមួយតណ្ហា ហៅថា **រូបលាភៈ** ។ ន័យដែលរួមទុកទាំងអស់នេះ គ្រាដំបូង លោកពោលទុកដោយអំណាចការកើតឡើងនៃធម៌ទាំងពួង ក្នុងអារម្មណ៍តែមួយប៉ុណ្ណោះ ។ ន័យមួយទៀតលាយនឹងអារម្មណ៍ដែលចរមក ។ គ្រាដំបូង ធម៌ ៤ ទាំងនេះ គឺ **រូបសញ្ញា រូបសង្កប្បៈ ផស្សៈ វេទនា** មាននៅក្នុងអារម្មណ៍ដែលបន្តជាប់គ្នាមិនដាច់ ជាអារម្មណ៍គួរប្រាថ្នា គួរត្រេកអរ គួរពេញចិត្ត គួរស្រឡាញ់ រមែងប្រាកដ

ដូចមានអារម្មណ៍យ៉ាងណាមួយ (មកឲ្យដឹង) ។ ចំណែកអារម្មណ៍ដែលចរមក ធ្វើឲ្យអារម្មណ៍ណាមួយដែលមាន ឲ្យកម្រើកឡើង ហើយតាំងនៅ ។

ក្នុងសេចក្តីនោះមានរឿងដូច្នេះ បានឮថា បុត្រអាមាត្រម្នាក់ ដែលជាអ្នកនៅក្នុងស្រុក ហែហមនៅកណ្តាលស្រុកធ្វើការងារ ។ ក៏សម័យនោះ ឧបាសិការបស់គេទៅកាន់ទន្លេ ងូតទឹកស្រេចហើយ ក៏តាក់តែងដោយគ្រឿងប្រដាប់ដែលពួកបងចិញ្ចឹមហែហមត្រឡប់មកផ្ទះ ។ គេឃើញពីចម្ងាយ ក៏កើតសេចក្តីសម្គាល់ឡើងថា មាតុគ្រាមជាភ្ញៀវនឹងមាន ដូច្នេះ ហើយទើបបញ្ជូនបុរសទៅ ដោយពោលថា នែនាយ អ្នកចូរទៅ ចូរដឹងស្រីនោះថាជាអ្នកណា ។ គេទៅឃើញស្រីនោះហើយត្រឡប់មក ត្រូវបុត្តអាមាត្យសួរថា ស្រីនុ៎ះជាអ្នកណាហ្ន៎ ទើបប្រាប់តាមការពិត យ៉ាងណា អារម្មណ៍ដែលចរមក រមែងធ្វើឲ្យកម្រើកឡើងយ៉ាងនេះ សេចក្តីពេញចិត្តដែលកើតឡើងក្នុងអារម្មណ៍នោះ ឈ្មោះថា **រូបឆន្ទៈ** សេចក្តីក្តៅក្រហាយ ដែលកើតឡើងព្រោះធ្វើរូបឆន្ទៈនោះឯងឲ្យជាអារម្មណ៍ ឈ្មោះថា **រូបបរិឡាហៈ** ។ ការនាំយកសម្លាញ់ទៅស្វែងរករូបនោះ ឈ្មោះថា **រូបបរិយេសនា** ។ អារម្មណ៍ដែលខ្លួនស្វែងរកបានព្រមជាមួយតណ្ហា ឈ្មោះថា **រូបលាភៈ** ។

ចំណែកព្រះចូឡតិស្សត្ថេរៈអ្នកនៅក្នុងឧរុវេលា ពោលថា ផស្សៈ

និងវេទនា ព្រះមានព្រះភាគទ្រង់កាន់យកត្រង់កណ្តាល តាមលំដាប់ យ៉ាង នោះក៏ពិត ទោះជាយ៉ាងនោះ តែកាលផ្លាស់លំដាប់ សញ្ញាដែលកើតឡើង ក្នុងអារម្មណ៍ មានប្រការដូចពោលហើយ ឈ្មោះថា **រូបសញ្ញា** ។ សេចក្តី ត្រិះរិះក្នុងរូបនោះឯង ឈ្មោះថា **រូបសង្កប្ប:** ។ សេចក្តីពេញចិត្តក្នុងរូប- សង្កប្ប:នោះ ឈ្មោះថា **រូបឆន្ទ:** ។ សេចក្តីក្តៅក្រហាយក្នុងរូបឆន្ទ:នោះ ឈ្មោះថា **រូបបរិឡាហ:** ។ ការស្វែងរកក្នុងរូបបរិឡាហ:នោះ ឈ្មោះថា **រូបបរិយេសនា** ។ អារម្មណ៍ដែលខ្លួនស្វែងរកបានព្រមជាមួយតណ្ហា ឈ្មោះ ថា **រូបលាភ:** ចំណែកការពាល់ត្រូវក្នុងអារម្មណ៍ ដែលបានហើយយ៉ាងនេះ ឈ្មោះថា **ផស្ស:** ។ ការសោយ ឈ្មោះថា **វេទនា** ។ គេរមែងបានធម៌ពីរ ទាំងនេះ គឺ រូបផស្ស: និងរូបសម្ផស្សជាវេទនា ។ ជនទាំងឡាយកាន់យក អារម្មណ៍ ឈ្មោះវារ:នៃអារម្មណ៍ដែលមិនប្រាកដច្បាស់សូម្បីដទៃទៀត ។ ពិតណាស់ អារម្មណ៍ (គឺរូប) ដែលគេដាក់លោមព័ទ្ធទុកដោយវាំងនន និង កំពែង ឬថា បិទបាំងបានដោយស្មៅ និងស្លឹកឈើជាដើម ។ កាលក្រឡេក មើលអារម្មណ៍នោះ ក៏គិតថា រូបារម្មណ៍នោះ ដែលយើងឃើញហើយម្តង យើងមិនឃើញរូបារម្មណ៍នោះច្បាស់ សញ្ញាដែលកើតឡើងក្នុងអារម្មណ៍នោះ ឈ្មោះថា **រូបសញ្ញា** ។ សេចក្តីត្រិះរិះជាដើម ដែលកើតឡើងក្នុងរូបនោះឯង

*គប្បីជ្រាបថា ឈ្មោះថា **រូបសង្កប្បៈ** (សេចក្តីត្រិះរិះក្នុងរូប) ជាដើម ដូច្នេះ ។ មួយទៀត ក្នុងអារម្មណ៍នេះ សញ្ញា សង្កប្បៈ ផស្សៈ វេទនា ឆន្ទៈ បានក្នុងជវនវារៈតែមួយជាមួយគ្នាខ្លះ ក្នុងជវនវារៈផ្សេងគ្នាខ្លះ ។ បរិឡាហៈ បរិយេសនា លាភៈ បានក្នុងជវនវារៈផ្សេងគ្នាប៉ុណ្ណោះ ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា ពាហិរឯសូត្រទី ៩

# អ ដ្ឋ ក ថា

## នោជស្សសូត្រទី ១០

*នោជស្សសូត្រទី ១០ មានសេចក្ដីងាយទាំងនោះឯង ។*

ចប់អដ្ឋកថា នោជស្សសូត្រទី ១០

## ធាតុសំយុត្ត

## ចប់នានត្តវគ្គទី ១

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា


១-អដ្ឋកថាធាតុសូត្រ
២-អដ្ឋកថាសម្ផស្សសូត្រ
៣-អដ្ឋកថានោសម្ផស្សសូត្រ
៤-អដ្ឋកថាវេទនាសូត្រ
៥-អដ្ឋកថានោវេទនាសូត្រ
៦-អដ្ឋកថាពាហិរធាតុសូត្រ
៧-អដ្ឋកថាសញ្ញាសូត្រ
៨-អដ្ឋកថានោសញ្ញាសូត្រ
៩-អដ្ឋកថាផស្សសូត្រ
១០-អដ្ឋកថានោផស្សសូត្រ

# ទុតិយវគ្គ

## អ ដ្ឋ ក ថា

### សត្តធាតុសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង សត្តធាតុសូត្រទី ១ នៃទុតិយវគ្គ ។*

[២០] *បទថា **អាភាធាតុ** បានដល់ អាលោកធាតុ ។ ពាក្យនោះជាឈ្មោះរបស់អាលោកៈ គឺ ឈានដែលកើតឡើងព្រោះធ្វើបរិកម្មក្នុងអាលោកកសិណ មានបីតិជាអារម្មណ៍ ។*

*បទថា **សុភាធាតុ** សេចក្តីថា ឈានព្រមទាំងអារម្មណ៍ ដោយអំណាចឈានដែលកើតឡើងក្នុងសុភកសិណ ។ អាកាសានញ្ចាយតនៈនោះឯង ឈ្មោះថា អាកាសានញ្ចាយតនធាតុ ។ សញ្ញាវេទយិតនិរោធឈ្មោះថា សញ្ញាវេទយិតនិរោធធាតុ ។ ព្រះមានព្រះភាគ កាលប្រទានឱកាសដល់ភិក្ខុដែលឈ្លាសក្នុងអនុសន្ធិ អង្គុយហើយក្នុងទីនោះ ប្រាថ្នានឹងសួរបញ្ហា ទើបញ៉ាំងទេសនាឲ្យចប់ស្រេច ដោយប្រការដូច្នេះ ។*

[២១] *បទថា **អន្ធការំ បដិច្ច** សេចក្តីថា ក៏ភាពងងឹតកំណត់ហើយ*

ដោយពន្លឺ សូម្បីពន្លឺក៏កំណត់ហើយដោយភាពងងឹត ពន្លឺនោះ ប្រាកដបាន ដោយភាពងងឹត ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **អាភាធាតុ** ព្រោះអាស្រ័យភាពងងឹតទើបប្រាកដបាន ។ ក្នុងបទនេះថា **អសុភំ បដិច្ច** ក៏មានន័យនេះឯង ។ ចំណែកអសុភៈ កំណត់ហើយដោយសុភៈ និងសុភៈ កំណត់ហើយដោយអសុភៈ កាលអសុភៈមាន សុភៈក៏ប្រាកដបាន ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់យ៉ាងនេះ ។ បទថា **រូបំបដិច្ច** បានដល់ អាស្រ័យ រូបាវចរសមាបត្តិ ។ ព្រោះថា កាលរូបាវចរសមាបត្តិមានហើយ ឈ្មោះថា អាកាសានញ្ចាយតនសមាបត្តិរមែងមាន ឬការឈានកន្លងរូប ក៏មាន ព្រោះ ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់យ៉ាងនេះ ។ សូម្បីក្នុងវិញ្ញាណញ្ចាយ-តនធាតុជាដើម ក៏មានន័យនេះឯង ។ បទថា **និរោធំ បដិច្ច** សេចក្តីថា អាស្រ័យការមិនប្រព្រឹត្តទៅក្នុងការពិចារណាខន្ធ ៤ ឈ្មោះថា និរោធសមា-បត្តិ ព្រោះអាស្រ័យការរលត់នៃខន្ធទើបប្រាកដបាន អាស្រ័យការប្រព្រឹត្ត ទៅនៃខន្ធប្រាកដមិនបាន ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់យ៉ាង នេះ ។ ក៏ក្នុងទីនេះការរលត់នៃខន្ធ ៤ គប្បីជ្រាបថាជា និរោធសមាបត្តិ ។ បទថា **កថំ សមាបត្តិ បត្តព្វា** សេចក្តីថា ជាសមាបត្តិដែលបុគ្គលគប្បីចូល ដល់ យ៉ាងណា គឺ សមាបត្តិដូចម្តេច ។

[២២] បទថា ***សញ្ញាសមាបត្តិ បត្តព្វា*** សេចក្តីថា បុគ្គលគប្បីចូលដល់សញ្ញាសមាបត្តិ ឈ្មោះថា សញ្ញាសមាបត្តិ ព្រោះមានសញ្ញា ។ បទថា ***សង្ខារាវសេសសមាបត្តិ បត្តព្វា*** សេចក្តីថា សង្ខារាវសេសសមាបត្តិដែលបុគ្គលគប្បីចូលដល់ ព្រោះសង្ខារដែលល្អិតនៅមាន ។ បទថា ***និរោធសមាបត្តិ បត្តព្វា*** សេចក្តីថា និរោធទុំឯង ឈ្មោះថា និរោធសមាបត្តិបុគ្គលគប្បីចូលដល់និរោធសមាបត្តិ អធិប្បាយថា ឈ្មោះថា និរោធសមាបត្តិដែលបុគ្គលគប្បីចូលដល់ ។

ចប់អដ្ឋកថា សត្តធាតុសូត្រទី ១

# អ ដ្ឋ ក ថា

## សនិទានសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុងសនិទានសូត្រទី ២ ដូចតទៅនេះ ៖*

[២៣] *បទថា* ***សនិទានំ*** *នោះ ជាការនបុំសកលិង្គ អធិប្បាយថា មានហេតុមានបច្ច័យកើតឡើង ។*

[២៤] *ក្នុងបទថា* ***កាមធាតុំ ភិក្ខវេ បដិច្ច*** *នេះ កាមវិតក្កក្តី កាមាវចរធម៌ក្តី ឈ្មោះថា កាមធាតុ សូម្បីប្រែកគ្នា ក៏ជាអកុសលទាំងអស់ សម ដូចព្រះមានព្រះភាគត្រាស់ថា ក្នុងធម៌ទាំងនោះ* ***កាមធាតុ*** *តើដូចម្តេច ។* ***តក្កៈ*** *(ការគិត) ,* ***វិតក្កៈ*** *(ការត្រិះរិះ) ,* ***សង្កប្បៈ*** *(សេចក្តីត្រិះរិះ) ,* ***អប្បនា*** *(ការនែបនិត) ,* ***ព្យាបន្នា*** *(សេចក្តីខ្វល់ខ្វាយ) ,* ***ចេតសា*** *(ការលើកចិត្តឡើង) ,* ***អភិនីរោបនា*** *(ការផ្តោតអារម្មណ៍) ,* ***មិច្ឆាសង្កប្បៈ*** *(ការត្រិះរិះខុស) ដែលប្រកបដោយកាម នេះលោកហៅថា* ***កាមធាតុ*** *។ ខាងក្រោមចាប់អំពីអវិចីនរក ខាងលើចាប់អំពីបរនិម្មិតវសវត្តី ធម៌ដែលត្រាច់ទៅក្នុងស្ថានទីទាំងនោះ ខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលរាប់បញ្ចូលក្នុងស្ថានទីនេះ នេះលោកហៅថា* ***កាមធាតុ*** *។ អកុសលធម៌*

សូម្បីទាំងពួង ឈ្មោះថា **កាមធាតុ** ដូច្នេះ ។ ក្នុងសេចក្តីនេះ មានពាក្យ ២ យ៉ាងគឺ រួមគ្នាទាំងអស់ (និង) ផ្សេងគ្នា ។ សួរថា តើដូចម្តេច ។ ឆ្លើយថា ពាក្យនេះគឺ ព្យាបាទធាតុ និងវិហិង្សាធាតុ ជាធម៌ដែលលោកកាន់យកហើយ ដោយសព្ទ កាមធាតុតែម្យ៉ាង ឈ្មោះថា **រួមគ្នាទាំងអស់** ។ ចំណែកពាក្យនេះថា ធម៌ដ៏សេសជាកាមធាតុ ឈ្មោះថា **ផ្សេងគ្នា** ព្រោះធាតុទាំងពីរនោះមកហើយក្នុងចំណែកមួយ ។

ក្នុងសេចក្តីនេះ គួរកាន់យកពាក្យនេះ ។ ឈ្មោះថា កាមសញ្ញា រមែងកើតឡើង ព្រោះអាស្រ័យកាមធាតុនេះ ដោយអំណាចនៃអារម្មណ៍ ឬដោយអំណាចការប្រកបព្រម (សម្បយោគ) ។ បទថា **កាមសញ្ញំ បដិច្ច** សេចក្តីថា ឈ្មោះថា សេចក្តីត្រិះរិះក្នុងកាម រមែងកើតឡើងព្រោះអាស្រ័យកាមសញ្ញា ដោយអំណាចការប្រកបព្រម (សម្បយោគ) ឬដោយអំណាចឧបនិស្សយប្បច្ច័យ ។ សេចក្តីក្នុងបទទាំងពួង ក៏គប្បីជ្រាបដោយន័យនេះឯង ។

បទថា **តីហិ ឋានេហិ** ប្រែថា ដោយហេតុ ៣ យ៉ាង ។ បទថា **មិច្ឆា បដិបជ្ជតិ** សេចក្តីថា ប្រព្រឹត្តតាមបដិបទាដែលខុស គឺ វត្តបដិបត្តិដែលមិននាំចេញចាកទុក្ខ ។ ក្នុងបទថា **ព្យាបាទធាតុំ ភិក្ខវេ** នេះ ព្យាបាទ-

វិតក្កក្តី ព្យាបាទក្តី ជាព្យាបាទធាតុ សមដូចព្រះមានព្រះភាគត្រាស់ថា ក្នុងធម៌ទាំងនោះ ព្យាបាទធាតុ ដូចម្តេច ការគិត សេចក្តីត្រិះរិះប្រកបដោយព្យាបាទ ។បេ។ នេះ លោកហៅថា **ព្យាបាទធាតុ** ។ ការចងអាឃាត ការក្រោធតប សេចក្តីក្រោធ សេចក្តីក្រោធខ្លាំង របស់ចិត្តក្នុងអាឃាតវត្ថុ ១០ ។បេ។ សភាពមិនពេញចិត្ត នេះលោកហៅថា **ព្យាបាទធាតុ** ។ ឈ្មោះ **ព្យាបាទសញ្ញា** រមែងកើតឡើងព្រោះអាស្រ័យព្យាបាទធាតុនេះ ដោយអំណាចសហជាតប្បច្ច័យជាដើម ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យមុននុ៎ះឯង ។

ក្នុងបទថា **វិហឹសាធាតុំ ភិក្ខវេ** នេះ វិហិង្សាវិតក្កក្តី វិហិង្សាក្តី ជាវិហិង្សាធាតុ សមដូចព្រះមានព្រះភាគត្រាស់ថា ក្នុងធម៌ទាំងនោះ វិហិង្សា-ធាតុ ដូចម្តេច ។ សេចក្តីត្រិះរិះ ការគិត ដែលប្រកបដោយវិហិង្សា ។បេ។ នេះលោកហៅថា **វិហិង្សាធាតុ** ។ បុគ្គលខ្លះក្នុងលោកនេះ រមែងបៀតបៀនសត្វដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយកំណាត់ឈើខ្លះ ដោយសស្ត្រាខ្លះ ដោយខ្សែខ្លះយ៉ាងណាមួយ ការវាយ ការធ្វើឲ្យលំបាក ការបៀតបៀន ការកៀបសង្កត់ សេចក្តីក្រោធ ការចូលទៅសម្លាប់អ្នកដទៃ នេះលោកហៅថា **វិហិង្សាធាតុ** ។ ឈ្មោះ **វិហិង្សាសញ្ញា** រមែងកើតឡើងព្រោះអាស្រ័យវិហិង្សាធាតុនេះ ដោយអំណាចសហជាតប្បច្ច័យជាដើម ។ ពាក្យដ៏សេស

សូម្បីក្នុងបទនេះ គប្បីជ្រាបដោយន័យមុនន៉ុះឯង ។

[២៥] បទថា **តិណទាយេ** បានដល់ ក្នុងព្រៃ គឺ ព្រៃស្មៅ ។ បទថា **អនយព្យសនំ** បានដល់ សេចក្ដីមិនចម្រើន គឺ វិនាស ។ ក្នុងបទថា **ឯវមេវ ខោ** នេះ សេចក្ដីថា គប្បីឃើញអារម្មណ៍ ដូចព្រៃស្មៅស្ងួត អកុសលសញ្ញា ដូចគប់ភ្លើង សត្វទាំងឡាយនេះ ដែលមានជីវិតអាស្រ័យស្មៅ និងស្លឹកឈើ កាលគេមិនព្យាយាមប្រញាប់ពន្លត់គប់ភ្លើងដែលតាំងទុកក្នុងព្រៃស្មៅស្ងួត សត្វមានជីវិតទាំងនោះ រមែងដល់សេចក្ដីនូវវិនាស យ៉ាងណា សមណៈ ឬព្រាហ្មណ៍ពួកណា មិនលះអកុសលសញ្ញាដែលកើតឡើងដោយវិក្ខម្ភនប្បហាន តទង្គប្បហាន សមុច្ឆេទប្បហាន សមណៈ ឬព្រាហ្មណ៍ទាំងនោះ រមែងនៅជាទុក្ខដូច្នោះដែរ ។ បទថា **វិសមគតំ** សេចក្ដីថា អកុសលសញ្ញាធ្លាក់ទៅកាន់អារម្មណ៍ដែលរុកកួនព្រោះរាគៈជាដើម ។ បទថា **ន ខិប្បមេវ បជហតិ** បានដល់ មិនប្រញាប់លះបង់ចេញ ដោយអំណាចវិក្ខម្ភនៈជាដើម ។ បទថា **ន វិនោទេតិ** បានដល់ មិននាំចេញ ។ បទថា **ន ព្យន្តីករោតិ** បានដល់ ធ្វើអកុសលសញ្ញានោះឲ្យអស់មិនមាននៅសល់សូម្បីត្រឹមតែកង្គខណៈ ។ បទថា **ន អនភាវំ គមេតិ** បានដល់ មិនឲ្យដល់សេចក្ដីមិនមាន ។ ន អក្សរគប្បីនាំមកប្រើក្នុងគ្រប់បទ យ៉ាងនេះ ។

បទថា **បដិកង្ខា** បានដល់ គប្បីប្រាថ្នា គឺ ត្រូវការ ។

[២៧] ក្នុងបទថា **នេក្ខម្មធាតុំ ភិក្ខវេ** នេះ នេក្ខម្មវិតក្កក្តី កុសលធម៌ទាំងពួងក្តី ជានេក្ខម្មធាតុ សមដូចព្រះមានព្រះភាគត្រាស់ថា ក្នុងធម៌ទាំងនោះ នេក្ខម្មធាតុ ដូចម្តេច ។ សេចក្តីត្រិះរិះ ការគិត ដែលប្រកបដោយនេក្ខម្មៈ ។ល។ សម្មាសង្កប្បៈ នេះលោកហៅថា **នេក្ខម្មធាតុ** ។ សូម្បីក្នុងសេចក្តីនេះ មានពាក្យ ២ យ៉ាង ក៏ធាតុទាំងពីរក្រៅពីនេះ រមែងកាន់យកដោយនេក្ខម្មធាតុសព្វ ព្រោះរាប់បញ្ចូលក្នុងកុសលធម៌ នេះឈ្មោះថា រួមគ្នាទាំងអស់ ចំណែកធាតុទាំងនោះ គប្បីសម្តែងទុកផ្សេងគ្នា កុសលទាំងពួងដ៏សេស វៀរធាតុទាំងនោះចេញ ជានេក្ខម្មធាតុ ព្រោះដូច្នោះ នេក្ខម្មធាតុនេះទើបមិនលាយគ្នា ។ ឈ្មោះ **នេក្ខម្មសញ្ញា** រមែងកើតឡើងព្រោះអាស្រ័យនេក្ខម្មធាតុនេះ ដោយអំណាចនៃសហជាតប្បច្ច័យជាដើម ។ ធម៌មានវិតក្កជាដើម រមែងកើតឡើងព្រោះអាស្រ័យសញ្ញាជាដើម តាមសមគួរ ។

ក្នុងបទថា **អព្យាបាទធាតុំ ភិក្ខវេ** នេះ អព្យាបាទវិតក្កក្តី អព្យាបាទក្តី ជាអព្យាបាទធាតុ សមដូចព្រះមានព្រះភាគត្រាស់ថា ក្នុងធម៌ទាំងនោះ **អព្យាបាទធាតុ** ដូចម្តេច ។ សេចក្តីត្រិះរិះ ដែលប្រកបដោយអព្យាបាទ ។ល។ នេះ លោកហៅថា អព្យាបាទធាតុ ។ សេចក្តីស្រឡាញ់ ភាព

មានមេត្រីចំពោះគ្នា ការប្រាថ្នាឲ្យអ្នកដទៃមានសេចក្ដីសុខក្នុងសត្វទាំងឡាយ មេត្តាចេតោវិមុត្តិ នេះ លោកហៅថា អព្យាបាទធាតុ ។ ឈ្មោះអព្យាបាទ-សញ្ញា រមែងកើតឡើង ព្រោះអាស្រ័យអព្យាបាទធាតុនេះ ដោយន័យដូចពោលហើយនោះឯង ។

សូម្បីក្នុងបទថា **អវិហឹសាធាតុំ ភិក្ខវេ** នេះ អវិហិង្សាវិតក្កៈក្ដី ករុណាក្ដី ជាអវិហិង្សាធាតុ សមដូចព្រះមានព្រះភាគត្រាស់ថា ក្នុងធម៌ទាំងនោះ អវិហិង្សាធាតុ ដូចម្ដេច ។ សេចក្ដីត្រិះរិះដែលប្រកបដោយអវិហិង្សា ។ល។ នេះ លោកហៅថា **អវិហិង្សាធាតុ** ។ សេចក្ដីករុណា សេចក្ដីអាណិតការជួយអ្នកដទៃឲ្យផុតទុក្ខក្នុងសត្វទាំងឡាយ ករុណាចេតោវិមុត្តិ នេះ លោកហៅថា អវិហិង្សាធាតុ ។ ឈ្មោះ អវិហិង្សាសញ្ញា រមែងកើតឡើង ព្រោះអាស្រ័យអវិហិង្សាធាតុនេះ ដោយន័យដូចពោលហើយនោះឯង ។ ពាក្យដ៏សេស គប្បីជ្រាបតាមដែលពោលហើយក្នុងបទទាំងពួងនោះឯង ។

ចប់អដ្ឋកថា សនិទានសូត្រទី ២

# អ ដ្ឋ ក ថា

## គិញ្ជកាវសថសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង **គិញ្ជកាវសថសូត្រទី ៣** ដូចតទៅនេះ ៖*

[២៩] *បទថា **ធាតុំ ភិក្ខវេ** លោកសម្តែងថា ធាតុ គឺ អជ្ឈាស្រ័យ ចាប់ផ្តើមតាំងពីនេះ ។*

*បទថា **ឧប្បជ្ជតិ សញ្ញា** សេចក្តីថា សញ្ញារមែងកើតឡើង ទិដ្ឋិរមែងកើតឡើង វិតក្កៈរមែងកើតឡើង ព្រោះអាស្រ័យអជ្ឈាស្រ័យ ។ សូម្បីក្នុងទីនេះ ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាដោយពាក្យមានប្រមាណប៉ុណ្ណេះ ដើម្បីឲ្យឱកាសដល់កច្ចានៈនោះ ដោយព្រះតម្រិះថា កច្ចានៈនឹងសួរបញ្ហាដូច្នេះ ។*

[៣០] *បទថា **អសម្មាសម្ពុទ្ធេសុ** បានដល់ គ្រូទាំង ៦ ។ បទថា **សម្មាសម្ពុទ្ធា** សេចក្តីថា តថាគតជាព្រះសម្មាសម្ពុទ្ធ តថាគតជាព្រះសម្មា-សម្ពុទ្ធ បទថា **កឹ បដិច្ច បញ្ញាយតិ** ព្រះកច្ចានៈសួរទិដ្ឋិដែលកើតឡើងដល់គ្រូទាំងឡាយថា កាលអ្វីមាន ទិដ្ឋិទើបមាន ទើបសួរទិដ្ឋិសូម្បីរបស់សាវក-តិរ្ថិយ ដែលកើតឡើងយ៉ាងនេះថា ព្រះសម្មាសម្ពុទ្ធទាំងនោះ ក្នុងបុគ្គលដែល*

មិនមែនព្រះសម្មាសម្ពុទ្ធ ។

[៣១] ឥឡូវនេះ ព្រោះសាវកតិរ្ថិយទាំងនោះមានទិដ្ឋិ ព្រោះអាស្រ័យធាតុ គឺ អវិជ្ជា, ក៏ធាតុធំ ឈ្មោះថា ធាតុ គឺ អវិជ្ជា ដូច្នោះ ព្រះមានព្រះភាគកាលទ្រង់អាស្រ័យធាតុធំ ទ្រង់សម្តែងការកើតឡើងនៃទិដ្ឋិនោះ ទើបត្រាស់ព្រះតម្រាស់ជាដើមថា **មហតី ខោ ឯសា** ។ បទថា **ហីនំ កច្ចាន ធាតុំ បដិច្ច** បានដល់ អាស្រ័យអធ្យាស្រ័យអាក្រក់ ។ បទថា **បណិធិ** ប្រែថា ការតាំងចិត្ត ។ ក៏ការតាំងចិត្តនេះ រមែងកើតឡើងដល់បុគ្គលដែលប្រាថ្នាភេទជាស្រី ឬប្រាថ្នាជាតិរច្ឆាន មានស្វាជាដើម ។ បទថា **ហីនោ បុគ្គលោ** សេចក្តីថា ធម៌អាក្រក់ទាំងនោះ រមែងកើតឡើងដល់បុគ្គលណា សូម្បីបុគ្គលនោះ ក៏ឈ្មោះថា អាក្រក់ ។ បទថា **ហីនា វាចា** សេចក្តីថា វាចាណា ជាវាចារបស់បុគ្គលនោះ សូម្បីវាចានោះក៏ចាត់ថា អាក្រក់ ។ បទថា **ហីនំ អាចិក្ខតិ** គប្បីប្រែកបបទគ្រប់បទថា បុគ្គលនោះសូម្បីកាលប្រាប់ ក៏ប្រាប់តែវត្ថុដែលអាក្រក់ប៉ុណ្ណោះ សូម្បីកាលសម្តែង ក៏សម្តែងតែវត្ថុដែលអាក្រក់ប៉ុណ្ណោះ ។ បទថា **ឧបបត្តិ** បានដល់ ឧបបត្តិ ២ យ៉ាងគឺ ការបានចំពោះ និងការកើត ។ **ការកើត** គប្បីជ្រាបដោយអំណាចត្រកូលដែលអាក្រក់ជាដើម, **ការបានចំពោះ** គប្បីជ្រាបដោយអំណាចសេចក្តីអាក្រក់

៣ ពួក ក្នុងខណៈចិត្តុប្បាទ ។ សួរថា តើដូចម្តេច ។

ឆ្លើយថា ក៏ព្រោះគេកើតក្នុងត្រកូលថោកទាប ៥ ត្រកូល ឈ្មោះថា ការកើតដែលអាក្រក់, ព្រោះគេកើតក្នុងត្រកូលវេស្សៈ និងសូទ្រៈ ឈ្មោះថា កណ្តាល, ព្រោះកើតក្នុងត្រកូលក្សត្រិយ៍ និងព្រាហ្មណ៍ ឈ្មោះថា ប្រណីត ។ ក៏ព្រោះបានចំពោះនូវអកុសលចិត្តុប្បាទ ១២ ដួង ឈ្មោះថា ការបានដែលអាក្រក់ ព្រោះការបានធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា កណ្តាល ព្រោះបានលោកុត្តរធម៌ ៩ ឈ្មោះថា ប្រណីត ចំណែកក្នុងទីនេះបំណងយកការកើត តែម្យ៉ាង ។

ចប់អដ្ឋកថា គិញ្ជកាវសថសូត្រទី ៣

# អ ដ្ឋ ក ថា

## ហីនាធិមុត្តិសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ហីនាធិមុត្តិសូត្រទី ៤** ដូចតទៅនេះ ៖*

[៣២] *បទថា **សំសន្ទន្តិ** ប្រែថា ជាអ្នកត្រូវគ្នា បទថា **សមេន្តិ** បានដល់ រមែងសមាគមគ្នាជានិរន្តរ៍ បទថា **ហីនាធិមុត្តកា** ប្រែថា មានអធ្យាស្រ័យអាក្រក់ បទថា **កល្យាណាធិមុត្តិកា** ប្រែថា មានអធ្យាស្រ័យល្អ ៗ*

ចប់អដ្ឋកថា ហីនាធិមុត្តិសូត្រទី ៤

# អ ដ្ឋ ក ថា

## ចង្កមសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុងចង្កមសូត្រទី ៥ ដូចតទៅនេះ ៖*

[៣៤] *បទថា* ***បស្សថ នោ*** *ប្រែថា អ្នកឃើញឬទេ ។ បទថា* ***សព្វេ ខោ ឯតេ*** *សេចក្ដីថា ព្រះមានព្រះភាគទ្រង់តាំងព្រះសារីបុត្តត្ថេរទុកក្នុងឯតទគ្គៈ ក្នុងបណ្ដាភិក្ខុដែលមានបញ្ញាថា "ម្នាលភិក្ខុទាំងឡាយភិក្ខុជាសាវករបស់តថាគត អ្នកមានបញ្ញាច្រើន ព្រះសារីបុត្រនេះ គឺជាកំពូល ។ ពួកភិក្ខុដែលមានបញ្ញាច្រើន រមែងហែហមព្រះថេរៈនោះ ដោយគិតថា យើងនឹងសួរបញ្ហាដែលជ្រាលជ្រៅ ដែលកំណត់ត្រៃលក្ខណៈបានហើយ ក្នុងលំដាប់ខន្ធ ធាតុ អាយតនៈ សតិប្បដ្ឋាន និងពោធិបក្ខិយធម៌ ដោយប្រការដូច្នេះ ។ សូម្បីព្រះថេរៈនោះ រមែងតបបញ្ហាដែលគេសួរហើយ និងសួរហើយដល់ពួកភិក្ខុទាំងនោះ ដូចពង្រីកផែនដី ដូចចាប់ខ្សាច់អំពីជើងភ្នំសិនេរុ ដូចទម្លាយភ្នំចក្រវាឡ ដូចលើកភ្នំសិនេរុឡើង ដូចពង្រីកអាកាសឲ្យធំទូលាយ និងដូចឲ្យព្រះចន្ទ និងព្រះអាទិត្យរះឡើងដូច្នោះ ។ ព្រោះហេតុនោះ ព្រះមាន-ព្រះភាគទើបត្រាស់ថា* ***សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ មហាបញ្ញា*** *" ដូច្នេះ ។*

ព្រះមានព្រះភាគ ទ្រង់តាំងព្រះមហាមោគ្គល្លាន ទុកក្នុងឯតទគ្គៈ ក្នុងបណ្ដាភិក្ខុដែលមានឫទ្ធិថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសាវករបស់តថាគតអ្នកមានឫទ្ធិ មោគ្គល្លាននេះ គឺជាកំពូល ។ ពួកភិក្ខុដែលមានឫទ្ធិរមែងហែហមព្រះថេរៈនោះ ដោយគិតថា យើងនឹងសួរដល់បរិកម្ម អានិសង្ស អធិដ្ឋាន ការធ្វើផ្សេងៗ ដោយប្រការដូច្នេះ ។ សូម្បីព្រះថេរៈនោះ តបបញ្ហាដែលគេសួរហើយ និងសួរហើយដល់ភិក្ខុទាំងនោះ ដោយន័យដែលពោលហើយនោះឯង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ***សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ មហិទ្ធិកា*** ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់តាំងសូម្បីព្រះមហាកស្សបៈទុកក្នុងឯតទគ្គៈ ក្នុងបណ្ដាភិក្ខុដែលជាធុតវាទថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុសាវករបស់តថាគតអ្នកជាធុតវាទ មហាកស្សបៈ គឺជាកំពូល ។ ពួកភិក្ខុដែលជាធុតវាទរមែងហែហមព្រះថេរៈនោះ ដោយគិតថា យើងនឹងសួរដល់ការរក្សាធុតង្គ អានិសង្ស ការសមាទាន ការអធិដ្ឋាន សេចក្ដីផ្សេងគ្នា ដោយប្រការដូច្នេះ ។ សូម្បីព្រះថេរៈនោះ បានតបបញ្ហាដែលគេសួរហើយ និងសួរហើយឲ្យជាក់ច្បាស់យ៉ាងនោះដូចគ្នា ដល់ភិក្ខុទាំងនោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ***សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ ធុតវាទា***" ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់តាំងសូម្បីព្រះអនុរុទ្ធត្ថេរទុកក្នុងឯតទគ្គៈក្នុងបណ្តាភិក្ខុដែលមានទិព្វចក្ខុថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលជាសាវករបស់តថាគតអ្នកមានទិព្វចក្ខុ អនុរុទ្ធ គឺជាកំពូល ។ ពួកភិក្ខុដែលមានទិព្វចក្ខុរមែងហែហមព្រះថេរៈនោះ ដោយគិតថា យើងនឹងសួរដល់បរិកម្ម អានិសង្ស ឧបក្កិលេសរបស់ភិក្ខុដែលមានទិព្វចក្ខុ ដោយប្រការដូច្នេះ ។ សូម្បីព្រះថេរៈនោះ រមែងតបបញ្ហាដែលគេសួរហើយ និងសួរហើយ យ៉ាងនោះដូចគ្នាដល់ភិក្ខុទាំងនោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ ទិព្វចក្ខុកា**" ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់តាំងសូម្បីព្រះបុណ្ណត្ថេរទុកក្នុងឯតទគ្គៈក្នុងបណ្តាភិក្ខុដែលជាព្រះធម្មកថិកថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុសាវករបស់តថាគតដែលជាធម្មកថិក បុណ្ណមន្តានីបុត្រនេះ គឺជាកំពូល ។ ពួកភិក្ខុដែលជាធម្មកថិករមែងហែហមព្រះថេរៈនោះ ដោយគិតថា យើងនឹងសួរអាការនោះៗ ក្នុងសេចក្តីសង្ខេប ពិស្តារ លំបាក ងាយ និងពាក្យពីរោះជាដើមនៃធម្មកថាដោយប្រការដូច្នេះ សូម្បីព្រះថេរៈនោះ រមែងប្រាប់ន័យធម្មកថានោះយ៉ាងនេះ ដល់ភិក្ខុទាំងនោះថា អ្នកមានអាយុ ធម្មតាព្រះធម្មកថិក គួរផ្តើមការពណ៌នាគុណបរិស័ទ ត្រង់កណ្តាលគួរប្រកាសសុញ្ញតធម៌ ទីបំផុតគួរ

កាន់យកកំពូលដោយអំណាចសច្ចៈ ៤ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ ធម្មកថិកា**" ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់តាំងសូម្បីព្រះឧបាលីត្ថេរទុកក្នុងឯតទគ្គៈក្នុងបណ្ដាភិក្ខុដែលទ្រទ្រង់វិន័យថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុសាវករបស់តថាគតអ្នកទ្រទ្រង់វិន័យ ឧបាលី គឺជាកំពូល ។ ពួកភិក្ខុដែលទ្រទ្រង់វិន័យ រមែងហែហមព្រះថេរៈនោះ ដោយគិតថា យើងនឹងសួរអាបត្តិធ្ងន់ អាបត្តិស្រាល អាបត្តិកែខៃបាន កែខៃមិនបាន អាបត្តិ និងអនាបត្តិ ដោយប្រការដូច្នេះ ។ សូម្បីព្រះថេរៈនោះ រមែងតបបញ្ហាដែលគេសួរហើយ និងសួរហើយដល់ភិក្ខុទាំងនោះ យ៉ាងនោះដូចគ្នា ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **សព្វេ ខោ ឯតេភិក្ខវេ ភិក្ខូ វិនយធរា** ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់តាំងសូម្បីព្រះអានន្ទត្ថេរទុកក្នុងឯតទគ្គៈក្នុងបណ្ដាភិក្ខុដែលពហុស្សូតថា "ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុសាវករបស់តថាគតដែលជាពហុស្សូត អានន្ទ គឺជាកំពូល ។ ពួកភិក្ខុពហុស្សូត រមែងហែហមព្រះថេរៈនោះ ដោយគិតថា យើងនឹងសួរសេចក្ដីដឹងក្នុងព្យញ្ជនៈ ១០ យ៉ាង ហេតុកើតអនុសន្ធិខាងដើម និងខាងចុង ដោយប្រការដូច្នេះ ។

សូម្បីព្រះថេរៈនោះ ក៏ប្រាប់រឿងទាំងពួងដល់ភិក្ខុទាំងនោះថា នេះ

គួរពោលយ៉ាងនេះ នេះគួរកាន់យកយ៉ាងនេះ ។ ព្រោះហេតុនោះ ព្រះមាន-ព្រះភាគទើបត្រាស់ថា **សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ ពហុស្សុតា**” ដូច្នេះ ។

ចំណែកទេវទត្តប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ ។ ព្រោះហេតុនោះ ពួកភិក្ខុដែលប្រាថ្នាលាមក រមែងហែហមទេវទត្តនោះ ដោយគិតថា យើងនឹងសួរការឃុំគ្រង ដើម្បីការសង្គ្រោះត្រកូល ការបញ្ចោតបន្ទំមានប្រការផ្សេងៗ ។

សូម្បីទេវទត្តនោះ ក៏ប្រាប់ការកំណត់នោះដល់ភិក្ខុទាំងនោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ បាបិច្ឆា** ដូច្នេះ ។ សួរថា ក៏ព្រោះហេតុអ្វី ភិក្ខុទាំងនោះចង្រ្កមហើយ ក្នុងទីមិនឆ្ងាយ ។ ឆ្លើយថា ដើម្បីកាន់ការរក្សាថា ទេវទត្ត គិតប្រទូស្តក្នុងព្រះសាស្តា ព្យាយាមនឹងធ្វើសេចក្តីវិនាសមិនមែនប្រយោជន៍ ។ សួរថា គ្រានោះទេវទត្តចង្រ្កមហើយ ព្រោះហេតុអ្វី ។ ឆ្លើយថា ដើម្បីបិទបាំងទោសដែលខ្លួនធ្វើហើយ ជាហេតុឲ្យអ្នកដទៃដឹងថា អ្នកនេះមិនធ្វើ បើធ្វើ គេក៏មិនមកក្នុងទីនេះ ។ សួរថា ក៏ទេវទត្តជាអ្នកអាចនឹងធ្វើសេចក្តីវិនាសចំពោះព្រះមាន-ព្រះភាគបានឬ នាទីត្រូវរក្សាព្រះមានព្រះភាគមាននៅឬ ។ ឆ្លើយថា មិនមាន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលអានន្ទ ប្រការដែល

តថាគតគប្បីបរិនិព្វានដោយសេចក្ដីព្យាយាមរបស់អ្នកដទៃនោះ មិនមែនជាឋានៈ មិនមែនជាឱកាសឡើយ ។ ចំណែកភិក្ខុទាំងឡាយ មកហើយដោយសេចក្ដីគោរពក្នុងព្រះសាស្ដា ។ ព្រោះហេតុនោះឯង ព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ទើបត្រាស់ឲ្យភិក្ខុទាំងនោះទៅ ដោយព្រះតម្រាស់ថា ម្នាលអានន្ទ អ្នកចូរឲ្យភិក្ខុសង្ឃចេញទៅចុះ ដូច្នេះ ។

ចប់អដ្ឋកថា ចង្កមសូត្រទី ៥

# អ ដ្ឋ ក ថា

## សគាថាវគ្គសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង **សគាថាវគ្គសូត្រទី ៦** ដូចតទៅនេះ ៖*

[៣៧] *បទថា **គូថោ គូថេន សំសន្ទតិ សមេតិ** សេចក្តីថា លាមក សូម្បីនៅចន្លោះសមុទ្រ ចន្លោះជនបទ ចន្លោះចក្រវាឡ ដោយពណ៌ក្តី ដោយក្លិនក្តី ដោយរសក្តី ជាវត្ថុមិនផ្សេងគ្នា រមែងចូលគ្នាបាន រួមគ្នាបាន គឺដូចគ្នាតែម្យ៉ាង ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះឯង ។ ក៏ឧបមាដោយរបស់មិនគួរប្រាថ្នានេះ លោកនាំមកដើម្បីសម្តែងដល់អធ្យាស្រ័យរបស់អ្នកមានអធ្យាស្រ័យអាក្រក់ស្មើគ្នា ។ ឧបមាដោយរបស់ល្អ មានទឹកដោះជាដើម លោកនាំមកដើម្បីសម្តែងដល់អធ្យាស្រ័យរបស់អ្នកមានអធ្យាស្រ័យល្អ ស្មើគ្នា ។*

[៤០] *បទថា **សំសគ្គា** សេចក្តីថា សេចក្តីស្នេហាដោយតណ្ហា មានការឃើញ ការស្តាប់ និងការសេពគប់ជាដើម ជាទីតាំង ។ បទថា **វនថោ ជាតោ** បានដល់ ព្រៃ គឺ កិលេសកើតហើយ ។ បទថា **អសំសគ្គេន ឆិជ្ជតិ** សេចក្តីថា កាលមិនធ្វើការឈរ និងការអង្គុយរួមគ្នា ក៏រមែងដាច់ (ទំនាក់*

*ទំនងគ្នា) ព្រោះមិនសេពគប់ គឺ មិនជួបគ្នា ។ បទថា* ***សាធុជីវី*** *បានដល់ កាលនៅមានជីវិត ក៏មានជីវិតបរិសុទ្ធិ ។*

*បទថា* ***សហាវសេ*** *បានដល់ គប្បីនៅរួមគ្នា ។*

ចប់អដ្ឋកថា សតាចារទុស្សូត្រទី ៦

# អ ដ្ឋ ក ថា

## បឋមអស្សទ្ធមូលកសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអស្សទ្ធមូលកសូត្រទី ៧ ដូចតទៅនេះ ៖*

[៨១] *ក្នុងបទជាដើមថា **អស្សទ្ធា អស្សទ្ធេហិ** សេចក្តីថា បុគ្គលមិនមានឱជា (គឺសទ្ធា) មិនមានរស (គឺសទ្ធា) វៀរជាច់ចាកសទ្ធាក្នុងព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃ នៅត្រង់ត្រើយសមុទ្រនេះ ក៏តែម្យ៉ាងដូចគ្នានឹងបុគ្គលមិនមានសទ្ធាដែលនៅត្រង់ត្រើយឯណោះ ព្រោះភាពជាអ្នកមិនមានសទ្ធានោះ ។ បុគ្គលមិនមានហិរិ គឺ គ្មានមារយាទ ក៏ដូចគ្នានឹងបុគ្គលមិនមានហិរិ ។ បុគ្គលមិនមានឱត្តប្បៈ គឺ មិនខ្លាចចំពោះការធ្វើបាប ក៏ដូចគ្នានឹងបុគ្គលមិនមានឱត្តប្បៈ ។ បុគ្គលមានសុតៈតិច គឺ វៀរចាកសុតៈ ក៏ដូចគ្នានឹងបុគ្គលមានសុតៈតិច ។ បុគ្គលខ្ជិលច្រអូស គឺ បុគ្គលមានសេចក្តីខ្ជិលច្រអូស ក៏ដូចគ្នានឹងបុគ្គលខ្ជិលច្រអូស ។ បុគ្គលវង្វេងស្មារតី គឺ ដូចជាសត្វក្អែករក្សាអាហារ និងដូចសត្វចចករក្សាសាច់ ក៏ដូចគ្នានឹងបុគ្គលវង្វេងស្មារតី ។ បុគ្គលមានបញ្ញាទន់ខ្សោយ គឺ ឈ្មោះថា មិនមានបញ្ញា ព្រោះមិនមានបញ្ញាដែលគប្បីកំណត់ខន្ធជាដើម ក៏ដូចគ្នានឹងបុគ្គលមានបញ្ញាទន់ខ្សោយ ។*

បុគ្គលអ្នកជល់ព្រមដោយសទ្ធា គឺ បុគ្គលខ្វល់ខ្វាយក្នុងកិច្ច មានការថ្វាយបង្គំព្រះចេតិយជាដើម ក៏ដូចគ្នានឹងបុគ្គលមានសទ្ធា ។ បុគ្គលមានហិរិ គឺ បុគ្គលមានសេចក្តីខ្មាស ក៏ដូចគ្នានឹងបុគ្គលមានហិរិ ។ បុគ្គលមានឱត្តប្បៈ គឺ ខ្លាចបាប ក៏ដូចគ្នានឹងបុគ្គលមានឱត្តប្បៈ ។ បុគ្គលមានសុតៈច្រើន គឺ ទ្រទ្រង់សុតៈ ទ្រទ្រង់អាគម (ព្រះបរិយត្តិ) រក្សាបែបផែន រក្សាវង្ស ក៏ដូចគ្នានឹងបុគ្គលមានសុតៈច្រើន ។ បុគ្គលប្រារព្ធសេចក្តីព្យាយាម គឺ មានសេចក្តីព្យាយាមបរិបូរ ក៏ដូចគ្នានឹងបុគ្គលប្រារព្ធសេចក្តីព្យាយាម ។ បុគ្គលមានសតិតាំងមាំ គឺ ប្រកបដោយសតិ ដែលកំណត់កិច្ចទាំងពួងបាន ក៏ដូចគ្នានឹងបុគ្គលមានសតិតាំងមាំ ។ បុគ្គលមានបញ្ញា សូម្បីនៅក្នុងទីឆ្ងាយពីបុគ្គលអ្នកមានបញ្ញាច្រើន គឺ អ្នកមានបញ្ញា មានសេចក្តីដឹង ប្រៀបដូចកែវវជិរៈរមែងសេពគប់គ្នាបាន សមាគមគ្នាបាន ដោយបញ្ញាសម្បត្តិនោះ ។

ចប់អដ្ឋកថា បឋមអស្សទ្ធមូលកសូត្រទី ៧

# អដ្ឋកថា

## អស្សទ្ធមូលកសូត្រទី ៨ ជាដើម

អស្សទ្ធមូលកសូត្រទី ៨ ជាដើម ព្រះមានព្រះភាគទ្រង់សម្តែងរួមធម៌ មានអស្សទ្ធាជាដើមទាំងនោះ ដោយអំណាចធម៌ ៣ យ៉ាង ។

ក្នុងបណ្តាសូត្រទាំងនោះ សូត្រទី ៨ ព្រះអង្គត្រាស់ធម៌ មានអស្សទ្ធាជាមូលជាដើម ៥ ដង (ក្នុងមួយដងៗ) មានធម៌ ៣ យ៉ាង ដោយអំណាចធម៌ចំណែកខ្មៅ និងចំណែកស ។ សូត្រទី ៩ ព្រះអង្គត្រាស់ធម៌ មានអហិរិកៈជាមូល ៤ ដង (ក្នុងមួយដងៗ) មានធម៌ ៣ យ៉ាង ។ សូត្រទី ១០ ព្រះអង្គត្រាស់ធម៌ មានអនោត្តប្បៈជាមូល ៣ ដង (ក្នុងមួយដងៗ) មានធម៌ ៣ យ៉ាង ។ សូត្រទី ១១ ត្រាស់ធម៌មានអប្បស្សុតៈ (មានសុតៈតិច) ជាមូល ២ ដង (ក្នុងមួយដងៗ) មានធម៌ ៣ យ៉ាង ។ សូត្រទី ១២ ត្រាស់ធម៌មានកុសិតៈ (សេចក្តីខ្ជិលច្រអូស) ជាមូល ១ ដង (ក្នុងមួយដងៗ) មានធម៌ ៣ យ៉ាង ដោយប្រការដូច្នេះ ។

ក្នុងទាំង ៥ សូត្រនោះ ទើបមានធម៌ ៣ យ៉ាង រួមជា ១៥ យ៉ាង ។ ក៏អាចារ្យពួកខ្លះពោលថា ធម៌ទាំង ១៥ យ៉ាងនេះ គឺ ព្រះសូត្រខាងចុងនេះ ឈ្មោះថា **តិកបេយ្យាលៈ** ។

ចប់អដ្ឋកថា អស្សទ្ធមូលកសូត្រទី ៨ ជាដើម

## ចប់ទុតិយវគ្គទី ២

### រួមក្នុងវគ្គនេះមាន ១២ អដ្ឋកថា

១-អដ្ឋកថាសត្តិមសូត្រ
២-អដ្ឋកថាសនិទានសូត្រ
៣-អដ្ឋកថាគិញ្ជកាវសថសូត្រ
៤-អដ្ឋកថាហីនាធិមុត្តិសូត្រ
៥-អដ្ឋកថាចង្កមសូត្រ
៦-អដ្ឋកថាសគាថាវទូសូត្រ
៧-អដ្ឋកថាបឋមអស្សទ្ធមូលកសូត្រ
៨-អដ្ឋកថាអស្សទ្ធមូលកសូត្រទី ៨
និងអដ្ឋកថាកុសិតសូត្រទី ១២

# ទសកម្មបថវគ្គ

## អ ដ្ឋ ក ថា

### អសមាហិតសូត្រទី ១

*ក្នុងសូត្រដទៃអំពីវគ្គទី ២ នេះ* ***អសមាហិតសូត្រទី ១*** *ព្រះអង្គត្រាស់ដោយអំណាចនៃធម៌ មានអស្សទ្ធាជាដើម ៥ យ៉ាង ។ ទុស្សីលសូត្រទី ២ ក៏ត្រាស់ដូច្នោះ ។ តែក្នុងអសមាហិតសូត្រទី ១ ព្រះអង្គត្រាស់* ***អសមាហិត*** *បទ ជាបទទី ៤ ។*

*ក្នុងទុស្សីលសូត្រទី ២ ព្រះអង្គត្រាស់* ***ទុស្សីល*** *បទ ជាបទទី ៤ ។ កាលព្រះអង្គត្រាស់យ៉ាងនេះ គឺ ទ្រង់ត្រាស់តាមអធ្យាស្រ័យរបស់បុគ្គលដែលនឹងត្រាស់ដឹង ។*

[៥៨] *បទថា* ***អសមាហិតា*** *ក្នុងសូត្រទី ១ នេះ សេចក្ដីថា វៀរចាកឧបចារសមាធិ និងអប្បនាសមាធិ ។ បទថា* ***ទុស្សីលា*** *ប្រែថា មិនមានសីល ។*

ចប់អដ្ឋកថា អសមាហិតសូត្រទី ១ និងទុស្សីលសូត្រទី ២

# អ ដ្ឋ ក ថា

## បញ្ចសិក្ខាបទសូត្រទី ៣

ក្នុងសូត្រទី ៣ ព្រះអង្គត្រាស់ដោយអំណាចអធ្យាស្រ័យរបស់បុគ្គលដែលនឹងត្រាស់ដឹង ។ សូត្រទី ៤ ទ្រង់ត្រាស់ដោយអំណាចកម្មបថ ៧ ។ សូត្រទី ៥ ទ្រង់ត្រាស់ដោយអំណាចកម្មបថ ១០ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង *បញ្ចសិក្ខាបទសូត្រទី ៣* ៖

[៦១] ក្នុងសូត្រនោះ បទថា *សុរាមេរយមជ្ជបមាទដ្ឋាយិនោ* សេចក្តីថា បុគ្គលទាំងឡាយផឹកទឹកស្រវឹង គឺ សុរា និងមេរ័យដោយចេតនាក្នុងសេចក្តីប្រមាទណា ។ ចេតនានោះហៅថា សេចក្តីប្រមាទ ព្រោះការផឹកទឹកស្រវឹង គឺ សុរា និងមេរ័យ បុគ្គលពួកណាតាំងនៅក្នុងសេចក្តីប្រមាទនោះ ព្រោះហេតុនោះ បុគ្គលទាំងនោះតាំងនៅក្នុងសេចក្តីប្រមាទ ព្រោះការផឹកទឹកស្រវឹង គឺ សុរា និងមេរ័យ នេះជាអធិប្បាយនៃបទមិនទូទៅក្នុងសូត្រនេះមុន ។

ចប់អដ្ឋកថា បញ្ចសិក្ខាបទសូត្រទី ៣

# អ ដ្ឋ ក ថា

## ទសកម្មបថសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុងទសកម្មបថសូត្រទី ៥ ដូចតទៅនេះ ៖*

[៦៥] *ឈ្មោះថា បុគ្គលធ្វើបាណាតិបាត ព្រោះអត្ថថា ធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះ ។ អធិប្បាយថា បុគ្គលសម្លាប់សត្វមានជីវិត ។ ឈ្មោះថា បុគ្គលធ្វើអទិន្នាទាន ព្រោះអត្ថថា កាន់យកវត្ថុដែលគេមិនបានឲ្យ អធិប្បាយថា លួចរបស់អ្នកដទៃ ។ ឈ្មោះថា បុគ្គលធ្វើកាមេសុមិច្ឆាចារ ព្រោះអត្ថថា ប្រព្រឹត្តខុសក្នុងវត្ថុកាម ដោយកិលេសកាម ។ ឈ្មោះថា បុគ្គលពោលមុសាវាទ ព្រោះអត្ថថា និយាយកុហក អធិប្បាយថា និយាយវាចាកុហកឡេះឡោះ ទម្លាយប្រយោជន៍របស់អ្នកដទៃ ។ ឈ្មោះថា បុគ្គលពោលនូវបិសុណាវាចា ព្រោះអត្ថថា មានវាចាស៊កសៀត ។ ឈ្មោះថា បុគ្គលពោលផរុសវាចា ព្រោះអត្ថថា មានវាចាគ្រោតគ្រាត កាត់បង់នូវពាក្យដែលជាទីស្រឡាញ់ ។ ឈ្មោះថា បុគ្គលពោលសម្ផប្បលាបៈ ព្រោះអត្ថថា និយាយពាក្យរោយរាយគ្មានប្រយោជន៍ ។ ឈ្មោះថា បុគ្គលមានអភិជ្ឈា ព្រោះអត្ថថា សម្លឹងរំពៃ អធិប្បាយថា ជាអ្នកមានប្រក្រតីចង់បានកណ្ឌៈរបស់អ្នកដទៃ ។*

ឈ្មោះថា បុគ្គលមានចិត្តព្យាបាទ ព្រោះអត្ថថា មានចិត្តបៀតបៀន ។ ឈ្មោះថា បុគ្គលមានមិច្ឆាទិដ្ឋិ ព្រោះអត្ថថា មានការឃើញខុស គឺ អាក្រក់ ដែលវិញ្ញូជនតិះដៀល អធិប្បាយថា ប្រកបដោយទិដ្ឋិដែលមិននាំឲ្យរួចផុតចាកទុក្ខ រាប់បញ្ចូលក្នុងកម្មបថ គឺ រាប់បញ្ចូលក្នុងការឃើញខុស មានវត្ថុជាដើមថា ទានដែលឲ្យហើយមិនមានផល ។ ឈ្មោះថា សម្មាទិដ្ឋិ ព្រោះអត្ថថា មានការឃើញប្រពៃ គឺ ល្អ ដែលវិញ្ញូជនសរសើរ អធិប្បាយថា ប្រកបដោយមគ្គទិដ្ឋិ រាប់បញ្ចូលក្នុងកម្មបថ គឺ រាប់បញ្ចូលក្នុងការឃើញប្រពៃថា សត្វមានកម្មជារបស់ខ្លួន ជាដើមថា ទានដែលឲ្យហើយមានផល នេះជាការពណ៌នាបទដែលលំបាកក្នុងសូត្រនេះមុន ។

ចំណែកបទទាំងនោះ មានអត្ថ ១០ យ៉ាង ក្នុងធម៌ចំណែកខ្មៅ គឺ បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ បិសុណវាចា ផរុសវាចា សម្ផប្បលាបៈ អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ។ ក្នុងបទទាំងនោះ ការញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះ ឈ្មោះថា បាណាតិបាត ។ មានអធិប្បាយថា សម្លាប់សត្វមានជីវិត គឺ ការសម្លាប់សត្វមានជីវិតឲ្យស្លាប់ ។ ចំណែកក្នុងបទថា **បាណោ** នេះ ដោយវោហារបានដល់ សត្វ ។

ដោយបរមត្ថ បានដល់ ជីវិតិន្ទ្រិយ ។ ក៏វធកចេតនារបស់អ្នកមាន

មានសេចក្ដីសម្គាល់ក្នុងសត្វមានជីវិតនោះថា សត្វមានជីវិត ដែលតាំងឡើង ព្រោះសេចក្ដីព្យាយាមជាហេតុ ចូលទៅផ្ដាច់ជីវិតិន្ទ្រិយចេញ ដែលប្រព្រឹត្ត ទៅផ្លូវកាយទ្វារ និងវចីទ្វារ ទ្វារណាមួយ ឈ្មោះថា បាណាតិបាត ។ បណ្ដា សត្វដែលមានជីវិត បុគ្គលវៀរចាកគុណ មានសត្វតិរច្ឆានជាដើម បាណា-តិបាតនោះ ឈ្មោះថា មានទោសតិច ព្រោះសត្វតូច ឈ្មោះថា មានទោស ច្រើន ព្រោះសត្វធំ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះមានសេចក្ដី ព្យាយាមច្រើន ។ សូម្បីកាលមានសេចក្ដីព្យាយាមស្មើគ្នា ក៏ឈ្មោះថា មាន ទោសច្រើន ព្រោះវត្ថុធំ ។

បណ្ដាសត្វអ្នកមានគុណ មានមនុស្សជាដើម បាណាតិបាត ឈ្មោះ ថា មានទោសតិច ព្រោះសត្វមានគុណតិច ឈ្មោះថា មានទោសច្រើន ព្រោះសត្វមានគុណច្រើន ។ ក៏កាលមានសរីរៈ និងគុណស្មើគ្នា ក៏គប្បី ជ្រាបថា មានទោសតិច ព្រោះកិលេស និងសេចក្ដីព្យាយាមតិច គប្បីជ្រាប ថា មានទោសច្រើន ព្រោះកិលេស និងសេចក្ដីព្យាយាមខ្លាំងក្លា ។ បាណា-តិបាតនោះ **មានអង្គ ៥** គឺ សត្វមានជីវិត ១ ជាអ្នកមានសេចក្ដីសម្គាល់ ថាសត្វមានជីវិត ១ ចិត្តគិតនឹងសម្លាប់ ១ មានសេចក្ដីព្យាយាម ១ សត្វ ស្លាប់ដោយសេចក្ដីព្យាយាមនោះ ១ ។ **ប្រយោគមាន ៦** គឺ សាហត្ថិកៈ ១

អាណត្តិកៈ ១ និស្សគ្គិយៈ ១ ថាវរៈ ១ ឥទ្ធិមយៈ ១ វិជ្ជាមយៈ ១ ។ សេចក្តីយឺតយូរក៏នឹងមានក្នុងរឿងនោះ ប្រសិនបើខ្ញុំធ្វើឲ្យពិស្តារទុកក្នុងទីនេះ ព្រោះដូច្នោះ ខ្ញុំនឹងមិនឲ្យរឿងនោះពិស្តារ ។ ចំណែករឿងដទៃ និងរឿងបែបនោះ អ្នកមានសេចក្តីត្រូវការគប្បីត្រួតមើលក្នុងអដ្ឋកថាព្រះវិន័យឈ្មោះសមន្តប្បាសាទិកាចុះ ។

ការកាន់យកវត្ថុដែលគេមិនបានឲ្យ ឈ្មោះថា **អទិន្នាទាន** មានអធិប្បាយថា លួចរបស់អ្នកដទៃ ជាការប្រព្រឹត្តរបស់ចោរ ។ ក្នុងបទទាំងនោះ បទថា **អទិន្នំ** សេចក្តីថា កាន់យកវត្ថុដែលអ្នកដទៃហួងហែង ។ ថេយ្យចេតនារបស់បុគ្គលដែលមានសេចក្តីសម្គាល់ក្នុងវត្ថុ ដែលអ្នកដទៃហួងហែងនោះថា ជាវត្ថុដែលអ្នកដទៃហួងហែងហើយ ប្រើអ្នកដទៃឲ្យធ្វើតាមសេចក្តីត្រូវការ មិនទាន់មានទោសផ្លូវអាជ្ញា គឺ មិនទាន់មានអ្នកណាពោលទោស ព្រោះសេចក្តីព្យាយាមជាហេតុកាន់យកនូវវត្ថុដែលអ្នកដទៃហួងហែងនោះ ឲ្យតាំងឡើង ក៏ឈ្មោះថា អទិន្នាទាន ។ អទិន្នាទាននោះ ឈ្មោះថា មានទោសតិចព្រោះវត្ថុអ្នកដទៃមិនល្អ ។ ឈ្មោះថា មានទោសច្រើន ព្រោះវត្ថុអ្នកដទៃប្រណីត ។ ព្រោះហេតុអ្វី ។ ព្រោះវត្ថុប្រណីត ។ កាលវត្ថុស្មើគ្នា ឈ្មោះថា មានទោសច្រើន ព្រោះជាវត្ថុនៃបុគ្គលដែលក្រៃលែងដោយគុណ ឈ្មោះថា

មានទោសតិច ព្រោះជាវត្ថុនៃបុគ្គលដែលមានគុណតិចជាងបុគ្គលដែលក្រៃលែងដោយគុណនោះ ព្រោះប្រៀបធៀបជាមួយបុគ្គលដែលក្រៃលែងដោយគុណនោះៗ ។ អទិន្នាទាននោះ **មានអង្គ ៥** គឺ វត្ថុដែលអ្នកដទៃហួងហែង ១ ជាអ្នកមានសេចក្តីសម្គាល់ថា ជារបស់ដែលអ្នកដទៃហួងហែង ១ ចិត្តគិតនឹងលួច ១ សេចក្តីព្យាយាម ១ លួចបានដោយសេចក្តីព្យាយាមនោះ ១ ។ **ប្រយោគមាន ៦** មានសាហត្ថិកៈជាដើម ក៏ឯប្រយោគទាំងនោះ ប្រព្រឹត្តទៅដោយអំណាចនៃអវហារទាំងនេះ តាមសមគួរ គឺ ថេយ្យាវហារ លួចដោយអាការជាចោរ ១ បសយ្ហាវហារ លួចដោយការគម្រាមកំហែង ១ បដិច្ឆន្នាវហារ លួចដោយការបិទបាំង ១ បរិកប្បាវហារ លួចដោយការកំណត់ ១ កុសាវហារ លួចដោយការផ្លាស់ប្តូរ ១ នេះជាសេចក្តីសង្ខេបក្នុងសេចក្តីនេះ ចំណែកសេចក្តីពិស្តារ លោកពោលទុកហើយក្នុងសមន្តប្បាសាទិកា ។

ចំណែកបទថា **កាមេសុ** ក្នុងបទថា **កាមេសុមិច្ឆាចារោ** នេះ បានដល់ការប្រព្រឹត្តនូវមេថុន ។ បទថា **មិច្ឆាចារោ** បានដល់ អាចារៈដែលថោកទាបដែលបណ្ឌិតតិះដៀលតែម្យ៉ាង ។ ក៏ដោយលក្ខណៈ ចេតនាជាហេតុឈានកន្លងឋានៈ ដែលបុគ្គលមិនគប្បីដល់ដោយការប្រព្រឹត្តតាមផ្លូវកាយ ដោយ

ប្រាថ្នាអសទ្ធម្ម ឈ្មោះថា កាមេសុមិច្ឆាចារ ។

ក្នុងកាមេសុមិច្ឆាចារនោះ ស្ត្រី ១០ ពួកដំបូង មានពួកដែលមាតាឃុំគ្រងរក្សាជាដើម គឺ **មាតុរក្ខិតា** ស្ត្រីដែលមាតាឃុំគ្រងរក្សា ១ **បិតុរក្ខិតា** ដែលបិតាឃុំគ្រងរក្សា ១ **មាតាបិតុរក្ខិតា** ដែលមាតាបិតាឃុំគ្រងរក្សា ១ **ភាតុរក្ខិតា** ដែលបងប្អូនប្រុសឃុំគ្រងរក្សា ១ **ភគិនីរក្ខិតា** ដែលបងប្អូនស្រីឃុំគ្រងរក្សា ១ **ញាតិរក្ខិតា** ដែលញាតិឃុំគ្រងរក្សា ១ **គោត្តរក្ខិតា** ដែលវង្សត្រកូលឃុំគ្រងរក្សា ១ **ធម្មរក្ខិតា** ដែលអ្នកប្រព្រឹត្តធម៌ឃុំគ្រងរក្សា ១ **សារក្ខា** ស្ត្រីដែលបុរសបំពាក់កម្រងផ្កាឲ្យ ១ **សបរិទណ្ឌា** ស្ត្រីដែលនៅក្នុងឃុំគ្រងរក្សាដោយអាជ្ញា ១ , និងស្ត្រី ១០ ពួកខាងក្រោយ មានពួកដែលបុរសទិញមកដោយទ្រព្យជាដើម ទាំងនេះ គឺ **ធនក្កីតា** ស្ត្រីដែលបុរសទិញមកដោយទ្រព្យ ១ **ឆន្ទវាសិនី** ស្ត្រីដែលនៅរួមដោយសេចក្តីពេញចិត្ត ១ **ភោគវាសិនី** ស្ត្រីដែលមកនៅរួមព្រោះភោគៈ ១ **បដវាសិនី** ស្ត្រីដែលមកនៅរួមព្រោះសំពត់ ១ **ឱទបត្តកិនី** ស្ត្រីដែលញាតិចាប់ដៃផ្សំផ្គុំជាមួយនឹងបុរសជ្រលក់ក្នុងភាជនៈទឹក ១ **ឱភតចុម្ពតា** ស្ត្រីដែលបុរសជួយឲ្យផុតកម្មការី ទាសីភរិយា ភរិយាដែលជាទាសី ១ **កម្មការីភរិយា** ភរិយាដែលជាកម្ម ១ **ធជាហដា** ស្ត្រីដែលជាឈ្លើយសឹក ១ **មុហុត្តិកា** ស្ត្រីដែល

ដែលនៅរួមមួយក្លែត ១ ៗ រួមជា ២០ ពួក ឈ្មោះថា **អគមនីយដ្ឋាន** (ឋានៈដែលមិនគប្បីទាក់ទង) សម្រាប់បុរស ៗ

ចំណែកក្នុងស្ត្រីទាំងឡាយ ១២ ពួក គឺ **សារក្ខា** ១ **បរិទណ្ឌា** ១ និង **ធនក្កីតា** ជាដើម ១០ ពួក នេះ ឈ្មោះថា អគមនីយដ្ឋានចំពោះស្ត្រី ៗ

ក៏មិច្ឆាចារនេះ ឈ្មោះថា មានទោសតិច ព្រោះអគមនីយដ្ឋាន វៀរចាកគុណ មានសីលជាដើម ឈ្មោះថា មានទោសច្រើន ព្រោះអគមនីយដ្ឋាន ដែលដល់ព្រមដោយគុណ មានសីលជាដើម ៗ កាមេសុមិច្ឆាចារនោះ **មានអង្គ ៤** គឺ វត្ថុដែលមិនគួរដល់ ១ ចិត្តគិតនឹងសេពក្នុងវត្ថុដែលមិនគួរដល់នោះ ១ សេចក្តីព្យាយាមក្នុងការសេព ១ ញុំាំងមគ្គនឹងមគ្គឲ្យដល់គ្នា ១ ៗ មានប្រយោគតែមួយ គឺ សាហត្ថិកៈប៉ុណ្ណោះ ៗ

បទថា **មុសាវាទោ** សេចក្តីថា វចីបយោគ ឬកាយបយោគ ដែលកាត់នូវប្រយោជន៍របស់អ្នកដទៃ ប្រាថ្នានឹងពោលឲ្យខុស ចេតនាដែលញុំាំងកាយបយោគ និងវចីបយោគរបស់អ្នកពោលឲ្យខុសចំពោះអ្នកដទៃ ឲ្យតាំងឡើងដល់អ្នកដទៃ ដោយប្រាថ្នានឹងពោលឲ្យខុស ឈ្មោះថា **មុសាវាទ** ៗ

ន័យមួយទៀត រឿងដែលមិនពិត មិនមានពិត ឈ្មោះថា **មុសា** ៗ ការញុំាំងអ្នកដទៃឲ្យដឹងរឿងនោះ ថាជារឿងពិត រឿងពិត ឈ្មោះថា វាទៈ ៗ

ដោយលក្ខណៈ ចេតនាដែលញ៉ាំងវិញ្ញត្តិយ៉ាងនោះឲ្យតាំងឡើង របស់អ្នកប្រាថ្នានឹងញ៉ាំងអ្នកដទៃឲ្យដឹងរឿងដែលមិនពិត ថាជារឿងពិត ឈ្មោះថា **មុសាវាទ** ។ មុសាវាទនោះ ឈ្មោះថា មានទោសតិច ព្រោះប្រយោជន៍ដែលមុសាវាទីបុគ្គលទម្លាយតិច ឈ្មោះថា មានទោសច្រើន ព្រោះប្រយោជន៍ដែលមុសាវាទីបុគ្គលទម្លាយច្រើន មួយទៀត សម្រាប់ពួកគ្រហស្ថ មុសាវាទដែលប្រព្រឹត្តទៅដោយន័យជាដើមថា មិនមាន ព្រោះមិនប្រាថ្នានឹងឲ្យទ្រព្យសម្បត្តិរបស់ខ្លួន ឈ្មោះថា មានទោសតិច ។ មុសាវាទដែលមុសាវាទីបុគ្គលជាសាក្សីពោលដើម្បីទម្លាយប្រយោជន៍ ឈ្មោះថា មានទោសច្រើន ។ ចំពោះពួកបព្វជិត មុសាវាទដែលប្រព្រឹត្តទៅដោយបូរណកថា ដោយន័យថា ថ្ងៃនេះ ប្រេងក្នុងស្រុកហូរទៅដូចទន្លេ ព្រោះបានប្រេង ឬទឹកដោះថ្លាសូម្បីបន្តិចបន្តួចហើយ ប្រាថ្នាដើម្បីនឹងឲ្យសើចលេង ឈ្មោះថា មានទោសតិច ។ តែមុសាវាទរបស់អ្នកពោលវត្ថុដែលខ្លួនមិនបានឃើញនុ៎ះឯង ដោយន័យជាដើមថា ខ្ញុំឃើញ ឈ្មោះថា មានទោសច្រើន ។

មុសាវាទនោះ **មានអង្គ ៤** គឺ រឿងមិនពិត ១ ចិត្តគិតនឹងពោលឲ្យខុស ១ សេចក្តីព្យាយាមកើតអំពីចិត្តនោះ ១ អ្នកដទៃដឹងរឿងនោះ ១ មានប្រយោគតែមួយ គឺ សាហត្ថិកៈនោះឯង ។ មុសាវាទនោះ គប្បីឃើញ

ក្នុងកិរិយាជាគ្រឿងពោលឲ្យខុសចំពោះអ្នកដទៃ ដោយកាយខ្លះ ដោយវត្ថុជាប់ដោយកាយខ្លះ ដោយវាចាខ្លះ ប្រសិនបើអ្នកដទៃដឹងរឿងនោះ ដោយកិរិយានោះ ។ ចេតនាដែលញ៉ាំងកិរិយាឲ្យតាំងឡើងនេះ រមែងចងរឹតដោយមុសាវាទកម្មក្នុងខណៈនោះឯង ។ បទ ក្នុងបទជាដើមថា **បិសុណា វាចា** សេចក្ដីថា បុគ្គលនិយាយដល់អ្នកដទៃដោយវាចាណា ធ្វើខ្លួនឲ្យជាទីស្រឡាញ់នៅក្នុងចិត្តរបស់អ្នកនោះ និងធ្វើអ្នកដទៃឲ្យវិនាស វាចានោះ ឈ្មោះថា **បិសុណាវាចា** ។ ចំណែកវាចាណា ធ្វើខ្លួនឯង និងអ្នកដទៃឲ្យអាក្រក់ ឬវាចាណាគ្រោតគ្រាត សូម្បីខ្លួនឯងក៏មិនពីរោះត្រចៀក មិនសប្បាយចិត្ត នេះឈ្មោះថា **ផរុសវាចា** ។ បុគ្គលពោលផ្ដេសផ្ដាស់ គ្មានប្រយោជន៍ ឈ្មោះថា **សម្ផប្បលាបៈ** ។ សូម្បីចេតនាដែលជាមូលនៃវាចាទាំងនោះ ក៏រមែងបានឈ្មោះថា បិសុណាវាចាជាដើមដូចគ្នា ។ ក៏ចេតនានោះឯង លោកបំណងយកក្នុងទីនេះ ។

ក្នុងបទនោះ ចេតនារបស់អ្នកមានចិត្តសៅហ្មង ដែលញ៉ាំងកាយបយោគ និងវចីបយោគឲ្យតាំងឡើង ដើម្បីទម្លាយជនពួកដទៃក្ដី ដើម្បីប្រាថ្នានឹងធ្វើខ្លួនឲ្យជាទីស្រឡាញ់ក្ដី ឈ្មោះថា **បិសុណាវាចា** ។ បិសុណា-វាចានោះ ឈ្មោះថា មានទោសតិច ព្រោះបុគ្គលដែលត្រូវបិសុណាវាចី-

បុគ្គល ធ្វើឲ្យបែកគ្នាក្នុងបុគ្គលដែលមានគុណតិច, ឈ្មោះថា មានទោសច្រើន ក្នុងបុគ្គលដែលមានគុណច្រើន ។

បិសុណាវាចានោះ **មានអង្គ ៤** គឺ ទម្លាយអ្នកដទៃ ១ ជាអ្នកប្រាថ្នាដើម្បីបំបែកបុគ្គលដទៃ ដោយប្រាថ្នាថា បុគ្គលទាំងនេះនឹងមានសភាពផ្សេងគ្នា នឹងវៀរចាកគ្នា ដោយឧបាយយ៉ាងនេះ ដូច្នេះ ឬប្រាថ្នានឹងធ្វើខ្លួនឯងឲ្យជាទីស្រឡាញ់ ដោយបំណងថា យើងនឹងជាទីស្រឡាញ់ នឹងជាអ្នកជិតជិតដោយឧបាយដូច្នេះ ១ សេចក្តីព្យាយាមដែលកើតអំពីចិត្តនោះ ១ អ្នកនោះដឹងសេចក្តីនោះ ១ ។ ចេតនាគ្រោតគ្រាតដោយចំណែកមួយ ដែលញ៉ាំងកាយបយោគ និងវចីបយោគដែលជាហេតុកាត់ចេញនូវពាក្យជាទីស្រឡាញ់របស់អ្នកដទៃឲ្យតាំងឡើង ឈ្មោះថា **ផរុសវាចា** ។ ដើម្បីឲ្យផរុសវាចានោះជាក់ច្បាស់ គប្បីជ្រាបរឿងតទៅនេះ ៖

បានឮថា ក្មេងម្នាក់មិនជឿពាក្យរបស់មាតា ទៅកាន់ព្រៃ កាលមាតាមិនអាចនឹងឲ្យក្មេងនោះត្រឡប់បាន ទើបជេរថា សូមឲ្យមេក្របីដេញតាមវា ។ គ្រានោះ មេក្របីក្នុងព្រៃ ប្រាកដដល់ក្មេងនោះ យ៉ាងនោះឯង ។ ក្មេងបានធ្វើសច្ចកិរិយាថា សូមពាក្យដែលម៉ែនិយាយដល់យើង ចូរកុំមាន សូម (អ្វី) ដែលម៉ែគិត ចូរមាន ។ មេក្របីបានឈប់ ដូចត្រូវចងក្នុងទីនោះឯង ។

វចីបយោគ សូម្បីជាហេតុកាត់ចេញនូវពាក្យជាទីស្រឡាញ់យ៉ាងនោះ ក៏មិនឈ្មោះថា ជាផរុសវាចា ព្រោះចិត្តទន់ ។ ពិតណាស់ គ្រាខ្លះមាតាបិតា រមែងនិយាយចំពោះបុត្រតូចទាំងឡាយយ៉ាងនេះថា សូមពួកចោរ ចូរធ្វើវាឲ្យជាកំណាត់តូចៗ ចុះ តែលោកក៏មិនបំណងសូម្បីតែនឹងឲ្យត្របកឧប្បលធ្លាក់ចុះខាងលើដល់បុត្រទាំងនោះ ។ មួយទៀត ពេលខ្លះអាចារ្យ និងឧបជ្ឈាយ៍ទាំងឡាយ និយាយនឹងពួកសិស្សយ៉ាងនេះថា អ្នកទាំងនេះមិនមានសេចក្ដីខ្មាស មិនមានសេចក្ដីខ្លាចក្រែង និយាយអ្វី ដេញគេចេញទៅ ។ ក៏ប៉ុន្តែលោកបំណងការដល់ព្រមដោយបរិយត្តិ បដិបត្តិ បដិវេធ ដើម្បីសិស្សទាំងនោះ ។ ដូចជា វចីបយោគដែលប្រព្រឹត្តទៅ ព្រោះអ្នកនិយាយ ជាអ្នកមានចិត្តទន់ មិនឈ្មោះថា ផរុសវាចា យ៉ាងណា វចីបយោគប្រព្រឹត្តទៅ ព្រោះអ្នកនិយាយជាអ្នកមានពាក្យផ្អែមល្ហែម មិនឈ្មោះថា ផរុសវាចា ក៏មិនមែនដូច្នោះ ។ ពិតណាស់ ពាក្យនិយាយរបស់អ្នកប្រាថ្នានឹងឲ្យគេស្លាប់ថា អ្នកទាំងឡាយចូរឲ្យអ្នកនេះដេកជាសុខចុះ មិនឈ្មោះថា ផរុសវាចាទុះ ក៏មិនមែន ។ ដែលពិត វាចានោះជាផរុសវាចាដោយពិត ព្រោះអ្នកនិយាយជាអ្នកមានចិត្តគ្រោតគ្រាត ។ ផរុសវាចានោះ ឈ្មោះថា មានទោសតិច ព្រោះអ្នកដែលត្រូវផរុសវាចីបុគ្គលសំដៅយកឲ្យប្រព្រឹត្តទៅមានគុណតិច ឈ្មោះថា

មានទោសច្រើន ព្រោះបុគ្គលនោះមានគុណច្រើន ។

ផរុសវាចានោះ **មានអង្គ ៣** គឺ បុគ្គលដទៃដែលគប្បីជេរ ១ មានចិត្តក្រោធ ១ បានជេរ ១ ។ អកុសលចេតនាដែលញុំាងកាយបយោគ និងវចីបយោគឲ្យតាំងឡើង ដែលញុំាងអ្នកដទៃឲ្យដឹងវត្ថុដែលមិនមែនប្រយោជន៍ ឈ្មោះថា **សម្ផប្បលាបៈ** ។ សម្ផប្បលាបៈនោះ ឈ្មោះថា មានទោសតិច ព្រោះសេពតិច ឈ្មោះថា មានទោសច្រើន ព្រោះសេពច្រើន ។

សម្ផប្បលាបៈនោះ **មានអង្គ ២** គឺ ជាអ្នកប្រាថ្នានិយាយរឿងដែលរកប្រយោជន៍មិនបាន មានរឿងការតយុទ្ធ និងរឿងដណ្តើមយកនាងសីតាជាដើម ១ ការនិយាយរឿងបែបនោះ ១ ។ ធម្មជាតិដែលឈ្មោះថា **អភិជ្ឈា** ព្រោះអត្ថថា សម្លឹងរំពៃ អធិប្បាយថា ប្រព្រឹត្តទៅដោយភាពជាអ្នកប្រាថ្នាភណ្ឌៈរបស់អ្នកដទៃ ហើយបង្អោនទៅក្នុងភណ្ឌៈនោះ ។ អភិជ្ឈានោះ មានលក្ខណៈសម្លឹងរំពៃចំពោះភណ្ឌៈរបស់អ្នកដទៃ យ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ វត្ថុនេះនឹងគប្បីជារបស់យើង ដូច្នេះ ឈ្មោះថា មានទោសតិច និងមានទោសច្រើន ដូចអទិន្នាទាន ។

អភិជ្ឈានោះ **មានអង្គ ២** គឺ ភណ្ឌៈរបស់អ្នកដទៃ ១ មានការបង្អោនមកដើម្បីខ្លួន ១ ពិតណាស់ លោភៈដែលមានភណ្ឌៈរបស់អ្នកដទៃជាទីតាំង

សូម្បីកើតឡើងហើយ អភិជ្ឈាលុបុគ្គលមិនទាន់បង្អោនមកដើម្បីខ្លួន ដោយគិតថា ធ្វើដូចម្តេចហ្ន៎ វត្ថុនេះនឹងគប្បីជារបស់យើង ដរាបណា កម្មបថក៏មិនទាន់ដាច់ដរាបនោះ ។

ធម៌ដែលឈ្មោះថា **ព្យាបាទ** ព្រោះអត្ថថា ញុំាងប្រយោជន៍សុខឲ្យដល់សេចក្តីវិនាស ។ ព្យាបាទនោះ មានលក្ខណៈប្រទូសរ៉ាយចិត្ត ដើម្បីសេចក្តីវិនាសដល់បុគ្គលដទៃ ឈ្មោះថា មានទោសតិច និងមានទោសច្រើន ដូចផរុសវាចា ។

ព្យាបាទនោះ **មានអង្គ ២** គឺ សត្វដទៃ ១ គិតដើម្បីឲ្យសត្វនោះវិនាស ១ ។ ក៏កាលសេចក្តីក្រោធ ដែលមានសត្វដទៃជាទីតាំង សូម្បីកើតឡើងហើយ វិបន្នចិត្តបុគ្គលមិនទាន់គិតចង់ឲ្យសត្វនោះវិនាសថា ធ្វើដូចម្តេចហ្ន៎ សត្វនេះគប្បីវិនាសទៅ ដរាបណា កម្មបថក៏មិនទាន់ដាច់ដរាបនោះ ។

ធម្មជាតិឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះអត្ថថា ឃើញខុស ព្រោះមិនកាន់យកតាមសេចក្តីពិត ។ មិច្ឆាទិដ្ឋិនោះ មានលក្ខណៈឃើញខុស ដោយន័យជាដើមថា ទានដែលឲ្យហើយមិនមានផល ឈ្មោះថា មានទោសតិច និងមានទោសច្រើន ដូចសម្ផប្បលាបៈ ។ ម្យ៉ាងទៀត មិច្ឆាទិដ្ឋិដែលមិនមែនជានិយតៈ ឈ្មោះថា មានទោសតិច ។ ដែលជានិយតៈ ឈ្មោះថា មានទោស

ច្រើន ។

មិច្ឆាទិដ្ឋិនោះ **មានអង្គ ២** គឺ អាការកាន់យកនៃបុគ្គលវិបរិត មិនត្រង់តាមសភាវៈវត្ថុ (**វត្ថុនោ គហិតាការវិបរិតា**) ១ ភាពប្រាកដនៃមិច្ឆាទិដ្ឋិនោះ ដែលប្រកាន់យកវត្ថុនោះថាពិត ១ (**យថា តំ គណ្ហាតិ តថាភាវេន តស្សុបដ្ឋានំ**)។

ក៏គប្បីជ្រាបវិនិច្ឆ័យអកុសលកម្មបថ ១០ ទាំងនេះ ដោយអាការ ៥ គឺ ដោយធម៌ ដោយកោដ្ឋាសៈ ដោយអារម្មណ៍ ដោយវេទនា ដោយមូល ។

បណ្តាបទទាំងនោះ បទថា **ធម្មតោ** (ដោយធម៌) សេចក្តីថា ក៏ក្នុងអកុសលកម្មបថទាំងនោះ មានចេតនាធម៌ ៧ យ៉ាងតាមលំដាប់ ។ អកុសលកម្មបថ មានអភិជ្ឈាជាដើមសម្បយុត្តដោយចេតនា ។ បទថា **កោដ្ឋាសតោ** (ដោយកោដ្ឋាសៈ) សេចក្តីថា ធម៌ ៨ យ៉ាងទាំងនេះគឺ ចេតនាធម៌ ៧ តាមលំដាប់ និងមិច្ឆាទិដ្ឋិ ជាកម្មបថតែម្យ៉ាង មិនជាមូល អភិជ្ឈា និងព្យាបាទ ជាកម្មបថផង ជាមូលផង ។ សេចក្តីពិត អភិជ្ឈា ជាលោភៈដល់ភាពជាមូល គឺ ជាអកុសលមូល ។ ព្យាបាទ ជាទោសៈ ដល់ភាពជាមូល គឺ ជាអកុសលមូល ។ បទថា **អារម្មណតោ** (ដោយអារម្មណ៍) សេចក្តីថា បាណាតិបាត មានសង្ខារជាអារម្មណ៍ ដោយអារម្មណ៍ គឺ ជីវិតិ-

ន្ទ្រិយ ។ អទិន្នាទាន មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ ។ មិច្ឆាចារ មានសង្ខារជាអារម្មណ៍ ដោយអំណាចផោដ្ឋព្វៈ ។ អាចារ្យពួកខ្លះពោលថា មានសត្វជាអារម្មណ៍ ដូច្នេះ ក៏មាន ។ មុសាវាទ មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ ។ បិសុណាវាចាក៏យ៉ាងនោះ ។ ផរុសវាចា មានសត្វជាអារម្មណ៍តែម្យ៉ាង ។ សម្ផប្បលាបៈ មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ ដោយអំណាចវត្ថុដែលខ្លួនបានឃើញ បានឮ បានជ្រាប និងបានដឹងហើយ ។ អភិជ្ឈាក៏យ៉ាងនោះ ។ ព្យាបាទ មានសត្វជាអារម្មណ៍តែម្យ៉ាង ។ មិច្ឆាទិដ្ឋិ មានសង្ខារជាអារម្មណ៍ ដោយអំណាចធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

បទថា **វេទនាតោ** (ដោយវេទនា) សេចក្តីថា បាណាតិបាត ជាទុក្ខវេទនា ។ ក៏ព្រះរាជាទ្រង់ឃើញចោរហើយ សូម្បីទ្រង់រីករាយ ត្រាស់បង្គាប់ថា អ្នកចូរទៅ ចូរសម្លាប់វា ដូច្នេះក៏ពិត សូម្បីយ៉ាងនោះ ចេតនាជាហេតុឲ្យសម្រេចបាន ក៏សម្បយុត្តដោយទុក្ខ ។ អទិន្នាទាន មានវេទនា ២ ។ មិច្ឆាចារ មានវេទនា ២ គឺ សុខវេទនា និងមជ្ឈត្តវេទនា (ឧបេក្ខាវេទនា) ចំណែកក្នុងចិត្តដែលជាហេតុឲ្យសម្រេច មិនជាមជ្ឈត្តវេទនា ។ មុសាវាទ មានវេទនា ៣ ។ បិសុណាវាចាក៏យ៉ាងនោះ ។ ផរុសវាចា ជាទុក្ខវេទនា ។

សម្ផប្បលាបៈ មានវេទនា ៣ ។ អភិជ្ឈា មានវេទនា ២ គឺ សុខវេទនា និងមជ្ឈត្តវេទនា ។ មិច្ឆាទិដ្ឋិក៏យ៉ាងនោះ ។ ព្យាបាទ ជាទុក្ខវេទនា ។

បទថា **មូលតោ** (ដោយមូល) សេចក្តីថា បាណាតិបាត មានមូល ២ គឺ ទោសៈ និងមោហៈ ។ អទិន្នាទាន មានមូល ២ គឺ ទោសៈ និងមោហៈ ឬលោភៈ និងមោហៈ ។ មិច្ឆាចារ មានមូល ២ គឺ លោភៈ និងមោហៈ ។ មុសាវាទ មានមូល ២ គឺ ទោសៈ និងមោហៈ ឬលោភៈ និងមោហៈ ។ បិសុណវាចា និងសម្ផប្បលាបៈក៏យ៉ាងនោះ ។ ផរុសវាចា មានមូល ២ គឺ ទោសៈ និងមោហៈ ។ អភិជ្ឈាមានមូលតែមួយ គឺ មោហៈ ។ ព្យាបាទក៏យ៉ាងនោះ ។ មិច្ឆាទិដ្ឋិ មានមូល ២ គឺ លោភៈ និងមោហៈ ។ បាណាតិបាត ជាដើម ក្នុងបទជាដើមថា **បាណាតិបាតា បដិវិរតា** មានអត្ថតាមដែលពោលហើយនោះឯង ។ ចំណែកជនទាំងនោះ ឈ្មោះថា វៀរដោយចំពោះនូវវិរតិណា ។ វិរតិនោះ ដោយប្រភេទមាន ៣ យ៉ាង គឺ សម្បត្តវិរតិ សមាទានវិរតិ សមុច្ឆេទវិរតិ ។ បណ្តាវិរតិទាំង ៣ នោះ វិរតិដែលកើតឡើងដល់បុគ្គលដែលមិនបានសមាទានសិក្ខាបទ ត្រឹមតែជាពិចារណាឋានៈទាំងឡាយ មានជាតិ វ័យ និងការសិក្សាច្រើនជាដើមរបស់ខ្លួន មិនឈានកន្លងវត្ថុដែលមកជួបប្រសព្វ ដោយគិតថា ការធ្វើដូច្នេះ មិនសមគួរដល់យើង ដូច្នេះ គប្បី

ជ្រាបថា សម្បត្តវិរតិ ។ ដូចវិរតិដែលកើតឡើងដល់ចក្កនៈឧបាសក ក្នុងកោះសីហឡ ដូច្នោះ ។

បានឮថា ក្នុងវេលាចក្កនៈឧបាសកនោះនៅកម្លោះនុ៎ះឯង រោគកើតឡើងដល់មាតា ។ ពេទ្យក៏ប្រាប់ថា គួរបានសាច់ទន្សាយស្រស់ ទើបគួរ ។ លំដាប់នោះ បងប្រុសរបស់គេប្រើនាយចក្កនៈទៅ ដោយបង្គាប់ថា នែ៎បា អ្នកឯងចូរទៅ ចូរទៅកាន់ស្រែចុះ ។ គេទៅស្រែនោះហើយ ។ ក៏សម័យនោះ ទន្សាយមួយក្បាលមកដើម្បីនឹងស៊ីសន្ទូងខ្ចី ។ ទន្សាយនោះ ឃើញនាយចក្កនៈចូលមក ទើបរត់ទៅដោយរហ័ស ត្រូវវល្លិរុំ បានស្រែកសំឡេងដ៏ខ្លាំង ឮ កិរិ កិរិ ។ នាយចក្កនៈទៅតាមសំឡេងនោះ ក៏ចាប់ទន្សាយនោះ ទើបគិតថា យើងនឹងផ្សំថ្នាំដល់មាតា ។ តែគេគិតតទៅទៀតថា ប្រការដែលយើងផ្តាច់ជីវិតសត្វ ព្រោះហេតុនៃជីវិតរបស់មាតា មិនគួរដល់យើងទេ ។ ដូច្នោះ ទើបព្រលែងទន្សាយនោះទៅ ដោយពាក្យថា ឯងចូរទៅ ចូរបរិភោគស្មៅ និងទឹកជាមួយទន្សាយក្នុងព្រៃចុះ ។ ក៏គេត្រូវបងប្រុសសួរថា ប្អូនឯងបានទន្សាយហើយឬ ទើបប្រាប់ការប្រព្រឹត្តនោះ ។ ដូច្នោះ បងប្រុសទើបជេរនាយចក្កនៈនោះ ។ គេទៅរកមាតា ឈរពោលពាក្យសច្ចថា តាំងពីកាលដែលខ្ញុំកើតមក មិនធ្លាប់ផ្តាច់ជីវិតសត្វទេ ។ ភ្លាមនុ៎ះឯង មាតារបស់

គេ ក៏បានជាសះស្បើយអំពីរោគ ។

ចំណែកវិរតិដែលកើតឡើងដល់បុគ្គល ដែលបានសមាទានសិក្ខាបទហើយ ព្រមលះបង់ជីវិតរបស់ខ្លួន ទាំងក្នុងវេលាសមាទានសិក្ខាបទ ទាំងក្នុងវេលាដទៃអំពីនោះ មិនឈានកន្លងវត្ថុ គប្បីជ្រាបថា ជាសមាទានវិរតិ ដូចវិរតិដែលកើតឡើងដល់ឧបាសកអ្នកស្រុកជិតភ្នំឧត្តរវឌ្ឍមានដូច្នោះ ។

បានឮថា ឧបាសកនោះទទួលសិក្ខាបទក្នុងសម្នាក់របស់ព្រះបិង្គលពុទ្ធរក្ខិតត្ថេរអ្នកនៅក្នុងអម្ពរិយវិហារ ហើយភ្ជួរស្រែ ។ គ្រានោះ គោរបស់គេបាត់ទៅ ។ គេកាលស្វែងរកគោនោះ បានឡើងទៅកាន់ភ្នំឈ្មោះថា ឧត្តរវឌ្ឍមាន ។ ពស់ធំលើភ្នំនោះបានក៏រឹតគេ ។ គេគិតថា យើងកាត់ក្បាលវាដោយកាំបិតដ៏មុតនេះ គិតទៀតថា យើងបានទទួលសិក្ខាបទក្នុងសម្នាក់របស់គ្រូដែលគួរសរសើរហើយ ទម្លាយចេញមិនសមគួរដល់យើងទេ ។ គ្រាគិតយ៉ាងនេះដរាបដល់ ៣ ដង ហើយសម្រេចចិត្តថា យើងនឹងព្រមលះបង់ជីវិតនឹងមិនព្រមលះបង់សិក្ខាបទ ហើយបោលកាំបិតព្រាដ៏មុតដែលលីនៅលើស្មា ក្នុងព្រៃនោះទៅ ពស់ធំបានលែងឧបាសកក្នុងវេលានោះដំណាលគ្នា ។

សម្បីការគិតថា យើងនឹងសម្លាប់សត្វដូច្នេះ រមែងមិនកើតឡើងដល់ព្រះអរិយបុគ្គលទាំងឡាយ ចាប់ផ្តើមតាំងពីការកើតឡើងនៃវិរតិណា វិរតិ

នោះសម្បយុត្តដោយអរិយមគ្គ គប្បីជ្រាបថាជា **សមុច្ឆេទវិរតិ** ។

គប្បីជ្រាបវិនិច្ឆ័យនៃកុសលកម្មបថទាំងនេះ ដោយអាការ ៥ គឺ ដោយធម៌ ដោយកោដ្ឋាសៈ ដោយអារម្មណ៍ ដោយវេទនា ដោយមូល ដូចអកុសលដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា **ធម្មតោ** សេចក្ដីថា ចេតនា ៧ ក្ដី វិរតិក្ដី រមែងគួរ តាមលំដាប់ក្នុងកុសលកម្មបថទាំងនោះ ។ ចំណែកធម៌ ៣ ក្នុងខាងចុង សម្បយុត្តដោយចេតនានោះឯង ។ បទថា **កោដ្ឋាសតោ** សេចក្ដីថា ចេតនា ៧ តាមលំដាប់ជាកម្មបថប៉ុណ្ណោះ មិនជាមូល ។ ធម៌ ៣ ខាងចុងជាមូលផង ជាកម្មបថផង ។ អព្យាបាទ ជាអទោសៈ ដល់ភាពជាមូលជាកុសលមូល សម្មាទិដ្ឋិ ជាអមោហៈ ដល់ភាពជាមូល ជាកុសលមូល ។ បទថា **អារម្មណតោ** សេចក្ដីថា អារម្មណ៍របស់បាណាតិបាតជាដើមនុ៎ះឯងក៏ជាអារម្មណ៍របស់កម្មបថទាំងនោះដូចគ្នា ។ ឈ្មោះថា វៀរចាកវត្ថុដែលនឹងគប្បីឈានកន្លងអារម្មណ៍នៃកម្មបថទាំងនោះ ។ ដូចជា អរិយមគ្គដែលមាននិព្វានជាអារម្មណ៍ រមែងលះកិលេសបាន យ៉ាងណា កម្មបថទាំងនោះមានជីវិតិន្ទ្រិយជាដើមជាអារម្មណ៍ គប្បីជ្រាបថា លះការទ្រុស្តសីល មានបាណាតិបាតជាដើមបាន ដូច្នោះ ។ បទថា **វេទនាតោ** សេចក្ដីថា វេទនា

ទាំងពួង ជាសុខវេទនា ឬមជ្ឈត្តវេទនា ។ ឈ្មោះថា ទុក្ខវេទនាដល់កុសល រមែងមិនមាន ។ បទថា **មូលតោ** សេចក្ដីថា ចេតនា ៧ តាមលំដាប់ មាន មូល ៣ គឺ អលោភៈ អទោសៈ និងអមោហៈ សម្រាប់អ្នកវៀរចាកដោយ ចិត្តជាញាណសម្បយុត្ត ។ មានមូល ២ សម្រាប់អ្នកវៀរចាកដោយចិត្តជា ញាណវិប្បយុត្ត ។ អនភិជ្ឈា មានមូល ២ សម្រាប់អ្នកវៀរចាកដោយចិត្ត ជាញាណសម្បយុត្ត ។ មានមូល ១ ដោយចិត្តជាញាណវិប្បយុត្ត ។ ចំណែក អលោភៈមិនជាមូលដល់ខ្លួនឯងឡើយ ។ សូម្បីក្នុងអព្យាបាទ ក៏ន័យនេះឯង ។ សម្មាទិដ្ឋិ មានមូល ២ គឺ អលោភៈ និង អទោសៈ ។

ចប់អដ្ឋកថា ឧសកម្មបថសូត្រទី ៥

# អ ដ្ឋ ក ថា

## អដ្ឋង្គិកសូត្រទី ៦

*អដ្ឋង្គិកសូត្រទី ៦ លោកពោលបានដោយអំណាចអធ្យាស្រ័យរបស់ពុជ្ឈនកជន (ពួកជនអ្នកយល់ដឹង) ដោយអំណាចអដ្ឋមគ្គ ៨ ។*

ចប់អដ្ឋកថា អដ្ឋង្គិកសូត្រទី ៦

# អ ដ្ឋ ក ថា

## ទសត្ថិកសូត្រទី ៧

*ទសត្ថិកសូត្រទី ៧ លោកពោលទុកដោយអំណាចមិច្ឆត្តៈ ១០ និងសម្មត្តៈ ១០ ។*

*[៦៩] ក្នុងបទទាំងនោះ បទថា* ***មិច្ឆាញាណិនោ*** *សេចក្តីថា បុគ្គលប្រកបដោយការដឹងខុស និងការពិចារណាខុស ។ បទថា* ***មិច្ឆាវិមុត្តិនោ*** *បានដល់ បុគ្គលដែលមិនទាន់រួចផុតចាកទុក្ខ គឺ ប្រកាន់ថា ជាកុសលវិមុត្តិ ហើយតាំងនៅ ។*

*[៧០] បទថា* ***សម្មាញាណិនោ*** *គឺ ការពិចារណាដោយប្រពៃ ។ បទថា* ***សម្មាវិមុត្តិនោ*** *សេចក្តីថា បុគ្គលប្រកបដោយផលវិមុត្តិ ដែលជាគ្រឿងនាំចេញចាកទុក្ខ ។*

ចប់អដ្ឋកថា ទសត្ថិកសូត្រទី ៧

## ចប់ទសកម្មបថវគ្គទី ៣

### រួមក្នុងវគ្គនេះមាន ៧ អដ្ឋកថា

១-អដ្ឋកថាសមាហិតសូត្រ ២-អដ្ឋកថាឧស្សីលសូត្រ
៣-អដ្ឋកថាបព្វសិក្ខាបទសូត្រ ៤-អដ្ឋកថាសត្តកម្មបថសូត្រ
៥-អដ្ឋកថាទសកម្មបថសូត្រ ៦-អដ្ឋកថាអដ្ឋត្ថិកសូត្រ
៧-អដ្ឋកថាទសត្ថិកសូត្រ

# ចតុទ្ធាតុវគ្គទី ៤

## អ ដ្ឋ ក ថា

### ចតស្សសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង* ***ចតស្សសូត្រទី ១*** *នៃចតុទ្ធាតុវគ្គទី ៤ ដូចតទៅនេះ ៖*

[៧១] *ធាតុដែលជាទីតាំង ឈ្មោះថា* ***បឋវីធាតុ*** *។ ធាតុដែលសើមជ្រួតជ្រាប ឈ្មោះថា* ***អាបោធាតុ*** *។ ធាតុដែលក្តៅ ឈ្មោះថា* ***តេជោធាតុ*** *។ ធាតុដែលតឹង ឈ្មោះថា* ***វាយោធាតុ*** *។ នេះជាសេចក្តីសង្ខេបក្នុងទីនេះ ។ ចំណែកសេចក្តីពិស្តារ គប្បីជ្រាបធាតុទាំងនោះ ដោយអំណាចកោដ្ឋាសៈ ២០ ជាដើម ។*

ចប់អដ្ឋកថា ចតស្សសូត្រទី ១

# អ ដ្ឋ ក ថា

## បុព្វសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង **បុព្វសូត្រទី ២** ដូចតទៅនេះ ៖

[៧២] បទថា **អយំ បថវីធាតុយា អស្សាទោ** សេចក្តីថា នេះជាអានិសង្សដែលអាស្រ័យបឋវីធាតុ ។ អានិសង្សនេះ មានការងើប និងការទម្រេតខ្លួន ដូចពោលថា លោកទាំងឡាយចូរព្យាយាមសឹកម្រាមដៃរបស់យើងចូលទៅក្នុងទីនេះចុះ ឬសណ្តូកដៃហើយ ទើបពោលថា លោកទាំងឡាយចូរព្យាយាមឱនកាយនេះចុះ ។ គប្បីជ្រាបអានិសង្ស ដោយអំណាចនៃសុខសោមនស្សដែលប្រព្រឹត្តទៅយ៉ាងនេះ ។

ក្នុងបទជាដើមថា **អនិច្ចា** សេចក្តីថា ឈ្មោះថា មិនទៀង ដោយអាការថា មានហើយត្រឡប់មិនមាន ឈ្មោះថា ជាទុក្ខ ដោយអាការបៀតបៀន ឈ្មោះថា មានសេចក្តីប្រែប្រួលជាធម្មតា ដោយអាការប្រាសចាកភាវៈរបស់ខ្លួន ។ បទថា **អយំ បឋវី ធាតុយា អាទីនវោ** សេចក្តីថា ឈ្មោះថា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលទៅជាធម្មតាដោយអាការណា ។ អាការនេះ ជាទោសនៃបឋវីធាតុ ។ បទថា **ឆន្ទរាគវិនយោ ឆន្ទរាគបហានំ** សេចក្តី

ថា ធនុរាគៈព្រោះបឋវីធាតុ ដែលបុគ្គលកម្ចាត់បាន និងលះបង់បាន អាស្រ័យនិព្វាន ។ ព្រោះដូច្នោះ និព្វាន ទើបជាគ្រឿងរលាស់ចេញចាកបឋវីធាតុនោះ ។

បទថា **អយំ អាបោធាតុយា អស្សាទោ** សេចក្ដីថា នេះជាអានិសង្សដែលអាស្រ័យអាបោធាតុ អានិសង្សនេះ ដូចឃើញអ្នកជទៃត្រូវអាបោធាតុបៀតបៀន គប្បីជ្រាបដោយអំណាចនៃសុខសោមនស្ស ដែលប្រព្រឹត្តទៅយ៉ាងនេះថា ហេតុអ្វី អ្នកនេះចេញ និងចូលទៅបន្ទោបង់បស្សាវៈតាំងពីវេលានឹងដេក ។ កាលគេធ្វើការងារស្ទួប្បបន្តិចបន្តួច ញើសក៏មាន សួប្បីសំពត់រមែងមានអាការដែលគេគួរពូតបាន ។ កាលពោលសួប្បីត្រឹមតែអនុមោទនា គេក៏ត្រូវកាន់ផ្ចិតស្លឹកត្នោត ។ តែយើងដេកក្នុងវេលាល្ងាច ក្រោកឡើងពីព្រឹកព្រលឹម ។ សរីរៈរបស់យើងដូចថ្នាំងដែលពេញស្ទួប្បីត្រឹមតែញើសរមែងមិនកើតឡើងដល់យើងអ្នកធ្វើការងារធ្ងន់ ។ កាលយើងពោលធម៌ដោយសំឡេងដូចសឡេងផ្គរលាន់ សួប្បីត្រឹមតែអាការអប់អុនក្នុងសរីរៈក៏មិនមានដល់យើង ដូច្នេះ ។

បទថា **អយំ តេជោធាតុយា អស្សាទោ** សេចក្ដីថា នេះជាអានិសង្សដែលអាស្រ័យតេជោធាតុ ។ អានិសង្សនេះ ដូចឃើញមនុស្សកំពុងត្រជាក់

គប្បីជ្រាបដោយអំណាចនៃសុខសោមនស្ស ដែលប្រព្រឹត្តទៅយ៉ាងនេះថា ហេតុអ្វី ពួកអ្នកទាំងនេះផឹកត្រឹមតែយាគូ ភត្ត និងរបស់ទំពារស៊ីបន្តិចបន្តួច អង្គុយស្វែងរកចង្ក្រានភ្លើងរហូតដល់អស់មួយយប់ ។ ពេលតំណក់ទឹកស្រក់ជិតសរីរៈ ពួកគេក៏ដេកជិតចង្ក្រានភ្លើងហើយដណ្តប់សំពត់ ។ ចំណែកយើងបរិភោគសាច់ ឬនំសូម្បីរឹងក្រៃលែង បរិភោគភត្តផ្អែតក្នុងវេលាណា វេលានុ៎ះឯង ភត្តទាំងអស់របស់យើងរមែងរលួយទៅដូចពពុះទឹក ។ កាលភ្លៀងរហូតអស់ ៧ ថ្ងៃប្រព្រឹត្តទៅ សូម្បីត្រឹមតែភាពត្រជាក់ក្នុងសរីរៈ ក៏មិនមានដល់យើង ដូច្នេះ ។

បទថា **អយំ វាយោធាតុយា អស្សាទោ** សេចក្តីថា នេះជាអានិសង្ស ដែលអាស្រ័យវាយោធាតុ ។ អានិសង្សនេះ ដូចឃើញអ្នកដទៃខ្វាចខ្យល់ គប្បីជ្រាបដោយអំណាចនៃសុខសោមនស្សប្រព្រឹត្តទៅយ៉ាងនេះថា កាលអ្នកទាំងនេះធ្វើការងារសូម្បីត្រឹមតែបន្តិចបន្តួច ពោលសូម្បីត្រឹមតែអនុមោទនា ខ្យល់ក៏រមែងចាក់សៀតសីសៈ ។ ដៃ និងជើងរបស់ពួកអ្នកដើរផ្លូវឆ្ងាយ សូម្បីត្រឹមតែមួយគាវុតក៏អស់កម្លាំង ឈឺចុកចាប់ខ្នង ។ គេត្រូវខ្យល់ក្នុងផ្ទៃ ខ្យល់ក្នុងសរីរៈ និងខ្យល់ក្នុងត្រចៀកជាដើម បៀតបៀនជានិច្ច ក៏នាំគ្នាផ្សំថ្នាំ មានប្រេង និងទឹកឃ្មុំជាដើម សម្រាប់ប្រើ ។ ចំណែកពួកយើង ធ្វើ

ការងារធ្ងន់ខ្លះ ពោលធម៌រហូតអស់មួយយប់បីយាមខ្លះ ធ្វើដំណើរអស់ ១០ យោជន៍ក្នុងមួយថ្ងៃខ្លះ ត្រឹមតែដៃ និងជើងដែលខ្សោយអស់កម្លាំង ឬត្រឹមតែឈឺចុកចាប់ខ្នងក៏មិនមាន ដូច្នេះ ។ ក៏ជាតុទាំងនេះ ដែលប្រព្រឹត្តទៅហើយយ៉ាងនេះ ឈ្មោះថា អានិសង្ស ។

[៧៣] បទថា **អព្ភញ្ញាសិ**[១] បានដល់ យើងបានដឹងហើយដោយញាណ-ពិសេស ។ បទថា **អនុត្តរំ សម្មាសម្ពោធិំ** បានដល់ ការត្រាស់ដឹងដោយប្រពៃដោយព្រះអង្គឯង វៀរធម៌ដទៃដ៏ក្រៃលែងជាង គឺ ប្រសើរជាងធម៌ទាំងអស់ ។ ម្យ៉ាងទៀត ការត្រាស់ដឹងនូវធម៌ដ៏ប្រសើរ និងល្អ ។ ដើមឈើក្តី មគ្គក្តី សព្វញ្ញុតញ្ញាណក្តី និព្វានក្តី ឈ្មោះថា **ពោធិ** ។ ក៏ដើមឈើក្នុងអនាគតស្ថានថា ការត្រាស់ដឹងត្រង់គល់ពោធិព្រឹក្ស និងថា ក្នុងចន្លោះដើមពោធិ និងគយា ហៅថា **ពោធិ** ។ ផ្លូវមគ្គ ក្នុងអនាគតស្ថានថា ញាណក្នុងមគ្គ ៤ ។ សព្វញ្ញុតញ្ញាណក្នុងអនាគតស្ថានថា អ្នកមានបញ្ញាដូចផែនដីសម្រេចពោធិញ្ញាណ ។ និព្វាន ក្នុងអនាគតស្ថានថា សម្រេចពោធិញ្ញាណដែលជាអមតៈ ដែលបច្ច័យតាក់តែងមិនបាន ។ ចំណែកក្នុងទីនេះ ព្រះមាន-ព្រះភាគទ្រង់បំណងយកអរហត្តមគ្គ ។ សួរថា អរហត្តមគ្គ គឺ អនុត្តរពោធិ-

---

១ បិដកថា នាព្ភញ្ញាសិ

ញាណ រមែងមាន ឬមិនមាន ដល់ព្រះសាវកទាំងឡាយ ។ ឆ្លើយថា មិនមាន ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះមិនឲ្យគុណដល់សាវកទាំងពួង ។ ក៏សម្រាប់ព្រះសាវកទាំងនោះ អរហត្តមគ្គរបស់សាវកណា ឲ្យចំពោះអរហត្តផលរបស់សាវកណា ឲ្យវិជ្ជា ៣ របស់សាវកណា ឲ្យអភិញ្ញា ៦ របស់សាវកណា ឲ្យសាវកបារមីញាណ ។ អរហត្តមគ្គរបស់ព្រះបច្ចេកពុទ្ធ ឲ្យចំពោះបច្ចេកពោធិញ្ញាណ ។ ចំណែកអរហត្តមគ្គរបស់ព្រះពុទ្ធ ឲ្យគុណសម្បត្តិគ្រប់យ៉ាង ដូចការអភិសេករបស់ព្រះរាជា ឲ្យភាពជាធំក្នុងលោកទាំងអស់ ។ ព្រោះដូច្នោះ អនុត្តរពោធិញ្ញាណ ទើបមិនមានដល់បុគ្គលដទៃណាៗ ។

បទថា **អភិសម្ពុទ្ធោ បច្ចញ្ញាសឹ** សេចក្តីថា យើងប្តេជ្ញាយ៉ាងនេះថា យើងត្រាស់ដឹង សម្រេច ចាក់ធ្លុះហើយឋិតនៅ ។ បទថា **ញាណញ្ច បន មេ ទស្សនំ ឧទបាទិ** សេចក្តីថា បច្ចវេក្ខណញ្ញាណនោះឯង ដែលអាចឃើញគុណដែលខ្លួនសម្រេច ហើយកើតឡើង ។ បទថា **អកុប្បា មេ វិមុត្តិ** សេចក្តីថា ញាណកើតឡើងយ៉ាងនេះថា អរហត្តផលវិមុត្តិនេះរបស់យើងមិនកម្រើក ។ ក្នុងការមិនកម្រើកនោះ គប្បីជ្រាបការមិនកម្រើក ដោយអាការ ២ យ៉ាង គឺ ដោយហេតុ និងដោយអារម្មណ៍ ។ ក៏ការមិនកម្រើកនោះ ឈ្មោះថា មិន

កម្រើក សូម្បីដោយហេតុ ព្រោះកិលេសដែលលះដោយមគ្គ ៤ មិនត្រឡប់មកទៀត ។ ឈ្មោះថា មិនកម្រើក សូម្បីដោយអារម្មណ៍ ព្រោះធ្វើនិព្វានមានការមិនកម្រើកជាធម្មតាឲ្យជាអារម្មណ៍ ប្រព្រឹត្តទៅ ។ បទថា **អន្តិមា** ប្រែថា ជាជាតិចុងក្រោយ ។ បទថា **នត្ថិទានិ បុនព្ភវោតិ** សេចក្តីថា ឥឡូវនេះឈ្មោះថា ភពដទៃទៀតមិនមាន ។ សច្ចៈ ៤ ព្រះអង្គត្រាស់ទុកក្នុងព្រះសូត្រនេះ ។ សួរថា ដូចម្តេច ។ ឆ្លើយថា ក៏អស្សាទៈក្នុងធាតុ ៤ ជាសមុទយសច្ច ។ **អាទីនវ** ជាទុក្ខសច្ច ។ ការរលាស់ចេញចាកទុក្ខ ជានិរោធសច្ច ។ មគ្គជាហេតុដឹងច្បាស់និរោធ ជាមគ្គសច្ច ។ បើនឹងពោលសូម្បីឲ្យពិស្តារ ក៏គួរ ។ តែក្នុងសូត្រនេះ ការយល់ដល់ហេតុដែលលះបង់ថា សុខសោមនស្ស រមែងកើតឡើងព្រោះអាស្រ័យបឋវីធាតុណា នេះជាអស្សាទៈរបស់បឋវីធាតុ ដូច្នេះ ជាសមុទយសច្ច ។ ការយល់ ដោយការកំណត់ដឹងថា បឋវីធាតុណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះជាអាទីនវរបស់បឋវីធាតុ ដូច្នេះ ជាទុក្ខសច្ច ។ ការចាក់ធ្លុះដោយការធ្វើឲ្យជាក់ច្បាស់ថា ការកម្ចាត់ឆន្ទរាគៈនៃបឋវីធាតុណា នេះជាគ្រឿងរលាស់ចេញចាកបឋវីធាតុនោះ ដូច្នេះ ជានិរោធសច្ច ។ ទិដ្ឋិ សង្កប្បៈ វាចា កម្មន្តៈ អាជីវៈ វាយាមៈ សតិ សមាធិណា ក្នុងឋានៈ ៣ ទាំងនេះ ។ ការចាក់ធ្លុះ

*ដោយការនោះ ជាមគ្គសច្ច ។*

ចប់អដ្ឋកថា បុព្វសូត្រទី ២

# អ ដ្ឋ ក ថា

## អចរិសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង **អចរិសូត្រទី ៣** ដូចតទៅនេះ ៖*

*[៧៤] បទថា **អចរឹ** សេចក្ដីថា តថាគតបានត្រាច់ទៅដោយញាណ អធិប្បាយថា ដោយការត្រាច់ទៅតាមលំដាប់នៃការនោ ។ បទថា **យាវតា** ប្រែថា ប្រមាណប៉ុនណា ។*

ចប់អដ្ឋកថា អចរិសូត្រទី ៣

# អដ្ឋកថា

## នោទេនសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុងនោទេនសូត្រទី ៤ ដូចតទៅនេះ ៖*

[៧៦] *បទថា* **នយិទំ** *ជាដើម លោកប្រកបដោយការបដិសេធតាមដែលពោលហើយអំពីដើម គប្បីជ្រាបយ៉ាងនេះថា សត្វទាំងឡាយចេញមិនបាន ប្រាសចេញមិនបាន រួចផុតទៅមិនបាន មានចិត្តធ្លងផុតពីដែននៃកិលេសមិនបាន ។*

[៧៧] *គប្បីជ្រាបវិនិច្ឆ័យក្នុងន័យទី ២ ។ បទថា* **វិមរិយាទិកតេន** *បានដល់ មានចិត្តមិនមានដែន ។ ក្នុងបទនោះ ដែនមាន ២ គឺ ដែន គឺ កិលេស ដែន គឺ វដ្ដៈ ។ ក៏ក្នុងបទទាំងនោះ កិលេសរបស់បុគ្គលណាដែលខ្ទនលះបានហើយពាក់កណ្ដាល ពាក់កណ្ដាលទៀតលះមិនទាន់បាន ។ ឬថាវដ្ដៈពាក់កណ្ដាលខ្ទនលះបានហើយ ពាក់កណ្ដាលទៀតលះមិនទាន់បាន ។ ចិត្តរបស់បុគ្គលនោះធ្លងផុតចាកដែន សំដៅដល់កិលេស ឬវដ្ដៈដែលលះបានហើយ ។ ចិត្តធ្លងផុតពីដែនមិនបាន សំដៅដល់កិលេស ឬវដ្ដៈដែលលះមិនទាន់បាន ។ ចំណែកទីនេះ លោកពោលថា មានចិត្តធ្លងផុតចាកដែន ដូច្នេះ*

ព្រោះកិលេស និងវដ្តៈសូម្បីទាំងពីរ លះបានហើយ ។ អធិប្បាយថា មានចិត្តមិនធ្វើនូវដែន (គឺ កិលេស) ធ្វងផុតចាកដែនហើយ ។ ពោលសច្ចៈ ៤ ប៉ុណ្ណោះ ទុកក្នុង ៣ សូត្រនេះ ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា ចេតនាសូត្រទី ៤

---

# អដ្ឋកថា

## ទុក្ខសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង* ***ទុក្ខសូត្រទី ៥*** *ដូចតទៅនេះ ៖*

*[៧៨] បទថា* ***ឯកន្តទុក្ខា*** *សេចក្តីថា ទុក្ខតែម្យ៉ាង ដូចអ្នកដើរទៅហើយឈប់ ក៏កើតសេចក្តីក្តៅ ដូច្នោះ ។ បទថា* ***ទុក្ខានុបតិតា*** *បានដល់ ដែលទុក្ខជាប់តាម ។ បទថា* ***ទុក្ខាវក្កន្តា*** *បានដល់ ដែលទុក្ខឈានចុះ មានទុក្ខធ្លាក់ចុះ គឺ ជាបច្ច័យដល់ទុក្ខវេទនា ។ គប្បីជ្រាបសេចក្តីក្នុងបទទាំងពួងយ៉ាងនេះ ។ លោកពោលទុក្ខលក្ខណៈទុកក្នុងសូត្រនេះ ។*

ចប់អដ្ឋកថា ទុក្ខសូត្រទី ៥

# អ ដ្ឋ ក ថា

## អភិនន្ទនសុត្រទី ៦

*លោកពោលវិវដ្តៈទុកក្នុងសូត្រទី ៦ សូត្រទី ៧ ។*

ចប់អដ្ឋកថា អភិនន្ទនសូត្រទី ៦

# អ ដ្ឋ ក ថា

## ឧប្បាទសូត្រទី ៧ ជាដើម

*ក្នុង ៣ សូត្រចុងក្រោយ (សូត្រទី ៨-៩-១០) លោកពោលសច្ចៈ ៤ ប៉ុណ្ណោះ ។*

ចប់អដ្ឋកថា ឧប្បាទសូត្រជាដើម

## ចប់ធាតុសំយុត្ត

## ចប់ចតុទ្វារវគ្គទី ៤

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា


១-អដ្ឋកថាចតស្សសូត្រ
២-អដ្ឋកថាបុព្វសូត្រ
៣-អដ្ឋកថាអចរិសូត្រ
៤-អដ្ឋកថានោចេទសូត្រ
៥-អដ្ឋកថាទុក្ខសូត្រ
៦-អដ្ឋកថាអភិនន្ទនសូត្រ
៧-អដ្ឋកថាឧប្បាទសូត្រជាដើម

# អនមតគ្គសំយុត្ត

## បឋមវគ្គ

## អ ដ្ឋ ក ថា

### តិណកដ្ឋសុត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង តិណកដ្ឋសូត្រទី ១ នៃអនមតគ្គសំយុត្តដូចតទៅនេះ ៖*

[៨៩] *បទថា **អនមតគ្គោ** ប្រែថា មានទីបំផុតខាងដើមដែលបុគ្គលតាមដឹងមិនបាន ។ អធិប្បាយថា សង្សារសូម្បីនឹងតាមទៅដោយញាណអស់មួយរយឆ្នាំ មួយពាន់ឆ្នាំ ក៏មានទីបំផុតដឹងមិនបាន គឺ មានទីបំផុតដែលជ្រាបមិនបាន ។ សង្សារនោះ បុគ្គលណាមិនអាចដឹងទីបំផុតខាងនេះ ឬខាងឯណោះបាន គឺ មានខាងដើម និងខាងចុងកំណត់មិនបាន ។ បទថា **សំសារោ** បានដល់ លំដាប់នៃខន្ធជាដើម ដែលប្រព្រឹត្តទៅកំណត់មិនបាន ។ បទថា **បុព្វា កោដិ ន បញ្ញាយតិ** បានដល់ ទីបំផុតខាងដើមមិនប្រាកដក៏ទីបំផុតខាងដើមរបស់សង្សារនោះ រមែងមិនប្រាកដដោយទីបំផុតណា ។*

សូម្បីទីបំផុតខាងចុង ក៏រមែងមិនប្រាកដដោយទីបំផុតនោះដូចគ្នា ។ ចំណែក សត្វទាំងឡាយ រមែងអន្ទោលទៅត្រង់កណ្តាល ។

[៩០] បទថា **បរិយាទានំ គច្ឆេយ្យ** នេះ លោកពោលថា ឧបមា ដោយវត្ថុតិច ។ ចំណែកក្នុងពាហិរសម័យ ប្រយោជន៍មានតិច ឧបមាមាន ច្រើន ។

កាលលោកពោលថា គោនេះដូចដំរី ជ្រូកដូចគោ ស្រះដូចសមុទ្រ ប្រយោជន៍ទាំងនោះ និងមានប្រមាណដូច្នោះ ក៏មិនមែន ។ ចំណែកក្នុងពុទ្ធ-សម័យឧបមាមានតិច ។ ប្រយោជន៍មានច្រើន ។ ពិតណាស់ ព្រោះក្នុងបាលី លោកកាន់យកតែជម្ពូទ្វីបមួយ ។ ស្មៅជាដើម គប្បីដល់ការអស់ទៅ ដោយ សេចក្តីព្យាយាមរបស់អ្នកជម្ពូទ្វីប ដោយវិធីបែបនេះក្នុងមួយរយឆ្នាំខ្លះ មួយ ពាន់ឆ្នាំខ្លះ មួយសែនឆ្នាំខ្លះ ។ ចំណែកមាតានៃមាតារបស់បុរស គប្បីដល់ ការអស់ទៅ ក៏មិនមែន ។ បទថា **ទុក្ខំ បច្ចនុភូតំ** បានដល់ អ្នកសោយទុក្ខ ។ បទថា **តិព្វំ** ជាវេវចនៈរបស់បទថា **អនុភូតំ** នោះឯង ។ បទថា **ព្យសនំ** បានដល់ សេចក្តីវិនាសច្រើនយ៉ាង មានសេចក្តីវិនាសនៃញាតិជាដើម ។

បទថា **កដសិ** បានដល់ បឋវីក្នុងព្រៃខ្មោច ។ សត្វទាំងនោះ កាល ស្លាប់រឿយៗ បានបង្កើនបឋវីក្នុងព្រៃខ្មោចនោះ ដោយការចោលសរីរៈ ។

*បទថា **អលំ** ប្រែថា ល្មមប៉ុណ្ណោះ ។*

ចប់អដ្ឋកថា តិណកដ្ឋសូត្រទី ១

# អ ដ្ឋ ក ថា

## បឋវីសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង **បឋវីសូត្រទី ២** ដូចតទៅនេះ ៖*

[៩២] *បទថា **មហាបឋវី** បានដល់ មានចក្រវាឡជាទីបំផុត ។ បទថា **និក្ខិបេយ្យ** សេចក្តីថា បុរសម្នាក់ធ្វើផែនដីនោះឲ្យជាដុំ មានប្រមាណដែលពោលហើយ គប្បីដាក់ទុកក្នុងទីដែលគួរម្ខាង ។*

ចប់អដ្ឋកថា បឋវីសូត្រទី ២

# អ ដ្ឋ ក ថា

## អស្សុសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង អស្សុសូត្រទី ៣ ដូចតទៅនេះ ៖*

*[៩៣] បទថា **កន្ទន្តានំ** បានដល់ ស្រែកយំរឿយៗ ។ បទថា **បសន្នំ** បានដល់ ទឹកភ្នែកហូរ គឺ ប្រព្រឹត្តទៅហើយ ។ បទថា **ចតូសុ មហាសមុទ្ទេសុ** បានដល់ ក្នុងមហាសមុទ្រទាំង ៤ ដែលកំណត់ស្មើដោយភ្នំសិនេរុ ។ ក៏ភ្នំសិនេរុ ទិសបស្ចឹម សម្រេចដោយប្រាក់ ។ ទិសទក្សិណ សម្រេចដោយកែវមណី ។ ទិសបច្ចិម សម្រេចដោយកែវផលឹក ។ ទិសឧត្តរ សម្រេចដោយមាស ។ រស្មីពណ៌ប្រាក់ និងកែវមណី ជះចេញខាងទិសបស្ចឹម និងទក្សិណ រួមគ្នាតែមួយ ផ្សាយទៅលើផ្ទៃមហាសមុទ្រ ដរាបដល់ភ្នំចក្រវាឡ ។ រស្មីកែវមណី និងកែវផលឹក ជះចេញខាងទិសទក្សិណ និងទិសបច្ចិម រស្មីកែវផលឹក និងមាស ជះចេញខាងទិសបច្ចិម និងទិសឧត្តរ ។ រស្មីពណ៌មាស និងប្រាក់ ជះចេញខាងទិសឧត្តរ និងទិសបស្ចឹម រួមគ្នាតែមួយផ្សាយទៅកាន់ផ្ទៃមហាសមុទ្រ ដរាបដល់ភ្នំចក្រវាឡ ។ ខាងក្នុងរស្មីទាំងនោះ ជាមហាសមុទ្រ*

ទាំង ៤ ។ លោកសំដៅយកមហាសមុទ្រទាំង ៤ នោះ ទើបពោលថា ចតូសុ មហាសមុទ្ទេសុ ។

[៩៤] បទថា ព្យសនំ ក្នុងបទជាដើមថា ញាតិព្យសនំ បានដល់ សេចក្ដីសាបសូន្យ សេចក្ដីវិនាស ការបាត់បង់ ។ សេចក្ដីវិនាសនៃពួក ញាតិ ឈ្មោះថា ញាតិព្យសនៈ ។ សេចក្ដីវិនាសនៃភោគៈ ឈ្មោះថា ភោគ-ព្យសនៈ ។ ឈ្មោះថា ព្យសនៈ ព្រោះការមានរោគរបស់ខ្លួនឯងផ្ទុះឯង គឺ ធ្វើឲ្យការមិនមានរោគវិនាស ។ ការវិនាសរោគ ឈ្មោះថា រោគព្យសនៈ ។

ចប់អដ្ឋកថា អស្សុសូត្រទី ៣

# អ ដ្ឋ ក ថា

## ខីរសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង ខីរសូត្រទី ៤ ដូចតទៅនេះ ៖

[៩៥] បទថា **មាតុ ថញ្ញំ** បានដល់ ទឹកដោះមាតា ដែលជាមនុស្ស មានឈ្មោះមួយនាក់ ៗ

ពិតណាស់ ក្នុងវេលាសត្វទាំងនេះកើតជាជន្លេន និងស្រមោចក្រហមជាដើម ក្នុងកំណើតត្រី និងអណ្តើកជាដើម ឬក្នុងជាតិជាបក្សី ទឹកដោះមេមិនមានឡើយ ។ ក្នុងវេលាកើតជាពពែ សត្វចិញ្ចឹម និងក្របីជាដើម ទឹកដោះមាន ។ ក្នុងពួកមនុស្ស ទឹកដោះមាន ។ បណ្តាកាលទាំងនោះ ទឹកដោះដែលគេផឹកក្នុងកាលដែលគេកាន់យកកំណើតក្នុងគភ៌របស់មាតា ដែលមានឈ្មោះម្នាក់ថា "**តិស្សា**" ប៉ុណ្ណោះ ដោយមិនត្រូវរាប់ក្នុងកាលដែលកាន់យកក្នុងកំណើតសត្វ មានពពែជាដើម និងសូម្បីក្នុងកាលដែលកាន់យកកំណើតក្នុងគភ៌នៃមាតាដែលមានឈ្មោះផ្សេងៗ គ្នា យ៉ាងនេះថា **ទេវី សុមនា តិស្សា** ក្នុងពួកមនុស្ស គប្បីជ្រាបថា ច្រើនជាងទឹកក្នុងមហាសមុទ្រទាំង ៤ ។

ចប់អដ្ឋកថា ខីរសូត្រទី ៤

# អ ដ្ឋ ក ថា

## បព្វតសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង **បព្វតសូត្រទី ៥** ដូចតទៅនេះ ៖*

*[៩៧] បទថា **សក្កា បន ភន្តេ** សេចក្តីថា បានឮថា ភិក្ខុនោះគិតថា ព្រះសាស្តាត្រាស់ថា មិនមែនធ្វើបានងាយ ព្រោះសង្សារកំណត់ទីបំផុតខាងដើម ខាងចុងមិនបាន នឹងកាត់ចេញយ៉ាងណាក៏មិនបាន យើងនឹងអាចឲ្យព្រះអង្គធ្វើឧបមាបានទេ ។ ព្រោះដូច្នោះ លោកទើបក្រាបទូលយ៉ាងនេះ ។*

*[៩៨] បទថា **កាសិកេន** សេចក្តីថា ដោយសំពត់សាច់ល្អិត ដែលសម្រេចដោយអំបោះដែលគេយកកប្បាស ៣ ប្រភេទមកត្បាញចូលគ្នា ។ បុរសគប្បីបោសទៅប្រមាណប៉ុនណា ដោយការធ្វើឲ្យរាបស្មើដោយសំពត់នោះ ។ គឺ ឲ្យនៅសល់ប្រមាណប៉ុនគ្រាប់ស្ពៃ ។*

ចប់អដ្ឋកថា បព្វតសូត្រទី ៥

# អ ដ្ឋ ក ថា

## សាសបសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុងសាសបសូត្រទី ៦ ដូចតទៅនេះ ៖*

[១០០] *បទថា* **អាយសំ នគរំ** *បានដល់ នគរលោមព័ទ្ធដោយកំពែងដែក ។ តែមិនគួរឃើញថា ខាងក្នុងពោរពេញដោយប្រាសាទមួយជាន់ជាដើមដែលធ្វើដោយដែក ។*

ចប់អដ្ឋកថា សាសបសូត្រទី ៦

# អ ដ្ឋ ក ថា

## សាវកសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង សាវកសូត្រទី ៧ ដូចតទៅនេះ ៖*

*[១០២] បទថា អនុស្សរេយ្យុំ សេចក្ដីថា សូម្បីព្រះសាវក ៤ រូប គប្បីរឭកថយក្រោយបាន ៤ សែនកប្បយ៉ាងនេះថា កាលមួយអង្គរឭកថយក្រោយបានមួយសែនកប្ប មួយអង្គទៀតរឭកថយក្រោយបានមួយសែនកប្ប សូម្បីអង្គដទៃក៏រឭកថយក្រោយបានមួយសែនកប្បទៀត អំពីស្ថានទីដែលភិក្ខុនោះនៅ ។*

ចប់អដ្ឋកថា សាវកសូត្រទី ៧

# អ ដ្ឋ ក ថា

## គង្គាសូត្រទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុង គង្គាសូត្រទី ៨ ដូចតទៅនេះ ៖

[១០៤] បទថា *យា ឯតស្មឹ អន្តរេ វាលិកា* សេចក្តីថា គ្រាប់ខ្សាច់ក្នុងចន្លោះនេះ មានប្រវែង ៥ យោជន៍ ។

ចប់អដ្ឋកថា គង្គាសូត្រទី ៨

# អ ដ្ឋ ក ថា

## ទណ្ឌសូត្រទី ៩

*ចំណែកក្នុង ទណ្ឌសូត្រទី ៩ ពាក្យនឹងត្រូវពោលមិនមាន ។*

ចប់អដ្ឋកថា ទណ្ឌសូត្រទី៩

# អ ដ្ឋ ក ថា

## បុគ្គលសូត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុង បុគ្គលសូត្រទី ១០ ដូចតទៅនេះ ៖

[១០៩] សូម្បី ៣ បទ មានបទជាដើមថា **អដ្ឋិកង្កលោ** ក៏ជាវេវចនៈរបស់គំនរឆ្អឹងនុ៎ះឯង ។ ក៏សត្វទាំងនេះ វេលាមិនមានឆ្អឹង ច្រើនជាងវេលាមានឆ្អឹង ។

ព្រោះថា ឆ្អឹងរបស់សត្វ មានជន្លេនជាដើមទាំងនោះមិនមាន ។ ចំណែកសត្វ មានត្រី និងអណ្តើកជាដើម មានឆ្អឹងច្រើនជាង ។ ព្រោះដូច្នោះ គប្បីកាន់យកចំពោះពេលដែលមានឆ្អឹង[១] មិនបានសំដៅដល់វេលាមិនមានឆ្អឹង និងវេលាមានឆ្អឹងច្រើន ។

[១១០] បទថា ឧត្តរោ គិជ្ឈកូដស្ស បានដល់ ភ្នំវេបុល្លស្ថិតនៅទិស

---

[១] ច្បាប់សីហឡថា វេលាមានឆ្អឹងតិច ។

ខាងជើងនៃភ្នំគិជ្ឈកូដ ។

បទថា មគធានំ គិរិព្វជេ គឺ (ក្រុងរាជគ្រឹះ) ដែនមគធៈ មានភ្នំព័ទ្ធជុំវិញ អធិប្បាយថា តាំងនៅក្នុងវង្វង់របស់ភ្នំ ។ ពាក្យដ៏សេសក្នុងបទទាំងពួងងាយទាំងនោះឯង ។

ចប់អដ្ឋកថា បុគ្គលសូត្រទី ១០

## ចប់បឋមវគ្គ

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា


១-អដ្ឋកថាតិណកដ្ឋសូត្រ
២-អដ្ឋកថាបឋវីសូត្រ
៣-អដ្ឋកថាអស្សុសូត្រ
៤-អដ្ឋកថាខីរសូត្រ
៥-អដ្ឋកថាបព្វតសូត្រ
៦-អដ្ឋកថាសាសបសូត្រ
៧-អដ្ឋកថាសាវកសូត្រ
៨-អដ្ឋកថាគង្គាសូត្រ
៩-អដ្ឋកថាទណ្ឌសូត្រ
១០-អដ្ឋកថាបុគ្គលសូត្រ

# ទុតិយវគ្គ

## អ ដ្ឋ ក ថា

## ទុគតសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុគតសូត្រទី ១ នៃទុតិយវគ្គ ដូចតទៅនេះ ៖*

*[១១១] បទថា ទុគ្គតំ បានដល់ មនុស្សកំសត់ គឺ មនុស្សកំព្រា ។ បទថា ទុរូបេតំ សេចក្តីថា ដៃ និងជើងមនុស្សកំសត់នោះ មានសណ្ឋានមិនល្អ ។*

ចប់អដ្ឋកថា ទុគតសូត្រទី ១

# អ ដ្ឋ ក ថា

## សុខិតសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង **សុខិតសូត្រទី ២** ដូចតទៅនេះ ៖*

[១១២] *បទថា **សុខិតំ** សេចក្តីថា បុគ្គលដល់ព្រមដោយសេចក្តីសុខ គឺ មានទ្រព្យច្រើន មានភោគៈច្រើន ។ បទថា **សុសជ្ជិតំ** សេចក្តីថា បាន ប្រដាប់តាក់តែងឡើងជិះកដំរីទៅ ហើយមានបរិវារច្រើន ។*

ចប់អដ្ឋកថា សុខិតសូត្រទី ២

# អ ដ្ឋ ក ថា

## តិង្សមត្តាសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុងតិង្សមត្តាសូត្រទី ៣ ដូចតទៅនេះ ៖*

[១១៣] *បទថា* ***បាវេយ្យកា*** *បានដល់ ភិក្ខុជាអ្នកក្រុងបាវេយ្យកៈ ។ ក្នុងបទ ជាដើមថា* ***សព្វេ អារញ្ញិកា*** *គប្បីជ្រាបថា ភិក្ខុទាំងនោះនៅក្នុងព្រៃ ជាវត្តជាដើម ដោយអំណាចសមាទានធុតង្គ ។ បទថា* ***សព្វេ សសញ្ញោជនា*** *សេចក្ដីថា ពួកភិក្ខុទាំងពួងនៅមានគ្រឿងចង គឺ ពួកខ្លះជាព្រះសោតាបន្ន ពួកខ្លះជាព្រះសកទាគាមី ឬព្រះអនាគាមី ។ ក៏ក្នុងភិក្ខុទាំងនោះ ភិក្ខុជា បុថុជ្ជន ឬព្រះខីណាស្រពមិនមាន ។*

[១១៦] *ក្នុងបទជាដើមថា* ***គុន្នំ*** *ប្រែថា គោ បានដល់ គប្បីកាន់យក វេលាមានពណ៌យ៉ាងណាមួយ ក្នុងបណ្ដាពណ៌ស និងខ្មៅជាដើម ។ បទថា* ***បារិបន្ថកា*** *បានដល់ ពួកចោរប្ល័ន់ស្ទាក់ត្រង់ផ្លូវ ។ បទថា* ***បារទារិកា*** *គឺ ចោរ ដែលប្រព្រឹត្តខុសក្នុងភរិយារបស់អ្នកដទៃ ។*

ចប់អដ្ឋកថា តិង្សមត្តាសូត្រទី ៣

# អ ដ្ឋ ក ថា

## មាតុសូត្រទី ៤

[១១៨] *គប្បីជ្រាបសេចក្តីក្នុង* **មាតុសូត្រទី ៤ ជាដើម** *ដោយកំណត់ភេទ និងដោយកំណត់ចក្រវាឡ ។ ក្នុងសេចក្តីនេះ មានការកំណត់ភេទយ៉ាងនេះថា វេលាបុរសជាមាតុគ្រាម និងវេលាមាតុគ្រាមជាបុរស ។ សត្វទាំងឡាយត្រាច់អន្ទោលអំពីចក្រវាឡនេះទៅកាន់ចក្រវាឡដទៃ និងអំពីចក្រវាឡដទៃមកកាន់ចក្រវាឡនេះ ។ បណ្តាការកំណត់ ២ យ៉ាងនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងស្ត្រីដែលជាមាតា ក្នុងវេលាជាមាតុគ្រាមក្នុងចក្រវាឡនេះ ទើបត្រាស់ថា* **យោ ន មាតា ភូតបុព្វោ** *សូម្បីក្នុងបទជាដើមថា* **យោ ន បិតា ភូតបុព្វោ** *ជាដើម ក៏ន័យនេះឯង ។*

ចប់អដ្ឋកថា មាតុសូត្រទី ៤ ជាដើម

# អ ដ្ឋ ក ថា

## វេបុល្លបព្វតសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង **វេបុល្លបព្វតសូត្រទី ១០** ដូចតទៅនេះ ៖*

[១២៥] *បទថា **ភូតបុព្វំ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់នាំរឿងរ៉ាវមួយក្នុងអតីតកាលមកសម្ដែង ។ បទថា **សមញ្ញា ឧទបាទិ** បានដល់ បានកើតឡើងហើយ ។ បទថា **ចតុហេន អារោហន្តិ** នេះ លោកពោលសំដៅដល់អ្នកមានកម្លាំងកណ្ដាល ។ បទថា **អគ្គំ** គឺ ខ្ពស់បំផុត ។ បទថា **ភទ្ទយុគំ** គឺ ជាគូដ៏ល្អ ។ បទថា **តីហេន អារោហន្តិ** សេចក្ដីថា បានឮថា ផែនដីក្រាស់ឡើង ១ យោជន៍ ក្នុងចន្លោះព្រះពុទ្ធទាំងពីរអង្គ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ ភ្នំនោះកម្ពស់ ៣ យោជន៍ ។*

[១២៨] *បទថា **អប្បំ វា ភិយ្យោ** សេចក្ដីថា បុគ្គលណារស់នៅលើស ១០០ ឆ្នាំ តិចជាង ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ។ អ្នកដែលឈ្មោះថារស់នៅរហូត ១០០ ឆ្នាំ មិនមានទៀត ។ តែដោយខ្ពស់បំផុត សត្វមានជីវិតរស់នៅបាន ៦០ ឆ្នាំខ្លះ ៨០ ឆ្នាំខ្លះ ចំណែកសត្វមិនទាន់ដល់ ១០០ ឆ្នាំស្លាប់ទៅក្នុងវេលា ៥ ឆ្នាំ ឬ ១០ ឆ្នាំជាដើម ក៏មានច្រើន ។ ពាក្យថា ក៏*

ព្រះមានព្រះភាគកកុសន្ធៈ ទ្រង់ឧប្បត្តិក្នុងវេលាមនុស្សមានអាយុ ៤ ម៉ឺនឆ្នាំ ព្រះមានព្រះភាគកោនាគមនៈ ទ្រង់ឧប្បត្តិក្នុងវេលាមនុស្សមានអាយុ ៣ ម៉ឺនឆ្នាំ ដូច្នេះ លោកចាត់ឲ្យជាសេចក្ដីសាបសូន្យតាមលំដាប់ ។ តែមិនគួរយល់ថា អាយុសាបសូន្យយ៉ាងនេះ ចម្រើនហើយៗ ក៏សាបសូន្យ ។ សួរថា តើសាបសូន្យដូចម្ដេច ។ ឆ្លើយថា គ្រាដំបូង ព្រះមានព្រះភាគកកុសន្ធៈ ទ្រង់ឧប្បត្តិក្នុងវេលាមនុស្សមានអាយុ ៤ ម៉ឺនឆ្នាំ ក្នុងកប្បនេះបែងចែកប្រមាណអាយុចេញជា ៥ ចំណែក តាំងនៅ ៤ ចំណែក បរិនិព្វានហើយក្នុងកាលចំណែកទី ៥ ។ អាយុនោះថយចុះដល់ ១០ ឆ្នាំ ត្រឡប់ចម្រើនឡើងទៀតដរាបដល់មួយអសង្ខេយ្យឆ្នាំ ហើយត្រឡប់ថយចុះ តាំងនៅក្នុងវេលាមនុស្សមានអាយុ ៣ ម៉ឺនឆ្នាំ ។ ព្រះកោនាគមនៈក៏ទ្រង់ឧប្បត្តិក្នុងកាលនោះ ។ សូម្បីព្រះអង្គក៏បរិនិព្វានយ៉ាងនោះឯង អាយុនោះក៏ថយចុះដល់ ១០ ឆ្នាំ ត្រឡប់ចម្រើនឡើងទៀតដរាបដល់មួយអសង្ខេយ្យឆ្នាំ ហើយក៏ថយចុះ តាំងនៅក្នុងវេលាមនុស្សមានអាយុ ២ ម៉ឺនឆ្នាំ ។ ព្រះមានព្រះភាគកស្សបៈទ្រង់ឧប្បត្តិក្នុងកាលនោះ ។ សូម្បីព្រះអង្គបរិនិព្វានហើយយ៉ាងនោះឯង អាយុនោះក៏ថយចុះដល់ ១០ ឆ្នាំ ត្រឡប់ចម្រើនឡើងទៀត ដរាបដល់មួយអស-ង្ខេយ្យឆ្នាំ ហើយថយចុះទៅដល់ ១០០ ឆ្នាំ ។ គ្រានោះ ព្រះសម្មាសម្ពុទ្ធនៃ

យើងទ្រង់ឧប្បត្តិឡើង ។ គប្បីជ្រាបថា អាយុវិនាសទៅ ហើយត្រឡប់ចម្រើន ចម្រើនហើយក៏វិនាសទៅវិញ ។ ព្រះពុទ្ធទាំងឡាយទ្រង់ឧប្បត្តិក្នុងមនុស្ស មានប្រមាណអាយុយ៉ាងណា ក្នុងកប្បនោះ យ៉ាងនោះឯងជាប្រមាណអាយុ សូម្បីរបស់ព្រះពុទ្ធទាំងនោះ ។

ចប់អដ្ឋកថា វេបុល្លបព្វតសូត្រទី ១០

# ចប់អនមតគ្គសំយុត្ត

## ចប់ទុតិយវគ្គ

### រួមក្នុងវគ្គនេះមាន ៥ អដ្ឋកថា

១-អដ្ឋកថាទុគតសូត្រ ២-អដ្ឋកថាសុខិតសូត្រ
៣-អដ្ឋកថាតិំសមត្តាសូត្រ ៤-អដ្ឋកថាមាតុសូត្រជាដើម
១០-អដ្ឋកថាវេបុល្លបព្វតសូត្រ

# កស្សបសំយុត្ត

## អ ដ្ឋ ក ថា

### សន្តុដ្ឋសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង **សន្តុដ្ឋសូត្រទី ១** នៃកស្សបសំយុត្ត ។*

[១៣០] *បទថា **សន្តុដ្ឋាយំ** បានដល់ កស្សបៈនេះជាអ្នកសន្តោស ។ បទថា **ឥតរីតរេន ចីវរេន** បានដល់ ដោយចីវរប្រភេទណាមួយ នៃចីវរសាច់គ្រោតគ្រាត ល្អិត សៅហ្មង ប្រណីត អន់ ចាស់ទ្រុឌទ្រោម ។ មានអធិប្បាយថា សន្តោសដោយចីវរប្រភេទណាមួយ តាមដែលបានហើយជាដើម ។ ក៏សេចក្តីសន្តោសក្នុងចីវរមាន ៣ យ៉ាង គឺ យថាលាភសន្តោស ១ យថាពលសន្តោស ១ យថាសារុប្បសន្តោស ១ ។ សូម្បីការសន្តោសក្នុងបិណ្ឌបាតជាដើម ក៏ន័យនេះឯង ។ ការពណ៌នា ប្រភេទនៃសន្តោសទាំងនោះ ដូចតទៅនេះ ៖*

*ភិក្ខុក្នុងធម្មវិន័យនេះ បានចីវរល្អខ្លះ មិនល្អខ្លះ លោកប្រើចីវរនោះតែម្យ៉ាង មិនប្រាថ្នាចីវរដទៃ សូម្បីបានក៏មិនទទួល ។ នេះឈ្មោះថា **យថា-***

លាភសន្តោសៈក្នុងចីវររបស់លោក ។ កាលបើដូច្នោះ ភិក្ខុជាអ្នកទុព្វលតាមប្រក្រតីខ្លះ ត្រូវអាពាធគ្របសង្កត់ខ្លះ កាលដណ្តប់ចីវរធ្ងន់ រមែងលំបាក ។ លោកដូរចីវរនោះនឹងភិក្ខុជាសភាគគ្នា ប្រើចីវរស្រាល ក៏ឈ្មោះថា ជាអ្នកសន្តោស ។ នេះឈ្មោះថា **យថាពលសន្តោសៈ** ក្នុងចីវររបស់លោក ។ ភិក្ខុមួយរូបទៀត បានបច្ច័យដែលប្រណីត ។ បណ្តាបាត្រ និងចីវរជាដើម លោកបានចីវរមានតម្លៃច្រើនណាមួយ ឬបានចីវរជាដើម ជាច្រើន ថ្វាយដោយគិតថា វត្ថុនេះសមគួរដល់ព្រះថេរៈអ្នកបួសយូរ វត្ថុនេះសមគួរដល់ភិក្ខុជាពហុស្សូត វត្ថុនេះសមគួរដល់ភិក្ខុដែលអាពាធ វត្ថុនេះចូរមានដល់ភិក្ខុមានលាភតិច ដូច្នេះ ហើយរក្សា (គឺកាន់យក) ចីវរចាស់របស់ភិក្ខុទាំងនោះ ឬក៏រក្សាសំពត់ដែលប្រឡាក់អំពីគំនរសម្រាមជាដើម យកសំពត់ទាំងនោះធ្វើសង្ឃាដិប្រើ ក៏ឈ្មោះថា ជាអ្នកសន្តោស ។ នេះឈ្មោះថា **យថាសារុប្ប-សន្តោស** ក្នុងចីវររបស់លោក ។

ក៏ភិក្ខុក្នុងធម្មវិន័យនេះ បានបិណ្ឌបាតសៅហ្មងខ្លះ ប្រណីតខ្លះ ។ លោកញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះប៉ុណ្ណោះ មិនប្រាថ្នាបិណ្ឌបាតដទៃ សូម្បីនឹងបានក៏មិនទទួល ។ នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងបិណ្ឌបាតរបស់លោក ។

ចំណែកភិក្ខុណា បានបិណ្ឌបាតខុសធម្មតារបស់ខ្លួន ឬមិនត្រូវនឹងអាពាធរបស់ខ្លួន ។ ភិក្ខុនោះ ឆាន់បិណ្ឌបាតនោះមិនមានសេចក្តីសប្បាយ ។ លោកថ្វាយបិណ្ឌបាតនោះដល់ភិក្ខុដែលពេញចិត្ត ឆាន់ភោជនជាទីសប្បាយអំពីដៃរបស់ភិក្ខុនោះ ធ្វើសមណធម៌ ក៏ឈ្មោះថា ជាអ្នកសន្តោស ។ នេះឈ្មោះថា **យថាពលសន្តោសៈ** ក្នុងបិណ្ឌបាតរបស់លោក ។ ភិក្ខុមួយរូបទៀត បានបិណ្ឌបាតដែលប្រណីតជាច្រើន ។ លោកថ្វាយដល់ភិក្ខុអ្នកបួសយូរ ភិក្ខុជាពហុស្សូត ភិក្ខុមានលាភតិច និងភិក្ខុអាពាធ ដូចថ្វាយចីវរនោះ ឆាន់អាហារដែលសល់ពីភិក្ខុទាំងនោះ ឬអាហារដែលត្រាច់បិណ្ឌបាត ហើយសម្រេច ។ ក៏ឈ្មោះថា ជាអ្នកសន្តោស ។ នេះឈ្មោះថា **យថាសារុប្បសន្តោសៈ** ក្នុងបិណ្ឌបាតរបស់លោក ។

ក៏ភិក្ខុក្នុងធម្មវិន័យនេះ បានសេនាសនៈគួរពេញចិត្តខ្លះ មិនគួរពេញចិត្តខ្លះ ។ លោកកើតសេចក្តីពេញចិត្ត មិនទាស់ចិត្តដោយសេនាសនៈនោះឯង ត្រេកអរតាមដែលបាន ដោយហោចទៅសូម្បីក្រាលដោយស្មៅ ។ នេះឈ្មោះថា **យថាលាភសន្តោសៈ** ក្នុងសេនាសនៈរបស់លោក ។

ចំណែកភិក្ខុណា បានសេនាសនៈដែលមិនសប្បាយ ឬមិនត្រូវនឹងអាពាធរបស់ខ្លួន ។ កាលលោកនៅ ក៏មិនសប្បាយ ។ ភិក្ខុនោះក៏ថ្វាយ

សេនាសនៈនោះ ដល់ភិក្ខុដែលពេញចិត្ត ហើយក៏នៅក្នុងសេនាសនៈជាទីសប្បាយដែលជារបស់ភិក្ខុនោះ ក៏ឈ្មោះថា ជាអ្នកសន្តោស ។ នេះឈ្មោះថា **យថាពលសន្តោសៈ** ក្នុងសេនាសនៈរបស់លោក ។

មួយរូបទៀត មានបុណ្យច្រើន បានសេនាសនៈដែលប្រណីតជាច្រើន មានល្អាង មណ្ឌប និងផ្ទះកំពូលជាដើម ។ លោកថ្វាយដល់ភិក្ខុដែលបួសយូរ ភិក្ខុជាពហុស្សូត ភិក្ខុមានលាភតិច និងភិក្ខុអាពាធ ដូចថ្វាយចីវរជាដើមទាំងនោះ ហើយនៅក្នុងទីកន្លែងណាមួយ ក៏ឈ្មោះថា ជាអ្នកសន្តោស ។ នេះឈ្មោះថា **យថាសារុប្បសន្តោសៈ** ក្នុងសេនាសនៈរបស់លោក ។ សូម្បីភិក្ខុសញ្ជឹងគិតថា ឈ្មោះថា សេនាសនៈដែលនៅសប្បាយ ច្រើនជាទីតាំងនៃសេចក្តីប្រមាទ កាលអង្គុយក្នុងសេនាសនៈនោះ ថីនមិទ្ធៈគ្របសង្កត់ អកុសលវិតក្កៈរមែងប្រាកដដល់អ្នកភ្ញាក់ឡើង ត្រូវកាពងើកន្ទុយគ្របសង្កត់ហើយ មិនទទួលសេនាសនៈនោះសូម្បីមានដល់ខ្លួន ។ លោកហាមសេនាសនៈនោះហើយ នៅក្នុងទីវាល និងគល់ដើមឈើជាដើម ក៏ឈ្មោះថា ជាអ្នកសន្តោស ។ សូម្បីនេះ ក៏ឈ្មោះថា **យថាសារុប្បសន្តោសៈ** ក្នុងសេនាសនៈ ។

ចំណែកភិក្ខុក្នុងធម្មវិន័យនេះ បានភេសជ្ជៈសៅហ្មងខ្លះ ប្រណីតខ្លះ ។

លោកក៏ត្រេកអរដោយភេសជ្ជៈដែលខ្លួនបានប៉ុណ្ណោះ មិនប្រាថ្នាភេសជ្ជៈដទៃសូម្បីនឹងបាន ក៏មិនទទួល ។ នេះឈ្មោះថា **យថាលាភសន្តោសៈ** ក្នុងគិលានប្បច្ច័យរបស់លោក ។ ចំណែកភិក្ខុត្រូវការប្រេង តែបានទឹកអំពៅ ។ លោកថ្វាយទឹកអំពៅនោះដល់ភិក្ខុដែលពេញចិត្ត ហើយទទួលប្រេងអំពីដៃភិក្ខុនោះ ឬស្វែងរកប្រេងដទៃមកធ្វើភេសជ្ជៈ ក៏ឈ្មោះថា ជាអ្នកសន្តោស ។ នេះឈ្មោះថា **យថាពលសន្តោសៈ** ក្នុងគិលានបច្ច័យរបស់លោក ។

ភិក្ខុមួយរូបទៀត មានបុណ្យច្រើន បានភេសជ្ជៈដែលប្រណីត មានប្រេង ទឹកឃ្មុំ និងទឹកអំពៅជាច្រើនជាដើម ។ លោកថ្វាយដល់ភិក្ខុដែលបួសយូរ ភិក្ខុជាពហុស្សូត ភិក្ខុមានលាភតិច និងភិក្ខុអាពាធ ដូចថ្វាយចីវរ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភេសជ្ជណាមួយដែលខ្លួននាំមក សម្រាប់ភិក្ខុទាំងនោះ ក៏ឈ្មោះថា ជាអ្នកសន្តោស ។ ចំណែកភិក្ខុដែលដាក់សម៉ត្រាំដោយទឹកមូត្រទុកក្នុងភាជនៈមួយ ដាក់របស់ផ្អែម ៤ យ៉ាង ទុកក្នុងភាជនៈមួយ កាលគេនិយាយថា លោកដ៏ចម្រើន លោកចូរកាន់យកតាមដែលប្រាថ្នាចុះ បើរោគរបស់គេរម្ងាប់បានដោយភេសជ្ជៈទាំងនោះណាមួយ បើដូច្នោះទើបហាមរបស់ផ្អែម ៤ យ៉ាង ដោយគិតថា ឈ្មោះថា សម៉ត្រាំទឹកមូត្រព្រះពុទ្ធជាដើមទ្រង់សរសើរ ដូច្នេះ ហើយធ្វើភេសជ្ជៈ ដោយសម៉ត្រាំទឹក

មូត្រ ក៏ឈ្មោះថា ជាអ្នកសន្តោសយ៉ាងក្រៃលែង ។ នេះឈ្មោះថា **យថាសារុប្បសន្តោសៈ** ក្នុងគិលានបច្ច័យរបស់លោក ។ ព្រះមានព្រះភាគត្រាស់សំដៅដល់សន្តោសទាំង ៣ នេះថា ម្នាលភិក្ខុទាំងឡាយ កស្សបៈនេះ សន្តោសដោយចីវរតាមមានតាមបាន គឺ ជាអ្នកសន្តោស ដោយចីវរតាមដែលបានជាដើមយ៉ាងណាមួយ ដោយប្រការដូច្នេះ ។

បទថា **វណ្ណវាទី** សេចក្តីថា ភិក្ខុមួយរូប ជាអ្នកសន្តោស តែមិនពោលគុណនៃសេចក្តីសន្តោស មួយរូបទៀតមិនជាអ្នកសន្តោស តែពោលគុណនៃសេចក្តីសន្តោស ។ មួយរូបទៀត ទាំងមិនជាអ្នកសន្តោស ទាំងមិនពោលគុណនៃសេចក្តីសន្តោស ។ មួយរូបទៀត ទាំងជាអ្នកសន្តោស ទាំងពោលគុណនៃសេចក្តីសន្តោស ។ ដើម្បីទ្រង់សម្តែងថា កស្សបៈនេះជាបុគ្គលដូច្នោះ ដូច្នេះ ព្រះមានព្រះភាគទើបត្រាស់ថា កស្សបៈជាអ្នកមានប្រក្រតីពោលសរសើរសេចក្តីសន្តោសដោយចីវរតាមមានតាមបាន ដូច្នេះ ។

បទថា **អនេសនំ** បានដល់ មិនស្វែងរកមានប្រការផ្សេងៗ មានប្រភេទ គឺ ជាអ្នកនាំដំណឹង និងជាអ្នកបម្រើ ។ បទថា **អលទ្ធា** ប្រែថា មិនបាន ។

អធិប្បាយថា ភិក្ខុរូបខ្លះគិតថា យើងនឹងបានចីវរយ៉ាងណាហ្ន៎ ហើយ

ក៏រួមជាពួកតែមួយនឹងពួកភិក្ខុដែលមានបុណ្យ ធ្វើការបញ្ឆោតបន្ទំ រមែងតក់-ស្លុត រមែងភ័យខ្លាច យ៉ាងណា ។ ភិក្ខុនេះ មិនបានចីវរក៏តក់ស្លុត ដូច្នោះ ។ បទថា **លទ្ធា ច** បានដល់ បានហើយដោយធម៌ ។ បទថា **អគធិតោ** បាន ដល់ មិនជាប់ក្នុងសេចក្តីលោភ ។

បទថា **អមុច្ឆិតោ** បានដល់ មិនដល់នូវការវង្វេងដោយតណ្ហា មានប្រមាណក្រៃលែង ។

បទថា **អនជ្ឈាបន្នោ** សេចក្តីថា តណ្ហាគ្របសង្កត់មិនបាន គឺ រួបរឹតមិនបាន ។ បទថា **អាទីនវទស្សាវី** សេចក្តីថា ឃើញទោសក្នុងអនេសនាបត្តិ និងក្នុងការជាប់ជំពាក់ការបរិភោគ ។ បទថា **និស្សរណប្បញ្ញោ** លោកពោលថា ត្រឹមតែដើម្បីកម្ចាត់ភាពត្រជាក់ ។ មានអធិប្បាយថា ដឹងការរលាស់ចេញ ទើបប្រើប្រាស់ ។ សូម្បីក្នុងបទជាដើមថា **ឥតរីតរេបិណ្ឌបាតេន** គប្បីឃើញសេចក្តីយ៉ាងនេះថា ដោយបិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេ-សជ្ជបរិក្ខារយ៉ាងណាមួយ តាមដែលបានជាដើម ។

[១៣១] ក្នុងបទថា **កស្សបេន វា ហិ វោ ភិក្ខវេ ឱវទិស្សាម** នេះ ដូចព្រះមហាកស្សបត្ថេរ សន្តោសដោយសេចក្តីសន្តោស ៣ ក្នុងបច្ច័យ ៤ ។ ភិក្ខុកាលពោលទូន្មានថា សូម្បីលោកទាំងឡាយចូរជាយ៉ាងនោះ ឈ្មោះថា

ពោលទូន្មានតាមកស្សបៈ ។ សូម្បីក្នុងបទថា **យោ វា បនស្ស កស្សបោទិសោ** នេះ ឬថា ភិក្ខុណាដូចកស្សបៈ គប្បីជាអ្នកសន្តោស ដោយសេចក្តីសន្តោស ៣ ក្នុងបច្ច័យ ៤ ដូចព្រះមហាកស្សបត្ថេរ ។ កាលពោលទូន្មានថា សូម្បីលោកទាំងឡាយ ចូរមានសភាពយ៉ាងនោះ ឈ្មោះថា រមែងទូន្មានដូចជាកស្សបៈ ។ បទថា **តថត្តាយ បដិបជ្ជិតព្វំ** សេចក្តីថា ឈ្មោះថា ពោលអំពីការប្រព្រឹត្ត និងការបដិបត្តិដុសខាត់តាមដែលពោលទុកក្នុងសន្តុដ្ឋិសូត្រនេះ ជាភារៈរបស់ព្រះសម្មាសម្ពុទ្ធ ។ តែការធ្វើវត្តបដិបត្តិនេះឲ្យបរិបូណ៌ ជាភារៈរបស់ពួកយើងដូចគ្នា ។ អ្នកគប្បីគិតថា ក៏យើងគួរកាន់យកភារៈដែលមកដល់ហើយ គប្បីបដិបត្តិដើម្បីបានសភាពយ៉ាងនោះ តាមដែលយើងពោលហើយ ។

ចប់អដ្ឋកថា សន្តុដ្ឋសូត្រទី ១

# អ ដ្ឋ ក ថា

## អនោត្តាបីសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង **អនោត្តាបីសូត្រទី ២** ដូចតទៅនេះ ៖

[១៣៣] បទថា **អនាតាបី** សេចក្តីថា វៀរចាកសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ។

បទថា **អនោត្តាបី** សេចក្តីថា មិនខ្លាច គឺ វៀរសេចក្តីខ្លាចអំពីការកើតនៃកិលេស និងការមិនកើតនៃកុសល ។ បទថា **សម្ពោធាយ** គឺ ដើម្បីការត្រាស់ដឹង ។ បទថា **និព្វានាយ** គឺ ដើម្បីធ្វើនិព្វានឲ្យជាក់ច្បាស់ ។ **អនុត្តរស្ស យោគក្ខេមស្ស** គឺ អរហត្ត ។ ក៏អរហត្តនោះ ជាធម៌ដ៏ប្រសើរក្រៃលែង និងជាធម៌ក្សេមចាកយោគៈ ៤ ។

[១៣៤] ក្នុងបទជាដើមថា **អនុប្បន្នា** សេចក្តីថា អកុសលធម៌ មានលោភៈជាដើមពួកណា រមែងកើតឡើងដល់ភិក្ខុដែលបានបច្ច័យ មានចីវរជាដើម ដែលខ្លួនមិនទាន់ធ្លាប់បាន វត្ថុជាទីពេញចិត្តណាមួយរបស់ឧបដ្ឋាកសទ្ធិវិហារិក និងអន្តេវាសិកទាំងឡាយ ហើយកាន់យកវត្ថុនោះ ដោយយល់ថាល្អ ជាសុខ ដូច្នេះ ដោយមិនឧបាយនៃប្រាជ្ញា ក៏រំពឹងដល់អារម្មណ៍ដែល

មិនធ្លាប់មានណាមួយ ដោយមិនមានយោនិសោមនសិការៈ ។ អកុសលធម៌ទាំងនោះ គប្បីជ្រាបថា មិនទាន់កើតឡើង ដូច្នេះ ។ បាបធម៌ ឈ្មោះថាមិនទាន់កើតឡើងក្នុងសង្សារ ដែលកំណត់ខាងដើមខាងចុងមិនបាន រមែងមិនមានដោយប្រការដទៃ ។ មួយទៀត អកុសលធម៌មិនទាន់កើតឡើងដល់ភិក្ខុ ព្រោះអារម្មណ៍ដែលជាវត្ថុ ដែលធ្លាប់មានមក ដោយសេចក្ដីបរិសុទ្ធិជាប្រក្រតី ឬដោយការរៀន និងការសាកសួរ ឬដោយអំណាចនៃបរិយត្តិ នវកម្ម និងធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា យ៉ាងណាមួយក្នុងកាលមុន ខាងក្រោយរមែងកើតឡើងបានរហ័សដោយបច្ច័យ ដូច្នោះ ។ អកុសលធម៌សូម្បីទាំងនេះ គប្បីជ្រាបថា នៅមិនកើតឡើង កាលកើតឡើង គប្បីប្រព្រឹត្តទៅដើម្បីវិនាសប្រយោជន៍ ។ ព្រោះថា អកុសលធម៌កាលកើតឡើងក្នុងវត្ថារម្មណ៍ (អារម្មណ៍ និងវត្ថុ) ទាំងនោះរឿយៗ ឈ្មោះថា លះមិនបាន ។ អកុសលធម៌ទាំងនោះ គប្បីជ្រាបថា ដែលកើតឡើងហើយ កាលលះមិនបាន គប្បីប្រព្រឹត្តទៅដើម្បីវិនាសប្រយោជន៍ ។ នេះជាសេចក្ដីសង្ខេបក្នុងសេចក្ដីនេះ ។ ចំណែកសេចក្ដីពិស្ដារនៃការកើតឡើង និងវិធីដែលលះបាន លះមិនបានទាំងអស់ លោកពោលទុកក្នុងវិសុទ្ធិមគ្គ ពោលអំពីញាណទស្សនវិសុទ្ធិនិទ្ទេស ។

បទថា **អនុប្បន្នា មេ កុសលា ធម្មា** សេចក្តីថា ធម៌ដែលមិនមានទោស ពោលគឺ សីល សមាធិ មគ្គ និងផល ដែលខ្ញុំនមិនទាន់បាន ។ បទថា **ឧប្បន្នា** បានដល់ កុសលធម៌ទាំងនោះដែលខ្ញុំនបានហើយ ។ បទថា **និរុជ្ឈមានា អនត្ថាយសំវត្តេយ្យុំ** សេចក្តីថា ធម៌ មានសីលជាដើមទាំងនោះកាលរលត់ទៅ ព្រោះមិនទាន់កើតទៀត ដោយអំណាចសេចក្តីវិនាស ។ ក៏ក្នុងធម៌ មានសីលជាដើមនេះ លោកិយធម៌រមែងវិនាស ។ លោកុត្តរធម៌មិនវិនាស ។ ចំណែកទេសនានេះ លោកសម្តែងដោយអំណាចសម្មប្បធាននេះថា ដើម្បីការតាំងនៅនៃកុសលធម៌ដែលកើតឡើងហើយ ដូច្នេះ ។

ម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងសេចក្តីនេះ យ៉ាងនេះថា កាលទុតិយ-មគ្គមិនទាន់កើត បឋមមគ្គកាលរលត់ គប្បីប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសប្រយោជន៍ ។ សម្មប្បធានទាំង ៤ នេះ លោកពោលក្នុងសូត្រនេះ ដោយអំណាចវិបស្សនាចំណែកខាងដើម ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា អនោត្តាបីសូត្រទី ២

# អ ដ្ឋ ក ថា

## ចន្ទូបមសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ចន្ទូបមសូត្រទី ៣** ដូចតទៅនេះ ៖*

[១៣៨] *បទថា **ចន្ទូបមា** សេចក្តីថា អ្នកទាំងឡាយចូរដូចជាព្រះចន្ទ ។ ដោយភាពជាបរិមណ្ឌល យ៉ាងណា ។ មួយវិញទៀត ព្រះចន្ទគោចរនៅលើផ្ទៃអាកាស មិនធ្វើសេចក្តីស្និទស្នាល សេចក្តីហួងហែង សេចក្តីស្រឡាញ់ សេចក្តីប្រាថ្នា ឬសេចក្តីព្យាយាមជាមួយនឹងបុគ្គលណា ។ តែនឹងមិនជាទីស្រឡាញ់ ជាទីពេញចិត្តរបស់មហាជនក៏មិនមែន យ៉ាងណា ។ សូម្បីពួកអ្នក ក៏ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ជនច្រើន ព្រោះមិនធ្វើសេចក្តីស្និទស្នាលជាដើមជាមួយនឹងបុគ្គលណា ដូចជាព្រះចន្ទ ចូលទៅកាន់ត្រកូលទាំង ៤ មានត្រកូលក្សត្រិយ៍ជាដើម ដូច្នោះ ។ មួយទៀត ព្រះចន្ទកម្ចាត់ភាពងងឹតហើយផ្សាយនូវពន្លឺ យ៉ាងណា ។ គប្បីឃើញអត្ថក្នុងសេចក្តីនេះ ដោយន័យមានជាដើមយ៉ាងនេះថា ពួកអ្នកចូរដូចជាព្រះចន្ទ ដោយការកម្ចាត់ភាពងងឹត គឺកិលេស និងដោយការផ្សាយនូវពន្លឺ គឺ បញ្ញា ដូច្នោះ ។*

*បទថា **អបកស្សេវ កាយំ អបកស្ស ចិត្តំ** ប្រែថា តែងដកកាយ ដក*

ចិត្តចេញ គឺ នាំចេញទាំងកាយ និងចិត្តដោយការមិនធ្វើសេចក្តីស្និទស្នាល ជាដើមនោះឯង ។ ព្រោះថា ភិក្ខុណាមិននៅសូម្បីក្នុងព្រៃ ទាំងជាអ្នកត្រិះរិះក្នុងកាមជាដើម ។ ភិក្ខុនេះឈ្មោះថា មិនដកកាយ និងចិត្តចេញ ។ ចំណែកភិក្ខុណា សូម្បីនៅក្នុងព្រៃ តែត្រិះរិះក្នុងកាមជាដើម ។ ភិក្ខុនេះឈ្មោះថា ដកកាយតែម្យ៉ាងចេញ តែមិនឈ្មោះថា ដកចិត្តចេញ ។ ភិក្ខុណានៅក្នុងចន្លោះស្រុក តែមិនត្រិះរិះក្នុងកាមជាដើម ។ ភិក្ខុនេះឈ្មោះថា ដកចិត្តចេញតែម្យ៉ាង តែមិនឈ្មោះថា ដកកាយចេញទេ ។ ចំណែកភិក្ខុណានៅព្រៃ ហើយមិនត្រិះរិះក្នុងកាមជាដើម ភិក្ខុនេះឈ្មោះថា ដកចេញសូម្បីទាំងពីរ ។ ព្រះមានព្រះភាគកាលទ្រង់សម្តែងថា ពួកអ្នកចូរមានសភាពបែបនេះ ចូរចូលទៅកាន់ត្រកូល ទើបត្រាស់ថា **អបកស្សេវ កាយំ អបកស្ស ចិត្តំ** ដូច្នេះ ។

បទថា **និច្ចនវកា** សេចក្តីថា ពួកអ្នកចូរជាអ្នកថ្មីជានិច្ច គឺ ដូចជាអាគន្តុកៈ ដូច្នេះ ។ ព្រោះថា អាគន្តុកៈចូលទៅកាន់ផ្ទះតាមលំដាប់ បើម្ចាស់ផ្ទះឃើញភិក្ខុចូល ក៏គិតថា បុត្របងប្អូនរបស់ពួកយើង ទៅសម្រាកយ៉ាងនេះ ដូច្នេះ កាលអនុគ្រោះ ទើបនិមន្តឲ្យគង់ ឲ្យឆាន់ ពេលលោកឆាន់រួច គិតថា លោកចូរកាន់យកភាជនៈរបស់លោកចុះ ដូច្នេះ ហើយក្រោកឡើងចៀសចេញទៅ រមែងមិនធ្វើសេចក្តីស្និទស្នាលជាមួយម្ចាស់ផ្ទះទាំងនោះ ឬចាត់

ធ្វើករណីយកិច្ច ។ លោកសម្តែងថា សូម្បីពួកលោកចូលទៅកាន់ផ្ទះតាមលំដាប់យ៉ាងនេះហើយ ពួកមនុស្សជ្រះថ្លាក្នុងឥរិយាបថ និងថ្វាយវត្ថុណាទទួលយកវត្ថុនោះ កាត់សេចក្តីស្និទស្នាល ជាអ្នកមិនខ្វល់ខ្វាយក្នុងករណីយកិច្ចរបស់មនុស្សទាំងនោះ ចេញទៅដូច្នេះ ។ លោកពោលរឿងរបស់ភិក្ខុពីរនាក់បងប្អូនទុក ដើម្បីជាការជាក់ច្បាស់ក្នុងភាពជាភិក្ខុអាគន្តុកៈ ដូចតទៅនេះ ៖

បានឮថា បងប្អូនពីរនាក់ចេញបួសអំពីស្រុកនវសោឡនគរ ។ បងប្អូនពីរនាក់ទាំងនោះ ប្រាកដថា ជាព្រះចូឡនាគត្ថេរ និងព្រះមហានាគត្ថេរ ។ ព្រះថេរៈទាំងនោះ នៅលើភ្នំចិត្តលបព៌តរហូតអស់ ៣០ ឆ្នាំ សម្រេចព្រះអរហត្ត ហើយគិតថា យើងនឹងសួរសុខទុក្ខមាតា មកហើយ សម្រាកក្នុងវិហារក្នុងនវសោឡនគរ ចូលទៅកាន់ស្រុកមាតាដើម្បីបិណ្ឌបាតក្នុងថ្ងៃស្អែក ។ សូម្បីមាតានាំបបរចេញទៅដោយបោយ ដើម្បីព្រះថេរៈទាំងនោះ ចាក់ចុះក្នុងបាត្ររបស់ព្រះថេរៈមួយរូប ។ កាលនាងសម្លឹងមើលព្រះថេរៈនោះ ក៏កើតសេចក្តីស្រឡាញ់ក្នុងបុត្រ ។ គ្រានោះ នាងទើបពោលនឹងលោកថា លោកកូន លោកឈ្មោះមហានាគ ជាកូនរបស់យើងឬ ។ ព្រះថេរៈពោលថា ឧបាសិកា ញោមចូរសួរព្រះថេរៈអង្គក្រោយចុះ ហើយក៏ចៀសចេញទៅ ។

នាំនថ្វាយយាគូសូម្បីដល់ព្រះថេរៈអន្ដែក្រោយ ហើយទើបសួរថា លោកកូន លោកឈ្មោះចូឡនាគជាកូនរបស់យើងឬ ។ ព្រះថេរៈពោលថា ឧបាសិកា ញោមមិនសួរព្រះថេរៈមុនឬ ដូច្នេះ ហើយក៏ចៀសចេញទៅ ។ ភិក្ខុដែល កាត់សេចក្ដីស្និទស្នាលនឹងមាតាយ៉ាងនេះ ឈ្មោះថា ជាអ្នកថ្មីជានិច្ច (ជា អាគន្ដុកភិក្ខុ) ។

បទថា **អប្បគព្ភា** គឺ មិនឃ្នើសឃ្នង អធិប្បាយថា វៀរដោយការ ឃ្នើសឃ្នងកាយមានឋានៈ ៨ ដោយការឃ្នើសឃ្នងវាចាមានឋានៈ ៤ និង ដោយការឃ្នើសឃ្នងចិត្តមានឋានៈមិនមែនតិច ការធ្វើដែលមិនសមគួរដោយ កាយក្នុងសង្ឃ គណៈ បុគ្គល រោងឆាន់ រោងភ្លើង កំពង់ងូតទឹក ផ្លូវភិក្ខាចារ ការចូលទៅក្នុងចន្លោះស្រុក ឈ្មោះថា ការឃ្នើសឃ្នងកាយមានឋានៈ ៨ ដូចកម្មជាដើមយ៉ាងនេះថា ភិក្ខុរបខ្ទះក្នុងធម្មវិន័យនេះ អង្គុយត្រដោម ក្បាលជង្គង់ត្រង់កណ្ដាលសង្ឃ ឬអង្គុយបត់ជើងម្ខាង បញ្ឈរជង្គង់ម្ខាង ។ ត្រង់កណ្ដាលគណៈក៏យ៉ាងនោះ ។ បទថា **គណមជ្ឈេ** សេចក្ដីថា ក្នុងការ ប្រជុំបរិស័ទ ៤ ឬប្រជុំគណៈព្រះសូត្រជាដើម ។ ក្នុងភិក្ខុដែលចាស់ជាង ក៏យ៉ាងនោះ ។ ចំណែកក្នុងរោងឆាន់ មិនថ្វាយអាសនៈដល់ភិក្ខុដែលចាស់ ហាមអាសនៈដល់ភិក្ខុដែលថ្មី ។ ក្នុងរោងភ្លើងក៏យ៉ាងនោះ ។ ក៏ក្នុងរោង

ភ្លើងនេះ លោកមិនប្រាប់ភិក្ខុចាស់ ធ្វើការបង្កាត់ភ្លើងជាដើម ។ ចំណែកក្នុងកំពង់ងូតទឹក មានអធិប្បាយយ៉ាងនេះថា លោកមិនកំណត់ថា ភិក្ខុកម្លោះ ភិក្ខុចាស់ គប្បីងូតទឹកតាមលំដាប់ដែលមក ។ លោកកាលមិនអើពើការកំណត់នោះ មកខាងក្រោយចុះទឹក រមែងបៀតបៀនភិក្ខុចាស់ និងភិក្ខុថ្មី ។ ចំណែកក្នុងផ្លូវភិក្ខាចារ មានកម្មជាដើមយ៉ាងនេះថា ដើរខាងមុខៗ ដើម្បីប្រយោជន៍ដល់អាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរ ប៉ះទង្គិចដៃ ចូលទៅខាងក្នុងចន្លោះស្រុកមុនពួកភិក្ខុចាស់ ធ្វើការលេងផ្លូវកាយជាមួយភិក្ខុកម្លោះ ដូច្នេះ ។ ពោលវាចាការមិនសមគួរត្រង់កណ្តាលសង្ឃ គណៈ បុគ្គល និងក្នុងចន្លោះស្រុក ឈ្មោះថា សេចក្តីឃ្លើសឃ្លងវាចា មានឋានៈ ៤ ដូចភិក្ខុរបខ្លះក្នុងធម្មវិន័យនេះ មិនប្រាប់មុន ពោលធម៌ក្នុងកណ្តាលសង្ឃ ក្នុងកណ្តាលគណៈ និងក្នុងសម្នាក់បុគ្គល មានប្រការតាមដែលពោលហើយ ត្រូវពួកមនុស្សសួរយ៉ាងនោះដូចគ្នា មិនសូមអនុញ្ញាតភិក្ខុចាស់ជាងដើម្បីដោះស្រាយបញ្ហា ។ ចំណែកក្នុងចន្លោះស្រុក រមែងពោលពាក្យជាដើមថា អ្នកឈ្មោះអ្វី តើមានយាគូ ឬរបស់គួរទំពារ គួរបរិភោគទេ អ្នកនឹងឲ្យអ្វីដល់អាត្មា ។ ថ្ងៃនេះយើងនឹងទំពារអ្វី ឆាន់អ្វី ផឹកអ្វី ។ ការមិនប្រព្រឹត្តកន្លងអាបត្តិ ដោយកាយវាចាក្នុងឋានៈទាំងនោះ តែចិត្តត្រិះរិះដល់

កាមជាដើម ឈ្មោះថា សេចក្ដីឃ្នើសឃ្នងចិត្ត ដែលមានឋានៈមិនមែនតិច ។ មួយទៀត ភិក្ខុទ្រុស្តសីល មានសេចក្ដីប្រាថ្នាលាមក ដែលប្រព្រឹត្តទៅយ៉ាងនេះថា សូមជនទាំងឡាយចូរដឹងយើងថា ជាអ្នកមានសីល ដូច្នេះ ឈ្មោះថា សេចក្ដីឃ្នើសឃ្នងចិត្ត ។

ព្រះដ៏មានព្រះភាគត្រាស់ថា ពួកអ្នកជាអ្នកមិនឃ្នើសឃ្នងចូលទៅ (កាន់ត្រកូល) ព្រោះមិនមានសេចក្ដីឃ្នើសឃ្នងទាំងអស់នេះ ដោយប្រការដូច្នេះ ។ បទថា **ជរុទបានំ** បានដល់ អណ្ដូងទឹកចាស់ ។ បទថា **បព្វត-វិសមំ** បានដល់ ទីមិនរាបស្មើ គឺ ជាជ្រោះលើភ្នំ ។

បទថា **នទីវិទុគ្គំ** បានដល់ ស្ទឹងឆ្លងបានដោយលំបាក ។ បទថា **អបកស្សេវកាយំ** បានដល់ បុគ្គលណាខ្វល់ខ្វាយក្នុងការលេងជាដើម មិនដកកាយ មិនរួមគ្នាធ្វើកម្មរហូតដល់អស់ស្ថានទីដូច្នោះ មិនខ្វល់ខ្វាយដល់អ្នកទំនុកបម្រុង (អ្នកធ្វើកម្មរួមគ្នា) មិនដកចិត្ត រំពឹងគិតដោយលំដាប់ ព្រោះឃើញទោសថា បុគ្គលដែលធ្លាក់ទៅក្នុងទីនេះ រមែងមានដៃ និងជើងបាក់ជាដើម ទើបមានសេចក្ដីស្រឡាញ់សម្លឹងមើល ។ បុគ្គលនោះធ្លាក់ទៅហើយ រមែងប្រសព្វនូវវត្ថុមិនមែនប្រយោជន៍ មានដៃ និងជើងបាក់ជាដើម ។ ចំណែកបុគ្គលណាត្រូវការទឹក ជាអ្នកប្រាថ្នានឹងត្រួតមើលដោយកិច្ចដទៃ ឬកិច្ចណា

មួយ ដកកាយ រួមគ្នាធ្វើកម្ម ខ្វល់ខ្វាយដល់អ្នកទំនុកបម្រុង ដកសូម្បីចិត្ត សម្លឹងមើលក៏កើតសង្វេគ ព្រោះឃើញទោស ។ បុគ្គលនោះក្រឡេកមើល តាមសេចក្តីពេញចិត្ត ហើយមានសេចក្តីសុខ រមែងចៀសចេញទៅ តាមសេចក្តីប្រាថ្នា ។

បទនេះ ក្នុងបទថា **ឯវមេវ ខោ** នេះ ជាគ្រឿងប្រៀបធៀប ។ ព្រោះថា ត្រកូល ៤ ដូចរណ្តៅចាស់ជាដើម ។ ភិក្ខុ ដូចបុរសអ្នកក្រឡេកមើល ។ បុរសមានកាយ និងចិត្តមិនទាន់ដកចេញបាន កាលក្រឡេកមើលរណ្តៅចាស់ជាដើមទាំងនោះ រមែងធ្លាក់ទៅក្នុងរណ្តៅនោះ យ៉ាងណា ភិក្ខុ មានកាយជាដើមមិនរក្សាហើយ កាលចូលទៅកាន់ត្រកូល រមែងជាប់នៅក្នុងត្រកូលតពីនោះ រមែងប្រសព្វវត្ថុមិនមែនប្រយោជន៍ មានការទម្លាយសីលជាដើម មានប្រការផ្សេងៗ ជាដើម ដូច្នោះ ។ ដូចជាបុរសមានកាយ និងចិត្តដកចេញបានហើយ រមែងមិនធ្លាក់ចុះទៅក្នុងរណ្តៅនោះ យ៉ាងណា ។ ភិក្ខុជាអ្នកមានកាយ និងចិត្តដកចេញ បានដោយកាយដែលខ្លួនរក្សាហើយ ដោយចិត្តដែលខ្លួនរក្សាហើយ ដោយវាចាដែលខ្លួនរក្សាហើយ ដោយសតិដែលតម្កល់មាំ កាលចូលទៅកាន់ត្រកូល រមែងមិនជាប់ក្នុងត្រកូល ក៏ដូច្នោះ ។ គ្រានោះ ជើង គឺ សីលរបស់លោកមិនបានទម្លាយ ដូចជើងរបស់បុរសដែល

មិនបានធ្លាក់ទៅក្នុងរណ្តៅនោះ មិនបានបាក់ ដូច្នោះ ។ ដៃ គឺ សទ្ធា រមែង មិនទម្លាយ ដូចដៃមិនបាក់ ដូច្នោះ ។ ពោះ គឺ សមាធិ រមែងមិនធ្លាយ ដូចពោះរបស់បុរសដែលធ្លាយ ដូច្នោះ ។ សីសៈ គឺ ញាណ រមែងមិនបែក ធ្លាយ ដូចសីសៈរបស់បុរសដែលមិនបែក ដូច្នោះ ។ មួយទៀត ជន្ធត់ និង បន្ទាជាដើម រមែងមិនមុតបុរសនោះ យ៉ាងណា ។ បន្ទា គឺ រាគៈជាដើម រមែងមិនចាក់ដោតភិក្ខុនេះក៏ដូច្នោះ ។ បុរសនោះមិនមានឧបទ្វវៈ ក្រឡេក មើលបានតាមសេចក្តីពេញចិត្ត មានសេចក្តីសុខ ចៀសចេញទៅបានតាម ប្រាថ្នា យ៉ាងណា ភិក្ខុអាស្រ័យត្រកូលហើយ សេពបច្ច័យ មានចីវរជាដើម ចម្រើនកម្មដ្ឋាន ពិចារណាក្នុងសង្ខារទាំងឡាយ សម្រេចព្រះអរហត្ត នៅ ជាសុខ ដោយលោកុត្តរសុខ រមែងទៅកាន់ទិស គឺ និព្វានដែលមិនធ្លាប់ទៅ បានតាមប្រាថ្នា ដូច្នោះ ។

ឥឡូវនេះ ភិក្ខុណាបង្អោនចិត្តទៅក្នុងផ្លូវអាក្រក់ បដិបត្តិខុស គប្បី ពោលយ៉ាងនេះថា ព្រះសម្មាសម្ពុទ្ធកាលត្រាស់ថា ពួកអ្នកចូរលះសេចក្តី ឃ្នើសឃ្នង ៣ យ៉ាង ដូចជាព្រះចន្ទ ចូលទៅកាន់ត្រកូល ដោយភាពជា អ្នកថ្មីជានិច្ច តាំងទុកក្នុង (ហេតុដែល) មិនមែនឋានៈ ឲ្យទទួលភារៈដែលធន់មិនបាន ឲ្យធ្វើវត្ថុដែលនរណាៗ មិនអាចនឹងធ្វើបាន ។

ព្រះមានព្រះភាគកាល ទ្រង់ជំទាស់ពាក្យរបស់ភិក្ខុនោះ សម្ដែងថា នរណាៗ អាចធ្វើបានយ៉ាងនេះ ភិក្ខុបែបនេះ ក៏មាន ដូច្នេះ ទើបត្រាស់ពាក្យជាដើមថា **កស្សបោភិក្ខវេ** ដូច្នេះ ។

[១៣៩] បទថា **អាកាសេ បាណឹ ចាលេសិ** សេចក្ដីថា ទ្រង់យោកព្រះហស្ដទៅមកទាំងពីរខាង ទាំងចំណែកខាងក្រោម ទាំងចំណែកខាងលើ ដូចនាំទៅនូវខ្សែផ្ដេកបន្ទោរជាគូៗ ក្នុងចន្លោះផ្ទៃអាកាសពណ៌ខៀវ ដូច្នោះ ។ តែប្រការនេះ ឈ្មោះថា ជាបទមិនលាយក្នុងព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ។ បទថា **អត្តមនោ** សេចក្ដីថា ជាអ្នកមានចិត្តត្រេកអរ មានចិត្តរីករាយ គឺមិនត្រូវទោមនស្សគ្របសង្កត់បាន ។ សូម្បីបទថា **កស្សបស្សភិក្ខវេ** នេះ ព្រះមានព្រះភាគទ្រង់បដិសេធពាក្យរបស់បុគ្គលដទៃ ដោយន័យមុនដូចគ្នា ទើបត្រាស់ដើម្បីសម្ដែងថា ភិក្ខុបែបនេះក៏មាន ។ បទថា **បសន្នាការំ ករេយ្យុំ** សេចក្ដីថា ជនអ្នកជ្រះថ្លាគប្បីថ្វាយបច្ច័យ មានចីវរជាដើម ។ បទថា **តថត្តាយ បដិបជ្ជេយ្យុំ** សេចក្ដីថា ពួកភិក្ខុបំពេញសីលឲ្យពេញក្នុងទីមកនៃសីល ហើយឲ្យសីលទាំងនោះ ដល់ព្រមក្នុងទីនៃសមាធិ វិបស្សនា មគ្គ និងផល ឈ្មោះថា គប្បីបដិបត្តិតាមយ៉ាងនោះ ។ បទថា **អនុទយំ** គឺ ការរក្សា ។

*បទថា* ***អនុកម្បំ*** *គឺ មានចិត្តទន់ភ្លន់ ។ ក៏ទាំងពីរបទនោះ ជាវេវចនៈរបស់សេចក្តីករុណា ។ សូម្បីបទថា* ***កស្សបោ ភិក្ខវេ*** *នេះ ព្រះមានព្រះភាគទ្រង់បដិសេធពាក្យរបស់បុគ្គលដទៃ ដោយន័យមុនដូចគ្នា ទើបត្រាស់ដើម្បីសម្តែងថា ភិក្ខុបែបនេះក៏មាន ។*

*[១៤១] ក្នុងបទថា* ***កស្សបេន*** *នេះ លោកតែងប្រកបដោយអំណាចឧបមាដូចជាព្រះចន្ទជាដើម គប្បីជ្រាបសេចក្តីដោយន័យមុនដូចគ្នា ។*

ចប់អដ្ឋកថា ចន្ទូបមសូត្រទី ៣

# អ ដ្ឋ ក ថា

## កុលូបកសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង កុលូបកសូត្រទី ៤ ដូចតទៅនេះ ៖*

[១៤២] *បទថា **កុលូបកោ** បានដល់ ចូលទៅកាន់ផ្ទះរបស់ត្រកូល ។*

[១៤៣] *បទថា **ទេន្តុយេវមេ** បានដល់ ចូរឲ្យដល់យើងប៉ុណ្ណោះ ។ បទថា **សន្និយតិ** បានដល់ អាក់អន់ចិត្ត ថ្នាំងថ្នាក់ចិត្ត ។ ពាក្យដ៏សេសក្នុងសេចក្តីនេះ គប្បីជ្រាបដោយន័យដែលពោលហើយនុ៎ះឯង ។*

ចប់អដ្ឋកថា កុលូបកសូត្រទី ៤

# អ ដ្ឋ ក ថា

## ជិណ្ណសូត្រទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុង ជិណ្ណសូត្រទី ៥ ដូចតទៅនេះ ៖

[១៤៧] បទថា **ជិណ្ណោ** បានដល់ ព្រះថេរៈចាស់ ។ បទថា **គរុកានិ** សេចក្តីថា សំពត់ធ្ងន់ជាសំពត់ច្រើនជាន់ ជារបស់ធ្ងន់ដែលដេរដោយអំបោះ និងដោយក្រណាត់សំពត់ក្នុងទីដែលទ្រុឌទ្រោម ចាប់ផ្តើមតាំងពីវេលាដែលលោកបានសំពត់នោះពីសម្នាក់ព្រះសាស្តា ។ បទថា **និព្វសនានិ** សេចក្តីថា បានឈ្មោះយ៉ាងនេះ ព្រោះព្រះមានព្រះភាគទ្រង់ស្លៀកមកមុន ហើយឈប់ ។ បទថា **តស្មា** សេចក្តីថា ព្រោះលោកជរា ហើយទ្រទ្រង់សំពត់បង្សុកូលធ្ងន់ ។ បទថា **គហបតានិ** ព្រះមានព្រះភាគត្រាស់ថា អ្នកចូរឈប់ទ្រង់សំពត់បង្សុកូលជាវត្ត ចូរទ្រទ្រង់ចីវរដែលគហបតីថ្វាយចុះ ។ បទថា **និមន្តនានិ** ព្រះមានព្រះភាគត្រាស់ថា អ្នកចូរត្រាច់បិណ្ឌបាតជាវត្ត ហើយចូរបរិភោគភត្តដែលគេនិមន្ត មានស្លាកភត្តជាដើម ។ បទថា **មម សន្តិកេ** ព្រះមាន-ព្រះភាគត្រាស់ថា អ្នកចូរឈប់នៅព្រៃជាវត្ត ចូរនៅក្នុងសេនាសនៈជិតស្រុកចុះ ។ សួរថា ក៏ព្រះរាជាទ្រង់បានតែងតាំងសេនាបតី ក្នុងតំណែងសេនាបតី

កាលសេនាបតីនោះឲ្យព្រះរាជាទ្រង់ត្រេកអរដោយនាទីរបស់ខ្លួន មានសេចក្តីស្រឡាញ់ចំពោះព្រះរាជាជាដើម ទ្រង់យកតំណែងនោះទៅព្រះរាជទានដល់អ្នកដទៃ ឈ្មោះថា ទ្រង់ធ្វើមិនសមគួរ យ៉ាងណា ព្រះសាស្តាក៏ដូច្នោះ ស្តេចទៅអស់ផ្លូវ ៣ គាវុត ដើម្បីទៅទទួលព្រះមហាកស្សបត្ថេរ ប្រថាប់ត្រង់គល់ដើមពហុបុត្តៈ ចន្លោះក្រុងរាជគ្រឹះ និងនាលន្ទា ទ្រង់ឲ្យឱវាទ ៣ ប្រការ ទ្រង់ប្តូរចីវររបស់ព្រះអង្គជាមួយនឹងព្រះមហាកស្សបត្ថេរនោះ ទ្រង់បានធ្វើព្រះថេរៈឲ្យនៅក្នុងព្រៃជាវត្ត និងឲ្យទ្រទ្រង់សំពត់បង្សុកូលជាវត្ត ។ កាលលោកញុាំងព្រះទ័យរបស់ព្រះសាស្តាឲ្យទ្រង់ត្រេកអរ នៅដោយកត្តុ-កម្យតាធន្ទៈ ព្រះសាស្តាព្រះអង្គនោះ ទ្រង់ឲ្យឈប់ទ្រទ្រង់ធុតង្គ មានទ្រទ្រង់សំពត់បង្សុកូលជាវត្តជាដើម ទ្រង់ណែនាំក្នុងការទទួលគហបតីចីវរជាដើម ឈ្មោះថា ទ្រង់ធ្វើមិនសមគួរមិនមែនឬ ។

ឆ្លើយថា មិនមែន ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះជាអជ្ឈាស្រ័យរបស់ខ្លួន ។ ពិតណាស់ ព្រះសាស្តាទ្រង់ឲ្យព្រះថេរៈឈប់ទ្រទ្រង់ធុតង្គក៏មិនមែន ។ ប្រៀបដូចស្គរមិនទាន់បានវាយជាដើម រមែងមិនឮ យ៉ាងណា ទ្រង់ប្រាថ្នានឹងឲ្យព្រះថេរៈបន្លឺសីហនាទ ដោយទ្រង់មានព្រះតម្រិះថា បុគ្គលបែបនេះ បើមិនមានហេតុណាមួយកើតឡើង រមែងមិនបន្លឺសីហនាទ

ដូច្នោះ ទើបត្រាស់យ៉ាងនេះ ដោយអធ្យាស្រ័យនៃសីហនាទ ។ សូម្បីព្រះថេរៈបន្លឺសីហនាទ ដោយន័យជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកនៅព្រៃរហូតអស់កាលយូរ ដូច្នេះ ដោយសមគួរចំពោះព្រះអធ្យាស្រ័យរបស់ព្រះសាស្តាប៉ុណ្ណោះ ។

[១៤៩] បទថា **ទិដ្ឋធម្មសុខវិហារំ** សេចក្តីថា ឈ្មោះថា ធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន រមែងបានដល់ភិក្ខុដែលនៅព្រៃប៉ុណ្ណោះ មិនបានដល់ភិក្ខុដែលនៅក្នុងចន្លោះស្រុកទេ ។ ព្រោះភិក្ខុដែលនៅក្នុងចន្លោះស្រុក បានឮសំឡេងក្មេង បានឃើញរូបមិនជាទីសប្បាយ បានឮសំឡេងមិនជាទីសប្បាយ ។ ដោយហេតុនោះ ភិក្ខុនោះទើបកើតសេចក្តីមិនត្រេកអរ ។ ចំណែកភិក្ខុដែលនៅព្រៃ កាលនៅចម្ងាយមួយគាវុត ឬកន្លះយោជន៍ ចូលកាន់ព្រៃ បានឮសំឡេងខ្លាដំបង ខ្លាធំ និងរាជសីហ៍ជាដើម សេចក្តីត្រេកអរក្នុងសំឡេងមិនមែនសំឡេងមនុស្សរមែងកើតឡើង ព្រោះស្តាប់សំឡេងជាបច្ច័យ ព្រះមានព្រះភាគ ទ្រង់សំដៅយកសេចក្តីត្រេកអរក្នុងសំឡេង ត្រាស់ថា សេចក្តីត្រេកអរដែលមិនមែនរបស់ពួកមនុស្ស រមែងមានដល់ភិក្ខុអ្នកចូលទៅកាន់សុញ្ញាគារ មានចិត្តស្ងប់ ជាអ្នកឃើញច្បាស់នូវធម៌ដោយប្រពៃ លោកពិចារណាឃើញការកើតឡើង និងសេចក្តីសាបសូន្យនៃខន្ធទាំងឡាយ

ពីអារម្មណ៍ណាៗ កាលលោកដឹងច្បាស់អារម្មណ៍ដែលជាអមតៈ រមែងបាន បីតិបាមោជ្ជៈ បើអ្នកដទៃទៀតមិនមានខាងមុខ ឬខាងក្រោយ សេចក្ដីសុខ រមែងមានដល់ភិក្ខុដែលត្រេកអរនៅក្នុងព្រៃតែម្នាក់ឯងក្នុងទីនោះឯង ។ ឯ ភិក្ខុដែលត្រាច់បិណ្ឌបាតប៉ុណ្ណោះ ក៏រមែងបានយ៉ាងនោះដូចគ្នា ចំពោះភិក្ខុ ដែលមិនត្រាច់បិណ្ឌបាតជាវត្ត មិនបានទេ ។ ព្រោះថា ភិក្ខុដែលមិនត្រាច់ បិណ្ឌបាត ជាអ្នកត្រាច់ទៅក្នុងកាលមិនមែនវេលា ( គឺវេលាមិនសមគួរ ) ប្រញាប់ទៅប្រញាប់ត្រឡប់ ទៅដោយសេចក្ដីកង្វល់ មានសេចក្ដីសង្ស័យ ច្រើនក្នុងសេចក្ដីកង្វល់នោះ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ភិក្ខុដែល មិនបិណ្ឌបាតជាវត្ត នៅក្នុងវិហារឆ្ងាយពីស្រុក គិតថា យើងនឹងបានយាគូ ឬភត្តរបស់ភិក្ខុដែលនៅបរិវាស ឬថា ភត្តណាមួយក្នុងបណ្ដាឧទ្ទេសភត្ត ជាដើមក្នុងរោងឆាន់នឹងមានដល់យើង ដូច្នេះ (ជាអ្នកត្រាច់ទៅក្នុងកាល មិនសមគួរ) ធ្វើសរសៃពីងពាងទាំងឡាយឲ្យដាច់ ញាំងគោដែលដេកឲ្យ ក្រោកឡើង ហើយទៅនៅពីព្រលឹម ឈ្មោះថា ត្រាច់ទៅក្នុងវេលាមិនមែន កាល ។ គ្រាមនុស្សចេញទៅអំពីផ្ទះ ដើម្បីធ្វើការងារក្នុងស្រែជាដើម លោក ក៏ទៅដោយរហ័ស ដូចជាប់តាមម្រឹគដើម្បីឲ្យទាន់ ឈ្មោះថា ប្រញាប់ទៅ ។ ក្នុងចន្លោះផ្លូវ គ្រាជួបនឹងអ្នកណាៗ ចូលមករក ក៏សួរថា ឧបាសកឯណោះ

ឬឧបាសិកាអ្នកឯណោះ នៅផ្ទះឬទេ ឬថា មិននៅផ្ទះ លុះជ្រាបថា ឧបាសក ឬឧបាសិកាមិននៅផ្ទះ ក៏ចេញចូលទៅកាន់ទិសបច្ចិម តែត្រឡប់បានស្លាកក្នុងទិសខាងកើត ទើបចូលទៅរកភិក្ខុដទៃ អ្នកបានស្លាកក្នុងទិសបច្ចិម ហើយពោលបបួលប្តូរស្លាកគ្នាថា លោកដ៏ចម្រើន ខ្ញុំនឹងទៅកាន់ទិសបច្ចិម សូមលោកចូរទទួលស្លាករបស់ខ្ញុំទុក ដោយឲ្យស្លាករបស់លោកដល់ខ្ញុំ ។ ឬថា កាលលោកនាំស្លាកកត្តទីមួយមកបរិភោគ គ្រាពួកមនុស្សពោលថា សូមលោកម្ចាស់ចូរឲ្យបាត្រ ដើម្បីស្លាកកត្តសូម្បីដទៃទៀត ទើបឲ្យភិក្ខុដទៃប្រគល់បាត្រឲ្យ ដោយពាក្យថា បពិត្រលោកដ៏ចម្រើន សូមឲ្យបាត្ររបស់លោកមក ខ្ញុំនឹងដាក់កត្តរបស់ខ្ញុំក្នុងបាត្រ ហើយសងបាត្រឲ្យដល់លោក ដូច្នេះ លុះឲ្យបាត្រដល់ភិក្ខុដទៃហើយ កាលកត្តដែលបុគ្គលនាំមកហើយ ទើបដាក់ក្នុងបាត្ររបស់ខ្លួន កាលប្រគល់បាត្រសងវិញ ឈ្មោះថា ផ្លាស់ប្តូរបាត្រគ្នា ។ ព្រះរាជា មហាមាត្ររបស់ព្រះរាជាជាដើម ថ្វាយមហាទានដល់ព្រះភិក្ខុក្នុងវិហារ ។ ព្រោះមហាទាននេះ ភិក្ខុបានស្លាកជាច្រើនអំពីស្រុកឆ្ងាយ ។ កាលភិក្ខុមិនទៅត្រង់វិហារនោះ ក៏នឹងមិនបានស្លាកដទៃទៀតរហូតអស់ ៧ ថ្ងៃ ដូច្នោះ ទើបទៅ ព្រោះក្រែងនឹង

មិនបានស្វាក ។ កាលលោកទៅយ៉ាងនេះ ទើបឈ្មោះថា ជាអ្នកមានសេចក្តីខ្វល់ខ្វាយ ទើបទៅ ។ ក៏លោកទៅដើម្បីប្រយោជន៍ដល់ស្វាកកត្តជាដើមរបស់អ្នកណា តែត្រឡប់មានសេចក្តីសង្ស័យជាច្រើនក្នុងអ្នកនោះ យ៉ាងនេះថា អ្នកទាំងឡាយ នឹងថ្វាយស្វាកកត្តនោះ ដល់យើងឬហ្ន៎ ឬថា នឹងមិនថ្វាយ ឬថ្វាយកត្តដ៏ប្រណីតឬហ្ន៎ ឬថា នឹងថ្វាយកត្តដែលមិនល្អ ឬក៏ថ្វាយកត្តបន្តិចបន្តួចឬហ្ន៎ ឬថា នឹងថ្វាយច្រើន ឬនឹងថ្វាយកត្តត្រជាក់ឬហ្ន៎ ឬថា នឹងថ្វាយកត្តដែលនៅក្តៅ ដូច្នេះ ។

ចំណែកភិក្ខុដែលបិណ្ឌបាតជាវត្ត ក្រោកឡើងតាមវេលា ធ្វើវត្ត-បដិបត្តិ ជម្រះសរីរៈចូលទៅកាន់ទីនៅ ធ្វើទុកក្នុងចិត្តដល់កម្មដ្ឋាន កំណត់វេលា រមែងទៅ ក្នុងវេលាដែលមហាជនត្រៀមថ្វាយភិក្ខាមួយវែកជាដើមក៏គ្រប់គ្រាន់ ដូច្នោះ ទើបមិនឈ្មោះថា ត្រាច់ទៅក្នុងវេលាមិនមែនកាល ។ លោកចែកជំហានទីមួយៗ ជា ៦ ចំណែក ដើរពិចារណា ដូច្នោះ ទើបមិនឈ្មោះថា ប្រញាប់ទៅ ។ មិនសួរថា អ្នកឈ្មោះឯណោះនៅផ្ទះ ឬមិននៅផ្ទះ ព្រោះភាពជាអ្នកធ្ងន់ (ក្នុងធម៌) របស់ខ្លួន ។ រមែងមិនបានទទួលស្វាក-កត្តជាដើម ។ កាលមិនបានទទួលនឹងផ្លាស់ប្តូរអ្វី ។ មិនមានសេចក្តីកង្វល់ក្នុងអំណាចរបស់អ្នកដទៃ ។

កាលធ្វើទុកក្នុងចិត្តដល់កម្មដ្ឋាន រមែងមិនបានតាមពេញចិត្ត សេចក្តីសង្ស័យច្រើនមិនមាន ដូចភិក្ខុក្រៅនេះ ។ មិនជាប់ក្នុងស្រុក ឬក្នុងអាវាស ត្រាច់ទៅក្នុងទីដទៃបាន ។ កាលមិនជាប់ចិត្តក្នុងស្រុកជាដើម ត្រាច់ទៅក្នុងទីដទៃ ឆាន់អាហារ សង្រួមដូចទឹកអម្រឹតហើយត្រាច់ទៅ ។ ផាសុកវិហារធម៌ រមែងបានចំពោះភិក្ខុអ្នកសមាទានសំពត់បង្សុកូលជាវត្តប៉ុណ្ណោះ មិនមានដល់ភិក្ខុដែលមិនទ្រទ្រង់សំពត់បង្សុកូលជាវត្តទេ ព្រោះថា ភិក្ខុដែលមិនទ្រទ្រង់សំពត់បង្សុកូលជាវត្ត ត្រាច់ស្វែងរកសំពត់ចាំវស្សា មិនស្វែងរកសេនាសនៈសប្បាយ ។ ចំណែកភិក្ខុដែលទ្រទ្រង់សំពត់បង្សុកូលជាវត្ត មិនត្រាច់ស្វែងរកសំពត់ចាំវស្សា ។ ស្វែងរកតែសេនាសនៈសប្បាយប៉ុណ្ណោះ ។ ផាសុកវិហារធម៌ រមែងបានចំពោះភិក្ខុដែលទ្រទ្រង់ត្រៃចីវរជាវត្ត ភិក្ខុក្រៅពីនេះមិនបានទេ ។ ព្រោះថា ភិក្ខុដែលមិនទ្រទ្រង់ត្រៃចីវរជាវត្ត មានវត្ថុច្រើន មានបរិក្ខារច្រើន ព្រោះហេតុនោះ លោកទើបមិនមានផាសុកវិហារធម៌ ។ ផាសុកវិហារធម៌ រមែងបានចំពោះពួកភិក្ខុដែលប្រាថ្នាតិចជាដើមប៉ុណ្ណោះ ពួកភិក្ខុក្រៅនេះ មិនបានទេ ។ ព្រោះហេតុនោះ លោកទើបពោលថា ពិចារណាឃើញនូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នរបស់ខ្លួន ដូច្នេះ ។

ចប់អដ្ឋកថា ជិណ្ណសូត្រទី ៥

# អ ដ្ឋ ក ថា

## បឋមឱវាទសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង* ***បឋមឱវាទសូត្រទី ៦*** *ដូចតទៅនេះ ៖*

[១៥១] *បទថា* ***អហំ វា*** *សួរថា ព្រះមានព្រះភាគត្រាស់ព្រោះហេតុអ្វី ។*

*ឆ្លើយថា ដើម្បីតាំងព្រះថេរៈទុកក្នុងឋានៈរបស់ព្រះអង្គ ។ សួរថា ព្រះសារីបុត្រ និងព្រះមោគ្គល្លាន មិនមានឬ ។ ឆ្លើយថា មាន ។ តែព្រះអង្គមានព្រះតម្រិះយ៉ាងនេះថា ព្រះថេរៈទាំងនេះ នឹងតាំងនៅយូរមិនបាន ។ ឯចំណែកកស្សបៈ មានអាយុ ១២០ ឆ្នាំ ។ កាលយើងបរិនិព្វានហើយ កស្សបៈនោះ នឹងអង្គុយក្នុងល្អាងសត្តបណ្ណគូហា ធ្វើការរួបរួមព្រះធម៌វិន័យ នឹងធ្វើព្រះសាសនារបស់យើងឲ្យប្រព្រឹត្តទៅបានរហូតវេលាប្រមាណ ៥,០០០ ឆ្នាំ ។ តថាគតទើបតាំងកស្សបៈទុកក្នុងឋានៈរបស់តថាគត ។ ពួកភិក្ខុនឹងសម្គាល់ពាក្យរបស់កស្សបៈ ដែលខ្លួនគប្បីស្តាប់ដោយល្អ ។ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់យ៉ាងនេះ ។*

[១៥២] *បទថា* ***ទុព្វចា*** *សេចក្តីថា ពួកភិក្ខុជាអ្នកប្រដៅក្រ ។ បទថា*

**ទោវចស្សករណេហិ** គឺ ដោយការធ្វើឲ្យជាអ្នកប្រដៅក្រ ។ បទថា **អប-ទក្ខិណគ្គាហិនោ** លោកសម្ដែងថា ស្ដាប់អនុសាសនីហើយ មិនទទួលយកដោយសេចក្ដីគោរព មិនប្រព្រឹត្តតាមពាក្យប្រៀនប្រដៅ កាលមិនប្រព្រឹត្តតាម ជាបុគ្គលឈ្មោះថា ទទួលយកដោយមិនគោរព ។ បទថា **អច្ចាវទន្តិ** សេចក្ដីថា ពោលលើស គឺ ពោលច្រើនពេក ព្រោះអាស្រ័យការរៀនព្រះ-សូត្រច្រើន ។

បទថា **កោ ពហុតរំ ភាសិស្សតិ** សេចក្ដីថា កាលពោលធម៌ រមែងពោលថា អ្នកណានឹងពោលធម៌ច្រើន ។ លោកឬ ឬជាយើង ។ បទថា **កោ សុន្ទរតរំ** សេចក្ដីថា ភិក្ខុមួយរូប សូម្បីកាលពោលច្រើន រមែងពោលមិនបានប្រយោជន៍ មិនពីរោះ ។ ភិក្ខុមួយរូបទៀត ពោលមានប្រយោជន៍ ពីរោះ ។ លោកសំដៅដល់ប្រការនោះ ទើបពោលថា **កោ សុន្ទរតរំ** ដូច្នេះ ។ ចំណែកមួយរូបទៀត ពោលច្រើន និងល្អ ក៏មិនពោលយូរ រហ័សឈប់ ។ មួយរូបទៀត រមែងប្រើវេលាយូរ លោកសំដៅដល់ប្រការនោះ ទើបពោលថា **កោ ចិរតរំ** ដូច្នេះ ។

ចប់អដ្ឋកថា បឋមឱវាទសូត្រទី ៦

# អ ដ្ឋ ក ថា

## ទុតិយឱវាទសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ទុតិយឱវាទសូត្រទី ៧** ដូចតទៅនេះ ៖*

*[១៥៨] បទថា **សទ្ធា** បានដល់ សទ្ធាដែលរឹងមាំ ។ បទថា **វីរិយំ** បានដល់ សេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **បញ្ញា** បានដល់ បញ្ញាដឹងក្នុងកុសលធម៌ ។*

*បទថា **ន សន្តិ ភិក្ខូ ឱវាទកា** ព្រះកស្សបៈសម្តែងថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះថា មិនមានពួកភិក្ខុអ្នកឲ្យឱវាទ តែទូន្មានកល្យាណមិត្តដូច្នេះ នេះជាសេចក្តីសាបសូន្យ ។*

ចប់អដ្ឋកថា ទុតិយឱវាទសូត្រទី ៧

# អ ដ្ឋ ក ថា

## តតិយឱវាទសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង **តតិយឱវាទសូត្រទី ៨** ដូចតទៅនេះ ៖*

[១៦២] *បទថា **តថា ហិ បន** ជានិបាត ចុះក្នុងហេតុជាទីតាំង ព្រោះកាលមុនជាអ្នកប្រដៅងាយ និងឥឡូវនេះជាអ្នកប្រដៅក្រ ។ បទថា **តត្រ** បានដល់ ក្នុងព្រះថេរៈទាំងនោះ ។ បទថា **កោ នាមាយំ ភិក្ខុ** សេចក្ដីថា ភិក្ខុនេះឈ្មោះអ្វី ឈ្មោះតិស្សត្ថេរ ឬនាគត្ថេរ បទថា **តត្រ** កាលសក្ការៈនោះ ដែលគេធ្វើហើយយ៉ាងនេះ ។ បទថា **តថត្តាយ** សេចក្ដីថា ដើម្បីសភាពជាយ៉ាងនោះ គឺ ដើម្បីភាពជាអ្នកនៅព្រៃជាវត្តជាដើម ។*

[១៦៤] *បទថា **សព្រហ្មចារិកាមោ** សេចក្ដីថា ឈ្មោះថា អ្នកប្រាថ្នាចំពោះសព្រហ្មចារីក្នុងអត្ថថា ប្រាថ្នាចង់បាន ត្រូវការយ៉ាងនេះថា ភិក្ខុទាំងនេះ ចូរហែហមយើងត្រាច់ទៅ ដូច្នេះ ។ បទថា **តថត្តាយ** បានដល់ ដើម្បីជាហេតុឲ្យលាភសក្ការៈកើតឡើង ។ បទថា **ព្រហ្មចារូបទ្ទវេន** សេចក្ដីថា ភិក្ខុណាមានឆន្ទរាគៈខ្លាំងក្លាក្នុងបច្ច័យ ៤ របស់សព្រហ្មចារី លោកហៅថាជាឧបទ្រព្យ ។ ព្រហ្មចរិយៈត្រូវឧបទ្រព្យនោះបៀតបៀន ។ បទថា **អភិភវនា***

គឺ ប្រាថ្នាហួសប្រមាណ ។ បទថា ព្រហ្មចារកិរិយានេន សេចក្តីថា បច្ច័យ ៤ ពោលគឺ សេចក្តីប្រាថ្នាហួសប្រមាណរបស់ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ។

ចប់អដ្ឋកថា ឱវាទសូត្រទី ៨

# អ ដ្ឋ ក ថា

## ឈានាភិញ្ញាសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឈានាភិញ្ញាសូត្រទី ៩ ដូចតទៅនេះ ៖*

[១៦៥] *បទថា **យាវទេ អាកង្ខាមិ** បានដល់ ដរាបដែលយើងប្រាថ្នា ។ ចំណែកអំពីនេះ យើងពោលរូបាវចរឈាន ៤ ដោយន័យជាដើមថា **វិវិច្ចេវ កាមេហិ** ដូច្នេះ ។*

[១៦៩] *អរូបសមាបត្តិ ៤ ដោយន័យជាដើមថា **សព្វសោ រូបសញ្ញានំ សមតិក្កមា** ដូច្នេះ ។*

[១៧៣] *ពោលនិរោធសមាបត្តិយ៉ាងនេះថា **សព្វសោ នេវសញ្ញានា-សញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ** ដូច្នេះ ។*

[១៧៤] *ពោលអភិញ្ញាជាលោកិយ៍ ៥ ដោយន័យជាដើមថា **អនេក-វិហិតំ ឥទ្ធិវិធំ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទដែលគប្បីពោលទាំងអស់នោះ ឲ្យពិស្តារក្នុងវិសុទ្ធិមគ្គ ព្រមដោយពណ៌នាតាមលំដាប់បទ និងវិធីភាវនា ។*

[១៧៩] *បទថា **អាសវានំ ខយា** បានដល់ ព្រោះអាសវៈអស់ទៅ ។ បទថា **អនាសវំ** បានដល់ មិនជាបច្ច័យនៃអាសវៈ ។ បទថា **ចេតោវិមុត្តិ***

បានដល់ សមាធិក្នុងអរហត្តផល ។

បទថា **បញ្ញាវិមុត្តិ** បានដល់ បញ្ញាក្នុងអរហត្តផល ។

ចប់អដ្ឋកថា ឈានាភិញ្ញាសូត្រទី៩

# អ ដ្ឋ ក ថា

## ភិក្ខុនូបស្សយសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ភិក្ខុនូបស្សយសូត្រទី ១០** ដូចតទៅនេះ ៖*

*[១៨០] បទថា **អាយាម ភន្តេ** សេចក្តីថា សួរថា ព្រះអានន្ទរមែង អង្វរការទៅកាន់ទីនៅនៃពួកភិក្ខុនី ព្រោះហេតុអ្វី ។ ឆ្លើយថា មិនមែនព្រោះ ហេតុនៃលាភ និងសក្ការៈ ។ លោករមែងអង្វរថា ក៏ក្នុងទីនៅរបស់ភិក្ខុនីនេះ ពួកភិក្ខុនីដែលត្រូវការកម្មដ្ឋាននៅមាន ។ ក៏យើងនឹងញុំាងភិក្ខុនីទាំងនោះ ឲ្យកើតសេចក្តីខ្វល់ខ្វាយហើយ គប្បីឲ្យកម្មដ្ឋាន ដូច្នេះ ។ សួរថា ព្រះថេរៈ នោះ ខ្លួនឯងក៏ទ្រទ្រង់ព្រះត្រៃបិដក ជាពហុស្សុតមិនមែនឬ មិនអាចនឹង ប្រាប់ដោយខ្លួនឯងឬ ។ ឆ្លើយថា មិនអាចក៏មិនមែន ។ តែរមែងអង្វរថា ពួកភិក្ខុនីនឹងសម្គាល់ធម៌របស់ព្រះសាវក អ្នកមានចំណែកប្រៀបផ្ទឹមដោយ ព្រះពុទ្ធដែលខ្លួនគប្បីជឿ ដូចម្តេច ។ បទថា **ពហុកិច្ចោត្វំ ពហុករណីយោ** សួរថា ព្រះថេរៈជាអ្នកខ្វល់ខ្វាយក្នុងនវកម្មជាដើមឬ ទើបពោលយ៉ាងនេះ ចំពោះព្រះអានន្ទ ។ ក៏កាលព្រះសាស្តារបស់យើងបរិនិព្វានហើយ បរិស័ទ ៤ ចូលទៅរកព្រះអានន្ទត្ថេរ ស្រែកយំហើយពោលថា បពិត្រលោកដ៏ចម្រើន*

ឥឡូវនេះលោកទទួលបាត្រ និងចីវររបស់អ្នកណាត្រាច់ទៅហ្ន៎ ។ លោកបោសបរិវេណរបស់អ្នកណា ។ លោកថ្វាយទឹកលាងមុខដល់អ្នកណា ។ ព្រះថេរៈលួងលោមបរិស័ទថា សទ្ធារទាំងឡាយមិនទៀង ។ ស្តេចមច្ចុរាជមិនខ្មាសប្រហារហើយសូម្បីក្នុងពុទ្ធសរីរៈ ។ នោះជាធម្មតារបស់សទ្ធារទាំងឡាយ អ្នកទាំងឡាយកុំសោកសៅ កុំទួញយំ ដូច្នេះ ។ នេះជាកិច្ចច្រើនរបស់លោក ។ ព្រះថេរៈសំដៅដល់ប្រការនោះ ទើបពោលយ៉ាងនេះ ។

[១៨១] បទថា **សន្ទស្សេសិ** បានដល់ សម្តែងគុណនៃការបដិបត្តិ ។ បទថា **សមាទបេសិ** ប្រែថា ឲ្យកាន់យក ។ បទថា **សមុត្តេជេសិ** ប្រែថា ឲ្យអាចហ៊ាន ។ បទថា **សម្បហំសេសិ** បានដល់ ឲ្យត្រេកអរដល់គុណដែលបានហើយ ។

[១៨២] បទថា **ថុល្លតិស្សា** សេចក្តីថា ឈ្មោះថា **តិស្សា** ព្រោះមានសរីរៈធាត់ ។ បទថា **វេទេហមុនិនោ** គឺ បណ្ឌិតមុនី ។ ក៏បណ្ឌិត រមែងនាំទៅ គឺ ធ្វើកិច្ចទាំងពួងដោយសេចក្តីដឹង ពោលគឺ ញាណ ។ ព្រោះដូច្នោះទើបហៅថា **វេទេហមុនី** ។ ឈ្មោះថា **វេទេហមុនី** ព្រោះអត្ថថា មុនីនោះផង ជាអ្នកមានការចេះដឹងផង ។ បទថា **ធម្មំ ភាសិតព្វំ មញ្ញតិ** សេចក្តីថា (នាងភិក្ខុនីគិតថា) ព្រះមហាកស្សបៈខ្លួនឯងនៅព្រៃ ទ្រទ្រង់សំពត់បង្សុកូល

ជាវត្ត ទើបសម្គាល់ធម៌ដែលខ្លួនគួរពោលថា យើងជាធម្មកថិក ដូច្នេះ ក្នុងទីចំពោះមុខព្រះអានន្ទអ្នកទ្រទ្រង់បិដក ជាឃ្លាំងព្រះធម៌ ។ នាងភិក្ខុនីនិយាយមើលងាយថា ក៏ព្រះថេរៈនេះជាអ្វី ។ បទថា **អស្សោសិ** សេចក្តីថា បានស្តាប់ហើយ ដោយអំណាចនៃពាក្យដែលបុគ្គលដទៃមកប្រាប់ ។

[១៨៣] បទថា **អាគមេហិ ត្វំ អាវុសោ** បានដល់ លោកអ្នកមានអាយុ ចូរឈប់សិន ។ បទថា **មា តេ សង្ឃោ ឧត្តរឹ ឧបបរិក្ខិ** សេចក្តីថា ភិក្ខុសង្ឃកុំត្រិះរិះក្នុងសេចក្តីនោះឲ្យហួសឱកាស (គឺ ហួសអ្វីដែលមាន) ។ មានអធិប្បាយថា សង្ឃកុំសម្គាល់ប្រការនោះយ៉ាងនេះថា ព្រះអានន្ទហាមសាវកអ្នកមានចំណែកប្រៀបស្មើនឹងព្រះពុទ្ធ មិនហាមខាងភិក្ខុនី ។ សេចក្តីជិតជិត ឬសេចក្តីហួងហែងរបស់ (ព្រះអានន្ទ) សាវកនឹងភិក្ខុនីនោះ នឹងមានដូច្នេះ ។

ឥឡូវនេះ ព្រះមហាកស្សបៈ កាលសម្តែងខ្លួនថា មានចំណែកប្រៀបផ្ទឹមដោយព្រះពុទ្ធ ទើបពោលពាក្យជាដើមថា **តំ កឹ មញ្ញសិ អាវុសោ** ដូច្នេះ ។

[១៨៤] បទថា **សត្តរតនំ** គឺ ប្រមាណ ៧ ហត្ថ ។ បទថា **នាគំ** គឺ ដំរី ។ បទថា **អឌ្ឍដ្ឋមរតនំ វា** បានដល់ ៧ ហត្ថកន្លះ អធិប្បាយថា តាំង

ពីដើមមុខដរាបដល់ពោង មាន ៧ ហត្ថកន្ទះ ។ បទថា **តាលបត្តិកាយ** គឺដោយស្លឹកត្នោតខ្ចី ។

បទថា **ចរិត្វ** សេចក្តីថា **ចុល្លតិស្សា** ភិក្ខុនីឃ្លាតហើយ វិនាសហើយ (ចាកព្រហ្មចរិយៈ) តែមិនទាន់ស្លាប់ ។

ក៏កាលព្រះមហាកស្សបត្ថេរ បន្លឺសីហនាទដោយអភិញ្ញា ៦ ហើយ សំពត់ជ្រលក់ទឹកអម្ចត់របស់ភិក្ខុនីនោះ ក៏ផ្តើមពេលរាលត្រង់រាងកាយ ដូចត្រូវបន្ទាចាក់ ឬខ្មៅពេល ព្រោះពោលប្រទូស្តចំពោះសាវកអ្នកមានចំណែកប្រៀបផ្ទឹមដោយព្រះពុទ្ធ ។ សេចក្តីពេញចិត្តកើតឡើង ក្នុងខណៈដោះសំពត់ទាំងនោះចេញ ស្លៀកសំពត់ស ដូច្នេះ ។

ចប់អដ្ឋកថា ភិក្ខុនូបស្សយសូត្រទី ១០

# អ ដ្ឋ ក ថា

## ចីវរសូត្រទី ១១

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចីវរសូត្រទី ១១ ដូចតទៅនេះ ៖*

[១៨៦] *បទថា ទក្ខិណាគិរិស្មឹ សេចក្តីថា ជនបទភាគទក្សិណនៃភ្នំលោមព័ទ្ធក្រុងរាជគ្រឹះ ឈ្មោះថា ទក្ខិណាគិរិ ។ អធិប្បាយថា ត្រាច់ចារិកទៅក្នុងទក្ខិណាគិរីជនបទនោះ ។ ឈ្មោះថា ចារិកមាន ២ យ៉ាង គឺ ចារិកប្រញាប់ ១ មិនប្រញាប់ ១ ។*

*ក្នុងបទទាំងនោះ ភិក្ខុរូបខ្លះស្មៀកសំពត់កាសាយៈមួយផ្ទាំង ដណ្តប់មួយផ្ទាំងរហូតវេលា ប្រដាប់បាត្រ និងចីវរត្រង់ស្មា កាន់ឆ័ត្រ មួយថ្ងៃដើរទៅបាន ៧-៨ យោជន៍ មានញើសហូរជោកខ្លួន ។ ឬថា ព្រះពុទ្ធជាម្ចាស់ទ្រង់ឃើញសត្វ គប្បីត្រាស់ដឹងធម៌ណាៗ ក្នុងខណៈនោះ ស្តេចទៅបានរយយោជន៍ខ្លះ ពាន់យោជន៍ខ្លះ ។ នេះឈ្មោះថា ចារិកប្រញាប់ ។*

*ក៏រាល់ថ្ងៃ ដែលព្រះពុទ្ធជាម្ចាស់ទទួលនិមន្តដើម្បីឆាន់ក្នុងថ្ងៃនេះ ។ ស្តេចទៅធ្វើការសង្គ្រោះជនមានប្រមាណប៉ុណ្ណេះថា មួយគាវុត កន្លះយោជន៍ បីគាវុត មួយយោជន៍ ។ នេះឈ្មោះថា ចារិកមិនប្រញាប់ ក្នុងទីនេះប្រាថ្នា*

ចារិកនេះ ។

ព្រះថេរៈបាននិមន្តតាមក្រោយព្រះទសពលរហូតដល់អស់ ២៥ ឆ្នាំ ដូចស្រមោលមិនមែនឬ ។ ព្រះអង្គមិនឲ្យឱកាសដល់ព្រះតម្រាស់ ដើម្បីត្រាស់សួរថា អានន្ទទៅណា ។ ព្រះអង្គបានឱកាសត្រាច់ចារិកទៅជាមួយនឹងភិក្ខុសង្ឃក្នុងកាលមួយ ។ ក្នុងឆ្នាំដែលព្រះសាស្តាបរិនិព្វាន ។ បានឮថា កាលព្រះសាស្តាបរិនិព្វានហើយ ព្រះមហាកស្សបត្ថេរអង្គុយត្រង់កណ្តាលភិក្ខុសង្ឃ ដែលប្រជុំព្រមគ្នាក្នុងការបរិនិព្វានរបស់ព្រះសាស្តា ជ្រើសរើសភិក្ខុ ៥០០ រូប ដើម្បីធ្វើសង្គាយនាព្រះធម៌វិន័យ ពោលថា ក៏លោកដ៏មានអាយុទាំងឡាយ យើងទាំងឡាយនឹងនៅចាំវស្សាក្នុងក្រុងរាជគ្រឹះ ហើយធ្វើការសង្គាយនាព្រះធម៌វិន័យ លោកទាំងឡាយមុនចូលវស្សា ចូរកម្ចាត់បង់បលិពោធចំណែកខ្លួនចេញ ហើយប្រជុំគ្នាក្នុងក្រុងរាជគ្រឹះចុះ ក៏ទៅកាន់ក្រុងរាជគ្រឹះដោយខ្លួនឯង ។ ព្រះអានន្ទត្ថេរ កាន់បាត្រ និងចីវររបស់ព្រះ-មានព្រះភាគ លួងលោមមហាជន ទៅកាន់ក្រុងសាវត្ថី ចេញចាកក្រុងសាវត្ថីនោះ ទៅកាន់ក្រុងរាជគ្រឹះ ត្រាច់ចារិកទៅក្នុងទក្ខិណាគិរីជនបទ ។ នេះលោកពោលសំដៅដល់សេចក្តីនោះ ។

បទថា **យេភុយ្យេន កុមារភូតា** សេចក្តីថា ពួកភិក្ខុណា ឈ្មោះថា

វិលមកដើម្បីជាហីនភេទ ភិក្ខុទាំងនោះដោយច្រើនជាក្មេងកម្លោះ នៅទន់ខ្សោយ គឺ ជាភិក្ខុ ១ វស្សា ២ វស្សា និងជាសាមណេរ ។ សួរថា ក៏ព្រោះហេតុអ្វី ក្មេងទាំងនោះទើបបួស ។ ព្រោះហេតុអ្វី ទើបវិលមកដើម្បីជាហីន-ភេទ ដូច្នេះ ។ ឆ្លើយថា បានឮថា មាតាបិតារបស់ក្មេងនោះគិតថា ព្រះអានន្ទជាអ្នកជិតដិតនឹងព្រះសាស្តា ទូលសូមពរ ៨ យ៉ាង ហើយទើបឧបដ្ឋាកទាំងអាចនឹងនាំយកព្រះសាស្តាទៅកាន់ស្ថានទីដែលខ្លួនប្រាថ្នា និងខ្លួនប្រាថ្នាបាន ។ យើងទាំងឡាយ ទើបឲ្យពួកក្មេងរបស់ពួកយើង បួសក្នុងសម្នាក់របស់ព្រះអានន្ទនោះ ។ ព្រះអានន្ទក៏នឹងនាំព្រះសាស្តាមក ។ កាលព្រះ-សាស្តាមកហើយ យើងទាំងឡាយនឹងបានធ្វើសក្ការៈជាច្រើន ដូច្នេះ ។ ពួកញាតិរបស់ក្មេងទាំងនោះ ទើបឲ្យក្មេងទាំងនោះបួស ដោយហេតុនេះឯង ។ តែកាលព្រះសាស្តាបរិនិព្វាន សេចក្តីប្រាថ្នារបស់អ្នកទាំងនោះក៏អស់ទៅ ។ កាលដូច្នោះ ទើបឲ្យក្មេងទាំងនោះសឹក ដោយថ្ងៃតែមួយប៉ុណ្ណោះ ។

[១៨៧] បទថា **យថាភិរន្តំ** បានដល់ តាមពេញចិត្ត គឺ តាមអធ្យា-ស្រ័យ ។ បទនេះថា **តិកភោជនំ បញ្ញត្តំ** លោកពោលដល់បទនេះថា ជាបាចិត្តិយក្នុងគណភោជន វៀរលែងតែមានសម័យ ដូច្នេះ ។ ក៏ភិក្ខុ ៣ រូបត្រេកអរស្មើម្បីទទួលនិមន្តជាអកប្បិយរួមគ្នា ជាអនាបត្តិ ព្រោះគណភោជន

នោះ ។ ព្រោះដូច្នោះ លោកទើបពោលថា **តិកភោជនំ** ដូច្នេះ ។

[១៨៨] បទថា **ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ** បានដល់ ដើម្បីគ្រប សង្កត់អ្នកទ្រុស្តសីល ។

បទថា **បេសលានំ ភិក្ខូនំ ផាសុវិហារាយ** សេចក្តីថា ឧបោសថ និង បវារណា រមែងប្រព្រឹត្តទៅដើម្បីភិក្ខុអ្នកមានសីលជាទីស្រឡាញ់ ដោយការ គ្របសង្កត់បុគ្គលនោះឯង ។ ការនៅព្រមព្រៀងគ្នា រមែងមាន ។ នេះជា ផាសុវិហាររបស់បេសលភិក្ខុទាំងនោះ ដើម្បីប្រយោជន៍ដល់ការនៅជាសុខ នេះ ។ បទថា **មា បាបិច្ឆា បក្ខំ និស្សាយសង្ឃំ ភិន្ទេយ្យុំ** សេចក្តីថា ទេវទត្ត ពោលសូមក្នុងត្រកូលដោយខ្លួនឯង បរិភោគ នៅអាស្រ័យ ភិក្ខុប្រាថ្នាលាមក បំបែកសង្ឃ យ៉ាងណា អ្នកប្រាថ្នាលាមកពួកដទៃ ពោលសូមក្នុងត្រកូល ដោយជាគណបរិភោគ ឲ្យគណៈចម្រើន ហើយអាស្រ័យបក្ខពួកទាំងនោះ គប្បីបំបែកសង្ឃបាន ដូច្នោះ ទើបទ្រង់បញ្ញត្តិទុកដោយហេតុនេះឯង ។

បទថា **កុលានុទយតាយ ច** សេចក្តីថា កាលភិក្ខុសង្ឃធ្វើឧបោសថ និងបវារណាព្រមព្រៀងគ្នាហើយ ពួកមនុស្សថ្វាយស្លាកភត្តជាដើម រមែង ជាអ្នកមានសួគ៌នៅខាងមុខ ។ អធិប្បាយថា ទ្រង់បញ្ញត្តិទុកដើម្បីអនុគ្រោះ ត្រកូលនេះ ដោយប្រការដូច្នេះ ។

[១៨៩] បទថា **សស្សឃាតំ មញ្ញេ ចរសិ** បានដល់ លោកត្រាច់ទៅដូចជាជាន់សន្ទូង ។ បទថា **កុលូបឃាតំ មញ្ញេ ចរសិ** បានដល់ លោកត្រាច់ទៅដូចជាបៀតបៀនសម្លាប់ត្រកូល ។ បទថា **ឱលុជ្ជតិ** បានដល់ បាក់បែក គឺ ខ្ទាត់ខ្ទាយទៅ ។ បទថា **បលុជ្ជន្តិ ខោ តេ អាវុសោ នវប្បាយា** សេចក្តីថា ម្នាលអាវុសោ ភិក្ខុទាំងនោះ ដោយច្រើន គឺ ចំណែកច្រើនរបស់លោកជាអ្នកបួសថ្មី ជាកម្លោះមានវស្សាមួយ ឬ ២ វស្សា និងជាសាមណេរ បែកបាក់ គឺ ខ្ទាត់ខ្ទាយ ។ បទថា **ន វាយំ កុមារកោ មត្តមញ្ញាសិ** ព្រះថេរៈ កាលពោលគម្រាមព្រះថេរៈថា ក្មេងនេះមិនស្គាល់ប្រមាណខ្លួន ។ បទថា **កុមារកវាទាន មុច្ចាម** សេចក្តីថា ពួកយើងមិនទាន់ផុតវាទៈថា ជាក្មេង ។ បទថា **តថា ហិ បនត្វំ** នេះ លោកពោលដើម្បីសម្តែងហេតុព្រោះព្រះអានន្ទនេះ គប្បីត្រូវព្រះថេរៈពោលយ៉ាងនេះ ។ ក្នុងសេចក្តីនេះមានសេចក្តីអធិប្បាយដូច្នេះថា ព្រោះលោកត្រាច់ទៅជាមួយនឹងពួកភិក្ខុថ្មីទាំងនេះ មិនសង្រួមឥន្ទ្រិយ ។ ដូច្នោះ លោកត្រាច់ទៅជាមួយនឹងពួកភិក្ខុក្មេងៗ ទើបគួរត្រូវគេពោលថា ជាក្មេង ។

[១៩០] បទថា **អញ្ញតិត្ថិយបុព្វោ សមានោ** នេះ ព្រោះ អាចារ្យឧបជ្ឈាយ៍របស់ព្រះថេរៈ មិនប្រាកដក្នុងសាសនានេះឡើយ ។ ខ្លួនកាន់យក

សំពត់កាសាយៈ ហើយចេញបួស ។ ដូច្នោះ ភិក្ខុនីថុល្លនន្ទា ពោលដល់ព្រះមហាកស្សបៈធ្លាប់ជាអន្យតិរ្ថិយ ព្រោះសេចក្តីមិនពេញចិត្ត ។

[១៩១] ក្នុងបទថា **សហសា** នេះ សូម្បីអ្នកប្រព្រឹត្តដោយរាគៈនិងមោហៈ គឺ មិនទាន់ត្រិះរិះ ។ តែបទនេះ លោកពោលដោយអំណាចការប្រព្រឹត្តដោយទោសៈ ។ បទថា **អប្បដិសង្ខា** គឺ មិនទាន់ពិចារណា ។

ឥឡូវនេះ ព្រះមហាកស្សបត្ថេរ កាលញ៉ាំងបព្វជ្ជារបស់ខ្លួនឲ្យបរិសុទ្ធិ ទើបពោលពាក្យជាដើមថា **យតោហំ អាវុសោ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **អញ្ញំ សត្ថារំ ឧទ្ទិសិតុំ** សេចក្តីថា យើងមិននឹក ដើម្បីឧទ្ទិសយ៉ាងនេះថា វៀរព្រះមានព្រះភាគ អ្នកដទៃជាគ្រូរបស់យើង ។ ក្នុងបទជាដើមថា **សម្ពាធោឃរាវាសោ** សេចក្តីថា ប្រសិនបើថា ប្តី និងប្រពន្ធទាំងពីរ រមែងនៅក្នុងផ្ទះ ទទឹង ៦០ ហត្ថ ឬសូម្បីខាងក្នុងចន្លោះរយយោជន៍ ការនៅគ្រប់គ្រងផ្ទះ ប្តីប្រពន្ធទាំងនោះឈ្មោះថា ចង្អៀតទ្រុំឯង ព្រោះអត្ថថា មានកិលេសជាគ្រឿងកង្វល់ គឺ ហួងហែង ។ បទថា **រជាបថោ** លោកពោលក្នុងមហាអដ្ឋកថាថា ជាស្ថានទីកើតនៃធូលី មានរាគៈជាដើម ។ នឹងពោលថា ជាផ្លូវនៃការមក ដូច្នេះក៏បាន ។ ឈ្មោះថា **អព្ភោកាសោ** ព្រោះអត្ថថា មិនជាប់ជំពាក់ រួចផុតស្រឡះ ព្រោះបព្វជិតនៅក្នុងទីបិទបាំង ក្នុងទីមានកូដាគារ

រតនប្រាសាទ និងទេវវិមានជាដើម ដែលមានទ្វារ និងបង្អួចបិទហើយ រមែង មិនទាស់ មិនជំពាក់ មិនជាប់ ។ ព្រោះហេតុនោះ លោកទើបពោលថា បព្វជ្ជា ជាអព្ភោកាសោ ។ មួយទៀត យកវាស ឈ្មោះថា ចង្អៀត ព្រោះ មិនជាឱកាសនៃកុសលកិរិយា ឈ្មោះថា ជាផ្លូវមកនៃធូលី ព្រោះជាទីប្រជុំ នៃធូលី គឺ កិលេស ដូចគំនរសម្រាមដែលគេមិនបិទទុក ។ បព្វជ្ជា ឈ្មោះ ថា អព្ភោកាសោ ព្រោះជាឱកាសនៃកុសលកិរិយា ជាសុខយ៉ាងណា ។

ក្នុងបទថា **នយិទំ សុករំ ។បេ។ បព្វជេយ្យំ** នេះ មានសង្ខេបកថា ដូច្នេះ អ្នកគប្បីធ្វើសិក្ខា ៣ ប្រព្រឹត្តព្រហ្មចរិយមិនឲ្យដាច់ សូម្បីមួយថ្ងៃ ឈ្មោះថា ប្រព្រឹត្តឲ្យសម្បូរណ៍ដោយចំណែកមួយ ព្រោះហេតុឲ្យសម្រេច ចរិមកចិត្ត ។ ធ្វើមិនឲ្យមានមន្ទិល ដោយមន្ទិល គឺ កិលេស សូម្បីមួយ ថ្ងៃ ឈ្មោះថា បរិសុទ្ធិដោយចំណែកមួយ ព្រោះហេតុឲ្យសម្រេចចរិមក-ចិត្ត ។ បទថា **សង្ខលិខិតំ** បានដល់ ដូចស័ង្ខដែលខាត់ គឺ គប្បីប្រព្រឹត្ត មានចំណែកស្មើដោយស័ង្ខដែលខាត់ហើយ ។ បទថា **ឥទំ ន សុករំ អគារំ អជ្ឈាវសតា** សេចក្ដីថា អ្នកនៅគ្រប់គ្រងផ្ទះប្រព្រឹត្ត ។ល។ ឲ្យបរិបូណ៌ដោយ ចំណែកមួយ ។ ដូចម្ដេចហ្ន៎ យើងកោរសក់ និងពុកមាត់ ស្លៀកដណ្ដប់ សំពត់កាសាយៈ ព្រោះជ្រួតជ្រាបដោយរស ដែលជ្រលក់ដោយទឹកអម្ចត់

គឺ សំពត់ដែលសមគួរដល់អ្នកប្រព្រឹត្តព្រហ្មចរិយៈ ចេញចាកផ្ទះ គប្បីបួស មិនមានផ្ទះ ។ ព្រោះក្នុងសេចក្តីនេះ កម្ម មានកសិកម្ម និងពាណិជ្ជកម្ម ជាដើម ដែលឧបត្ថម្ភដល់ផ្ទះ ហៅថា **អគារិយ** ។ ផ្ទះនោះ មិនមានក្នុង បព្វជ្ជា ។ ដូច្នោះ បព្វជ្ជាគប្បីដឹងថាជា **អនាគារិយ** ។ ដែលជាអនាគារិយៈ ការមិនមានផ្ទះនោះ ។ បទថា **បព្វជេយ្យំ** គឺ គប្បីបដិបត្តិ ។ បទថា **បដបិលោតិកានំ** គឺ សំពត់ចាស់ ។ សំពត់ថ្មីសូម្បី ១៣ ហត្ថ លោកហៅ ថា សំពត់ចាស់ ផ្តើមតាំងពីវេលាកាត់ជាយ ។ លោកសំដៅដល់សង្ឃាដិ ដែលលោកកាត់សំពត់ដែលមានតម្លៃច្រើន ពោលថា សង្ឃាដិនៃសំពត់ចាស់ ដូច្នេះ ។ បទថា **អទ្ធានមគ្គំ បដិបន្នោ** បានដល់ ក៏ផ្លូវតាំងពីកន្លះយោជន៍ ហៅថា ឆ្ងាយ ។ អធិប្បាយថា ដើរផ្លូវឆ្ងាយនោះ ។

ឥឡូវនេះ គប្បីពោលអនុបុព្វីកថា ចាប់ផ្តើមតាំងពីអភិនិហារ ដើម្បី សេចក្តីជាក់ច្បាស់នៃប្រការនេះ ដូចបព្វជិតនោះ និងអ្នកដើរផ្លូវឆ្ងាយ ដូច តទៅនេះ ៖

បានឮថា ក្នុងអតីតកាលក្នុងទីបំផុតសែនកប្ប ព្រះសាស្តាព្រះនាម ថា ព្រះបទុមុត្តរៈ បានឧប្បត្តិឡើង ។ កាលព្រះបទុមុត្តរៈ ស្តេចចូលទៅ អាស្រ័យនៅនគរហង្សវតី ប្រថាប់នៅក្នុងខេមមិគទាយវ័ន កុដុម្ពី ឈ្មោះថា

វេទេហៈ មានទ្រព្យសម្បត្តិ ៨០ កោដិ បរិភោគអាហារយ៉ាងល្អ តាំងពីព្រឹកព្រលឹម អធិដ្ឋានអដ្ឋឧបោសថ កាន់របស់ក្រអូប និងផ្កាឈើជាដើមទៅកាន់ព្រះវិហារបូជាព្រះសាស្ដា ថ្វាយបង្គំនមស្ការហើយ អង្គុយនៅក្នុងទីដ៏សមគួរមួយ ។

ខណៈនោះ ព្រះសាស្ដាទ្រង់តាំងព្រះសាវករូបទី ៣ ឈ្មោះ មហា-និសភត្ថេរទុកក្នុងឋានៈជាឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុដែលជាសាវករបស់តថាគតជាអ្នកពោលទូន្មាននូវធុតង្គ និសភៈ ជាអ្នកប្រសើរជាងភិក្ខុទាំងនោះ ។ ឧបាសកបានស្ដាប់ដូច្នោះជ្រះថ្លា ក្នុងទីបំផុតធម្មកថាកាលមហាជនក្រោកឡើងត្រឡប់ទៅ ទើបថ្វាយបង្គំនមស្ការព្រះសាស្ដា ក្រាបទូលថា ថ្ងៃស្អែកនេះ សូមព្រះអង្គទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ។ ព្រះសាស្ដាត្រាស់ថា ឧបាសក ភិក្ខុសង្ឃមានចំនួនច្រើន ។ ឧបាសកទូលសួរថា បពិត្រព្រះមានព្រះភាគ ភិក្ខុសង្ឃមានប្រមាណប៉ុនណា ព្រះអង្គ ។ ព្រះសាស្ដាត្រាស់ថា មាន ៦ លាន ៨ សែនរូប ។ ឧបាសកទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ឲ្យភិក្ខុមិនឲ្យនៅសល់ទុកក្នុងវិហារសូម្បីសាមណេរតែមួយអង្គ ទទួលនិមន្តចុះព្រះអង្គ ។ ព្រះសាស្ដាទ្រង់ទទួលនិមន្តហើយ ។

ឧបាសកជ្រាបថា ព្រះសាស្ដាទទួលនិមន្តហើយ ទើបទៅផ្ទះត្រៀម

មហាទានថ្ងៃស្អែក ឲ្យមនុស្សទៅក្រាបទូលដល់វេលាចំពោះព្រះសាស្តា ។ ព្រះសាស្តាទ្រង់ប្រដាប់បាត្រ និងចីវរ ហែហមដោយពួកភិក្ខុសង្ឃ ស្តេចទៅផ្ទះរបស់ឧបាសក ប្រថាប់អង្គុយលើអាសនៈដែលគេក្រាលទុកស្រេចហើយ ក្នុងទីបំផុតនៃទក្ខិណោទក ទ្រង់ទទួលបាយយាគូជាដើម ទ្រង់ចែកកត្ត ។ សូម្បីឧបាសកក៏អង្គុយជិតព្រះសាស្តា ។

ក្នុងលំដាប់នោះ ព្រះមហានិសភត្ថេរ ត្រាច់ទៅបិណ្ឌបាតដល់ថ្នល់នោះ ។ ឧបាសកលុះឃើញហើយ ទើបក្រោកឡើងទៅថ្វាយព្រះថេរៈ ហើយពោលថា សូមលោកម្ចាស់ចូរឲ្យបាត្រ ។ ព្រះថេរៈក៏ឲ្យបាត្រ ។ ឧបាសកពោលថា និមន្តលោកម្ចាស់ចូលទៅក្នុងផ្ទះនេះ ។ សូម្បីព្រះសាស្តាក៏ប្រថាប់អង្គុយក្នុងផ្ទះ ។ ព្រះថេរៈពោលថា មិនសមគួរទេឧបាសក ។ ឧបាសកទទួលបាត្ររបស់ព្រះថេរៈហើយ ដាក់បិណ្ឌបាតដរាបពេញនាំទៅប្រគេន ។ បន្ទាប់ពីនោះ ឧបាសកក៏ជូនព្រះថេរៈទៅ ហើយត្រឡប់ទៅអង្គុយក្នុងសម្នាក់របស់ព្រះសាស្តា ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហា-និសត្ថេរ សូម្បីខ្ញុំព្រះអង្គពោលថា ព្រះសាស្តាប្រថាប់អង្គុយក្នុងផ្ទះ ក៏មិនប្រាថ្នានឹងចូលទៅ ។ ព្រះសាស្តាត្រាស់ថា មហានិសភត្ថេរនោះ មានគុណក្រៃលែងជាងគុណរបស់ពួកលោក ។ ក៏សេចក្តីកំណាញ់ ពាក្យសរសើរ

រមែងមិនមានដល់ព្រះសម្ពុទ្ធទាំងឡាយ ។ គ្រានោះ ព្រះសាស្តាទើបត្រាស់យ៉ាងនេះថា ឧបាសក តថាគតប្រថាប់អង្គុយរង់ចាំភិក្ខុក្នុងផ្ទះ ។ ភិក្ខុនោះអង្គុយយ៉ាងនេះមិនក្រឡេកមើលសូម្បីភិក្ខុ ។ តថាគតនៅក្នុងសេនាសនៈចុងស្រុក ។ ភិក្ខុនោះនៅក្នុងព្រៃ ។ តថាគតនៅក្នុងទីប្រក់បាំង ។ ភិក្ខុនោះនៅក្នុងទីវាល ។ ព្រះសាស្តាត្រាស់ ដូចញ៉ាំងមហាសមុទ្រឲ្យពេញថា នេះឯង នេះឯង គុណរបស់ភិក្ខុនោះ ដោយប្រការដូច្នេះ ។

ឧបាសកជ្រះថ្លាក្រៃលែងឡើង ដូចប្រទីបដែលភ្លឺហើយ សូម្បីតាមប្រក្រតីចាក់ប្រេងចូលទៅដូច្នោះ គិតថា ប្រយោជន៍អ្វីដោយសម្បត្តិដទៃដល់យើង ។ យើងនឹងធ្វើសេចក្តីប្រាថ្នា ដើម្បីភាពជាអ្នកប្រសើរជាងភិក្ខុដែលពោលធុតង្គក្នុងសម្នាក់របស់ព្រះពុទ្ធមួយព្រះអង្គក្នុងអនាគត ។ គេនិមន្តព្រះសាស្តាទៀត ថ្វាយទានរហូតអស់ ៧ ថ្ងៃ ដោយទំនងនេះ ក្នុងថ្ងៃទី ៧ ថ្វាយត្រៃចីវរដល់ភិក្ខុ ៦ លាន ៨ សែនរូប ហើយក្រាបចុះទៀបបាទមូលរបស់ព្រះសាស្តា ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ទានដែលខ្ញុំព្រះអង្គថ្វាយរហូតអស់ ៧ ថ្ងៃ ជាទានដែលប្រកបដោយមេត្តាកាយកម្ម មេត្តាវចីកម្ម មេត្តាមនោកម្ម ខ្ញុំព្រះអង្គមិនបានប្រាថ្នាទេវសម្បត្តិ ឬសក្កសម្បត្តិ មារសម្បត្តិ និងព្រហ្មសម្បត្តិយ៉ាងដទៃ ដោយទាននេះ ។ តែកម្ម

របស់ខ្ញុំព្រះអង្គនេះ សូមចូរសម្រេចផលគ្រប់ប្រការនៃភាពជាអ្នកប្រសើរជាងភិក្ខុដែលទ្រទ្រង់ធុតង្គ ១៣ ដើម្បីដល់ឋានន្តរៈដែលព្រះមហានិសភត្ថេរដល់ហើយ ក្នុងសម្នាក់របស់ព្រះពុទ្ធមួយព្រះអង្គក្នុងអនាគតចុះ ។

ព្រះសាស្តាទ្រង់ពិចារណាមើលថា ឋានៈដ៏ធំដែលឧបាសកនេះប្រាថ្នានឹងសម្រេចឬទេហ្ន៎ ទ្រង់ជ្រាបថានឹងសម្រេច ទើបត្រាស់ថា ឋានៈដែលអ្នកប្រាថ្នានឹងបានសម្រេច ។ ក្នុងទីបំផុតមួយសែនកប្បក្នុងអនាគត ព្រះពុទ្ធព្រះនាមថា គោតមនឹងឧប្បត្តិឡើង ។ លោកនឹងជាសាវករូបទី ៣ របស់ព្រះគោតមអង្គនោះ នឹងឈ្មោះថា មហាកស្សបត្ថេរ ។

ឧបាសកបានស្តាប់ដូច្នោះ ត្រិះរិះថា ឈ្មោះថា ព្រះពុទ្ធទាំងឡាយរមែងមិនមានព្រះតម្រាស់ជាពីរ បានសម្គាល់សម្បត្តិនោះ ដូចដល់ក្នុងថ្ងៃស្អែក ។ គេរក្សាសីលរហូតដល់អស់អាយុ លុះធ្វើកាលកិរិយាក្នុងទីនោះបានកើតក្នុងឋានសួគ៌ ។ ចាប់តាំងពីនោះ គេសោយសម្បត្តិក្នុងទេវលោកនិងមនុស្សលោក កាលព្រះវិបស្សីសម្មាសម្ពុទ្ធអាស្រ័យក្រុងពន្ធុមតី ប្រថាប់នៅក្នុងខេមមិគទាយវ័ន ក្នុងកប្បទី ៩១ រាប់អំពីកប្បនេះ (គេ) ចុតិចាកទេវលោក កើតក្នុងត្រកូលព្រាហ្មណ៍ចាស់មួយ ។ ក៏ក្នុងកាលនោះ ព្រះមានព្រះភាគព្រះនាមថា វិបស្សី ទ្រង់សម្តែងធម៌រាល់ៗ ៧ ឆ្នាំ ។ មាន

កោលាហលដ៏ធំ ពួកទេវតារៀងៗ ខ្លួន ក្នុងសកលជម្ពូទ្វីបប្រាប់ដំណឹងតៗ គ្នាថា ព្រះសាស្ដាទ្រង់នឹងសម្ដែងធម៌ ។ ព្រាហ្មណ៍បានស្ដាប់ដំណឹងនោះហើយ ។ តែគេមានសំពត់សាដកសម្រាប់ស្លៀកតែមួយផ្ទាំង ។ របស់ព្រាហ្មណីក៏ដូចគ្នា ។ ទាំងពីរនាក់ មានសំពត់ដណ្ដប់តែមួយផ្ទាំងប៉ុណ្ណោះ ។ ប្រាកដទូទៅទាំងក្រុងថា **ឯកសាដកព្រាហ្មណ៍** ។ កាលមានការប្រជុំគ្នាដោយកិច្ចយ៉ាងមួយរបស់ពួកព្រាហ្មណ៍ គេទៅដោយខ្លួនឯង ឲ្យនាងព្រាហ្មណីនៅចាំផ្ទះ ។ កាលមានការប្រជុំខាងនាងព្រាហ្មណី គេក៏នៅផ្ទះឯង ។ នាងព្រាហ្មណីដណ្ដប់សំពត់ផ្ទាំងនោះទៅ ។ ក៏ក្នុងថ្ងៃនោះ ព្រាហ្មណ៍ពោលនឹងនាងព្រាហ្មណីថា នាងដ៏ចម្រើន នាងនឹងស្ដាប់ធម៌ពេលយប់ ឬពេលថ្ងៃ ។ នាងព្រាហ្មណីនិយាយថា ខ្ញុំជាមាតុគ្រាម មិនអាចនឹងស្ដាប់ធម៌ក្នុងវេលាយប់បាន ។ ខ្ញុំនឹងស្ដាប់ធម៌ក្នុងវេលាថ្ងៃ ទើបឲ្យព្រាហ្មណ៍នៅចាំផ្ទះ ដណ្ដប់សំពត់ផ្ទាំងនោះ ទៅជាមួយនឹងពួកឧបាសិកាក្នុងវេលាថ្ងៃ ថ្វាយបង្គំព្រះសាស្ដាអង្គុយស្ដាប់ធម៌ក្នុងទីដ៏សមគួរមួយ ហើយត្រឡប់ទៅជាមួយនឹងពួកឧបាសិកា ។ គ្រានោះ ព្រាហ្មណ៍ឲ្យនាងព្រាហ្មណីនៅចាំផ្ទះ ដណ្ដប់សំពត់នោះទៅវិហារ ។

ក៏សម័យនោះ ព្រះសាស្ដាប្រថាប់អង្គុយក្នុងធម្មាសនៈដែលតាក់តែងហើយក្នុងកណ្ដាលបរិស័ទ ទ្រង់ចាប់ផ្លិតវីជនីដ៏វិចិត្រ ត្រាស់ធម្មកថា ដូច

ញ៉ាំងបុគ្គលវិសេសឲ្យឈានចុះកាន់អាកាសគង្គា ដូចធ្វើកំពូលភ្នំសិនេរុឲ្យរលំចុះកាន់សាគរ ។ កាលព្រាហ្មណ៍អគ្គិយនៅបំផុតជួរ ស្តាប់ធម៌ហើយក្នុងយាមដើមនោះឯង បីតិមានវណ្ណៈ ៥ កើតជ្រួតជ្រាបពេញទាំងខ្លួន ។ គេបត់សំពត់ដណ្តប់ គិតថា យើងនឹងថ្វាយចំពោះព្រះទសពល ។

លំដាប់នោះ គេកើតចិត្តកំណាញ់ ចង្អុលដល់ទោសពាន់ដួង ។ សំពត់របស់នាងព្រាហ្មណី និងរបស់យើងមានតែមួយផ្ទាំងប៉ុណ្ណោះ ។ មិនមានសំពត់ដណ្តប់ណាៗ ដទៃទៀត ។ កាលមិនដណ្តប់ហើយ ក៏មិនអាចនឹងចេញទៅខាងក្រៅបាន ព្រោះដូច្នោះ ទើបមិនប្រាថ្នានឹងថ្វាយសូម្បីដោយប្រការទាំងពួង ។ លុះបឋមយាមកន្លងទៅ សូម្បីក្នុងមជ្ឈិមយាម គេក៏កើតបីតិយ៉ាងនោះទៀត ។ ក៏គ្រាគិតដូចយ៉ាងនោះហើយ ក៏មិនប្រាថ្នានឹងថ្វាយ ដូចយ៉ាងនោះទៀត ។ កាលមជ្ឈិមយាមកន្លងទៅ សូម្បីក្នុងបច្ឆិមយាម គេក៏កើតបីតិយ៉ាងនោះទៀត ។ គេគិតថា ស្លាប់ ឬមិនស្លាប់ក៏ដោយចុះ ។ យើងនឹងដឹងក្នុងខាងក្រោយ ទើបបត់សំពត់ដណ្តប់ ដាក់ទុកត្រង់បាទមូលរបស់ព្រះសាស្តា បន្ទាប់ពីនោះ គេយកដៃឆ្វេង ទះដៃស្តាំ បន្លឺសម្លេងថា យើងឈ្នះហើយ យើងឈ្នះហើយ ដល់ ៣ គ្រា ។

សម័យនោះ ព្រះបាទពន្ធុមហារាជ ទ្រង់ប្រថាប់អគ្គិយស្តាប់ធម៌នៅ

ខាងក្នុងវាំងននខាងក្រោយធម្មាសនៈ ។ ក៏ធម្មតាព្រះរាជា រមែងមិនពេញព្រះទ័យថា យើងឈ្នះហើយ យើងឈ្នះហើយ ដូច្នេះ ។

ព្រះអង្គទ្រង់បញ្ជូនរាជបុរសទៅ មានព្រះតម្រាស់ថា អ្នកចូរទៅសួរព្រាហ្មណ៍នោះថា លោកនិយាយអ្វី ។ បុរសនោះទៅសួរថា លោកនិយាយអ្វី ។

លុះបុរសនោះទៅសួរហើយ ព្រាហ្មណ៍និយាយថា ពួកជនដ៏សេសឡើងយានដំរីជាដើម ហើយឈ្នះសត្រូវ ប្រការនោះមិនអស្ចារ្យឡើយ ។

ក៏យើងលះបង់ចិត្តកំណាញ់ បានថ្វាយសំពត់ដណ្តប់ចំពោះព្រះទសពល ដូចយកឈើអន្ទង់ដំក្បាលគោកាចដែលដើរមកខាងក្រោយ ហើយឲ្យវាគេចចេញទៅ ដូច្នោះ ។

ព្រាហ្មណ៍ពោលថា យើងឈ្នះសេចក្តីកំណាញ់នោះ ។

រាជបុរសត្រឡប់មកក្រាបទូលរឿងនោះចំពោះព្រះរាជា ទ្រង់ត្រាស់ថា នាយ យើងមិនដឹងវត្ថុសមគួររបស់ព្រះទសពល ព្រាហ្មណ៍ជាអ្នកដឹង ទើបទ្រង់បញ្ជូនសំពត់ទៅមួយគូ ។

ព្រាហ្មណ៍ឃើញសំពត់គូនោះទើបគិតថា ព្រះរាជាអង្គនេះ មិនព្រះរាជទានអ្វីៗ ដល់យើងអ្នកអង្គុយស្ងៀមនោះ កាលយើងពោលដល់គុណ

របស់ព្រះសាស្តាហើយ ទើបព្រះរាជទាន ។ ប្រយោជន៍អ្វីដល់យើងដោយសំពត់ដែលកើតឡើងព្រោះអាស្រ័យគុណរបស់ព្រះសាស្តា ទើបបានថ្វាយសំពត់គូនោះ ចំពោះព្រះទសពលទៀត ។

ព្រះរាជាត្រាស់សួរថា ព្រាហ្មណ៍ធ្វើអ្វី ស្តាប់ថា ព្រាហ្មណ៍ថ្វាយសំពត់គូនោះចំពោះព្រះសាស្តា ទើបទ្រង់បញ្ជូនសំពត់ ២ គូដទៃទៅឲ្យ ។

ព្រាហ្មណ៍ក៏បានថ្វាយសំពត់ ២ គូនោះទៀត ។ ព្រះរាជាទ្រង់បញ្ជូនសំពត់ទៅទៀត ៤ គូ ដរាបដល់ ៣២ គូ ។

គ្រានោះ ព្រាហ្មណ៍គិតថា គូសំពត់នេះមើលទៅដូចជានឹងបន្ថែមចំនួនច្រើនឡើង ទើបកាន់យកត្រឹមតែ ២ គូ គឺ ដើម្បីខ្លួនមួយគូ ដើម្បីនាងព្រាហ្មណីមួយគូ បានថ្វាយចំពោះព្រះសាស្តា ៣០ គូ តាំងពីនោះមក ព្រាហ្មណ៍នោះបានស្និទស្នាលនឹងព្រះសាស្តា ។

ថ្ងៃមួយក្នុងរដូវត្រជាក់ ព្រះរាជាទ្រង់ឃើញព្រាហ្មណ៍នោះស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ទើបព្រះរាជទានសំពត់កម្ពលពណ៌ក្រហមដែលព្រះអង្គដណ្តប់ មានតម្លៃមួយសែន ហើយត្រាស់ថា តាំងពីនេះទៅ លោកចូរដណ្តប់សំពត់ផ្ទាំងនេះ ស្តាប់ធម៌ ។ គេគិតថា ប្រយោជន៍អ្វីដល់យើងដោយសំពត់កម្ពលផ្ទាំងនេះដែលនឹងនាំចូលទៅក្នុងកាយស្អុយនេះ ទើបធ្វើ

ជាពិតានខាងលើគ្រែរបស់ព្រះតថាគតខាងក្នុងព្រះគន្ធកុដិ ហើយទើបទៅ ។

ថ្ងៃមួយ ព្រះរាជាស្តេចទៅវិហារពីព្រឹកព្រលឹម ប្រថាប់អង្គុយក្នុងសម្នាក់របស់ព្រះសាស្តា ខាងក្នុងព្រះគន្ធកុដិ ។ សម័យនោះ ព្រះពុទ្ធរស្មីមានពណ៌ ៦ ប្រការប៉ះខ្ទប់សំពត់កម្ពល ។ សំពត់កម្ពលរុងរឿងក្រៃលែងណាស់ ។ ព្រះរាជាទ្រង់មើលទៅខាងលើទ្រង់ចាំបាន ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់កម្ពលផ្ទាំងនេះរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គបានឲ្យដល់ឯកសាដកព្រាហ្មណ៍ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ព្រះអង្គបូជាព្រាហ្មណ៍ហើយ ឯព្រាហ្មណ៍បូជាតថាគត ។ ព្រះរាជត្រិះរិះថា ព្រាហ្មណ៍បានដឹងវត្ថុដែលគួរ យើងមិនដឹង ។ ទ្រង់ជ្រះថ្លា ហើយទ្រង់ធ្វើវត្ថុដែលជួយឧបត្ថម្ភមនុស្សទាំងអស់ ឲ្យវត្ថុមួយមុខៗ ៨ ព្រះរាជទានមួយៗ ៨ ទាំងអស់ ហើយទ្រង់តែងតាំងព្រាហ្មណ៍ក្នុងតំណែងបុរោហិត ។ ឈ្មោះថាទានមួយមុខៗ ៨ រួមជា ៦៤ ។ គេបង្អោននាំស្លាកភត្ត ៦៤ រក្សាសីល ចុតិអំពីនោះទៅកើតក្នុងឋានសួគ៌ ។ លុះចុតិអំពីនោះ បានកើតក្នុងផ្ទះកុដុម្ពីក្នុងក្រុងពារាណសី ក្នុងចន្លោះព្រះពុទ្ធ ២ ព្រះអង្គ គឺ ព្រះមានព្រះភាគព្រះនាមថា **កោនាគមនៈ** និងព្រះទសពលព្រះនាមថា **កស្សបៈ** ក្នុងកប្បនេះ ។ គេអាស្រ័យសេចក្តីចម្រើននៅគ្រប់គ្រងផ្ទះ ថ្ងៃមួយត្រាច់ទៅជង្ឃវិហារ ក្នុង

ព្រៃ ។

ក៏សម័យនោះ ព្រះបច្ចេកពុទ្ធធ្វើចីវរកម្មនៅក្នុងត្រើយទន្លេ កាល អនុវាតចីវរមិនល្មម ទើបប្រារព្ធដើម្បីនឹងបត់ទុក ។ គេឃើញ ទើបសួរថា ព្រោះហេតុអ្វី លោកម្ចាស់ទើបបត់ទុក ។ ព្រះបច្ចេកពុទ្ធឆ្លើយថា អនុវាត មិនល្មម ។ គេពោលថា សូមលោកម្ចាស់ចូរធ្វើដោយសំពត់ផ្ទាំងនេះចុះ ។ ហើយថ្វាយសំពត់សាដក តាំងសេចក្តីប្រាថ្នាថា ចូរឲ្យខ្ញុំកុំមានសេចក្តីសាប-សូន្យណាៗ ក្នុងទីដែលខ្ញុំទៅកើតចុះ ។ ក្នុងផ្ទះកាលប្អូនក្រមុំរបស់គេឈ្លោះគ្នាជាមួយនឹងភរិយា ពេលព្រះបច្ចេកពុទ្ធចូលទៅបិណ្ឌបាត ។ លំដាប់នោះ ប្អូនក្រមុំរបស់គេថ្វាយបិណ្ឌបាតចំពោះព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្តី ប្រាថ្នាថា យើងគប្បីវៀរជនពាលបែបនេះទៅ ១០០ យោជន៍ នាងពោល យ៉ាងនេះ សំដៅដល់ភរិយារបស់ព្រាហ្មណ៍នោះ ។ ភរិយាឈរត្រង់ទ្វារផ្ទះ លុះបានឮ ទើបគិតថា ព្រះបច្ចេកពុទ្ធកុំឆាន់ភត្តដែលស្រីនេះថ្វាយនៅឡើយ ទើបទទួលបាត្រមក ចាក់បិណ្ឌបាតចេញ យកភក់មកដាក់ដាបពេញ ហើយ ថ្វាយ ។ ប្អូនក្រមុំឃើញ ទើបនិយាយថា ស្ត្រីពាល អ្នកឯងចូរជេរ ឬវាយ តប់យើងក៏បាន តែអ្នកឯងមិនគួរចាក់ភត្តអំពីបាត្ររបស់លោកអ្នកបំពេញ បារមីមករហូតអស់ ២ អសង្ខេយ្យ ១ សែនកប្ប ហើយដាក់ភក់ថ្វាយទេ ។

ពេលនោះ ភរិយារបស់គេទើបកើតការគិតឡើង ។ នាងពោលថា ឈប់សិនលោកម្ចាស់ ហើយចាក់កក់ លាងបាត្រ ខាស់ដោយកម្ទេចផង់ក្រអូប ហើយដាក់អាហារដែលមានរសឆ្ងាញ់ ៤ ប្រភេទ ដកាបពេញបាត្រ ដាក់បាត្រដែលពោរពេញដោយសប្បិ មានពណ៌ដូចត្របកផ្កាឈូក ដែលរោយទុកខាងលើ ក្នុងដៃរបស់ព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្តីប្រាថ្នាថា សូមរាងកាយរបស់ខ្ញុំចូរមានពន្លឺដូចបិណ្ឌបាតនេះ ដែលមានពន្លឺចុះ ។ ព្រះបច្ចេកពុទ្ធអនុមោទនាហើយហោះទៅកាន់អាកាស ។ ភរិយាស្វាមីបំពេញកុសលរហូតអស់អាយុ បានកើតក្នុងឋានសួគ៌ លុះចុតិចាកសួគ៌ ឧបាសកបានកើតជាបុត្ររបស់សេដ្ឋី មានសម្បត្តិ ៨០ កោដិ ក្នុងក្រុងពារាណសី ។ ចំណែកភរិយា បានកើតជាធីតារបស់សេដ្ឋីដូចគ្នាដែរ ។ មាតាបិតាបាននាំធីតាសេដ្ឋីនោះឯង មកឲ្យដល់បុត្រសេដ្ឋីដែលចម្រើនវ័យ ។ ត្រឹមតែកាលសេដ្ឋីធីតាចូលទៅកាន់ត្រកូលស្វាមី ដោយអានុភាពនៃកម្មដែលជាផលដែលនាងមិនថ្វាយទានមកមុន សកលកាយក៏កើតក្លិនស្អុយដូចបង្គន់ដែលគេបើកចំហ ។ សេដ្ឋីកុមារសួរថា នេះក្លិនរបស់អ្នកណា លុះបានស្តាប់ហើយ ជាក្លិនរបស់សេដ្ឋីធីតា ទើបពោលឡើងថា ចូរនាំចេញទៅ ចូរនាំចេញទៅ ហើយបញ្ជូនឲ្យត្រឡប់ទៅកាន់ផ្ទះត្រកូល ដោយទំនងនោះឯង ដូចដែលនាំ

មក ។ សេដ្ឋីធីតាត្រូវបញ្ជូនឲ្យត្រឡប់ទៅអស់ ៧ ដង ដោយទំនងនេះឯង គិតថា យើងត្រឡប់ទៅដល់ ៧ ដងហើយ យើងនឹងទៅធ្វើអ្វី ទើបរំលាយគ្រឿងអាភរណៈរបស់ខ្លួនឲ្យធ្វើឥដ្ឋមាស ប្រវែងបណ្តោយ ១ ហត្ថ ទទឹង ១ ចំអាម កម្ពស់ ៤ ធ្នាប់ ។ បន្ទាប់ពីនោះ នាងកាន់ដុំថ្មហរិតាល និងមនោសិលា ហើយកាន់ផ្កាឈូក ៨ ក្តាប់ ទៅកាន់ទីសាងចេតិយរបស់ព្រះកស្សបទសពល ។

ក៏ក្នុងខណៈនោះ កាលនាងមកដល់ ដុំឥដ្ឋបានធ្លាក់ចុះមក ។ សេដ្ឋីធីតាទើបប្រាប់ចំពោះជាងថា លោកចូរដាក់ឥដ្ឋដុំនេះទុកត្រង់នេះ ។ ជាងពោលថា ម៉ែម្ចាស់ដ៏ចម្រើន កាលវេលាម៉ែម្ចាស់ដល់ហើយ ។ នាងឡើងទៅយកប្រេងផ្សំជាមួយថ្មហរិតាល និងមនោសិលា កឥដ្ឋឲ្យណែនដោយថ្មហរិ-តាល និងមនោសិលាដែលផ្សំដោយប្រេងនោះ ធ្វើការបូជាដោយផ្កាឈូក ៨ ក្តាប់ខាងលើ ហើយថ្វាយបង្គំ ធ្វើសេចក្តីប្រាថ្នាថា សូមកុំិនចន្ទន៍ចូរផ្សាយចេញពីមាត់ក្នុងទីដែលកើតចុះ ហើយថ្វាយបង្គំព្រះចេតិយ ធ្វើប្រទក្សិណត្រឡប់ទៅ ។

ក្នុងខណៈនោះ សេដ្ឋីបុត្រវឭកដល់សេដ្ឋីធីតាដែលនាំទៅកាន់ផ្ទះក្នុងគ្រាដំបូង ។

សូម្បីក្នុងនគរ ក៏មានការប្រកាសលេងនក្ខត្តឫក្ស ។ សេដ្ឋីបុត្តសួរអ្នកបម្រើថា សេដ្ឋីធីតាដែលនាំទៅកាលនោះ នាងនៅទីណា ។ អ្នកបម្រើឆ្លើយថា នៅក្នុងផ្ទះត្រកូលលោកម្ចាស់ ។ សេដ្ឋីបុត្រពោលថា ពួកអ្នកឯងចូរនាំមក យើងនឹងលេងនក្ខត្តឫក្សនោះ ។ ពួកបម្រើនាំគ្នាទៅឈរសំពះសេដ្ឋីធីតា សេដ្ឋីធីតាពោលថា ពួកលោកមកធ្វើអ្វី ទើបប្រាប់រឿងរ៉ាវឲ្យនាងស្តាប់ ។ សេដ្ឋីធីតាពោលថា នែ៎បា យើងយកគ្រឿងអាភរណៈបូជាព្រះចេតិយអស់ហើយ យើងមិនមានអាភរណៈ ។ អ្នកបម្រើនាំគ្នាទៅប្រាប់ដល់សេដ្ឋីបុត្រ សេដ្ឋីបុត្រពោលថា ពួកអ្នកចូរនាំនាងមកចុះ ។ យើងនឹងឲ្យគ្រឿងប្រដាប់ ។ អ្នកបម្រើនាំនាងមកហើយ ។ ព្រមពេលដែលនាងចូលទៅកាន់ផ្ទះ ក្លិនចន្ទន៍ និងក្លិនផ្កាឈូក ផ្សាយទៅរហូតពេញផ្ទះ ។ សេដ្ឋីបុត្រសួរសេដ្ឋីធីតាថា គ្រាដំបូងក្លិនស្អុយផ្សាយចេញពីរាងកាយរបស់នាង ។ តែឥឡូវនេះ ក្លិនចន្ទន៍ផ្សាយចេញពីរាងកាយ ក្លិនផ្កាឈូកផ្សាយចេញពីមាត់របស់នាង ។ តើមានរឿងអ្វី ។ នាងបានប្រាប់កម្មដែលនាងធ្វើតាំងពីដើម ។ សេដ្ឋីបុត្រជ្រះថ្លាថា ពាក្យទូន្មានរបស់ព្រះពុទ្ធទាំងឡាយ ជាពាក្យទូន្មានដែលនាំចេញចាកទុក្ខហ្ន៎ ទើបយកអាវកម្ពលគ្របចេតិយមាស ប្រកបដោយផ្កាបទុមមាស ប្រមាណប៉ុនកង់រថក្នុងទីនោះ ព្យួរសំយ៉ុងចុះមកប្រមាណ ១២-

១៣ ហត្ថ ។

សេដ្ឋីបុត្រនោះ តាំងនៅក្នុងទីនោះដរាបអស់អាយុ ហើយទៅកើតក្នុងឋានសួគ៌ ចុតិអំពីនោះ ទៅកើតក្នុងត្រកូលអាមាត្រមួយក្នុងទីប្រមាណ ១០០ យោជន៍ ពីក្រុងពារាណសី ។ សេដ្ឋីជីតាចុតិអំពីទេវលោក ទៅកើតជារាជជីតាក្នុងរាជត្រកូល ។ កាលបុគ្គលទាំងពីរចម្រើនវ័យ ជិតស្រុកដែលកុមារនៅបាន មានការប្រកាសលេងនក្ខត្តឫក្ស ។ កុមារនិយាយចំពោះមាតាថា ម៉ែ ម៉ែឲ្យសំពត់សាដកដល់ខ្ញុំមក ។ ខ្ញុំនឹងលេងនក្ខត្តឫក្ស ។ មាតានាំសំពត់ដែលបោកហើយមកឲ្យ ។ កុមារបានបដិសេធសំពត់ផ្ទាំងនោះ ។ មាតានាំសំពត់ផ្ទាំងដទៃមកឲ្យទៀត ។ កុមារបដិសេធសំពត់ផ្ទាំងនោះទៀត ។

លំដាប់នោះ មាតានិយាយចំពោះកុមារនោះថា កូនអើយ យើងកើតក្នុងផ្ទះណា យើងមិនមានបុណ្យដើម្បីនឹងបានសំពត់សាច់ល្អិតជាងនោះ ។ កុមារពោលថា ម៉ែ កូននឹងទៅទីដែលរកបាន ។ មាតាពោលថា កូនអើយ ម៉ែប្រាថ្នានឹងឲ្យកូនបានរាជសម្បត្តិក្នុងក្រុងពារាណសីក្នុងថ្ងៃនេះឯង ។ កុមារនោះ ថ្វាយបង្គំមាតាហើយពោលថា ម៉ែ កូននឹងទៅហើយណា៎ ។ មាតាពោលថា ទៅចុះកូន ។ ន័យថា មាតាមានសេចក្ដីគិតយ៉ាងនេះថា កុមារនេះនឹងទៅក្នុងទីណា នឹងដេកក្នុងទីនេះ ឬក្នុងផ្ទះនេះ ។ ក៏កុមារនោះចេញទៅ

ដោយការកំណត់របស់បុណ្យ ទៅដល់ក្រុងពារាណសី ដេកគ្របសីសៈលើផ្ទាំងមង្គលសិលាក្នុងព្រះឧទ្យាន ។ មួយវិញទៀត កាលព្រះបាទក្រុងពារាណសីសោយទីវង្គត ថ្ងៃនោះជាថ្ងៃទី ៧ ។ ពួកអាមាត្យលុះថ្វាយព្រះភ្លើងសាកសពរបស់ព្រះរាជាហើយ ទើបអង្គុយប្រឹក្សាគ្នាក្នុងព្រះរាជវាំងថា ព្រះរាជាមានព្រះធីតាតែមួយអង្គប៉ុណ្ណោះ មិនមានព្រះឱរស រាជសម្បត្តិដែលមិនមានព្រះរាជា នឹងតាំងនៅមិនបាន អ្នកណានឹងជាព្រះរាជា ព្រោះដូច្នោះសូមលោកចូរប្រឹក្សាគ្នាមើលចុះ ។ បុរោហិតពោលថា មិនគួរគិតច្រើនទេ ។ យើងនឹងផ្សងបុស្សរាជរថ ។ ពួកអាមាត្យទឹមសេះសិន្ធព ៤ ក្បាល មានពណ៌ស តាំងគ្រឿងរាជកកុធភ័ណ្ឌ (គ្រឿងប្រដាប់សម្រាប់គ្រងរាជ) ៥ យ៉ាងនិងស្វេតឆត្រទុកលើរថ ហើយព្រលែងរថ ឲ្យប្រគំតន្ត្រីទៅតាមក្រោយ ។ រាជរថចេញតាមទ្វារផ្នែកខាងលិច បែរមុខទៅព្រះរាជឧទ្យាន ។ រាជរថបែរមុខទៅព្រះរាជឧទ្យានដោយបុណ្យបារមី ។ ពួកអាមាត្យខ្លះប្រាប់ថា ពួកយើងត្រឡប់មកវិញ ។ បុរោហិតប្រាប់ថា ពួកលោកកុំត្រឡប់ ។ រាជរថបានធ្វើប្រទក្សិណកុមារ ហើយក៏ឈប់ ជាការត្រៀមឲ្យកុមារឡើង ។ បុរោហិតទាញជាយសំពត់ដណ្តប់ចេញ សម្លឹងមើលបាតជើង ពោលថា ទ្វីបនេះលើកទុកសិន កុមារនេះគួរគ្រងរាជសម្បត្តិក្នុងទ្វីបទាំង ៤ មានទ្វីបតូច ២,០០០

ជាបរិវារ ហើយឲ្យប្រគំតន្ត្រី ៣ ដង ថា ពួកលោកចូរប្រគំទៀត ពួកលោកចូរប្រគំទៀត ។

លំដាប់នោះ កុមារបើកមុខសម្លឹងមើល ហើយសួរថា នែ៎អ្នកទាំងឡាយ ពួកលោកមកធ្វើអ្វី ។ ឆ្លើយថា អ្នកដ៏ចម្រើន រាជសម្បត្តិនឹងមានដល់អ្នក ។ សួរថា ព្រះរាជារបស់ពួកលោកទៅណា ។ ឆ្លើយថា សោយទិវង្គត់ហើយ លោក ។

សួរថា ប៉ុន្មានថ្ងៃហើយ ។ ឆ្លើយថា ៧ ថ្ងៃក្នុងថ្ងៃនេះ ។ សួរថា ព្រះឱរស ឬព្រះធីតាមិនមានឬ ។ ឆ្លើយថា មានតែព្រះធីតា មិនមានព្រះ-ឱរស លោកដ៏ចម្រើន ។ កុមារទទួលថា យើងនឹងគ្រងរាជសម្បត្តិ ។ ពួកអាមាត្រសាងមណ្ឌបសម្រាប់អភិសេកមុន ប្រដាប់ព្រះរាជធីតាដោយគ្រឿងប្រដាប់គ្រប់ប្រភេទ ហើយនាំមកកាន់ព្រះរាជឧទ្យាន បានធ្វើអភិសេកព្រះកុមារ ។ លំដាប់នោះ ពួកអាមាត្របាននាំសំពត់តម្លៃមួយសែន បង្អោនថ្វាយចំពោះព្រះកុមារ ហើយបានធ្វើការអភិសេក ។ ព្រះកុមារត្រាស់សួរថា អ្វីនេះ ។ ទូលថា សំពត់ស្លៀកព្រះអង្គ ។ ត្រាស់សួរថា ជាសំពត់សាច់គ្រោតគ្រាតមិនមែនឬ ។ ទូលថា បណ្តាសំពត់ដែលពួកមនុស្សប្រើប្រាស់ មិនមានសំពត់សាច់ល្អិតល្អន់ជាងនេះទេ ព្រះអង្គ ។ ត្រាស់សួរថា ព្រះរាជារបស់ពួកលោក

ស្លៀកសំពត់យ៉ាងនេះឬ ។ ទូលថា មែនហើយព្រះអង្គ ។ ត្រាស់ថា ព្រះរាជារបស់ពួកលោក គង់នឹងមិនមានបុណ្យ ។ ពួកអាមាត្រនាំព្រះកុណ្ឌីមាសមកថ្វាយ ។ ព្រះកុមារស្តេចក្រោកឡើងជម្រះព្រះហស្ថទាំងពីរ ទ្រង់ខ្ពុរព្រះឱស្ឋហើយ ទ្រង់បៀមទឹកព្រួសទៅទិសខាងកើត ។ ដើមកល្បព្រឹក្ស ៨ ដើម ទម្លាយផែនដីដ៏ក្រាស់ផុសឡើង ។ ព្រះកុមារទ្រង់បៀមទឹកព្រួសទៅទិសត្បូង ទិសខាងលិច ទិសខាងជើងទៀត ព្រោះហេតុនោះ ដើមកល្ប-ព្រឹក្សផុសឡើងហើយទាំង ៤ ទិស យ៉ាងនេះ ។ ក្នុងគ្រប់ទិស ដើមកល្ប-ព្រឹក្សផុសឡើងក្នុងមួយទិស ៨ ដើម ទើបរួមជា ៣២ ដើម ។ ព្រះកុមារទ្រង់ស្លៀកសំពត់ទិព្វមួយផ្ទាំង ទ្រង់ដណ្តប់មួយផ្ទាំង ត្រាស់ថា ពួកលោកចូរវាយស្គរ ប្រកាសក្នុងដែនរបស់ព្រះបាទនន្ទៈថា ពួកស្រីរវៃអំបោះ កុំរវៃអំបោះ ហើយឲ្យលើកឆត្រ ទ្រង់ឡើងជិះដំរីដ៏ប្រសើរ ដែលប្រដាប់តាក់តែងហើយ ស្តេចចូលកាន់ព្រះនគរ ទ្រង់ឡើងកាន់ប្រាសាទសោយមហា-សម្បត្តិ ។

កាលកន្លងទៅដោយប្រការដូច្នេះ ថ្ងៃមួយ ព្រះទេវីទ្រង់ឃើញសម្បត្តិរបស់ព្រះរាជា ទ្រង់សម្តែងអាការនៃសេចក្តីករុណាថា ឱ! អ្នកមានតបៈ ។ ត្រាស់សួរថា អ្វីព្រះទេវី ។ ទូលថា សម្បត្តិធំក្រៃលែង ណាស់ព្រះអង្គ ក្នុង

អតីត ព្រះអង្គជឿព្រះពុទ្ធ បានធ្វើសេចក្តីល្អ ឥឡូវនេះ ព្រះអង្គមិនធ្វើកុសលដែលជាបច្ច័យនៃអនាគត ។ ត្រាស់សួរថា យើងនឹងឲ្យដល់អ្នកណា ។ អ្នកមានសីលក៏មិនមាន ។ ទូលថា ព្រះអង្គ ជម្ពូទ្វីប មិនទទេចាកព្រះអរហន្តឡើយ ។ សូមព្រះអង្គទ្រង់ត្រៀមទានទុក នាងខ្ញុំនឹងបាន (និមន្ត) ព្រះអរហន្តមក ។ ក្នុងថ្ងៃស្អែក ព្រះរាជាត្រាស់បង្គាប់ឲ្យត្រៀមទានក្នុងទ្វារទិសខាងកើត ។ ព្រះទេវីទ្រង់អធិដ្ឋានអង្គឧបោសថពីព្រឹកព្រលឹម បែរមុខទៅទិសខាងកើតខាងលើប្រាសាទ ក្រាបចុះពោលថា បើព្រះអរហន្តមាននៅក្នុងទិសនេះ សូមព្រះអរហន្តទាំងឡាយចូរមកទទួលភិក្ខាររបស់ពួកខ្ញុំ ក្នុងថ្ងៃស្អែកនេះចុះ ។ ក្នុងទិសនោះ មិនមានព្រះអរហន្ត បានឲ្យសក្ការៈនោះដល់មនុស្សកំព្រា និងយាចក ។ ក្នុងថ្ងៃស្អែក ព្រះទេវីបានត្រៀមទានផ្នែកទិសខាងត្បូងហើយធ្វើដូច្នោះ ។ ក្នុងថ្ងៃស្អែក ព្រះទេវីបានត្រៀមទានក្នុងទិសខាងលិចហើយធ្វើដូច្នោះ ។

ក៏ក្នុងថ្ងៃដែលព្រះនាងត្រៀមទានក្នុងទិសខាងជើង ព្រះបច្ចេកពុទ្ធព្រះនាមថា **មហាបទុម** ទ្រង់ជាធំជាងព្រះបច្ចេកពុទ្ធ ៥០០ បុត្ររបស់នាងបទុមវតី នៅក្នុងហិមវន្ត ដែលព្រះទេវីនិមន្តហើយ បានហៅព្រះបច្ចេកពុទ្ធជាប្អូនមកពោលថា លោកអ្នកនិទុក្ខទាំងឡាយ ព្រះរាជានន្ទៈទ្រង់និមន្តពួក

លោក សូមពួកលោកចូរទទួលនិមន្តព្រះអង្គចុះ ។ ព្រះបច្ចេកពុទ្ធទាំងនោះទទួលនិមន្តហើយ ថ្ងៃស្អែកទ្រង់លុះបលាងមុខត្រង់អនោតត្តស្រះ ហោះមកចុះក្នុងត្រង់ទ្វារទិសខាងជើង ។ ពួកមនុស្សនាំគ្នាទៅក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបច្ចេកពុទ្ធ ៥០០ មកហើយ ព្រះអង្គ ។ ព្រះរាជាព្រមនឹងព្រះទេវីស្តេចយាងទៅ ទ្រង់ថ្វាយបង្គំ ហើយទទួលបាត្រ និមន្តព្រះបច្ចេកពុទ្ធឲ្យឡើងលើប្រាសាទ ហើយទ្រង់ថ្វាយទានដល់ព្រះបច្ចេកពុទ្ធទាំងឡាយលើប្រាសាទនោះ ហើយទ្រង់ថ្វាយទានដល់ព្រះបច្ចេកពុទ្ធទាំងឡាយលើប្រាសាទនោះ លុះសម្រេចភត្តកិច្ចហើយ ព្រះរាជាទ្រង់ក្រាបត្រង់បាទមូលរបស់ព្រះសង្ឃត្ថេរ ព្រះទេវីទ្រង់ក្រាបទៀបបាទមូលរបស់ព្រះសង្ឃនវកៈទ្រង់បានធ្វើបដិញ្ញាថា លោកម្ចាស់ទាំងឡាយនឹងមិនលំបាកដោយបច្ច័យ ខ្ញុំទាំងឡាយនឹងមិនសាបសូន្យចាកបុណ្យ សូមលោកម្ចាស់ទាំងឡាយចូរឲ្យបដិញ្ញាដើម្បីនៅក្នុងទីនេះរហូតអស់ជីវិតដល់ពួកខ្ញុំទាំងឡាយចុះ ហើយទ្រង់សាងទីនៅ ដោយអាការទាំងពួង គឺ បណ្ណសាលា ៥០០ ទីចង្រ្កម ៥០០ ក្នុងព្រះឧទ្យាន ។ ហើយអារាធនាព្រះបច្ចេកពុទ្ធឲ្យប្រថាប់នៅក្នុងទីនោះ ។ កាលកន្លងទៅយ៉ាងនេះ ដាយដែនរបស់ព្រះរាជាក៏កម្រើក ។ ព្រះរាជាត្រាស់បង្គាប់ចំពោះព្រះទេវីថា ខ្ញុំនឹងទៅធ្វើដាយដែនឲ្យស្ងប់ នាងចូរកុំប្រមាទក្នុង

ព្រះបច្ចេកពុទ្ធទាំងឡាយ ហើយស្តេចក៏យាងទៅ ។ កាលព្រះរាជាស្តេចមិនទាន់មក អាយុសង្ខាររបស់ព្រះបច្ចេកពុទ្ធទាំងឡាយអស់ទៅ ។

ព្រះបច្ចេកពុទ្ធនាមមហាបទុម ចូលឈានរហូតអស់ ៣ យាមក្នុងរាត្រី កាលអរុណរះ ឈរផ្អែកក្តារបរិនិព្វាន ដោយនិព្វានធាតុ ដែលជាអនុបាទិសេស ។

សូម្បីព្រះបច្ចេកពុទ្ធដ៏សេស ក៏បរិនិព្វានដោយឧបាយនេះ ។ ក្នុងថ្ងៃស្អែក ព្រះទេវីត្រាស់បង្គាប់ឲ្យធ្វើទីអង្គុយរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ លាបដោយរបស់ខៀវ ចាក់រោយផ្កាឈើ ធ្វើការបូជា អង្គុយក្រឡេកមើលព្រះបច្ចេកពុទ្ធទាំងឡាយមក កាលមិនឃើញមក ទើបទ្រង់បញ្ជូនរាជបុរសទៅថា លោកចូរទៅ ចូរជ្រាបថា លោកម្ចាស់ទាំងឡាយមិនសប្បាយ ឬយ៉ាងណា ។ រាជបុរសទៅបើកទ្វារបណ្ណសាលារបស់ព្រះបច្ចេកពុទ្ធមហាបទុម កាលមិនឃើញក្នុងទីនោះ ទើបទៅកាន់ទីចង្ក្រម ឃើញលោកឈរផ្អែកក្តារថ្វាយបង្គំ ហើយពោលថា ដល់វេលាហើយលោកម្ចាស់ ។ រាងកាយរលត់ហើយ នឹងនិយាយបានដូចម្តេច ។ រាជបុរសគិតថា លោកសឹងលក់ ទើបទៅស្ទាបត្រង់ខ្នងជើង ដឹងថា លោកបរិនិព្វានហើយ ព្រោះជើងត្រជាក់ និងរឹង ទើបទៅរកអង្គទី ២ អង្គទី ៣ ក៏យ៉ាងនោះ ដឹងថា លោកបរិនិព្វាន

អស់ហើយ ទើបទៅកាន់រាជត្រកូល កាលសួរថា ព្រះបច្ចេកពុទ្ធទាំងឡាយទៅណា ក្រាបទូលថា បពិត្រព្រះទេវី ព្រះបច្ចេកពុទ្ធទាំងឡាយបរិនិព្វានអស់ហើយ ។ ព្រះទេវីទ្រង់ព្រះកន្សែង ស្ដេចចេញព្រមទាំងអ្នកក្រុង ទៅដល់កន្លែងនោះ ឲ្យលេងសាធុកីឡា ធ្វើឈាបនកិច្ចព្រះបច្ចេកពុទ្ធទាំងឡាយ ហើយកាន់យកព្រះធាតុកសាងព្រះចេតិយបញ្ចុះ ។

ព្រះរាជាលុះធ្វើឲ្យជាយដែនស្ងប់ ស្ដេចត្រឡប់ ត្រាស់សួរព្រះទេវីដែលមកទទួលថា ប្អូនស្រី នាងមិនប្រមាទក្នុងព្រះបច្ចេកពុទ្ធទាំងឡាយទេឬ ។ លោកម្ចាស់ទាំងឡាយសប្បាយរីករាយទេឬ ។ ទូលថា ព្រះបច្ចេក-ពុទ្ធទាំងឡាយបរិនិព្វានអស់ហើយ ព្រះអង្គ ។ ព្រះរាជាទ្រង់ត្រិះរិះថា សេចក្ដីស្លាប់នៅកើតដល់បណ្ឌិតបែបនេះបាន ពួកយើងនឹងផុតពីសេចក្ដីស្លាប់បានអំពីណា ។ ព្រះរាជាស្ដេចមិនត្រឡប់ចូលព្រះនគរ ស្ដេចចូលទៅកាន់ព្រះឧទ្យាននោះឯង ត្រាស់ឲ្យហៅជេស្ឋឱរសមក ទ្រង់ប្រគល់រាជសម្បត្តិដល់ឱរសនោះ ព្រះអង្គស្ដេចទ្រង់បួសជាសមណភេទ ។ សូម្បីព្រះទេវី កាលព្រះស្វាមីបួស ទ្រង់ត្រិះរិះថា យើងនឹងធ្វើអ្វីបាន ទើបទ្រង់បួសក្នុងព្រះឧទ្យាននោះដែរ ។

សូម្បីទាំងពីរព្រះអង្គ ញុំាងឈានឲ្យកើត ចុតិអំពីទីនោះ ហើយក៏

កើតក្នុងព្រហ្មលោក ។ កាលទាំងពីរអង្គនៅក្នុងព្រហ្មលោកនោះឯង ព្រះ-សាស្តារបស់យើងទាំងឡាយ ទ្រង់ឧប្បត្តិឡើងក្នុងលោក ទ្រង់ញ៉ាំងធម្មចក្រដ៏បវរឲ្យប្រព្រឹត្តទៅ ហើយស្តេចយាងទៅកាន់ក្រុងរាជគ្រឹះដោយលំដាប់ ។ បិប្ផលិមាណពនេះ កើតក្នុងផ្ទៃរបស់អគ្គមហេសីរបស់កបិលព្រាហ្មណ៍ ក្នុងស្រុកមហាតិត្ថព្រាហ្មណ៍ក្នុងដែនមគធៈ ។ នាងភទ្ទាកាបិលានី កើតក្នុងផ្ទៃរបស់អគ្គមហេសីរបស់ព្រាហ្មណ៍កោសិយគោត្រ ក្នុងសាគលនគរ ដែនមគធៈ ។ កាលគេចម្រើនវ័យដោយលំដាប់ បិប្ផលិមាណពអាយុ ២០ នាងភទ្ទាអាយុ ១៦ មាតាបិតាសម្លឹងមើលបុត្រ បន្ទឹថា កូនអើយ កូនធំហើយ គប្បីរក្សាវង្សត្រកូល ។ មាណពពោលថា បពិត្រមាតាបិតា កុំនិយាយពាក្យដូច្នេះឲ្យចូលត្រចៀកកូនឡើយ ។ កូននឹងប្រណិបត្តិជរាបមាតាបិតាតាំងនៅ ។ កូននឹងចេញបួសជាខាងក្រោយ ។ កន្លងទៅបន្តិច មាតាបិតាក៏និយាយទៀត ។ សូម្បីមាណពក៏បដិសេធដូចខាងដើម ។ តាំងពីនោះមក មាតាក៏នៅនិយាយមិនដាច់ឡើយ ។

មាណពគិតថា យើងនឹងឲ្យមាតាអនុញ្ញាត ។ ទើបឲ្យមាសពណ៌ក្រហមមួយពាន់ដុំ ឲ្យជាងមាសធ្វើរូបស្ត្រីម្នាក់ កាលធ្វើស្រេចហើយ ទើបឲ្យស្លៀកសំពត់ក្រហម ឲ្យប្រដាប់ដោយផ្កាឈើ បរិបូរណ៍ដោយពណ៌ និង

គ្រឿងប្រដាប់ផ្សេងៗ ហើយហៅមាតាមកប្រាប់ថា ម៉ែ កូនកាលបានអារម្មណ៍ បែបនេះ ទើបនៅគ្រប់គ្រងផ្ទះ កាលមិនបាននឹងមិននៅគ្រប់គ្រងផ្ទះឡើយ ។ ព្រាហ្មណីជាស្ត្រីឆ្លាត គិតថា បុត្ររបស់យើងមានបុណ្យ ឲ្យទាន សន្សំសេចក្តីល្អ កាលធ្វើបុណ្យ មិនបានធ្វើត្រឹមតែម្នាក់ឯងប៉ុណ្ណោះ ។ គង់នឹងមានស្ត្រីដែលធ្វើបុណ្យទុកច្រើន នឹងមានរូបដូចជារូបមាសដូចរូបស្រីនេះដោយពិត ។ ទើបហៅព្រាហ្មណ៍ ៨ នាក់ មកប្រាប់ថា ពួកលោកចូរបានសេចក្តីរីករាយ និងសេចក្តីសុខសប្បាយតាមសេចក្តីប្រាថ្នាគ្រប់យ៉ាង ហើយលើករូបមាសឡើងកាន់រថទៅចុះ ។ ពួកលោកចូរស្វែងរកទារិកាដូចនេះ ក្នុងត្រកូលដែលស្មើដោយជាតិ គោត្រ និងភោគៈនឹងយើង ។ ពួកលោកចូរប្រដាប់ត្រាទុក ហើយឲ្យរូបមាសនេះ ។ ព្រាហ្មណ៍ទាំងនោះចេញទៅដោយគិតថា នេះជាកម្មរបស់ពួកយើង ហើយគិតតទៅថា យើងនឹងទៅទីណា ដឹងថា ប្រកពរបស់ស្ត្រី មាននៅក្នុងមទ្ទរដ្ឋ[១] យើងនឹងទៅមទ្ទរដ្ឋ ទើបនាំគ្នាទៅសាគលនគរក្នុងមទ្ទរដ្ឋ ។ ពួកព្រាហ្មណ៍តាំងរូបមាសនោះទុកត្រង់កំពង់ទឹក ហើយនាំគ្នាទៅអង្គុយក្នុងទីដ៏សមគួរមួយ ។

គ្រានោះ មេដោះរបស់នាងកទ្ទា ឲ្យនាងកទ្ទាងូតទឹក តែងខ្លួនហើយ

---

(១) មទ្ទរដ្ឋ (តាមកូមា) ក៏គឺ មគធរដ្ឋនុ៎ះឯង ។

ឲ្យអង្គុយក្នុងបន្ទប់ដែលជាសិរី ហើយមកង្គុតទឹក លុះឃើញរូបនោះ ទើបគម្រាមដោយសម្គាល់ថា កូនក្រមុំលោកម្ចាស់យើងមកនៅក្នុងទីនេះ ពោលថា នាងក្បាលរឹង នាងមកទីនេះធ្វើអ្វី ក៏ងាលំពែង គឺ បាតដៃ ទះនាងកន្ទាត្រង់ កន្ទែងមួយ ពោលថា ចូរប្រញាប់ចេញទៅ ។ ដៃញ័ររន្ធត់ដូចប៉ះត្រូវលថ្ម ។ មេដោះក៏ចៀសចេញទៅ កើតការសម្គាល់ថា កូនក្រមុំលោកម្ចាស់យើង តែងខ្លួនហើយ រឹងដល់យ៉ាងនេះ ។ មេដោះពោលថា ពិតហើយ សូម្បីអ្នក ប្រដាប់សំពត់ស្លៀកនេះ មិនសមគួរដល់កូនក្រមុំលោកម្ចាស់របស់យើង ។

លំដាប់នោះ ពួកអ្នកហែហមមេដោះនោះ នាំគ្នាសួរថា កូនក្រមុំ លោកម្ចាស់របស់នាងមានរូបយ៉ាងនេះឬ ។ នាងនាំគ្នាពោលថា អ្វី កូនស្រី របស់លោកម្ចាស់យើង មានរូបស្អាតជាងស្ត្រីនេះទាំងរយទាំងពាន់ដង ។ កាលនាងអង្គុយនៅក្នុងបន្ទប់ ប្រមាណ ១២ ហត្ថ មិនមានកិច្ចដោយប្រទីប ។ ព្រោះពន្លឺនៃរាងកាយប៉ុណ្ណោះ កម្ចាត់សេចក្តីងងឹតបាន ។ ពួកមនុស្សពោល ថា បើដូច្នោះ លោកចូរមកនាំស្រីគមនោះទៅ ឲ្យលើករូបមាសទុកក្នុងរថ តាំងទុកត្រង់ទ្វារផ្ទះរបស់ព្រាហ្មណ៍កោសិយគោត្រ ប្រកាសឲ្យដឹងថា មក ។ ព្រាហ្មណ៍ធ្វើបដិសណ្ឋារៈ ហើយសួរថា ពួកលោកមកពីណា ។ ពួកមនុស្ស ពោលថា ពួកយើងមកពីផ្ទះរបស់កបិលព្រាហ្មណ៍ ក្នុងស្រុកមហាតិត្ថ ក្នុង

ដែនមគធៈ ដោយហេតុឈ្មោះនេះ ។ ព្រាហ្មណ៍ពោលថា ល្អហើយ បា ។ ព្រាហ្មណ៍របស់ពួកយើង មានជាតិ គោត្រ និងសម្បត្តិស្មើគ្នា យើងនឹងឲ្យនាងទារិកា ។ ហើយទទួលបណ្ណាការទុក ។ ព្រាហ្មណ៍ទាំងនោះ បញ្ជូនដំណឹងឲ្យកបិលព្រាហ្មណ៍ជ្រាបថា បាននាងទារិកាហើយ មេត្តាធ្វើវត្ថុដែលគួរធ្វើចុះ ។ មាតាបិតាស្តាប់ដំណឹងនោះហើយ ទើបប្រាប់ដល់បិប្ផលិមាណពថា ដំណឹងថា បាននាងទារិកាហើយ ។ មាណពគិតថា យើងគិតថា យើងនឹងមិនបាន ក៏មាតាបិតាពោលថា បានហើយ យើងមិនត្រូវការ នឹងបញ្ជូនសំបុត្រទៅ ទើបទៅក្នុងទីកំបាំងសរសេរសំបុត្រថា ម្នាលនាងកទ្ទា ចូរគ្រប់គ្រងផ្ទះតាមសមគួរដល់ជាតិ គោត្រ និងភោគៈរបស់ខ្លួនចុះ យើងនឹងចេញបួស ។ នាងកុំមានសេចក្តីក្តៅក្រហាយចិត្តក្នុងកាលជាខាងក្រោយឡើយ ។ សូម្បីនាងកទ្ទាក៏បានឮថា ន័យថា មាតាបិតាប្រាថ្នានឹងលើកយើងឲ្យដល់អ្នកឯណោះ ទើបទៅក្នុងទីកំបាំងសរសេរសំបុត្រថា អយ្យបុត្រដ៏ចម្រើន ចូរគ្រប់គ្រងផ្ទះតាមសមគួរដល់ជាតិ គោត្រ និងភោគៈរបស់ខ្លួនចុះ យើងនឹងបួស លោកកុំមានសេចក្តីក្តៅក្រហាយចិត្តក្នុងកាលជាខាងក្រោយឡើយ ។ សំបុត្រសូម្បីទាំងពីរ បានមកដល់ព្រមគ្នាក្នុងចន្លោះផ្លូវ ។ សួរថា នេះសំបុត្ររបស់អ្នកណា ។ ឆ្លើយថា បិប្ផលិមាណពបញ្ជូនឲ្យនាងកទ្ទា ។ សួរថា នេះ

ជារបស់អ្នកណា ។ ឆ្លើយថា នាងកន្ទាបញ្ជូនឲ្យបិបួលិមាណព ។ អ្នកទាំងពីរ ក៏បាននិយាយឡើងថា ពួកលោកចូរមើលការធ្វើរបស់ពួកទារកចុះ ទើបហែក ចោលក្នុងព្រៃ សរសេរសំបុត្រមានសេចក្តីដូចគ្នា បញ្ជូនទៅទាំងខាងនេះ និងខាងឯណោះ កាលអ្នកទាំងពីរមិនប្រាថ្នាដូចគ្នាទុំះឯង ក៏មានការនៅរួម គ្នា ។

ក៏ក្នុងថ្ងៃនោះឯង មាណពក៏ឲ្យកម្រងផ្កាឈើមួយកួង ។ សូម្បីនាង កន្ទាក៏ឲ្យមួយកួង ។ សូម្បីអ្នកទាំងពីរបរិភោគអាហារក្នុងវេលាល្ងាចហើយ បានដាក់កួងផ្កាឈើទាំងនោះទុកត្រង់កណ្តាលទីដេក គិតថា យើងទាំងពីរនឹង ចូលដេក មាណពដេកខាងស្តាំ នាងកន្ទាដេកខាងឆ្វេង ។ អ្នកទាំងពីរនោះ ព្រោះខ្លាចការពាល់ត្រូវរាងកាយគ្នានិងគ្នា ទើបដេកមិនលក់ រហូតកន្លងទៅ អស់ ៣ យាម ។ ក្នុងវេលាថ្ងៃ សូម្បីតែញញឹមដាក់គ្នាក៏មិនមាន ។ អ្នក ទាំងពីរមិនបានរួមគ្នាដោយលោកាមិស ។ គេទាំងពីរមិនបានពេញចិត្តដល់ សម្បត្តិក្នុងវេលាដែលមាតាបិតានៅមានជីវិត កាលមាតាបិតាធ្វើកាលកិរិយា ហើយ ទើបពេញចិត្ត ។ មាណពមានសម្បត្តិច្រើន ។ ក្នុងថ្ងៃមួយ បានកម្ទេច មាសដែលដុសខាត់រាងកាយ ទុកចោលប្រមាណ ១២ នាឡិ ដោយនាឡិរបស់ អ្នកស្រុកមគធ ។ មានស្រះធំ ៦០ កន្លែង ជាប់ដោយគ្រឿងយន្ត ។ មាន

ផ្ទៃដីសម្រាប់ប្រកបការងារ ១២ យោជន៍ ។ មានស្រុកទាស ១៤ កន្លែង ប៉ុនអនុរាធបុរី ។ មានដំរីចម្បាំង ១៤ , រថ ១៤ ។

ថ្ងៃមួយមាណព ជិះសេះដែលតាក់តែងហើយ មានមហាជនហែហម ទៅកាន់ដីដែលប្រកបការងារ ឈរក្នុងទីបំផុតខេត្ត ឃើញបក្សី មានក្អែកជាដើម ចឹកសត្វ មានជន្លេនជាដើមស៊ី បន្ទាប់ពីត្រូវនង្គ័លក្ជួរហើយ ទើបសួរថា បក្សីទាំងនេះស៊ីអ្វី ។ ឆ្លើយថា ស៊ីជន្លេនលោកម្ចាស់ ។

សួរថា បាបដែលបក្សីទាំងនេះធ្វើ នឹងមានដល់អ្នកណា ។ ឆ្លើយថា ដល់លោកម្ចាស់ ។ មាណពគិតថា បាបដែលបក្សីទាំងនេះធ្វើ នឹងមានដល់យើង ។ ទ្រព្យ ៨៦ កោដិនឹងជួយអ្វីយើងបាន ។ ផ្ទៃដីការងារប្រមាណ ១២ យោជន៍ នឹងជួយអ្វីបាន ។ ស្រះ ៦០ កន្លែងជាប់ដោយគ្រឿងយន្ត ស្រុក ១៤ កន្លែង នឹងជួយអ្វីបាន យើងនឹងប្រគល់សម្បត្តិទាំងអស់នោះដល់នាងភទ្ទា ហើយចេញបួស ។ ក្នុងខណៈនោះ សូម្បីនាងភទ្ទាកាបិលានី ក៏ឲ្យចាក់ល្ង ៣ ឆ្នាំងចុះក្នុងរវាងផ្ទៃដី ពួកមេដោះអង្គុយលោមព័ទ្ធ ឃើញក្អែកស៊ីសត្វដែលស៊ីល្ង ទើបសួរថា ក្អែកទាំងនេះស៊ីអ្វីមេដោះ ។ ឆ្លើយថា ស៊ីសត្វម៉ែម្ចាស់ ។ សួរថា អកុសលនឹងមានដល់អ្នកណា ។ ឆ្លើយថា និងមានដល់ម៉ែម្ចាស់ ។ នាងគិតថា យើងគួរបានសំពត់ប្រមាណ ៤ ហត្ថ និងបានបាយ

ប្រមាណមួយនាឡិ ។ ប្រសិនបើថា អកុសលដែលជនប្រមាណប៉ុណ្ណោះធ្វើ នឹងមានដល់យើង ព្រោះថា យើងមិនអាចនឹងលើកសីសៈឡើងបានអំពីវដ្តៈ សូម្បីពាន់នៃភព ។ លុះកាលអយ្យបុត្រ (មាណព) មកដល់ យើងនឹងប្រគល់សម្បត្តិទាំងអស់ដល់គេ ហើយចេញបួស ។

មាណពមកពីងូតទឹកហើយ ឡើងកាន់ប្រាសាទអង្គុយក្នុងបល្ល័ង្កមានតម្លៃច្រើន ។ លំដាប់នោះ ជនទាំងឡាយ ចាត់ចែងភោជនដ៏សមគួរដល់ស្តេចចក្រពត្តិឲ្យដល់គេ ។ ទាំងពីរនាក់បរិភោគហើយ កាលបរិវារជនចេញទៅអស់ ទើបនិយាយគ្នាក្នុងទីកំបាំង អង្គុយក្នុងទីសប្បាយ ។ ពេលនោះមាណពពោលនឹងនាងភទ្ទាថា ម្នាលនាងភទ្ទា នាងមកកាន់ផ្ទះនេះ នាំយកទ្រព្យមកប៉ុន្មាន ។ នាងឆ្លើយថា ៥៥,០០០ រទេះអយ្យបុត្រ ។ មាណពពោលថា ទ្រព្យ ៨៧ កោដិ និងសម្បត្តិមានស្រះ ៦០ កន្លែងជាប់ដោយគ្រឿងយន្តមាននៅក្នុងផ្ទះនេះទាំងអស់ យើងប្រគល់ឲ្យដល់នាងតែម្នាក់ឯង ។ នាងសួរថា ចុះចំណែកលោក ។ ឆ្លើយថា យើងនឹងបួស ។ នាងពោលថា សូម្បីខ្ញុំ (ក៏មិន) អង្គុយសម្លឹងមើលការមករបស់លោក ។ ខ្ញុំក៏នឹងបួសដែរ ។

ទាំងពីរនាក់ពោលថា ភពទាំងបី ដូចបណ្ណកុដិដែលត្រូវភ្លើងឆេះ ។ យើងនឹងបួស ទើបឲ្យនាំសំពត់កាសាយៈ ជ្រលក់ដោយទឹកអម្ពត់ ដែលជា

ទីត្រេកអរ និងបាត្រដីមកអំពីផ្សារ ញុំាងគ្នានិងគ្នាឲ្យកោរសក់ បួសដោយ តាំងចិត្តថា បព្វជ្ជារបស់ពួកយើងឧទ្ទិសចំពោះព្រះអរហន្តក្នុងលោក យក បាត្រដាក់ស្មោកស្ពាយត្រង់ចង្កេះយស្មា ចុះអំពីប្រាសាទ ។ បណ្ដាទាសៈ និង កម្មករក្នុងផ្ទះមិនមានអ្នកណាដឹងឡើយ ។ គ្រានោះអ្នកស្រុកទាសៈស្គាល់ គេ ព្រោះធ្លាប់ចេញចាកស្រុកព្រាហ្មណ៍ទៅកាន់ស្រុកទាសៈ ដោយអំណាច អាកប្បកិរិយា ។ អ្នកស្រុកទាសៈទាំងនោះក៏ស្រែកយំ ក្រាបចុះទៀបជើង ពោលថា អយ្យបុត្រ លោកម្ចាស់នឹងធ្វើឲ្យពួកខ្ញុំគ្មានទីពឹងឬ ។ អ្នកទាំងពីរ ពោលថា យើងទាំងពីរបួសដោយគិតថា ភពទាំងបីដូចជាបណ្ណសាលាដែល ត្រូវភ្លើងឆេះ ។ ប្រសិនបើយើងទាំងពីរ នឹងធ្វើក្នុងពួកអ្នកម្នាក់ៗ ឲ្យជាអ្នក គ្មានបំណុល ។ សូម្បីមួយរយឆ្នាំក៏នៅមិនទាន់អស់ ។ ពួកអ្នកចូរជម្រះ សីសៈរបស់ខ្លួន ហើយចូរជាអ្នកគ្មានបំណុលចុះ ។ កាលជនទាំងនោះយំ គេនាំគ្នាចៀសចេញទៅ ។

ព្រះថេរៈដើរទៅខាងមុខ សម្លឹងមើលដោយគិតថា ស្ត្រីអ្នកមានតម្លៃ ក្នុងសកលជម្ពូទ្វីប ឈ្មោះ ភទ្ទាកាបិលានីនេះ ដើរមកខាងក្រោយយើង ។ ដែលនរណាៗ គប្បីគិតយ៉ាងនេះថា អ្នកទាំងពីរនេះ សូម្បីបួសហើយ ក៏ មិនអាចនឹងប្រាសចាកគ្នាបាន ឈ្មោះថា ធ្វើកម្មដែលមិនសមគួរ នេះមិនជា

ឋានៈដែលសមគួរ ។ម្យ៉ាងទៀត នរណាៗ គប្បីមានចិត្តប្រទូសរ៉ាយហើយ នឹងធ្លាក់ទៅក្នុងអបាយដ៏ច្រើន ។ព្រះថេរៈទើបកើតការគិតឡើងថា យើងគួរលះបង់ស្ត្រីនេះ ។ព្រះថេរៈទៅខាងមុខ ឃើញផ្លូវបែកជាពីរ ទើបបានឈរក្នុងទីបំផុតផ្លូវបែកជាពីរនោះ ។សុម្បីនាងភទ្ទា ក៏បានមកឈរសំពះ ។ព្រះថេរៈពោលចំពោះនាងថា ភទ្ទាដ៏ចម្រើន មហាជនឃើញស្ត្រីដូចនាងដើរមកខាងក្រោយយើង ហើយគិតថា លោកទាំងពីរនេះ សូម្បីបួសហើយក៏មិនអាចនឹងប្រាសចាកគ្នាបាន នឹងគប្បីមានចិត្តប្រទុស្តក្នុងយើង នឹងធ្លាក់ទៅក្នុងអបាយយ៉ាងច្រើន ។នាងចូរកាន់យកផ្លូវមួយ ក្នុងផ្លូវបែកជាពីរនេះ ។ខ្ញុំនឹងទៅតែម្នាក់ឯង ។នាងភទ្ទាពោលថា ត្រូវហើយលោកម្ចាស់ឈ្មោះថា មាតុគ្រាមជាមន្ទិលរបស់ពួកបព្វជិត ។ជនទាំងឡាយនឹងឃើញទោសរបស់យើងថា លោកទាំងពីរសូម្បីបួសហើយ ក៏នៅមិនទាន់ប្រាស-ចាកគ្នា ។សូមនិមន្តលោកម្ចាស់កាន់យកផ្លូវមួយ ។យើងទាំងពីរនឹងបែកគ្នា ។នាងធ្វើប្រទក្សិណ ៣ ជុំ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានក្នុងឋានៈ ៤ ផ្គងអញ្ជលីដ៏រុងរឿងដោយទសនខសមោធាន (ប្រជុំម្រាមដៃទាំង ១០) ដោយសេចក្តីស្និទស្នាលក្នុងភាពជាមិត្ត ដែលមានមកជាយូរប្រមាណមួយសែនកប្ប នឹងត្រូវបែកគ្នាក្នុងថ្ងៃនេះ ។លោកម្ចាស់ឈ្មោះថា ជាទក្ខិណៈ

ផ្លូវខាងស្តាំ រមែងគួរដល់លោកម្ចាស់ ។ ខ្ញុំម្ចាស់ឈ្មោះថា ជាមាតុគ្រាម ជាចំណែកឆ្វេង ផ្លូវខាងឆ្វេង រមែងគួរដល់ខ្ញុំម្ចាស់ ដូច្នេះ ថ្វាយបង្គំហើយ ដើរទៅកាន់ផ្លូវ ។ ក្នុងវេលាដែលអ្នកទាំងពីរបែកពីគ្នា មហាប្រថពីនេះ បន្លឺសំឡេងសាធុការ កក្រើកញាប់ញ័រ ហាក់ដូចជាពោលថា សូម្បីយើង អាចនឹងទ្រទ្រង់ភ្នំចក្រវាឡ និងភ្នំសិនេរុទុកបាន ក៏មិនអាចនឹងទ្រទ្រង់គុណ របស់លោកទាំងពីរទុកបាន ។ រមែងប្រព្រឹត្តទៅដូចសំឡេងផ្គរបន្លឺពួជ៏ អាកាស ។ ភ្នំចក្រវាឡក៏បន្លឺឡើង ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រថាប់គង់ក្នុងព្រះគន្ធកុដិជិតមហាវិហារវេឡុវ័ន ទ្រង់ស្តាប់សម្លេងផែនដីញ័រ ទ្រង់ព្រះរំពឹងថា ផែនដីញ័រដើម្បីអ្នកណាហ្ន៎ ទ្រង់ជ្រាបថា បិប្ផលិមាណព និងនាងភទ្ទាកាបិលានី លះបង់សម្បត្តិច្រើន ណាស់ ឧទ្ទិសចំពោះតថាគត ។ ការញ័ររបស់ផែនដីនេះ កើតដោយកម្លាំង គុណរបស់អ្នកទាំងពីរក្នុងកន្លែងដែលគេបែកគ្នា សូម្បីតថាគត ក៏គួរធ្វើការ សង្គ្រោះដល់គេទាំងពីរ ទើបស្តេចចេញចាកព្រះគន្ធកុដិ ទ្រង់ប្រដាប់បាត្រ និងចីវរដោយព្រះអង្គឯង ទ្រង់មិនប្រឹក្សាអ្នកណាៗ ក្នុងបណ្តាមហាថេរៈ ៨០ អង្គ ទ្រង់ធ្វើការទទួលប្រមាណ ៣ គាវុត ប្រថាប់អង្គុយចម្រើនសមាធិ ក្រោមដើមពហុបុត្តកនិគ្រោធ ក្នុងចន្លោះក្រុងរាជគ្រឹះ និងក្រុងនាលន្ទា ។

ក៏កាលប្រថាប់គង់ មិនបានប្រថាប់គង់ដូចភិក្ខុដែលសមាទានសំពត់បង្សុកូល ជាវត្ថុរូបណាមួយ ទ្រង់កាន់ភេទនៃព្រះពុទ្ធ ប្រថាប់គង់បញ្ចេញព្រះពុទ្ធរស្មី ប្រមាណ ៨០ ហត្ថ ។ ក្នុងខណៈនោះ ពុទ្ធរស្មីប្រមាណប៉ុនស្លឹកឈើ ឆត្រ កង់រទេះ និងផ្ទះកំពូលជាដើម ផ្សាយចេញទៅខាងនេះ ខាងនោះ ប្រាកដ ហេតុដូចវេលាព្រះចន្ទ និងព្រះអាទិត្យរះឡើងមួយពាន់ដួង បានធ្វើបរិវេណ ព្រៃធំឲ្យមានពន្លឺតែមួយ ដោយប្រការដូច្នេះ ។ បរិវេណព្រៃ រុងរឿងដោយ សិរីនៃមហាបុរិសលក្ខណៈ ៣២ ដូចផ្ទៃមេឃរុងរោចន៍ដោយពួកផ្កាយ ដូច ទឹកដែលមានគុម្ពផ្កាឈូករីកស្គុះស្គាយ ។ ដើមនិគ្រោធមានពណ៌ស ។ ស្លឹក ពណ៌ខៀវ ស្លឹកចាស់ពណ៌ក្រហម ។ តែក្នុងថ្ងៃនោះ ដើមនិគ្រោធ ទាំងដើម និងមែក មានពណ៌ដូចមាស ។ គប្បីជ្រាបអនុបុព្វីកថា ដែលលោកពោល សេចក្តីនៃបទថា **អទ្ធានមគ្គំ បដិបន្នោ** ហើយពោលថា ឥឡូវនេះ អ្នកនេះ បួសហើយដោយប្រការណា និងដើរផ្លូវឆ្ងាយដោយប្រការណា ដើម្បីញ៉ាំង សេចក្តីនេះឲ្យជាក់ច្បាស់ គប្បីពោលអនុបុព្វីកថានេះ តាំងអំពីអភិនីហារ យ៉ាងនេះ ។

បទថា **អន្តរា ច រាជគហំ អន្តរា ច នាឡន្ទំ** សេចក្តីថា ក្នុងចន្លោះ ក្រុងរាជគ្រឹះ និងស្រុកនាលន្ទា ។ បទថា **សត្ថារញ្ច វតាហំបស្សេយ្យំ** ភគ-

វន្ទេយ្យំ បស្សេយ្យំ សេចក្តីថា ប្រសិនបើ យើងជួបព្រះសាស្តាសោត ។ យើងគប្បីជួបព្រះមានព្រះភាគជាព្រះពុទ្ធនោះឯង ។ ព្រោះសាស្តាដទៃអំពីនេះ មិនអាចជាសាស្តារបស់យើងបានឡើយ ។ បទថា សុគតញ្ច វតាហំ បស្សេយ្យំ កគវន្តមេវ បស្សេយ្យំ សេចក្តីថា ប្រសិនបើយើងជួបនឹងបុគ្គលអ្នកមានគតិល្អ ព្រោះសេចក្តីនៃសម្មាបដិបត្តិ ដែលលោកដល់ហើយដោយល្អ យើងគប្បីជួបព្រះមានព្រះភាគ ដែលជាព្រះពុទ្ធនោះឯង ។ ព្រោះបុគ្គលអ្នកមានគតិល្អ ដទៃអំពីនេះមិនអាចជាសាស្តារបស់យើងបាន ។

បទថា សម្មាសម្ពុទ្ធញ្ច វតាហំ បស្សេយ្យំ កគវន្តមេវ បស្សេយ្យំ សេចក្តីថា ប្រសិនបើយើងពុំជួបព្រះសម្មាសម្ពុទ្ធ ព្រោះទ្រង់ត្រាស់ដឹងដោយព្រះអង្គឯងដោយប្រពៃ ។ យើងគប្បីឃើញព្រះមានព្រះភាគអង្គនេះឯង ។ ព្រោះបុគ្គលដែលត្រាស់ដឹងធម៌ដទៃក្រៅអំពីនេះ មិនអាចនឹងមានដល់យើងបាន នេះជាបំណងប្រាថ្នាក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។ កេចិអាចារ្យសម្តែងដោយការឃើញប៉ុណ្ណោះថា យើងមិនមានសេចក្តីសង្ស័យក្នុងព្រះ-មានព្រះភាគដែលជាទីពឹងថា នេះព្រះសាស្តា នេះព្រះសុគត នេះព្រះសម្មា-សម្ពុទ្ធ ដោយប្រការដូច្នេះ ។

បទថា សត្ថា មេ ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជា

សាស្តារបស់ខ្ញុំព្រះអង្គ) នេះ មកហើយ ២ ដងក៏ពិត តែគប្បីជ្រាបថា លោកពោលហើយ ៣ ដង ។ កេចិអាចារ្យសម្តែងថា ដោយបទនេះ ម្នាលអាវុសោ យើងប្រកាសភាពជាសាវក ៣ ដងយ៉ាងនេះ ។

[១៩២] បទថា **អជានញ្ញេវ** ប្រែថា មិនដឹងនៅ ។ សូម្បីក្នុងបទទី ២ ក៏មានន័យនេះដូចគ្នា ។ បទថា **មុទ្ធាបិតស្ស វិបតេយ្យ** (សីសៈរបស់បុគ្គលនោះគប្បីបែក) សេចក្តីថា សាវកអ្នកមានចិត្តជ្រះថ្លា តាំងចិត្តយ៉ាងនេះ គប្បីធ្វើសេចក្តីគោរពដ៏យ៉ាងក្រៃលែង ចំពោះសាស្តាខាងក្រៅដែលមិនដឹង ប្តេជ្ញាថា យើងដឹង សីសៈរបស់សាស្តានោះ គប្បីធ្លាក់ចុះអំពីកដូចត្នោតទុំជ្រុះ ដូច្នោះ ។ អធិប្បាយថា ក៏សីសៈគប្បីបែកចេញ ៧ ចំណែក ។ ដោយរឿងនេះ មានសេចក្តីប្រៀបធៀបទុកយ៉ាងណា ។

ប្រសិនបើព្រះមហាកស្សបត្ថេរ គប្បីធ្វើសេចក្តីគោរពយ៉ាងក្រៃលែងដោយចិត្តជ្រះថ្លាចំពោះមហាសមុទ្រ ។ មហាសមុទ្រ នឹងត្រូវរីងស្ងួត ដូចតំណក់ទឹកដែលដាក់ក្នុងក្បឿងក្តៅ ។ បើគប្បីធ្វើសេចក្តីគោរពចំពោះចក្រ-វាឡ ។ ចក្រវាឡត្រូវខ្ចាត់ខ្ចាយដូចបាចអង្កាម ។ ប្រសិនបើគប្បីធ្វើសេចក្តីគោរពចំពោះភ្នំសិនេរុ ។ ភ្នំសិនេរុត្រូវខ្ចាត់ខ្ចាយ ដូចដុំម្សៅដែលត្រូវក្អែកចឹក ។ ប្រសិនបើគប្បីធ្វើសេចក្តីគោរពចំពោះផែនដី ។ ផែនដីត្រូវខ្ចាតខ្ចាយ

ដូចកម្ទេចផង់ដែលត្រូវខ្យល់បក់មក ។ ក៏ការធ្វើសេចក្តីគោរពរបស់ព្រះថេរៈ បែបនេះ មិនអាចសូម្បីត្រឹមតែព្រះលោមាត្រង់ខ្នងព្រះបាទ ពណ៌ដូចមាស របស់ព្រះសាស្តាឲ្យកម្រើកបាន ។ម្យ៉ាងទៀត ព្រះមហាកស្សបលើកទុកចុះ ភិក្ខុដូចព្រះមហាកស្សបទាំងពាន់ ទាំងសែន ក៏មិនអាចសូម្បីត្រឹមតែធ្វើព្រះ លោមាត្រង់ខ្នងព្រះបាទរបស់ព្រះទសពលឲ្យកម្រើកបាន ឬសូម្បីត្រឹមតែ សំពត់បង្សុកូលចីវរឲ្យកម្រើកបាន ។

ដោយការសម្តែងសេចក្តីគោរព ពិតណាស់ ព្រះសាស្តាមានអានុភាព ច្រើនដោយប្រការដូច្នេះ ។ **តស្មាតិហ តេ កស្សប** សេចក្តីថា ព្រោះតថាគត ដឹង តថាគតក៏ពោលថា ដឹងនុ៎ះឯង និងកាលឃើញ តថាគតក៏ពោលថា តថាគតឃើញ ដូច្នោះ ម្នាលកស្សបៈ អ្នកគប្បីសិក្សាយ៉ាងនេះ ។ បទថា **តិព្វំ** ប្រែថា ដ៏ក្លៀវក្លា បានដល់ ក្រាស់ គឺ ធំ ។ បទថា **ហិរោត្តប្បំ** បានដល់ ហិរិ និងឱត្តប្បៈ ។ បទថា **បច្ចុបដ្ឋិតំ ភវិស្សតិ** បានដល់ នឹង ចូលទៅតម្កល់ទុក ។ អធិប្បាយថា ពិតហើយ អ្នកណាញ៉ាំងហិរិ និងឱត្តប្បៈ ឲ្យចូលទៅតម្កល់ទុកក្នុងព្រះថេរៈជាដើម ហើយចូលទៅរក ។ សូម្បីព្រះថេរៈ ជាដើម ក៏ជាអ្នកមានហិរិ និងឱត្តប្បៈចូលទៅរកអ្នកនោះ នេះជាអានិសង្ស ក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។ បទថា **កុសលូបសញ្ហិតំ** គឺ អាស្រ័យ

ធម៌ជាកុសល ។ បទថា **អដ្ឋិកត្វា** សេចក្តីថា ធ្វើខ្លួនឲ្យជាប្រយោជន៍ដោយធម៌នោះ ឬធ្វើធម៌នោះឲ្យជាប្រយោជន៍ថា នេះប្រយោជន៍របស់យើង ដូច្នេះ ។ បទថា **មនសិកត្វា** គឺ ធ្វើទុកក្នុងចិត្ត ។ បទថា **សព្វចេតសោ សមន្នាហរិត្វា** សេចក្តីថា មិនឲ្យចិត្តទៅខាងក្រៅបានសូម្បីតែតិច រួបរួមទុក ដោយប្រមូលមកទាំងអស់ ។ បទថា **ឱហិតសោតោ** ប្រែថា ផ្ទៀងត្រចៀក ។

អធិប្បាយថា អ្នកគប្បីសិក្សាយ៉ាងនេះថា យើងនឹងតាំងសោតញ្ញាណនិងបសាទសោត ហើយស្តាប់ធម៌ដែលតថាគតសម្តែងហើយដោយគោរព ។ បទថា **សាតសហគតា ច មេ កាយគតាសតិ** សេចក្តីថា កាយគតាសតិសម្បយុត្តដោយសុខ ដោយអំណាចបឋមជ្ឈានក្នុងអសុភកម្មដ្ឋាន និងក្នុងអានាបានកម្មដ្ឋាន ។

ក៏ឱវាទនេះមាន ៣ យ៉ាង ។ បព្វជ្ជា និងឧបសម្បទានេះឯង មានដល់ព្រះថេរៈ ។ បទថា **សារណោ** បានដល់ ជាអ្នកមានកិលេស គឺ បំណុល ។ បទថា **រដ្ឋបិណ្ឌំ ភុញ្ជិំ** បានដល់ បរិភោគអាហារដែលគេឲ្យដោយសទ្ធា ។

ពិតណាស់ ការបរិភោគមាន ៤ យ៉ាង គឺ ថេយ្យបរិភោគ ១ , ឥណបរិភោគ ១ , ទាយជ្ជបរិភោគ ១ , សាមិបរិភោគ ១ ។

ក្នុងបរិភោគទាំងនោះ ភិក្ខុជាអ្នកទ្រុស្តសីល សូម្បីអង្គុយបរិភោគ

ក្នុងកណ្តាលជំនុំសង្ឃ ក៏ឈ្មោះថា **ថេយ្យបរិភោគ** ។ ព្រោះហេតុអ្វី ព្រោះមិនជាឥស្សរៈក្នុងបច្ច័យ ៤ ។

អ្នកមានសីល បរិភោគមិនពិចារណា ឈ្មោះថា **ឥណបរិភោគ** ។ ការបរិភោគរបស់ព្រះសេក្ខៈទាំង ៧ ឈ្មោះថា **ទាយជ្ជបរិភោគ** ។ ការបរិភោគរបស់ព្រះខីណាស្រព ឈ្មោះថា **សាមីបរិភោគ** ដោយប្រការដូច្នេះ ។ ព្រះថេរៈកាលធ្វើការបរិភោគដែលខ្លួនជាបុថុជ្ជនបរិភោគ ឲ្យជាឥណបរិភោគ ទើបពោលយ៉ាងនេះ ។

បទថា **អដ្ឋមិយា អញ្ញា ឧទបាទិ** បានដល់ ព្រះអរហត្តផលកើតឡើងហើយក្នុងថ្ងៃទី ៨ ។ បទថា **អថខោ ភគវា មគ្គា ឱក្កម្ម** សេចក្តីថា ការចុះចាកផ្លូវទៅមុន បានមានហើយក្នុងថ្ងៃនោះ ខាងក្រោយទើបបានសម្រេចព្រះអរហត្ត ។ ក៏លោកសម្តែងការសម្រេចព្រះអរហត្តមុន ព្រោះវារៈទេសនាមកហើយយ៉ាងនេះ ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបទ្រង់ចុះចាកផ្លូវ ។ ឆ្លើយថា បានឮថា ព្រះអង្គបានទ្រង់មានព្រះតម្រិះយ៉ាងនេះថា តថាគតនឹងធ្វើភិក្ខុនេះឲ្យជាអ្នកនៅព្រៃជាវត្ត ទ្រទ្រង់សំពត់បង្សុកូលជាវត្ត មានអាសនៈតែមួយជាវត្ត ព្រោះដូច្នោះ ព្រះអង្គទើបចុះចាក ។

បទថា **មុទុកា ខោ ត្យាយំ** បានដល់ សំពត់សង្ឃាដិនេះឯង របស់

អ្នកទន់ល្អ ។ ក៏ព្រះមានព្រះភាគ កាលស្ទាបអង្អែលចីវរនោះដោយចុងព្រះហស្ត មានពណ៌ដូចផ្កាបទុម ទើបត្រាស់ព្រះវាចានេះ ។ សួរថា ព្រះអង្គត្រាស់យ៉ាងនេះ ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះទ្រង់ប្រាថ្នានឹងផ្លាស់ប្តូរចីវរជាមួយនឹងព្រះថេរៈ ។ សួរថា ព្រះអង្គទ្រង់ប្រាថ្នានឹងផ្លាស់ប្តូរព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះទ្រង់ប្រាថ្នានឹងតាំងព្រះថេរៈទុកក្នុងតំណែងរបស់ព្រះអង្គ ។ ក៏ព្រោះកាលលោកពោលគុណរបស់ចីវរ ឬបាត្រ ព្រះថេរៈទើបក្រាបទូលថា សូមព្រះអង្គទ្រង់ទទួលចីវរនេះ ដើម្បីព្រះអង្គចុះ នេះជាចារិត្តៈ ដូច្នោះ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់ទទួលរបស់ខ្ញុំព្រះអង្គចុះ ។ បទថា **ធារេស្សសិ បន មេ ត្វំ កស្សប សាណានិ បំសុកូលានិ និព្វសនានិ** សេចក្តីថា ម្នាលកស្សបៈ អ្នកនឹងអាចស្លៀកដណ្តប់សំពត់បង្សុកូលដែលតថាគតប្រើប្រាសហើយឬទេ ដូច្នេះ ។ ក៏ព្រះអង្គសំដៅដល់កម្លាំងកាយ ទើបត្រាស់ហើយយ៉ាងនេះ មិនមែនឬ តែទ្រង់សំដៅដល់ការបដិបត្តិ ទើបត្រាស់យ៉ាងនេះ ។

ក្នុងសេចក្តីនេះមានអធិប្បាយដូច្នេះ ៖

ចីវរនេះ ដែលគេដណ្តប់ ទាសីឈ្មោះបុណ្ណៈបោលក្នុងព្រៃស្មសាន តថាគតចូលទៅកាន់ព្រៃស្មសាននោះ ដែលមានសត្វប្រាសទៅហើយប្រមាណ

មួយបត្ត (ទាឡិ) ពោសសត្វទាំងនោះហើយ តាំងនៅក្នុងមហាអរិយវង្ស កាន់យក ។ ក្នុងថ្ងៃដែលតថាគតកាន់យកចីវរនេះ មហាប្រថពីក្នុងម៉ឺនចក្រ- វាឡបានបញ្ចេញសំឡេងញាប់ញ័រ អាកាសនោះក៏បញ្ចេញសំឡេងលាន់ ឮ តដ: តដ: ទេវតាក្នុងចក្រវាឡបានឲ្យសាធុការថា ភិក្ខុដែលកាន់យក ចីវរនេះ គួរជាអ្នកទ្រទ្រង់សំពត់បង្សុកូលជាវត្តតាមធម្មជាតិ អង្គុយអាសនៈ តែមួយជាវត្តតាមធម្មជាតិ ត្រាច់ទៅតាមលំដាប់ប្រកដូវជាវត្តតាមធម្មជាតិ លោកនឹងអាចធ្វើឲ្យសមគួរដល់ចីវរនេះបាន ដូច្នេះ ។ សូម្បីព្រះថេរៈខ្លួនឯង ទ្រទ្រង់ទុកនូវកម្លាំងដំរី ៥ ។ លោកទើបមិនត្រិះរិះដល់ប្រការនោះ ប្រាថ្នា នឹងធ្វើឲ្យសមគួរដល់សុគតចីវរដោយសេចក្តីឧស្សាហ៍ថា យើងនឹងញ៉ាំង ការបដិបត្តិនោះឲ្យបរិបូរណ៍ ដូច្នេះ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងគ្រង ដូច្នេះ ។

[១៩៣] បទថា **បដិបជ្ជឹ** (បានទទួល) បានដល់ យើងបានបដិបត្តិ ហើយ ក៏ព្រះមានព្រះភាគទ្រង់ធ្វើការផ្លាស់ប្តូរចីវរយ៉ាងនេះហើយ ទ្រង់គ្រង ចីវរដែលព្រះថេរៈគ្រង ព្រះថេរៈគ្រងចីវររបស់ព្រះសាស្តា ។ សម័យនោះ មហាប្រថពីញាប់ញ័រដរាបដល់ទឹកទ្រផែនដី ។

ក្នុងបទថា **ភគវតោ បុត្តោ** ជាដើម សេចក្តីថា ព្រះថេរៈអាស្រ័យ

ព្រះមានព្រះភាគកើតហើយដោយអរិយជាតិ ដូច្នោះ បុត្ររបស់ព្រះមាន-ព្រះភាគ ឈ្មោះថា អ្នកកើតពីទ្រូង កើតពីព្រះឱស្ឋ ព្រោះនៅក្នុងទ្រូង តាំងនៅក្នុងបព្វជ្ជា និងឧបសម្បទា ដោយអំណាចព្រះឱវាទចេញពីព្រះឱស្ឋ ឈ្មោះថា អ្នកកើតពីព្រះធម៌ដែលធម៌និមិត្តហើយ ព្រោះកើតពីព្រះឱវាទធម៌ និងព្រោះទ្រង់និមិត្តដោយព្រះឱវាទធម៌ ឈ្មោះថា ធម្មទាយាទ ព្រោះគួរដល់ទាយាទ គឺ ព្រះធម្មឱវាទ ឬទាយាទ គឺ លោកុត្តរធម៌ ៩ ។

បទថា **បដិគ្គហិតានិ សញ្ញាណានិ បំសុកូលានិ** សេចក្ដីថា ទទួលសំពត់បង្សុកូលចីវរដែលព្រះសាស្ដាទ្រង់គ្រងហើយ ដើម្បីប្រយោជន៍ដល់ការគ្រង ។

បទថា **សម្មា វទមានោ វទេយ្យ** សេចក្ដីថា កាលបុគ្គលនឹងនិយាយឲ្យត្រូវ គប្បីនិយាយដល់បុគ្គលណាដោយគុណជាដើមថា បុត្ររបស់ព្រះ-មានព្រះភាគ កាលនិយាយដល់បុគ្គលនោះឲ្យត្រូវ គប្បីនិយាយដល់យើងថា យើងដែលមានសភាពបែបនេះ ដូច្នេះ ។ បព្វជ្ជាដែលព្រះថេរៈឲ្យបរិសុទ្ធិហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ ក្នុងសេចក្ដីនេះមានអធិប្បាយថា ម្នាលអាវុសោ ឧបជ្ឈាយ៍ អាចារ្យរបស់បុគ្គលណាមិនប្រាកដ ឧបជ្ឈាយ៍បុគ្គលនោះមិនមាន អាចារ្យមិនមាន កោរក្បាល កាន់យកសំពត់កាសាយៈ

ខ្លួនឯង ដល់ការរាប់ថា ចូលតិត្ថិយឬ បានការទទួលរហូតដល់អស់ផ្លូវ ៣ គាវុតយ៉ាងនេះ បានបព្វជ្ជា ឬឧបសម្បទាដោយឱវាទ ៣ បានផ្លាស់ប្តូរចីវរដោយកាយ អ្នកឃើញពាក្យ សូម្បីទុក្កាសិតត្រឹមណារបស់ថុល្លនន្ទាភិក្ខុនីទេ ។

[១៩៤] ព្រះថេរៈឲ្យបព្វជ្ជាបរិសុទ្ធិយ៉ាងនេះហើយ ឥឡូវនេះដើម្បីបន្លឺសីហនាទដោយអភិញ្ញា ៦ ទើបពោលពាក្យជាដើមថា **អហំ ខោ អាវុសោ** ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យមុនន្ទុ៎ះឯង ។

ចប់អដ្ឋកថា ចីវរសូត្រទី ១១

# អ ដ្ឋ ក ថា

## បរម្មរណសូត្រទី ១២

គប្បីជ្រាបវិនិច្ឆ័យក្នុង បរម្មរណសូត្រទី ១២ ដូចតទៅនេះ ៖

[១៨៧] បទថា តថាគតោ គឺ សត្វ ។ បទថា ន ហេតំ អាវុសោ អត្ថសញ្ហិតំ (នោះមិនប្រកបដោយប្រយោជន៍ទេ) សេចក្តីថា ម្នាលអាវុសោ ប្រការនោះ គឺ ទិដ្ឋិមិនអាស្រ័យប្រយោជន៍ ។ បទថា នាទិព្រហ្មចរិយកំ សេចក្តីថា មិនមែនជាវត្តបដិបត្តិខាងដើមនៃមគ្គព្រហ្មចរិយៈ ។

[១៨៨] បទថា ឯតញ្ហិ អាវុសោ អត្ថសញ្ហិតំ (ម្នាលអាវុសោ ព្រោះថា ពាក្យនេះប្រកបដោយប្រយោជន៍) សេចក្តីថា ពាក្យនោះ គឺ សច្ចកម្មដ្ឋាន ៤ អាស្រ័យប្រយោជន៍ ។ បទថា អាទិព្រហ្មចរិយកំ ពាក្យនោះ គឺ ខាងដើម បានដល់ វត្តបដិបត្តិខាងដើមនៃមគ្គព្រហ្មចរិយៈ ។

ចប់អដ្ឋកថា បរម្មរណសូត្រទី ១២

# អ ដ្ឋ ក ថា

## សទ្ធម្មបដិរូបកសូត្រទី ១៣

គប្បីជ្រាបវិនិច្ឆ័យក្នុងសទ្ធម្មបដិរូបកសូត្រទី ១៣ ដូចតទៅនេះ ៖

[១៩៩] បទថា អញ្ញាយ សណ្ឋហឹសុ ភិក្ខុតាំងនៅក្នុងព្រះអរហត្ត-ផល ។ បទថា សទ្ធម្មបដិរូបកំ បានដល់ សទ្ធម្មបដិរូប ២ គឺ សទ្ធម្មបដិរូប គឺ អធិគម ១ សទ្ធម្មបដិរូប គឺ បរិយត្តិ ១ ។ ក្នុងសទ្ធម្មបដិរូបនោះ

ឋានៈ ១០ ទាំងនេះគឺ ចិត្តរមែងញាប់ញ័រដោយឋានៈណា
គឺ ញាប់ញ័រក្នុងឱភាស ញាណ បីតិ បស្សទ្ធិ សុខ និង
ញាប់ញ័រក្នុងអធិមោក្ខៈ បគ្គាហៈ ឧបដ្ឋានៈ ឧបេក្ខាអាវជ្ជនៈ
ឧបេក្ខានិកន្តិ បញ្ញាដែលបុគ្គលណាអប់រំហើយ បុគ្គលនោះ
ជាអ្នកឈ្លាសក្នុងសេចក្តីរាយមាយក្នុងធម៌ នឹងមិនដល់ភាព
វង្វេង ដូច្នេះ ។

នេះឈ្មោះថា អធិគម គឺ សទ្ធម្មបដិរូបកៈ ដែលជាឧបក្កិលេសនៃវិបស្សនាញាណ ។

ចំណែកពាក្យមិនមែនព្រះពុទ្ធវចនៈ មានគុឡ្ហវិន័យ គុឡ្ហវេស្សន្តរ

គុម្ពហោសថ វណ្ណបិដក អង្គុលិមាលបិដក រដ្ឋបាលគជ្ជិតៈ និងវេទល្ល-បិដកជាដើម ក្រៅពីកថាវត្ថុទាំង ៤ នេះ គឺ ធាតុកថា អារម្មណកថា អសុភ-កថា ញាណវត្ថុកថា វិជ្ជាករណ្ឌកៈ ដែលមិនទាន់លើកឡើងកាន់សង្គាយនាទាំង ៣ លើក ឈ្មោះថា **សទ្ធម្មបដិរូប** គឺ **បរិយត្តិ** ។

[២០០] បទថា **ជាតរូបបដិរូបកំ** សេចក្តីថា វត្ថុដែលស្រដៀងនឹងមាសដែលជាងមាសច្នៃចេញជាគ្រឿងប្រដាប់ ។ ក៏ក្នុងវេលាមានមហោស្រពមនុស្សទាំងឡាយទៅ ដោយគិតថា យើងនឹងទទួលគ្រឿងអាករណៈ ដូច្នេះ ។ គ្រានោះ ឈ្មួញនិយាយនឹងពួកគេយ៉ាងនេះថា បើលោកត្រូវការអាករណៈអញ្ជើញទទួលអាករណៈទាំងនេះ ។ ព្រោះអាករណៈទាំងនេះក្រាស់ ពណ៌ល្អតម្លៃក៏ថោកផង ។ អ្នកទាំងនោះស្តាប់ឈ្មួញទាំងនោះ ហើយក៏ទទួលយកអាករណៈទាំងនោះទៅ ដោយគិតថា ឈ្មួញទាំងនេះប្រាប់ហេតុថា លោកប្រើអាករណៈទាំងនេះលេងនក្ខត្តឫក្សបាន ល្អក៏ល្អ ទាំងតម្លៃក៏ថោក ដូច្នេះ ។ មាសធម្មជាតិ គេមិនលក់ គេរក្សាទុក ។ កាលរបស់ស្រដៀងមាសកើតឡើង មាសធម្មជាតិនោះ ទើបឈ្មោះថា បាត់ទៅយ៉ាងនេះ ។

បទថា **អថ សទ្ធម្មស្ស អន្តរធានំ ហោតិ** បានដល់ សទ្ធម្មសូម្បី ៣ យ៉ាង គឺ **អធិគមសទ្ធម្ម បដិបត្តិសទ្ធម្ម បរិយត្តិសទ្ធម្ម** រមែងអន្តរធាន ។

ក៏ក្នុងបឋមពោធិកាល ពួកភិក្ខុបានដល់បដិសម្ភិទា ។ លុះកាលកន្លងទៅ ការដល់បដិសម្ភិទាមិនបាន តែក៏បានអភិញ្ញា ៦ តមកការដល់អភិញ្ញា ៦ មិនបាន ក៏ដល់វិជ្ជា ៣ ។ កាលកន្លងមកឥឡូវនេះ ការដល់វិជ្ជា ៣ មិនបាន នឹងដល់ត្រឹមតែការអស់ទៅនៃអាសវៈ ការដល់សូម្បីការអស់អាសវៈមិនបាន ក៏នឹងសម្រេចអនាគាមិផល ការសម្រេចសូម្បីអនាគាមិផលនោះមិនបាន ក៏នឹងសម្រេចសកទាគាមិផល កាលសូម្បីសម្រេចសកទាគាមិផលនោះមិនបាន ក៏នឹងសម្រេចសូម្បីសោតាបត្តិផល ។ កាលវេលាកន្លងទៅ នឹងសម្រេចសូម្បីសោតាបត្តិផលក៏មិនបាន ។ គ្រានោះ ក្នុងកាលណាវិបស្សនានឹងចាប់ផ្តើមសៅហ្មងដោយឧបក្កិលេសទាំងនេះ នឹងតាំងនៅត្រឹមតែប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ក្នុងកាលនោះ អធិគមសទ្ធម្មរបស់ពួកភិក្ខុទាំងនោះ ឈ្មោះថា វិនាសទៅ សូន្យទៅ ។ កាលបឋមពោធិកាល ពួកភិក្ខុញុំាងការបដិបត្តិដែលសមគួរដល់បដិសម្ភិទា ៤ ឲ្យបរិបូណ៌ កាលកន្លងទៅ ការបដិបត្តិប្រការនោះមិនបាន ក៏បដិបត្តិដែលសមគួរដល់អភិញ្ញា ៦ បានបរិបូណ៌ ការបដិបត្តិប្រការនោះសូម្បីមិនបាន ក៏បដិបត្តិដែលសមគួរដល់វិជ្ជា ៣ បានបរិបូណ៌ កាលបដិបត្តិប្រការនោះមិនបាន ក៏បដិបត្តិដែលសមគួរដល់ព្រះអរហត្តផលបានបរិបូណ៌ កាលកន្លងទៅ កាលបដិបត្តិដែលសម

គួរដល់ព្រះអរហត្តមិនបានបរិបូណ៌ ក៏នឹងបដិបត្តិដែលសមគួរដល់ព្រះអនា-គាមិផលបានបរិបូណ៌ បដិបត្តិសូម្បីប្រការនោះមិនបាន ក៏នឹងបដិបត្តិដែលសមគួរដល់ព្រះសកទាគាមិផលបានបរិបូណ៌ កាលបដិបត្តិសូម្បីប្រការនោះមិនបាន ក៏នឹងបដិបត្តិដែលសមគួរដល់សោតាបត្តិផលបានបរិបូណ៌ ។ ចំណែកក្នុងកាលណា កាលបដិបត្តិដែលសមគួរសូម្បីដល់ព្រះសោតាបត្តិផលមិនបានបរិបូណ៌ ក៏នឹងតាំងនៅត្រឹមតែសីលដែលបរិសុទ្ធិ ។ ក្នុងកាលនោះបដិបត្តិសទ្ធម្ម ឈ្មោះថា វិនាសសូន្យទៅ ។

នឹងពោលថា សាសនាមិនអន្តរធាន រហូតដល់វេលាដែលព្រះត្រៃបិដកពុទ្ធវចនៈនៅប្រព្រឹត្តទៅ ដូច្នេះក៏គួរ ។ម្យ៉ាងទៀត បិដកទាំង ៣ តាំងនៅកាលអភិធម្មបិដកវិនាសទៅ បិដក ២ ក្រៅពីនេះ ក៏នៅប្រព្រឹត្តទៅ មិនគួរពោលថា សាសនាអន្តរធាន ដូច្នេះ ។ កាលបិដក ២ វិនាសទៅ ក៏តាំងនៅត្រឹមតែវិន័យបិដក សូម្បីក្នុងវិន័យបិដកនោះ កាលខន្ធកបរិវារៈវិនាសទៅក៏តាំងនៅត្រឹមតែឧភតោវិភង្គ កាលមហាវិន័យវិនាសទៅ កាលបាតិមោក្ខទាំងពីរនៅប្រព្រឹត្តទៅ សាសនាអន្តរធានក៏មិនមែន ។ តែកាលណាបាតិ-មោក្ខទាំងពីរវិនាសទៅ កាលនោះបរិយត្តិសទ្ធម្ម ឈ្មោះថា អន្តរធាន ។ កាលបរិយត្តិសទ្ធម្មនោះវិនាសទៅ សាសនាឈ្មោះថា អន្តរធានហើយ ។ ព្រោះថា

កាលបរិយត្តិវិនាសទៅ ការបដិបត្តិក៏វិនាសទៅ កាលការបដិបត្តិវិនាសទៅ អធិគមក៏វិនាសទៅ ។ សួរថា ព្រោះហេតុអ្វី ។

ឆ្លើយថា បរិយត្តិនេះជាបច្ច័យដល់ការបដិបត្តិ ការបដិបត្តិជាបច្ច័យដល់អធិគម ។ នេះពោលអំពីការបដិបត្តិកំណត់បរិយត្តិប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

សួរថា ក្នុងសម័យព្រះកស្សបសម្មាសម្ពុទ្ធ អនាថារ ភិក្ខុឈ្មោះកបិល ចាប់ផ្ចិតអង្គុយលើអាសនៈ ដោយគិតថា យើងនឹងសូត្របាតិមោក្ខ ដូច្នេះ ទើបសួរថា ក្នុងទីនេះអ្នកសូត្របាតិមោក្ខមាននៅឬ ។ គ្រានោះ ភិក្ខុសូម្បីពួកណាសូត្របាដិមោក្ខបានក៏ពិត ទោះបីជាយ៉ាងនោះ ភិក្ខុទាំងនោះក៏មិននិយាយថា ពួកយើងសូត្របាន តែនិយាយថា ពួកយើងសូត្រមិនបាន ដូច្នេះ ព្រោះខ្លាច ភិក្ខុនោះលោកដាក់ផ្ចិតក្រោកចាកអាសនៈចេញទៅ ។ សួរថា ក្នុងកាលនោះ សាសនារបស់ព្រះសម្មាសម្ពុទ្ធឪសាបសូន្យហើយ មិនមែនឬ ។ ឆ្លើយថា សាបសូន្យក៏ពិត សូម្បីយ៉ាងនោះ ក៏កំណត់បរិយត្តិតែម្យ៉ាង ។ ប្រៀបដូចស្រះធំ មានមាត់ប្រាំងរឹងមាំ មិនគប្បីពោលថា មិនបានឃាំងទឹកទុក ដូច្នេះ កាលមានទឹក មិនគប្បីពោលថា ផ្កាឈើ មានផ្កាបទុមជាដើមនឹងមិនរីក ដូច្នេះ យ៉ាងណា ក៏ដូច្នោះដែរ កាលមានព្រះត្រៃបិដក គឺ ពុទ្ធ-

វចនៈ ដូចជាមាត់ប្រាំងរឹងមាំរបស់ស្រះធំ មិនគប្បីពោលថា មិនមានកុល-បុត្រញុំាងបដិបត្តិឲ្យបរិបូណ៌បាន ដូចជាទឹកក្នុងស្រះធំ ដូច្នេះ ។ តែកំណត់ដល់បរិយត្តិដោយចំណែកមួយយ៉ាងនេះថា កាលកុលបុត្រទាំងនោះមាននៅមិនគប្បីពោលថា ព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម មិនមានដូចផ្កាឈើ មានផ្កាបទុមជាដើមក្នុងស្រះទឹកធំ មិនមានដូច្នោះ ។

[២០១] បទថា **បឋវីធាតុ** បានដល់ មហាប្រថពីដែលមានកម្រាស់ពីរសែនបួនម៉ឺនទហុត ។

បទថា **អាបោធាតុ** បានដល់ ទឹកដែលញុំាងកប្បឲ្យវិនាស ចាប់ផ្តើមតាំងពីផែនដី ហើយជន់លិចខ្ពស់ឡើងទៅដរាបដល់ព្រហ្មលោកជាន់សុភ-កិណ្ហា ។

បទថា **តេជោធាតុ** បានដល់ ភ្លើងដែលញុំាងកប្បឲ្យវិនាស ផ្តើមពីផែនដី ឆេះឡើងទៅដរាបដល់ព្រហ្មលោកជាន់អាភស្សរា ។

បទថា **វាយោធាតុ** បានដល់ ខ្យល់ដែលញុំាងកប្បឲ្យវិនាស ចាប់ផ្តើមតាំងពីផែនដី ហើយបក់ឡើងទៅដរាបដល់ព្រហ្មលោកជាន់វេហប្ផលា ។

ក្នុងធម៌ មានបឋវីធាតុជាដើមទាំងនោះ សូម្បីធម៌មួយណា មិនអាចនឹងញុំាងសត្ថុសាសន៍ឲ្យអន្តរធានបាន ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់យ៉ាងនេះ ។

បទថា **ឥធេវ តេ ឧប្បជ្ជន្តិ** មោឃបុរសទាំងនោះ កើតឡើងក្នុងសាសនារបស់តថាគតនេះឯង ដូចច្រែះកើតពីដែកស៊ីនូវដែក ដូច្នោះ ។ បទថា **មោឃ-បុរិសា** គឺ បុរសទទេ ។

ក្នុងបទថា **អាទិកេនេវ ឱបិឡាវេតិ** គឺ ដោយការកាន់ បានដល់ចាប់ ។ បទថា **ឱបិឡាវេតិ** គឺ ក្រឡាប់ ឬលិច ។ មានអធិប្បាយថា ទូកនៅក្នុងទឹកផ្ទុកវត្ថុរមែងក្រឡាប់ ឬលិច យ៉ាងណា ព្រះសទ្ធម្ម រមែងមិនអន្តរធានទៅ ព្រោះពេញដោយបរិយត្តិជាដើម ដូច្នោះ ។ ព្រោះកាលណាបរិយត្តិសាបសូន្យ បដិបត្តិក៏សាបសូន្យ ។ កាលបដិបត្តិសាបសូន្យ អធិគមក៏សាបសូន្យ កាលបុគ្គលញុំាងបដិបត្តិឲ្យបរិបូណ៌ បុគ្គលដែលទ្រទ្រង់បរិ-យត្តិ ក៏ញុំាងបដិបត្តិឲ្យបរិបូណ៌បាន ។ បុគ្គលកាលញុំាងបដិបត្តិឲ្យបរិបូណ៌ហើយ ក៏ញុំាងអធិគម (បដិវេធ) ឲ្យបរិបូណ៌បាន ។ លោកសម្តែងថា កាលបរិយត្តិជាដើមចម្រើនហើយ សាសនារបស់តថាគតក៏ចម្រើនឡើង ដូចជាព្រះចន្ទដែលភ្លឺស្វាង ដូច្នោះ ។

ឥឡូវនេះ កាលទ្រង់សម្តែងធម៌ជាហេតុអន្តរធាន និងសេចក្តីតាំងនៅនៃព្រះសទ្ធម្ម ទើបត្រាស់ពាក្យជាដើមថា **បញ្ច ខោ** ដូច្នេះ ។

[២០២] ក្នុងបទទាំងនោះ បទថា **ឱក្កមនិយា** សេចក្តីថា ការឈាន

ចុះ គឺ ហេតុចំណែកក្រោម ។ បទថា **អគារវោ** ក្នុងបទថា **សត្ថរិ អគារវោ** ជាដើម បានដល់ ការមិនកោតក្រែង គឺ មិនប្រព្រឹត្តបន្ទាបខ្លួន ។ ក្នុងសេចក្តីមិនគោរពនោះ ភិក្ខុណាឡើងកាន់លានព្រះចេតិយ បាំងឆត្រ ពាក់ស្បែកជើង ក្រឡេកមើលទីដទៃ ដើរជជែកគ្នា ។ ភិក្ខុនេះ ឈ្មោះថា មិនមានសេចក្តីគោរពក្នុងព្រះសាស្តា ។

ភិក្ខុណា កាលគេប្រកាសវេលាស្តាប់ធម៌ ដែលមានភិក្ខុកម្មោះ និងសាមណេរអង្គុយចោមរោម ឬកំពុងធ្វើនវកម្មជាដើម អង្គុយដេកលក់ក្នុងរោងស្តាប់ធម៌ ឬជាអ្នករវើរវាយ អង្គុយជជែកគ្នារឿងដទៃ ភិក្ខុនេះ ឈ្មោះថា មិនមានសេចក្តីគោរពក្នុងព្រះធម៌ ។

ចំណែកភិក្ខុណា ទៅកាន់ទីបម្រើព្រះថេរៈ អង្គុយមិនថ្វាយបង្គំ គ្របោមក្បាលជង្គង់ដោយដៃ ឬសំពត់ ឬឃ្មើសឃ្នងដៃ និងជើង មិនបានទទួលការអារាធនា ក៏ពោលធម៌ក្នុងសម្នាក់របស់ព្រះថេរៈចាស់ ភិក្ខុនេះ ឈ្មោះថា មិនមានសេចក្តីគោរពក្នុងព្រះសង្ឃ ។

ចំណែកអ្នកមិនញ៉ាំងសិក្ខា ៣ ឲ្យបរិបូណ៌ ជាអ្នកឈ្មោះថា មិនមានសេចក្តីគោរពក្នុងសិក្ខា ។ អ្នកមិនញ៉ាំងសមាបត្តិ ៨ ឲ្យកើត ឬមិនធ្វើសេចក្តីព្យាយាម ដើម្បីការកើតសមាបត្តិទាំងនោះ ឈ្មោះថា មិនមានការ

គោរពក្នុងសមាធិ ។ ធម៌ចំណែកស គប្បីជ្រាបដោយផ្ទុយគ្នានឹងពាក្យដែលពោលហើយនោះឯង ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា សទ្ធម្មប្បដិរូបកសូត្រទី ១៣

# ចប់កស្សបសំយុត្ត

## រួមក្នុងវគ្គនេះមាន ១៣ អដ្ឋកថា


១-អដ្ឋកថាសន្តុដ្ឋសូត្រ
២-អដ្ឋកថាអនោត្តាបីសូត្រ
៣-អដ្ឋកថាចន្ទូបមសូត្រ
៤-អដ្ឋកថាកុលូបកសូត្រ
៥-អដ្ឋកថាជិណ្ណសូត្រ
៦-អដ្ឋកថាបឋមឱវាទសូត្រ
៧-អដ្ឋកថាទុតិយឱវាទសូត្រ
៨-អដ្ឋកថាតតិយឱវាទសូត្រ
៩-អដ្ឋកថាឈានាភិញ្ញាសូត្រ
១០-អដ្ឋកថាភិក្ខុនូបស្សយសូត្រ
១១-អដ្ឋកថាចិវរសូត្រ
១២-អដ្ឋកថាបរម្មរណសូត្រ
១៣-អដ្ឋកថាសទ្ធម្មប្បដិរូបកសូត្រ

# លាភសក្ការសំយុត្ត

## សុទ្ធកវគ្គ

## អ ដ្ឋ ក ថា

### សុទ្ធកសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុទ្ធកសូត្រទី ១ នៃលាភសក្ការសំយុត្ត ដូចតទៅនេះ ៖*

[២០៥] *បទថា **ទារុណោ** គឺ រឹងប៉ឹង ។ ការបានបច្ច័យ ៤ ឈ្មោះថា លាភ ក្នុងបទនេះថា **លាភសក្ការសិលោកោ** ។ បទថា **សក្ការោ** បានដល់ លាភរបស់ភិក្ខុទាំងនោះ ដែលពួកគេធ្វើល្អ គឺ តាក់តែងទុកល្អ ។ បទថា **សិលោកោ** គឺ សំឡេងសរសើរ ។ បទថា **កដុកោ** គឺ ក្ដៅផ្សា ។ បទថា **ផរុសោ** គឺ គ្រោតគ្រាត ។ បទថា **អន្តរាយិកោ** គឺ ធ្វើអន្តរាយ ។*

ចប់អដ្ឋកថា សុទ្ធកសូត្រទី ១

# អ ដ្ឋ ក ថា

## ពឡិសសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ពឡិសសូត្រទី ២** ដូចតទៅនេះ ៖*

*[២០៧] បទថា **ពាឡិសិកោ** បានដល់ ព្រានសន្ទូចកាន់យកសន្ទូចត្រាច់សម្លាប់ត្រី ។ បទថា **អាមិសគតំ** គឺ ជាប់ដោយនុយ ។ បទថា **អាមិសចក្ខុ** បានដល់ ឈ្មោះអាមិសចក្ខុ ព្រោះអត្ថថា ឃើញសន្ទូចជាប់នុយ ។ បទថា **គិលពឡិសោ** គឺ លេបសន្ទូច ។ បទថា **អនយំ អាបន្នោ** បានដល់ ដល់នូវទុក្ខ ។ បទថា **ព្យសនំ អាបន្នោ** បានដល់ ដល់សេចក្តីវិនាស ។ បទថា **យថាកាមករណីយោ** សេចក្តីថា ព្រានសន្ទូចប្រាថ្នាត្រីនោះតាមត្រូវការ គឺ តាមសេចក្តីពេញចិត្ត យ៉ាងណា គប្បីធ្វើត្រីនោះបានយ៉ាងនោះ ។*

*[២០៨] បទថា **យថាកាមករណីយោ បាបិមតោ** សេចក្តីថា ដែលមារ គឺ កិលេស គប្បីធ្វើបានតាមសេចក្តីប្រាថ្នា គឺ គប្បីឲ្យដល់នរក កំណើតសត្វតិរច្ឆាន ឬប្រេតវិស័យក៏បាន ។*

ចប់អដ្ឋកថា ពឡិសសូត្រទី ២

# អ ដ្ឋ ក ថា

## កុម្ភសុត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង កុម្ភសូត្រទី ៣ ដូចតទៅនេះ ៖

[២១១] បទថា **មហាកុម្ភកុលំ** បានដល់ ត្រកូលអណ្តើកមានស្នូកធំ ។ បទថា **អគមាសិ** សេចក្តីថា បានទៅដោយសេចក្តីសម្គាល់ថា ក្នុងទីនេះគប្បីមានរបស់យ៉ាងណាមួយស៊ីដោយពិត កាលគេកំណាញ់វត្ថុនោះ ទើបហាមយើង ដូច្នេះ ។ បទថា **បបតាយ** (មូល) បន្ទាដែក មានសណ្ឋានស្រដៀងផ្កាក្រពុំ មានឆ្នៀង ចងដោយខ្សែវែង ស៊កទុកក្នុងដងឈើកាន់ទៅ ពេលពួយទៅជាប់ត្រង់ស្នូកអណ្តើក ឈើក៏របូតចេញដោយរហ័ស នៅជាប់តែខ្សែជាមួយផ្លែ លោកហៅថា មូល ។ បទថា **សោ កុម្មោ** គឺ អណ្តើកនោះ ត្រូវគេពួយ ។ បទថា **យេន សោ កុម្មោ** សេចក្តីថា អណ្តើកដែលត្រូវគេពួយដែលមានសេចក្តីត្រូវការ (ចេញទៅខាងក្រៅ) នោះ ទើបត្រឡប់មកវិញ ដោយគិតថា សេចក្តីសង្ស័យនឹងមាន ព្រោះបានឮសំឡេងទឹក ដូច្នេះ ។ ឈ្មោះថា កុម្មៈ អណ្តើក ។ បទថា **នទានិ ត្វំ អម្ហាកំ** សេចក្តីថា ឥឡូវនេះលោកនៅក្នុងកណ្តាប់ដៃរបស់សត្រូវ មិនមែនដូចពួករបស់យើងទេ ។ មួយទៀត

នាយព្រានទៅក្នុងទូកទាញខ្សែមកចងអណ្តើកដែលសន្ទូនាយ៉ាងនេះ ធ្វើបាន តាមប្រាថ្នា ។ ពាក្យដ៏សេសក្នុងសូត្រនេះ និងក្នុងសូត្រតអំពីនេះ ងាយទាំង អស់នោះឯង ។

ចប់អដ្ឋកថា កុម្មសូត្រទី ៣

# អ ដ្ឋ ក ថា

## ទីឃលោមសូត្រទី ៤

*មិនមានសេចក្តីអធិប្បាយរបស់ព្រះអដ្ឋកថាទេ ។*

# អ ដ្ឋ ក ថា

## ឯឡកសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឯឡកសូត្រទី ៥ ដូចតទៅនេះ ៖*

[២១៦] *បទថា* ***កំសឡកា*** *គឺ សត្វកំពោង ។ បទថា* ***គូថាទី*** *គឺ មានលាមកជាអាហារ ។ បទថា* ***គូថបូរា*** *គឺ ខាងក្នុងពេញដោយលាមក ។ បទថា* ***បុណ្ណា គូថស្ស*** *នេះ សម្តែងសេចក្តីបទដំបូងប៉ុណ្ណោះ ។ បទថា* ***អតិមញ្ញេយ្យ*** *សេចក្តីថា សត្វកំពោងនោះដាក់ជើងក្រោយទុកលើផែនដី លើកជើងមុខដាក់លើលាមក ហើយនិយាយបែបមើលងាយថា យើងមានលាមកជាអាហារ ដូច្នេះជាដើម ។ បទថា* ***បិណ្ឌបាតោបស្ស បូរោ*** *សេចក្តីថា បិណ្ឌ-បាតដែលប្រណីតពេញបាត្រសូម្បីដទៃទៀត គប្បីមានដល់គេ ។*

ចប់អដ្ឋកថា ឯឡកសូត្រទី ៥

# អ ដ្ឋ ក ថា

## អសនិសុត្រទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុង *អសនិសូត្រទី ៦* ដូចតទៅនេះ ៖

[២១៨] បទថា *កំ ភិក្ខវេ អសនិវិចក្កំ* សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ កាំរន្ទះធ្លាក់ចុះមកទម្លាយលើសីសៈបុគ្គលណា ។ បទថា **អប្បត្តមានសំ** គឺ ព្រះអរហត្តផលដែលខ្លួនមិនទាន់សម្រេច ។ ព្រះមានព្រះភាគត្រាស់ ព្រោះប្រាថ្នាសេចក្ដីទុក្ខដល់សត្វក៏មិនមែន តែត្រាស់យ៉ាងនេះ ដើម្បីសម្ដែងទោសដោយប្រការដូច្នេះ ។ សេចក្ដីពិត កាំរន្ទះធ្លាក់ចុះលើសីសៈ ឲ្យអត្តភាពតែម្យ៉ាងប៉ុណ្ណោះវិនាស បុគ្គលមានចិត្តជាប់ក្នុងលាភសក្ការៈ និងសេចក្ដីសរសើរ រមែងសោយអនន្តទុក្ខក្នុងនរកជាដើម ។

ចប់អដ្ឋកថា អសនិសុត្រទី ៦

# អ ដ្ឋ ក ថា

## ទិដ្ឋិសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង* ***ទិដ្ឋិសូត្រទី ៧*** *ដូចតទៅនេះ ៖*

[២១៩] *បទថា* ***ទិដ្ឋិគតេន*** *គឺ ទិដ្ឋិ ។ បទថា* ***វិសេន*** *គឺ លាបដោយពិស ។*

[២២០] *បទថា* ***សល្លេន*** *គឺ កូនសរ ។*

ចប់អដ្ឋកថា ទិដ្ឋិសូត្រទី ៧

# អ ដ្ឋ ក ថា

## សិង្គាលសូត្រទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុង សិង្គាលសូត្រទី ៨ ដូចតទៅនេះ ៖

[២២២] បទថា ជរសិគាលោ គឺ ចចក ។ កាយសម្បុរមានពណ៌ដូចមាស គេក៏ហៅថា កាយស្អុយ មូត្រសម្បុរបន្ទោបង់ក្នុងខណៈនោះ គេក៏ហៅថា មូត្រ យ៉ាងណា ចចកសម្បុរកើតក្នុងថ្ងៃនោះ គេក៏ហៅថា ចចកចាស់ដូច្នោះ ។ បទថា ឧក្កណ្ណកេន នាម (រោគអង្គែ) បានដល់ រោគមានឈ្មោះយ៉ាងនេះ ។ បានឮថា រោគនោះកើតក្នុងវេលាត្រជាក់ ។ កាលវាកើត រោមក៏ជ្រុះអំពីសរីរៈទាំងអស់ ។ សរីរៈទាំងអស់មិនមានរោម រមែងមានពងខ្ទុះពេញសរីរៈទាំងអស់ ដំបៅដែលត្រូវខ្យល់បក់ ចាក់សៀត (ដូច) មនុស្សត្រូវឆ្កែឆ្កួតខាំ នឹងមិនវិលទៅសភាពដើម ឬមិនតាំងនៅតាមសភាពដើមបានយ៉ាងណា កាលចចកនោះកើតរោគយ៉ាងនេះ វាគប្បីទៅដូច្នោះ មិនប្រាកដថា ក្នុងទីឯណោះនឹងមានសេចក្តីសុខ ដូច្នេះ ។

ចប់អដ្ឋកថា សិង្គាលសូត្រទី ៨

# អ ដ្ឋ ក ថា

## វេរម្ភសូត្រទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុង **វេរម្ភសូត្រទី ៩** ដូចតទៅនេះ ៖

[២២៤] បទថា **វេរម្ភវាតា** (ខ្យល់ព្យុះ) បានដល់ ខ្យល់ធំមានឈ្មោះយ៉ាងនេះ ។ សួរថា ក៏ខ្យល់ទាំងនោះបក់ក្នុងទីណា ។ ឆ្លើយថា បុគ្គលឈរក្នុងទីណា កោះទាំង ៤ ប្រាកដដូចស្លឹកឈូក ។ បទថា **យោ បក្ខី គច្ឆតិ** សេចក្ដីថា កាលភ្លៀងធ្លាក់ថ្មី សត្វបក្សីស្រែកយំត្រាច់ទៅក្នុងទីនោះ នោះលោកសំដៅដល់ប្រការនោះ ទើបពោល ។ ក្នុងបទជាដើមថា **អរក្ខិតេនេវ កាយេន** សេចក្ដីថា គ្រវាសដៃ និងជើងលេង ឬផ្អៀងក ឈ្មោះថា មិនរក្សាកាយ ។ និយាយពាក្យគ្រោតគ្រាតច្រើនយ៉ាង ឈ្មោះថា មិនរក្សាវាចា ។ បុគ្គលត្រិះរិះក្នុងកាមជាដើម ឈ្មោះថា មិនរក្សាចិត្ត ។ បទថា **អនុបដ្ឋិតាយ សតិយា** បានដល់ មិនតាំងនៅក្នុងកាយគតាសតិ ។

ចប់អដ្ឋកថា វេរម្ភសូត្រទី៩

# អ ដ្ឋ ក ថា

## សគយ្ហកសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង សគយ្ហកសូត្រទី ១០ ដូចតទៅនេះ ៖*

*[២២៧] បទថា **អសក្ការេន ចូកយំ** បានដល់ អសក្ការៈ ២ យ៉ាង ។ បទថា **សមាធិ** គឺ អរហត្តផលសមាធិ ។ ក៏សមាធិនោះ មិនញាប់ញ័រដោយអសក្ការៈនោះ ។*

*បទថា **អប្បមាណវិហារិនោ** គឺ នៅដោយផលសមាធិ រកប្រមាណមិនបាន ។ បទថា **សាតតិកំ** គឺ ធ្វើជាប់តគ្នា ។ បទថា **សុខុមទិដ្ឋិវិបស្សកំ** សេចក្តីថា ឈ្មោះថា ឃើញច្បាស់ ព្រោះផ្តើមតាំងវិបស្សនាក្នុងអរហត្តមគ្គទិដ្ឋិ ដើម្បីប្រយោជន៍ដល់ទិដ្ឋិដ៏ល្អិតសុខុមក្នុងផលសមាបត្តិ ។ បទថា **ឧបាទានក្ខយារាមំ** បានដល់ ត្រេកអរក្នុងនិព្វាន ពោលគឺ ជាទីអស់ឧបាទាន ។ បទថា **អាហុ សប្បុរិសោ** បានដល់ ពោលគឺ សប្បុរស ។*

ចប់អដ្ឋកថា សគយ្ហកសូត្រទី ១០

# ចប់សុទ្ធកវគ្គ នៃលាភសក្ការសំយុត្ត

## រួមក្នុងវគ្គនេះមាន ៩ អដ្ឋកថា


១-អដ្ឋកថាសុទ្ធកសូត្រ
២-អដ្ឋកថាពទ្ធិសសូត្រ
៣-អដ្ឋកថាកុម្មសូត្រ
៤-ឌីឃលោមសូត្រ មិនមានអដ្ឋកថា
៥-អដ្ឋកថាឯឡកសូត្រ
៦-អដ្ឋកថាអសនិសូត្រ
៧-អដ្ឋកថាទិទ្ធិសូត្រ
៨-អដ្ឋកថាសិង្គាលសូត្រ
៩-អដ្ឋកថាវេរម្ភសូត្រ
១០-អដ្ឋកថាសកឃ្ឍកសូត្រ

# ធាតុវគ្គ

## អ ដ្ឋ ក ថា

## សុវណ្ណធាតុសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យ *សុវណ្ណធាតុសូត្រទី ១* នៃវគ្គទី ២ ដូចតទៅនេះ ៖

[២២៩] *បទថា* **សម្បជានមុសា ភាសន្តំ** *សេចក្តីថា ពោលមុសាទាំងដែលដឹងខ្លួនដោយហេតុសូម្បីត្រឹមតែបន្តិចបន្តួច ។ បទថា* **សីលំ បូរេស្សាមិ** *សេចក្តីថា គំនរបច្ច័យសូម្បីប៉ុនភ្នំសិនេរុ មិនអាចធ្វើឲ្យភិក្ខុដែលមានចិត្តបញ្ជូនទៅហើយថា យើងនឹងញុំាងសីលឲ្យបរិបូណ៌ ដូច្នេះ ញាប់ញ័របាន ។ ក៏កាលណាអ្នកលះបង់សីល អាស្រ័យលាភ និងសក្ការៈ ក្នុងកាលនោះ អ្នកក៏និយាយកុហក សូម្បីព្រោះមានកន្ទក់[១]មួយក្តាប់ជាហេតុ ឬធ្វើវត្តុដទៃដែលមិនមែនកិច្ច ។*

ចប់អដ្ឋកថា សុវណ្ណធាតុសូត្រទី ១

---

*១-បាលី : កុណ្ឌក*

# អ ដ្ឋ ក ថា

## រូបិយចាតិសូត្រទី ២

*មិនព្រះអដ្ឋកថាជួយកែសេចក្តីទេ ព្រោះងាយទាំងអស់ហើយ ។*

ចប់អដ្ឋកថា រូបិយចាតិសូត្រទី២

# អ ដ្ឋ ក ថា

## សុវណ្ណនិក្ខសូត្រទី ៣ ជាដើម

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុវណ្ណនិក្ខសូត្រទី ៣ ជាដើម ។*

[២៣២] *បទថា* ***សុវណ្ណនិក្ខស្ស*** *គឺ ដុំមាសមួយដុំ ។ បទថា* ***សិង្គិនិក្ខស្ស*** *គឺ ដុំមាសសិង្គី ។ បទថា* ***បឋវិយា*** *គឺ ផែនដីធំខាងក្នុងចក្រវាឡ ។*

*បទថា* ***អាមិសកិញ្ចិក្ខហេតុ*** *បានដល់ ព្រោះហេតុនៃអាមិសតិចតួចប៉ុណ្ណោះ គឺ ដោយហោចទៅសូម្បីកន្ទក់មួយក្តាប់ ។ បទថា* ***ជីវិតហេតុ*** *សេចក្តីថា កាលត្រូវចោរក្នុងព្រៃចាប់ផ្តាច់ជីវិត ព្រោះហេតុនៃជីវិតនោះ ។ បទថា* ***ជនបទកល្យាណិយា*** *គឺ ស្រីមានលំអរក្នុងជនបទ ។*

ចប់អដ្ឋកថា សុវណ្ណនិក្ខសូត្រទី ៣ ជាដើម

## ចប់ចាតិវគ្គ នៃលាភសក្ការសំយុត្ត

### រួមក្នុងវគ្គនេះមាន ៣ អដ្ឋកថា

១-អដ្ឋកថាសុវណ្ណចាតិសូត្រ ២-អដ្ឋកថារូបិយចាតិសូត្រ

៣-អដ្ឋកថាសុវណ្ណនិក្ខសូត្រ ៤-សូត្រទី ៤ ជាដើម មិនមានអដ្ឋកថា

# មាតុគាមវគ្គ

## អ ដ្ឋ ក ថា

### មាតុគ្រាមសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង មាតុគ្រាមសូត្រទី ១ នៃវគ្គទី ៣ ដូចតទៅនេះ ៖*

[២៣៤] *បទថា ន តស្ស ភិក្ខវេ មាតុគាមោ សេចក្តីថា លាភសក្ការៈនិងសេចក្តីសរសើរ រួបរឹតចិត្តរបស់ភិក្ខុណាបាន មាតុគ្រាមសូម្បីមានសេចក្តីត្រូវការដោយធម៌ មិនអាចនឹងញ៉ាំញីចិត្តរបស់ភិក្ខុតែមួយរូបអ្នកអង្គុយនៅក្នុងទីកំបាំងនោះបាន ។*

ចប់អដ្ឋកថា មាតុគ្រាមសូត្រទី ១

# អ ដ្ឋ ក ថា

## ជនបទកល្យាណីសូត្រទី ២

*ជនបទកល្យាណីសូត្រទី ២ ងាយទាំងអស់នោះឯង ។*

# អ ដ្ឋ ក ថា

## បុត្តសូត្រទី ៣

[២៣៨] *ក្នុងបុត្តសូត្រទី ៣ បទថា សទ្ធា គឺ សោតាបន្ន ។ ពាក្យដ៏សេសក្នុងបទទាំងនេះ ក៏ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា បុត្តសូត្រទី ៣

*ក្នុង ឯកធីតុសូត្រទី ៤ ក្នុង សមណព្រាហ្មណសូត្រទី ៥ ក្នុង សមណព្រាហ្មណសូត្រទី ៦ ក៏យ៉ាងនោះ ។*

ចប់អដ្ឋកថា ឯកធីតុសូត្រទី ៤ ជាដើម

# អ ដ្ឋ ក ថា

## សមណព្រាហ្មណសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមណព្រាហ្មណសូត្រទី ៧ ដូចតទៅនេះ ៖*

*[២៤៤] ក្នុងបទជាដើមថា សមុទយំ សេចក្តីថា ឈ្មោះថា ហេតុកើតនៃលាភ និងសក្ការៈជាដើម យ៉ាងនេះថា អត្តភាពព្រមដោយបុព្វកម្ម ភាពជាអ្នកមានសម្បុរល្អក្នុងបុត្រអ្នកមានត្រកូល សំឡេងពីរោះ ធុតង្គគុណ ទ្រទ្រង់ចីវរ បរិវារសម្បត្តិ ។ មិនដឹងហេតុកើតនោះ ដោយអំណាចសមុទយសច្ចៈ ។ និរោធ និងបដិបទា គប្បីជ្រាបដោយអំណាចនិរោធសច្ចៈ និងមគ្គសច្ចៈនុ៎ះឯង ។*

ចប់អដ្ឋកថា សមណព្រាហ្មណសូត្រទី ៧

# អ ដ្ឋ ក ថា

## ឆវិសុត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឆវិសូត្រទី ៨ ដូចតទៅនេះ ៖*

[២៤៥] *ព្រោះថា លាភសក្ការៈ និងសេចក្ដីសរសើរ (ជាហេតុ) ឲ្យកើតក្នុងនរកជាដើម ញ៉ាំងអត្តភាពនេះសូម្បីទាំងអស់ឲ្យវិនាស សេចក្ដីស្ងាប់ក្ដី សេចក្ដីទុក្ខស្មើរតែនឹងស្លាប់ក្ដី នាំទុក្ខមកឲ្យសូម្បីក្នុងអត្តភាពនេះ ដូច្នោះ លោកពោលពាក្យជាដើមថា ឆវឹ ឆិន្ទតិ ដូច្នេះ ។*

ចប់អដ្ឋកថា ឆវិសូត្រទី ៨

# អ ដ្ឋ ក ថា

## វជ្ឈសូត្រទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុង វជ្ឈសូត្រទី ៩ ដូចតទៅនេះ ៖

[២៤៧] បទថា ពាលវជ្ឈយា បានដល់ ខ្សែធ្វើដោយអំបោះជាដើម ទន់ ខ្សែធ្វើដោយកន្ទុយសត្វ រឹង គ្រោតគ្រាត ព្រោះដូច្នោះ លោកកាន់យកខ្សែនេះឯង ។

ចប់អដ្ឋកថា វជ្ឈសូត្រទី៩

# អ ដ្ឋ ក ថា

## ភិក្ខុសូត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុងភិក្ខុសូត្រទី ១០ ដូចតទៅនេះ ៖

[២៤៩] បទថា *ទិដ្ឋធម្មសុខវិហារា* គឺ នៅជាសុខដោយផលសមាបត្តិ ។ បទថា *តេសាហមស្ស* កាត់បទថា *តេសំ អហំ អស្ស* ។ ក៏ព្រោះព្រះវីណាស្រេពមានលាភដល់ព្រមដោយបុណ្យ ទទួលយាគូ និងរបស់ទំពាស៊ីជាដើម កាលធ្វើអនុមោទនា សម្ដែងធម៌ដោះស្រាយបញ្ហាដល់ជនអ្នកមកហើយ មកហើយ រមែងមិនបានឱកាសដើម្បីនឹងអង្គុយតាំងមាំក្នុងផលសមាបត្តិ លោកសំដៅដល់ប្រការនោះ ទើបពោលដោយប្រការ ដូច្នេះ ។

ចប់អដ្ឋកថា ភិក្ខុសូត្រទី ១០

## ចប់មាតុគ្គាមវគ្គ នៃលាភសក្ការសំយុត្ត

### រួមក្នុងវគ្គនេះមាន ៧ អដ្ឋកថា

១-អដ្ឋកថាមាតុគាមសូត្រ
២-អដ្ឋកថាជនបទកល្យាណីសូត្រ
៣-អដ្ឋកថាបុត្តសូត្រ
៤-សូត្រទី ៤-៥-៦ មិនមានអដ្ឋកថា
៧-អដ្ឋកថាតតិយសមណព្រាហ្មណសូត្រ
៨-អដ្ឋកថាឆវិសូត្រ
៩-អដ្ឋកថារជ្ជុសូត្រ
១០-អដ្ឋកថាភិក្ខុសូត្រ

# ភេទវគ្គ

## អ ដ្ឋ ក ថា

## ភិន្ទិសូត្រទី ១

[២៥០] *គប្បីជ្រាបវិនិច្ឆ័យក្នុង ភិន្ទិសូត្រទី ១ នៃចតុត្ថវគ្គទី ៤ ងាយទាំងនោះឯង ។*

ចប់អដ្ឋកថា ភិន្ទិសូត្រទី ១

# អ ដ្ឋ ក ថា

## មូលសូត្រទី ២ ជាដើម

*គប្បីជ្រាបវិនិច្ឆ័យក្នុង មូលសូត្រទី ២ ជាដើម ដូចតទៅនេះ ៖*

*[២៥១] បទថា កុសលមូលំ បានដល់ កុសលធម៌ ៣ យ៉ាង មាន អលោភៈជាដើម ។*

*ម្យ៉ាងទៀត បទថា សុក្កា ធម្មា បានដល់ បរិយាយទេសនានៃ កុសលធម៌នោះឯង ។ ចំណែកសេចក្ដីសង្ខេបក្នុងសេចក្ដីនេះ មានដូច្នេះ ទេវទត្តគប្បីកើតក្នុងស្ថានសួគ៌ ឬគប្បីសម្រេចមគ្គផលបាន ព្រោះកម្មដែលមិនមានទោស ពោលគឺ កុសលមូលជាដើមមិនទាន់ទម្លាយ ។ តែទេវទត្តនោះ អាស្រ័យការកាត់ផ្ដាច់នៃកុសលធម៌នោះ ទើបដាច់ហើយ ទើបវិនាសហើយ ។*

ចប់អដ្ឋកថា មូលសូត្រទី ២ ជាដើម

**បឋមធម្មសូត្រទី ៣** មិនមានអដ្ឋកថាអធិប្បាយ ។

**ទុតិយធម្មសូត្រទី ៤** មិនមានអដ្ឋកថាអធិប្បាយ ។

# អ ដ្ឋ ក ថា

## បកន្តេសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង បកន្តេសូត្រទី ៥ ដូចតទៅនេះ ៖*

*[២៥៤] បទថា **បរាភវាយ** សេចក្តីថា ដើម្បីសេចក្តីមិនចម្រើន គឺសេចក្តីវិនាស ។*

*[២៥៨] បទថា **អស្សតរី** សេចក្តីថា សេះអស្សតរ កើតក្នុងផ្ទៃរបស់មេសេះ ។ បទថា **អត្តវធាយ គព្ភំ គណ្ហាតិ** សេចក្តីថា សូម្បីមេសេះអស្សតរ មានគភ៌នោះនឹងបាសេះ ។ មេសេះអស្សតរនោះ តាំងគភ៌ មិនអាចនឹងឲ្យកូនកើតបាន កាលដល់វេលា ឈរយកជើងកកាយដី កាលបើដូច្នោះ គេទើបចងជើងទាំង ៤ របស់មេសេះអស្សតរនោះទុកត្រង់បង្គោល ៤ ហើយវះពោះយកកូនចេញ ។ មេសេះអស្សតរនោះ ស្លាប់ក្នុងទីនោះឯង ។ ព្រោះហេតុនោះ លោកទើបពោលប្រការនោះ ។*

ចប់អដ្ឋកថា បកន្តេសូត្រទី ៥

# អ ដ្ឋ ក ថា

## វេថសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង **វេថសូត្រទី ៦** ដូចតទៅនេះ ៖*

[២៦០] *បទថា **ភត្តាភិហារោ** បានដល់ ភត្តដែលគេគប្បីនាំមក ។ ក៏ដើម្បីសម្ដែងប្រមាណក្នុងភត្តនោះ លោកទើបពោលថា **បញ្ច ច ថាលិ-បាកសតានិ** ។ ក្នុងភត្តទាំងនោះ ភត្តមួយថាសបុរសបរិភោគបាន ១០ នាក់ ។*

[២៦២] *បទថា **នាសាយ បិត្តំ ភិន្ទេយ្យុំ** សេចក្ដីថា គេដាក់ប្រមាត់ខ្លាឃ្មុំ ឬប្រមាត់ត្រីក្នុងប្រមុះ (ឆ្កែ) ។*

ចប់អដ្ឋកថា វេថសូត្រទី ៦

# អ ដ្ឋ ក ថា

## មាតុសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង មាតុសូត្រទី ៧ ដូចតទៅនេះ ៖*

*[២៦៤] បទថា មាតុបិ ហេតុ សេចក្ដីថា គេត្រូវពួកចោរសួរក្នុងព្រៃយ៉ាងនេះថា ប្រសិនបើអ្នកនិយាយកុហក យើងនឹងព្រលែងមាតារបស់អ្នក ប្រសិនបើមិននិយាយកុហក យើងនឹងមិនលែង ដូច្នេះ មិនគប្បីនិយាយកុហកទាំងដឹងខ្លួន ព្រោះហេតុសូម្បីនៃមាតា ព្រោះមាតានោះនៅក្នុងកណ្ដាប់ដៃចោរ ។ សូម្បីក្នុងបទដទៃអំពីនេះ ក៏មានន័យដូចគ្នានោះឯង ។*

ចប់អដ្ឋកថា មាតុសូត្រទី ៧

ព្រះសូត្រទី ៨ ដល់ទី ១៣ មិនមានអដ្ឋកថា

## ចប់ភេទវគ្គ នៃលាភសក្ការសំយុត្ត

### រួមក្នុងវគ្គនេះមាន ៧ អដ្ឋកថា

| | |
|---|---|
| ១-អដ្ឋកថាភិន្ទិសូត្រ | ២-អដ្ឋកថាមូលសូត្រ |
| ៣-អដ្ឋកថាបឋមធម៌សូត្រ | ៤-អដ្ឋកថាទុតិយធម៌សូត្រ |
| ៥-អដ្ឋកថាបក្កន្តសូត្រ | ៦-អដ្ឋកថារថសូត្រ |
| ៧-អដ្ឋកថាមាតុសូត្រ | ៨-សូត្រទី៨ជាដើម មិនមានអដ្ឋកថា |

# រាហុលសំយុត្ត

## អប្បមាទវគ្គ

## អ ដ្ឋ ក ថា

### ចក្ខុសូត្រទី ១

*ចក្ខុសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៦៧] បទថា **ឯកោ** បានដល់ មានប្រក្រតីនៅតែម្នាក់ឯង ក្នុងឥរិយាបថទាំង ៤ ។ បទថា **វូបកដ្ឋោ** ប្រែថា ចៀសចេញ ចាកចេញ ។ បទថា **អប្បមត្តោ** បានដល់ តាំងនៅក្នុងភាពជាអ្នកមិនប្រាសចាកសតិ ។ បទថា **អាតាបី** បានដល់ ដល់ព្រមដោយសេចក្តីព្យាយាម ។*

*បទថា **បហិតត្តោ វិហរេយ្យំ** បានដល់ ជាអ្នកមានចិត្តបញ្ជូនទៅដើម្បីប្រយោជន៍ដល់ការសម្រេចគុណវិសេស ។*

*[២៦៨] បទថា **អនិច្ចំ** បានដល់ ឈ្មោះថា មិនទៀង ដោយអាការដែលមានហើយក៏មិនមានវិញ ។ ន័យមួយទៀត ឈ្មោះថា មិនទៀង ដោយហេតុសូម្បីទាំងនេះ គឺ ព្រោះមានការកើតឡើង និងការវិនាសទៅ ។ ព្រោះ*

ជារបស់ប្រព្រឹត្តទៅមួយរយៈខ្លី ព្រោះមានសេចក្តីប្រែប្រួលជាទីបំផុត ព្រោះបដិសេធសេចក្តីទៀង ។

បទថា **ទុក្ខំ** បានដល់ ឈ្មោះថា ទុក្ខ ដោយហេតុ ៤ ប្រការ គឺ ដោយអត្ថថា **ទ្រាំបានលំបាក** ដោយអត្ថថា **ជាវត្ថុដែលជាទីតាំងនៃសេចក្តីទ្រាំបានលំបាក** ។ ដោយអត្ថថា **បៀតបៀនសត្វដោយការបដិសេធសេចក្តីសុខ** ។ ត្រាស់ថា គួរឬ ប្រកាន់ដោយតណ្ហាថា នុ៎ះរបស់យើង ប្រកាន់ដោយមានះថា នុ៎ះជាយើង ប្រកាន់ដោយទិដ្ឋិថា នុ៎ះជាខ្លួនយើង ។

បណ្តាសេចក្តីប្រកាន់ទាំងនោះ ប្រកាន់ដោយតណ្ហា ក៏គប្បីជ្រាបដោយអំណាចតណ្ហាវិចរិត ១០៨ , ប្រកាន់ដោយមានះ ក៏គប្បីជ្រាបដោយអំណាចមានះ ៩ ប្រការ , ប្រកាន់ដោយទិដ្ឋិ ក៏គប្បីជ្រាបដោយអំណាចទិដ្ឋិ ៦២ ។

[២៦៩] ក្នុងពាក្យថា **និព្វិន្ទំ វិរជ្ជតិ** នេះ ត្រាស់មគ្គ ៤ ដោយអំណាចវិរាគៈ ។ ក្នុងពាក្យថា **វិរាគា វិមុច្ចតិ** នេះ ទ្រង់ត្រាស់សាមញ្ញផល ៤ ដោយអំណាចវិមុត្តិ ។

ក៏ក្នុងព្រះសូត្រទី ១ នេះ ទ្រង់កាន់យកបសាទរូបក្នុងទ្វារ ៥ ។ ទ្រង់កាន់យកសមន្នាហារចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយបទនេះថា **មនោ** ។

ចប់អដ្ឋកថា ចក្ខុសូត្រទី ១

# អ ដ្ឋ ក ថា

## រូបសូត្រទី ២

[២៧០] ក្នុង រូបសូត្រទី ២ ទ្រង់កាន់យកអារម្មណ៍តែមួយ៉ាង ក្នុងទ្វារ ៥ ។

ចប់អដ្ឋកថា រូបសូត្រទី ២

# អដ្ឋកថា

## វិញ្ញាណសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង វិញ្ញាណសូត្រទី ៣ ដូចតទៅនេះ ៖

[២៧២] ក្នុងទ្វារទាំង ៥ ទ្រង់កាន់យកចិត្តដែលមានបសាទជាទីអាស្រ័យប៉ុណ្ណោះក្នុងទ្វារទាំង ៥ ទ្រង់កាន់យកសមន្នាហារចិត្ត ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយមនោវិញ្ញាណ ។ គប្បីនាំន័យទៅប្រើក្នុងទីគ្រប់កន្លែងយ៉ាងនេះ ។

ចប់អដ្ឋកថា វិញ្ញាណសូត្រទី ៣

សម្ផស្សសូត្រទី ៤ មិនមានអដ្ឋកថា អធិប្បាយ ។

វេទនាសូត្រទី ៥ មិនមានអដ្ឋកថា អធិប្បាយ ។

# អ ដ្ឋ ក ថា

## សញ្ញាសូត្រទី ៦

[២៧៨] ក្នុង *សញ្ញាសូត្រទី ៦ ទ្រង់កាន់យកធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។*

ចប់អដ្ឋកថា សញ្ញាសូត្រទី ៦

*ចេតនាសូត្រទី ៧ មិនមានអដ្ឋកថាកែទេ ។*

# អ ដ្ឋ ក ថា

## តណ្ហាសូត្រទី ៨

[២៨២] *តែក្នុង តណ្ហាសូត្រទី ៨ ទើងបានឈ្មោះថា តណ្ហា ក្នុងកាលធ្លាក់ដល់ជវនៈក្នុងទ្វារនោះៗ ប៉ុណ្ណោះ ។*

ចប់អដ្ឋកថា តណ្ហាសូត្រទី ៨

# អ ដ្ឋ ក ថា

## ធាតុសូត្រទី ៩

[២៨៤] ក្នុង ធាតុសូត្រទី ៩ ត្រាស់នាមដោយអំណាចវិញ្ញាណធាតុ ត្រាស់រូបដោយធាតុដ៏សេស ព្រោះដូច្នោះ ទើបជាការដែលទ្រង់ត្រាស់នាម-រូបទុកហើយ ។

ចប់អដ្ឋកថា ធាតុសូត្រទី ៩

# អ ដ្ឋ ក ថា

## ខន្ធសូត្រទី ១០

[២៨៦] ក្នុង ខន្ធសូត្រទី ១០ រូបក្ខន្ធជាកាមាវចរៈ ខន្ធ ៤ ដ៏សេស ប្រព្រឹត្តទៅក្នុងភូមិ ៤ ដោយការកំណត់រូបរួមធម៌ទាំងអស់ ។ តែក្នុងព្រះសូត្រនេះ គប្បីយល់ថា ប្រព្រឹត្តទៅក្នុងភូមិ ៣ ។

ចប់អដ្ឋកថា ខន្ធសូត្រទី ១០

## ចប់អប្បមានវគ្គ នៃរាហុលសំយុត្ត

### រួមក្នុងវគ្គនេះមាន ៧ អដ្ឋកថា

១-អដ្ឋកថា ចក្ខុសូត្រ
២-អដ្ឋកថា រូបសូត្រ
៣-អដ្ឋកថា វិញ្ញាណសូត្រ
៤-អដ្ឋកថា មិនមាន
៥-អដ្ឋកថា មិនមាន
៦-អដ្ឋកថា សញ្ញាសូត្រ
៧-អដ្ឋកថា មិនមាន
៨-អដ្ឋកថា តណ្ហាសូត្រ
៩-អដ្ឋកថា ធាតុសូត្រ
១០-អដ្ឋកថា ខន្ធសូត្រ

# អនុសយវគ្គ

*ក្នុង ទុតិយវគ្គ សូត្រទី ១-១០ មានសេចក្ដីងាយទាំងនោះ ។*

# អដ្ឋកថា

## អនុសយសូត្រទី ១១

គប្បីជ្រាបវិនិច្ឆ័យក្នុង **អនុសយសូត្រទី ១១** ដូចតទៅនេះ ៖

ព្រះមានព្រះភាគទ្រង់សម្ដែងកាយដែលមានវិញ្ញាណរបស់ខ្លួន

[៣០០] ដោយបទថា **ឥមស្មិញ្ច សវិញ្ញាណកេ កាយេ** ទ្រង់សម្ដែងកាយដែលមានវិញ្ញាណ ឬមិនមានវិញ្ញាណរបស់អ្នកដទៃ ឬវិញ្ញាណតែម្យ៉ាងទាំងរបស់ខ្លួន ទាំងរបស់អ្នកដទៃដោយបទដើម ទ្រង់សម្ដែងរូបដែលជាប់ដោយអនិន្ទ្រិយខាងក្រៅ ដោយបទក្រោយ ។

បទថា **អហំការមមំការមានានុសយា** បានដល់ ទិដ្ឋិថា ជាយើង តណ្ហាថា របស់យើង និងអនុស័យ គឺ មានះ ។ បទថា **ន ហោន្តិ** បានដល់ត្រាស់សួរថា កិលេសទាំងនេះ រមែងមិនមានក្នុងវត្ថុទាំងនេះ ដល់អ្នកដឹងឬឃើញដោយល្អ

[៣០១] បទថា **សម្មប្បញ្ញាយ បស្សតិ** បានដល់ ឃើញដោយល្អដោយមគ្គប្បញ្ញា ព្រមទាំងវិបស្សនាបញ្ញា ។

ចប់អដ្ឋកថា អនុសយសូត្រទី ១១

# អ ដ្ឋ ក ថា

## អបគតសូត្រទី ១២

*គប្បីជ្រាបវិនិច្ឆ័យក្នុង* **អបគតសូត្រទី ១២** *ដូចតទៅនេះ ៖*

[៣០២] *បទថា* **អហំការមមំការមានាបគតំ** *បានដល់ ប្រាសចាក អហង្ការ (ទិដ្ឋិ) មមង្ការ (តណ្ហា) និងមានះ ។ បទថា* **វិធា សមតិក្កន្តំ** *បានដល់ ឈានកន្លងដោយល្អនូវចំណែកនៃមានះ ។ បទថា* **សន្តំ សុវិមុត្តំ** *បានដល់ ឈ្មោះថា ស្ងប់ ព្រោះស្ងប់កិលេស ឈ្មោះថា រួចផុតដោយល្អពីកិលេសទាំងឡាយ ។ ពាក្យដ៏សេសងាយទាំងនោះឯង ។*

ចប់អដ្ឋកថា អបគតសូត្រទី ១២

## ចប់អនុសយវគ្គ នៃរាហុលសំយុត្ត

### រួមក្នុងវគ្គនេះមាន ២ អដ្ឋកថា

ព្រះសូត្រទី ១ ដល់ទី ១០ មិនមានអដ្ឋកថាជួយកោទ

១១-អដ្ឋកថាអនុសយសូត្រ　　　១២-អដ្ឋកថាអបគតសូត្រ

# លក្ខណសំយុត្ត

## អដ្ឋិសង្ខលិកវគ្គ

## អ ដ្ឋ ក ថា

### អដ្ឋិសូត្រទី ១

*ក្នុង លក្ខណសំយុត្ត មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣០៤] *ពាក្យថា* ***អាយស្មា ច លក្ខណោ*** *គឺ ព្រះលក្ខណត្ថេរដែលលោកពោលថា ជាអ្នកឧបសម្បទដោយឯហិភិក្ខុឧបសម្បទា ជាមួយនឹងពួកជដិលចំនួន ១,០០០ នាក់ សម្រេចព្រះអរហត្តក្នុងវេលាចប់អាទិត្តបរិយាយសូត្រ គប្បីជ្រាបថា ជាព្រះមហាសាវកមួយរូប ។ ក៏ព្រោះលោកប្រកបដោយអត្តភាពដល់ព្រមដោយលក្ខណៈ បរិបូណ៌ដោយអាការទាំងពួង ស្មើដោយព្រហ្ម ។ ដូច្នោះ ទើបបានឈ្មោះហៅក្រៅថា លក្ខណៈ ។ ចំណែកព្រះមហាមោគ្គល្លាន សម្រេចព្រះអរហត្តក្នុងថ្ងៃទី ៧ រាប់ពីថ្ងៃដែលលោកបួស ជាព្រះអគ្គសាវកអង្គទី ២ ។*

[៣០៥] *បទថា* ***សិតំ បាត្វាកាសិ*** *សេចក្តីថា បានធ្វើការញញឹមតិចៗ*

ឲ្យប្រាកដ លោកអធិប្បាយទុកថា ប្រកាស គឺ សម្តែង ។

សួរថា ក៏ព្រោះឃើញអ្វី ព្រះថេរៈទើបធ្វើការញញឹមឲ្យប្រាកដ ។

ឆ្លើយថា ព្រោះបានឃើញសត្វដែលកើតក្នុងបេតលោកមួយ មានតែរាងឆ្អឹង ដែលមកហើយក្នុងបាលីខាងដើម ។ ក៏លោកឃើញសត្វនោះដោយទិព្វចក្ខុ មិនបានឃើញដោយចក្ខុបសាទទេ ។ ពិតណាស់ អត្តភាពទាំងនោះរមែងមិនប្រាកដដល់ចក្ខុបសាទ ។

សួរថា ក៏កាលលោកឃើញអត្តភាពបែបនេះហើយ គួរធ្វើសេចក្តីករុណា ព្រោះហេតុអ្វីទើបធ្វើការញញឹមឲ្យប្រាកដ ។

ឆ្លើយថា ព្រោះរលឹកដល់សម្បត្តិរបស់ខ្លួន និងពុទ្ធញាណ ។ ពិតណាស់ ព្រះថេរៈឃើញអត្តភាពនោះហើយ រលឹកដល់សម្បត្តិរបស់ខ្លួនថា យើងរួចផុតហើយចាកអត្តភាពដែលមានសភាពបែបនេះ ដែលបុគ្គលអ្នកមិនឃើញសច្ចៈនឹងគប្បីបាន នោះជាលាភរបស់យើង យើងបានល្អហើយ និងរលឹកដល់សម្បត្តិនៃពុទ្ធញាណ យ៉ាងនេះថា ឱ ញាណសម្បត្តិរបស់ព្រះ-មានព្រះភាគ ព្រះពុទ្ធទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ កម្មវិបាកជាអចិ-ន្តេយ្យ មិនគួរគិត ដូច្នេះ ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងសម្តែងកម្មវិបាក យ៉ាងនោះឲ្យប្រចក្ស ។ ធម្មធាតុដែលព្រះពុទ្ធទាំងឡាយទ្រង់ចាក់ធ្លុះល្អហើយ

ដូច្នេះ ទើបធ្វើសេចក្ដីញញឹមឲ្យប្រាកដ ។

សួរថា បើដូច្នោះ ហេតុអ្វីព្រះលក្ខណៈទើបមិនឃើញ លោកមិនមានទិព្វចក្ខុឬ ។

ឆ្លើយថា មិនមាន ក៏មិនមែន ។ តែព្រះមហាមោគ្គល្លានត្រូវនឹករលឹកដល់ ទើបបានឃើញ ។ ចំណែកព្រះលក្ខណៈមិនបានឃើញ ព្រោះមិននឹករលឹកដល់ ។ ព្រោះធម្មតា ព្រះខីណាស្រពទាំងឡាយ នឹងញញឹមដោយហេតុដែលមិនសមគួរក៏ទេ ដូច្នោះ ព្រះលក្ខណៈទើបសួរលោកថា មោគ្គល្លានដ៏មានអាយុ អ្វីហ្ន៎ជាហេតុ ជាបច្ច័យឲ្យការញញឹមប្រាកដ ដូច្នេះ ។ ចំណែកព្រះថេរៈបានអាងព្រះមានព្រះភាគជាសាក្សី ព្រោះអ្នកដែលមិនបានឃើញរឿងដែលកើតឡើងដោយខ្លួនឯង នឹងជឿបានលំបាក ទើបពោលពាក្យជាដើមថា **អកាលោ ខោ អាវុសោ** ដូច្នេះ ព្រោះប្រាថ្នានឹងព្យាករណ៍អាងព្រះមានព្រះភាគជាសាក្សី ។

[៣០៧] បន្ទាប់ពីនោះ កាលត្រូវសួរក្នុងសម្នាក់របស់ព្រះមានព្រះភាគទើបព្យាករណ៍ ដោយន័យមានជាដើមថា **ឥធាហំ អាវុសោ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អដ្ឋិសង្ខលិកំ** បានដល់ គ្រោងឆ្អឹងសមិនមានសាច់ និងឈាម ។ បទថា **គិជ្ឈាបិ កាកាបិ កុលលាបិ** សេចក្ដីថា

សូម្បីសត្វទាំងនេះ ទាំងត្មាតយក្ខ ទាំងក្អែកយក្ខ ទាំងស្ទេចត្មាតយក្ខ ហោម-រោមចឹក ។ ក៏សត្វនោះ រមែងមិនប្រាកដដល់ត្មាតជាដើម តាមប្រក្រតី ។ បទថា **អនុបតិត្វា** បានដល់ ជាប់តាម ។ បទថា **វិតុទេន្តិ** សេចក្ដីថា ប្រើចំពុះដែកដ៏មុតដូចដាវ ចឹកចោះខាងនេះខ្លះ ខាងនោះខ្លះ ។ បទថា **សុទំ** ក្នុងបទថា **សា សុទំ អដ្ដស្សរំ ករោតិ** នេះ ជានិបាត ។ អធិប្បាយថា គ្រោងឆ្អឹងនោះ បញ្ចេញសំឡេងស្រែកថ្ងូរ គឺ សំឡេងសម្ដែងសេចក្ដីទុក្ខសោកក្ដៅក្រហាយ ។ អត្តភាពដូច្នោះ មានប្រមាណដល់ ៣ យោជន៍ កើតឡើងដើម្បីសោយវិបាករបស់អកុសលកម្ម ជាអត្តភាពថ្លាដូចបុសទុំ ។ ដូច្នោះ គ្រោងឆ្អឹងនោះ ក្ដៅក្រហាយព្រោះវេទនាមានកម្លាំង ទើបបញ្ចេញសំឡេងស្រែកថ្ងូរ ដូច្នោះ ។

ក៏គ្រាពោលយ៉ាងនេះហើយ ព្រះមហាមោគ្គល្លានទើបគិតថា ធម្មតាសត្វអ្នកវិលវល់នៅក្នុងវដ្ដៈ រមែងមិនផុតពីអត្តភាពបែបនេះ កាលនឹងសម្ដែងធម្មសង្វេគ ដែលកើតឡើងព្រោះអាស្រ័យសេចក្ដីករុណាក្នុងសត្វទាំងឡាយ ទើបពោលពាក្យមានជាដើមថា **តស្ស មយ្ហំ អាវុសោ ឯតទហោសិ អច្ឆរិយំ វត ភោ** ដូច្នេះ ។

[៣០៤] លំដាប់នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់ប្រកាសអានុភាព

របស់ព្រះថេរៈ ទើបត្រាស់ពាក្យមានជាដើមថា **ចក្ខុភូតា វត ភិក្ខវេ សាវកា វិហរន្តិ** ដូច្នេះ ។

បណ្តាបទទាំងនោះ សាវកឈ្មោះថា **ចក្ខុភូតា** ព្រោះភិក្ខុទាំងនោះ ចក្ខុកើតមាន ។ អធិប្បាយថា ភិក្ខុទាំងនោះមានចក្ខុ ញ៉ាំងចក្ខុឲ្យកើតឡើងហើយ ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ បទថា **យត្រ** ក្នុងពាក្យថា **យត្រ ហិ នាម** នេះ សំដៅដល់ហេតុ ។ ក្នុងសេចក្តីនោះ មានអត្ថ-យោជនា (ប្រកបសេចក្តី) ដូចតទៅនេះ

សូម្បីធម្មតាថា សាវករមែងឃើញសត្វបែបនេះ ឬនឹងធ្វើឲ្យជាសាក្សីបាន ដូច្នោះ ព្រះមានព្រះភាគទើបបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយជាអ្នកមានចក្ខុ ជាអ្នកមានញាណ ដោយពាក្យថា **បុព្វេវ មេ សោ ភិក្ខវេ សត្តោ ទិដ្ឋោ** ដូច្នេះ ព្រះមានព្រះភាគត្រាស់ថា តថាគត កាលធ្វើសត្តនិកាយ និងភព **គតិ យោនិ ឋិតិ និវាស** ដែលរកប្រមាណមិនបាន ក្នុងចក្រវាឡដែលរកប្រមាណមិនបានឲ្យជាសាក្សី ដោយការបោកដុះព្រះ-សព្វញ្ញុតញ្ញាណត្រង់ពោធិមណ្ឌល បានឃើញសត្វនោះហើយ ក្នុងកាលមុននោះឯង ។

បទថា **គោឃាតកោ** បានដល់ អ្នកសម្លាប់គោ ពន្លះឆ្អឹង និងសាច់

លក់ចិញ្ចឹមជីវិត ។

បទថា តស្សេវ កម្មស្ស វិបាកាវសេសេន (ដោយផលរបស់កម្ម នោះឯងនៅសល់) សេចក្តីថា អបរាបរិយកម្ម (កម្មដែលឲ្យផលក្នុងកពតទៅ) នោះ ដែលចេតនាផ្សេងៗ ប្រមូលទុក ។ ពិតណាស់ កាលវិបាករបស់ចេតនាដែលជាហេតុ ឲ្យបដិសន្ធិក្នុងនរកនោះអស់ហើយ បដិសន្ធិ ធ្វើកម្មដែលសល់ ឬកម្មនិមិត្ត ឲ្យជាអារម្មណ៍ហើយ ក៏កើតក្នុងប្រេតជាដើមទៀត ។ ព្រោះដូច្នោះ បដិសន្ធិនោះ លោកហៅថា ជាផល់វិបាករបស់កម្មនោះឯង ព្រោះមានចំណែកស្មើនឹងកម្ម ឬព្រោះមានចំណែកស្មើនឹងអារម្មណ៍ ។ ក៏សត្វនេះ កើតឡើងហើយដោយអាការយ៉ាងនេះ ។ ព្រោះហេតុនោះ លោកទើបពោលថា ដោយផល់វិបាករបស់កម្មនោះឯង ។

បានឮថា ក្នុងវេលាដែលសត្វនោះចុតិអំពីនរក គំនរឆ្អឹងរបស់គោទាំងឡាយដែលមិនមានសាច់នុ៎ះឯង បានប្រាកដជានិមិត្ត ។ សត្វនោះ សូម្បីធ្វើកម្មដែលបិទបាំងទុកនោះ ក៏ដូចប្រាកដដល់វិញ្ញូជន ទើបកើតជាអដ្ឋិសង្ខលិកប្រេត ។

ចប់អដ្ឋកថា អដ្ឋិសូត្រទី ១

# អ ដ្ឋ ក ថា

## បេសិសូត្រទី ២

[៣០៩] *ក្នុងរឿង មំសបេសិប្រេត មានវិនិច្ឆ័យដូចតទៅនេះ ៖*

*បទថា **គោឃាតកោ** សេចក្តីថា អ្នកសម្លាប់គោនោះ ធ្វើសាច់គោជាចំរៀកៗ ហាលឲ្យស្ងួត លក់សាច់ស្ងួតចិញ្ចឹមជីវិតជាច្រើនឆ្នាំ ។ ដោយហេតុនោះ ក្នុងវេលាដែលសត្វនោះចុតិពីនរក ចំរៀកសាច់ទុំះឯងបានប្រាកដជានិមិត្ត ។ សត្វនោះទើបកើតជាមំសបេសិប្រេត ។*

ចប់អដ្ឋកថា បេសិសូត្រទី ២

# អ ដ្ឋ ក ថា

## បិណ្ឌសូត្រទី ៣

[៣១០] ក្នុងរឿង មំសបិណ្ឌប្រេត មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា សាកុណិកោ សេចក្តីថា ក្នុងវេលាចាប់សត្វមកលក់ ព្រាន បក្សី យករោម និងស្បែកចេញ សល់ទុកតែដុំសាច់លក់ចិញ្ចឹមជីវិត ។ ព្រោះហេតុនោះ ក្នុងវេលាដែលសត្វនោះចុតិអំពីនរក ដុំសាច់នុ៎ះឯង បាន ប្រាកដជានិមិត្ត ។ សត្វនោះទើបកើតជាមំសបិណ្ឌប្រេត (ប្រេតដុំសាច់) ។

ចប់អដ្ឋកថា បិណ្ឌសូត្រទី ៣

# អ ដ្ឋ ក ថា

## និច្ឆវិសូត្រទី ៤

[៣១១] ក្នុងរឿង ប្រេតមិនមានស្បែកក្រៅ មានវិនិច្ឆ័យដូចតទៅនេះ ៖ កាលព្រាននោះ សម្លាប់ចៀមពន្លាត់ស្បែកចេញ លក់ចិញ្ចឹមជីវិតខ្លួនរបស់ចៀមដែលមិនមានស្បែក បានប្រាកដជានិមិត្ត ដោយន័យមុនទុំះឯង ។ ព្រោះដូច្នោះ ព្រាននោះ ទើបកើតជានិច្ឆវិប្រេត ។

ចប់អដ្ឋកថា និច្ឆវិសូត្រទី ៤

# អ ដ្ឋ ក ថា

## អសិសូត្រទី ៥

[៣១២] ក្នុងរឿង *អសិលោមប្រេត* *(សត្វមានរោមជារោម)* មានវិនិច្ឆ័យដូចតទៅនេះ ៖

*អ្នកសម្លាប់ជ្រូកនោះ យកដាវសម្លាប់ជ្រូក ដែលចិញ្ចឹមដោយបន្ទែអស់កាលយូរ ចិញ្ចឹមជីវិតអស់កាលយូរ ។ ការៈដែលគេនាំដាវទុំរឯង បានប្រាកដជានិមិត្ត ព្រោះដូច្នោះ គេទើបកើតជាអសិលោមប្រេត ។*

ចប់អដ្ឋកថា អសិសូត្រទី ៥

# អ ដ្ឋ ក ថា

## សត្តិសូត្រទី ៦

[៣១៣] *ក្នុងរឿង សត្តិលោមប្រេត (សត្វមានរោមជាលំពែង) មានវិនិច្ឆ័យដូចតទៅនេះ ៖*

*អ្នកសម្លាប់ម្រឹគនោះ នាំម្រឹគមួយ (សម្រាប់បញ្ឆោតម្រឹគ) និងកាន់លំពែងទៅព្រៃ យកលំពែងចាក់ពួកម្រឹគដែលមកឈរនៅជិតៗ នោះឲ្យស្លាប់ ។ ការៈដែលគេយកលំពែងចាក់ម្រឹគនុ៎ះឯង បានប្រាកដជានិមិត្ត ព្រោះដូច្នោះ គេទើបកើតជាសត្តិលោមប្រេត ។*

ចប់អដ្ឋកថា សត្តិសូត្រទី ៦

# អ ដ្ឋ ក ថា

## ឧសុសូត្រទី ៧

[៣១៤] រឿង ឧសុលោមប្រេត (សត្វមានរោមដូចព្រួញ) មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **ការណិកោ** បានដល់ បុរសអ្នកបៀតបៀនដល់អ្នកដែលធ្វើខុសក្នុងព្រះរាជាដោយហេតុច្រើនយ៉ាង (ពេជ្ឈឃាត) ក្នុងទីបំផុតយកកូនព្រួញចាក់សម្លាប់ ។ បានឮថា បុរសនោះចាក់ ព្រោះដឹងថា អ្នកដែលត្រូវចាក់ក្នុងទីឯណោះនឹងស្លាប់ ។ កាលគេចិញ្ចឹមជីវិតដោយអាការយ៉ាងនេះ ហើយកើតក្នុងនរក បន្ទាប់ពីនោះ ដោយផលសេសសល់ក្នុងវេលាដែលគេកើតក្នុងនរកនោះ ការៈដែលគេប្រើព្រួញចាក់ ទើបបានប្រាកដជានិមិត្ត ព្រោះដូច្នោះ គេទើបកើតជាឧសុលោមប្រេត ។

ចប់អដ្ឋកថា ឧសុសូត្រទី ៧

# អ ដ្ឋ ក ថា

## បឋមសូចិសូត្រទី ៨

[៣១៥] *ក្នុងរឿង បឋមសូចិលោកប្រេត (សត្វមានរោមដូចជន្លួញ) មានវិនិច្ឆ័យដូចតទៅនេះ ៖*

*បទថា* ***សុតោ*** *បានដល់ អ្នកទូន្មានសេះ (សារថី) ។ អាចារ្យពួកខ្លះពោលថា អ្នកទូន្មានគោ ដូច្នេះក៏មាន ។ ការៈដែលគេយកចុងជន្លួញចាក់នោះឯង បានប្រាកដជានិមិត្ត ព្រោះដូច្នោះ គេទើបកើតជាសូចិលោមប្រេត ។*

ចប់អដ្ឋកថា បឋមសូចិសូត្រទី ៨

# អ ដ្ឋ ក ថា

## ទុតិយសូចិសូត្រទី ៩

[៣១៦] ក្នុងរឿង ទុតិយសូចិលោមប្រេត (សត្វមានរោមដូចម្ជុល) មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **សូចិកោ**(១) បានដល់ អ្នកធ្វើការញុះញង់ ។ បានឮថា គេញុះញង់ពួកមនុស្សឲ្យបែកគ្នា ។ម្យ៉ាងទៀត ក្នុងរាជត្រកូលគេញុះញង់ ហើយញុះញង់ថា អ្នកនេះមានវត្ថុនេះ អ្នកនេះធ្វើវត្ថុនេះដោយវត្ថុនេះ ឲ្យដល់សេចក្តីវិនាស ។ ព្រោះដូច្នោះ ការសោយទុក្ខ ព្រោះធ្វើឲ្យគេបែកគ្នា ព្រោះការញុះញង់ដោយប្រការដែលពួកមនុស្សត្រូវញុះញង់ហើយ បែកគ្នា គេធ្វើកម្មនុ៎ះឯងឲ្យជានិមិត្ត ទើបកើតជាសូចិលោមប្រេត ។

ចប់អដ្ឋកថា ទុតិយសូចិសូត្រទី៩

(១) ម. សូចកោ អ្នកពោលស៊កសៀត ។

# អ ដ្ឋ ក ថា

## អណ្ឌភារីសូត្រទី ១០

[៣១៧] ក្នុងរឿង កុម្ភណ្ឌប្រេត (បុរសមានអណ្ឌៈ[១]ប៉ុនក្អម) មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **គាមកូដោ** (អ្នកកាត់ក្តីកោង) បានដល់ អាមាត្យអ្នកវិនិច្ឆ័យក្តី ព្រោះគេមានចំណែកស្មើនឹងកម្ម ទើបមានអណ្ឌៈប្រមាណប៉ុនក្អម គឺ ខ្នាតក្អមធំ ។ ព្រោះគេទទួលសំណូកក្នុងទីកំបាំង គឺ ទីបិទបាំង ធ្វើទោសឲ្យប្រាកដក្នុងការវិនិច្ឆ័យក្តីកោង ធ្វើអ្នកម្ចាស់ទ្រព្យ មិនឲ្យជាម្ចាស់ទ្រព្យ ដូច្នោះ អវយវៈភេទកំបាំងរបស់គេ ទើបកើតក្នុងទីមិនបិទបាំង ព្រោះកាលដាក់ទោស គេបានគម្រាមអ្នកដទៃ ដូច្នោះ អវយវៈភេទកំបាំងរបស់គេ ទើបកើតជាវត្ថុគម្រាម (ទូន្មានខ្លួន) ព្រោះហេតុដែលអវយវៈតាំងនៅក្នុងតំណែងដែលតាំងនៅហើយ គួរនឹងរៀបរយ ត្រឡប់ជាមិនរៀបរយ ដូច្នោះ ទើបគេត្រូវអង្គុយមិនរៀបរយលើអវយវៈភេទកំបាំង ។

ចប់អដ្ឋកថា អណ្ឌភារីសូត្រទី ១០

---

១ ពងស្វាស ។

## ចប់អដ្ឋសង្ខលិកវគ្គ នៃលក្ខណសំយុត្ត

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថា អដ្ឋិសូត្រ
២-អដ្ឋកថា បេសិសូត្រ
៣-អដ្ឋកថា បិណ្ឌសូត្រ
៤-អដ្ឋកថា និច្ឆវិសូត្រ
៥-អដ្ឋកថា អសិសូត្រ
៦-អដ្ឋកថា សត្តិសូត្រ
៧-អដ្ឋកថា ឧសុសូត្រ
៨-អដ្ឋកថា បឋមសូចិសូត្រ
៩-អដ្ឋកថា ទុតិយសូចិសូត្រ
១០-អដ្ឋកថា អណ្ឌភារីសូត្រ

# ចារទារិកវគ្គ

## អ ដ្ឋ ក ថា

### កូបនិមុគ្គសូត្រទី ១

[៣១៨] *សូត្រទី ១ រឿងបុរសប្រព្រឹត្តបរទារិកកម្ម (គឺលួចប្រពន្ធអ្នកដទៃ) មានវិនិច្ឆ័យដូចតទៅ នេះ ៖*

*សត្វនោះពាល់ត្រូវសម្ផស្សស្ត្រីមានស្វាមី ដែលអ្នកដទៃរក្សាឃុំគ្រង មានចិត្តត្រេកអរដោយសុខពីឧច្ចារៈ និងសុខពីកាម ព្រោះគេមានចំណែកស្មើនឹងកម្ម ទើបពាល់ត្រូវលាមក បានកើតក្នុងរណ្តៅលាមកនោះ សោយទុក្ខធំ ៗ*

ចប់អដ្ឋកថា កូបនិមុគ្គសូត្រទី ១

# អ ដ្ឋ ក ថា

## គូថខាទិសូត្រទី ២

[៣១៩] *រឿងបុរសអ្នកស៊ីលាមក ប្រាកដច្បាស់ហើយនោះឯង ។*

ចប់អដ្ឋកថា គូថខាទិសូត្រទី ២

# អ ដ្ឋ ក ថា

## និច្ចវិត្តិសូត្រទី ៣

[៣២០] ក្នុង *រឿងស្ត្រីមិនមានស្បែកក្រៅ* មានវិនិច្ឆ័យដូចតទៅនេះ ៖ *ព្រោះធម្មតាថា មាតុគ្រាម រមែងមិនជាធំក្នុងផ្សះរបស់ខ្លួន ហើយមាតុគ្រាមនោះលួចផ្សះដែលជារបស់ស្វាមី ហើយឲ្យកើតសេចក្តីត្រេក-អរក្នុងផ្សះរបស់អ្នកដទៃ ដូច្នោះ នាងទើបមានផ្សះជាសុខ ព្រោះមានចំណែកស្មើគ្នានឹងកម្ម ចុតិអំពីអត្តភាពនោះឯង ទើបកើតជាស្ត្រីមិនមានស្បែកក្រៅ ទើបសោយសម្ព័ស្សជាទុក្ខ ។*

ចប់អដ្ឋកថា និច្ចវិត្តិសូត្រទី ៣

# អ ដ្ឋ ក ថា

## មង្គុឡិត្ថីសូត្រទី ៤

[៣២១] ក្នុង *រឿងស្ត្រីមានក្លិនស្អុយ* មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា *មង្គុឡី* បានដល់ មានរូបប្លែក មិនគួរមើល គួរខ្ពើស ។ បានឮថា នាងជាស្ត្រីមេមត់ ធ្វើកម្មរបស់ស្ត្រីដែលជាទាសីយក្ខ ដើរប្រកាសថា កាលអ្នកនេះៗ ធ្វើពលីកម្មយ៉ាងនេះ ពួកលោកទាំងឡាយនឹងចម្រើនយ៉ាងនេះ ដូច្នេះ ហើយឆបោកយកគ្រឿងក្រអូប និងផ្កាឈើជាដើម របស់មហាជន ឲ្យមហាជនមានការឃើញអាក្រក់ ឃើញខុស ។ ព្រោះដូច្នោះ នាងទើបមានចំណែកស្មើគ្នានឹងកម្មនោះ នាងទើបមានក្លិនស្អុយ ព្រោះហេតុលួចគ្រឿងក្រអូប និងផ្កាឈើជាដើម នាងកើតមានរូបមិនគួរមើល ប្លែកចម្លែក គួរខ្ពើស ព្រោះហេតុឲ្យគេកាន់យកការឃើញខុស ។

ចប់អដ្ឋកថា មង្គុឡិត្ថីសូត្រទី ៤

# អ ដ្ឋ ក ថា

## ឱកិលិនីសូត្រទី ៥

[៣២២] ក្នុង រឿងស្ត្រីមានទឹករងៃហូរ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា ឱបក្កំ ឱកិលិនី ឱកិរិណី សេចក្តីថា បានឮថា នាងដេកក្តៅក្រហាយរសាប់រសល់ អន្ទះអន្ទែងនៅលើជើងក្ករ ពេញទៅដោយរងើកភ្លើង ព្រោះដូច្នោះ នាងទើបក្តៅគគុក គឺ មានរាងកាយត្រូវភ្លើងដុតរោល នាងមានទឹករងៃហូរ មានរាងកាយប្រឡាក់ប្រឡូស គឺ មានទឹករងៃហូរចេញពីរាងកាយរបស់នាង និងមានរាងកាយពេញទៅដោយរងើកភ្លើង ពោរពេញទៅដោយរងើកភ្លើង គឺ ខាងក្រោមនាង មានរងើកភ្លើងពណ៌ដូចផ្កាថ្កូវមាស សូម្បីទាំងពីរខាងក៏ដូចគ្នា ពីខាងលើនាងមានរងើកភ្លើងធ្លាក់ចុះមកពីអាកាស ហេតុនោះលោកទើបពោលថា ឱបក្កំ ឱកិលិនិ ឱកិរិណី ដូច្នេះ ។ បទថា សា ឥស្សាបកតា សបតី អង្គារកដាហេន ឱកិរិ សេចក្តីថា បានឮថា ស្ត្រីរបាំម្នាក់របស់ព្រះរាជានោះ តាំងចង្ក្រានរងើកភ្លើងទុកជិតៗ ជូតទឹកពីខ្លួន និងយកបាតដៃជូតញើស សូម្បីព្រះរាជាក៏ទ្រង់សន្ទនា និងទ្រង់សម្តែងអាការត្រេកអរនឹងនាង ។

ព្រះអគ្គមហេសីទ្រង់អត់ធន់អាការដូច្នោះមិនបាន ត្រូវសេចក្តីប្រណែនគ្រប សង្កត់ កាលព្រះរាជាស្តេចចេញទៅមិនយូរ ព្រះនាងកាន់ចង្ក្រានរងើកភ្លើង នោះ ចាក់រងើកភ្លើងលើស្ត្រីនោះ ។ ព្រះនាងធ្វើកម្មនោះហើយ កើតក្នុង បេតលោក ទើបសោយផលនោះ ដូច្នោះ ។

ចប់អដ្ឋកថា ឱក្កិលិនីសូត្រទី ៥

# អ ដ្ឋ ក ថា

## សីសច្ឆិន្នសូត្រទី ៦

[៣២៣] ក្នុង *រឿងអ្នកសម្លាប់ចោរ* មានវិនិច្ឆ័យដូចតទៅនេះ ៖

*អ្នកសម្លាប់ចោរនោះ កាត់ក្បាលពួកចោរអស់កាលយូរ តាមពាក្យបង្គាប់ព្រះរាជា កាលកើតក្នុងបេតលោក កើតមានតែខ្លួន មិនមានក្បាល ។*

*(ប្រេតនោះមានភ្នែក និងមុខនៅត្រង់ទ្រូង ។ តាមបិដក។)*

ចប់អដ្ឋកថា សីសច្ឆិន្នសូត្រទី ៦

# អ ដ្ឋ ក ថា

## ភិក្ខុសូត្រទី ៧

[៣២៤] ក្នុងរឿងភិក្ខុ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **បាបភិក្ខុ** បានដល់ ភិក្ខុលាមក ។ បានឮថា ភិក្ខុនោះបរិភោគបច្ច័យ ៤ ដែលអ្នកស្រុកថ្វាយដោយសទ្ធា ជាអ្នកមិនសង្រួមកាយទ្វារ និងវចីទ្វារ ទម្លាយអាជីវៈ ត្រាច់បញ្ជូនចិត្តឲ្យសប្បាយរីករាយ ។ បន្ទាប់ពីនោះលោកឆេះនៅក្នុងនរករហូតអស់មួយចន្លោះព្រះពុទ្ធ កាលកើតក្នុងបេតលោក កើតដោយអត្តភាពដូចភិក្ខុនុ៎ះឯង ។

ចប់អដ្ឋកថា ភិក្ខុសូត្រទី ៧

# អ ដ្ឋ ក ថា

## ភិក្ខុនីសូត្រទី ៨ ជាដើម

[៣២៥] *សូម្បីក្នុង រឿងរបស់នាងភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ក៏មានវិនិច្ឆ័យយ៉ាងនេះ ដូចគ្នានោះឯង ។*

ចប់អដ្ឋកថា ភិក្ខុនីសូត្រទី ៨ ជាដើម

**ចប់ចារនារិកវគ្គ នៃលក្ខណសំយុត្ត**

**រួមក្នុងវគ្គនេះមាន ៧ អដ្ឋកថា**


១-អដ្ឋកថា កូបនិមុគ្គសូត្រ
២-អដ្ឋកថា គុថខាទិសូត្រ
៣-អដ្ឋកថា និច្ឆវិត្ថីសូត្រ
៤-អដ្ឋកថា មង្គុឡិត្ថីសូត្រ
៥-អដ្ឋកថា ឱកិលិនីសូត្រ
៦-អដ្ឋកថា សីសច្ឆិន្នសូត្រ
៧-អដ្ឋកថា ភិក្ខុសូត្រ
៨-ភិក្ខុនីសូត្រជាដើម មិនមានអដ្ឋកថា

# ឱបម្មសំយុត្ត

## អ ដ្ឋ ក ថា

### កូដាគារសូត្រទី ១

[៣៣០] កូដាគារសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖

ឈ្មោះថា កូដង្គមា ព្រោះឆាកទៅរកកំពូល ។ ឈ្មោះថា កូដសមោសរណា ព្រោះប្រជុំទៅរកកំពូល ។ បទថា កូដសមុគ្ឃាតា សេចក្ដីថា កាលរើដំបូលផ្ទះ ។

បទថា អវិជ្ជាសមុគ្ឃាតា សេចក្ដីថា ព្រោះដកអវិជ្ជាបានដោយអរហត្តមគ្គ ។ បទថា អប្បមត្តា បានដល់ ជាអ្នកតាំងនៅក្នុងការនៅមិនប្រាសចាកសតិ ។

ចប់អដ្ឋកថា កូដាគារសូត្រទី ១

# អដ្ឋកថា

## ឆខសិខសូត្រទី ២

ក្នុង *ឆខសិខសូត្រទី ២* មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៣២] បទថា **មនុស្សេសុ បច្ចាជាយន្តិ** (ពួកសត្វដែលត្រឡប់បានមកកើតក្នុងពួកមនុស្ស) មានអធិប្បាយថា ពួកជនដែលចុតិអំពីមនុស្សលោកហើយ កើតក្នុងមនុស្សលោកនោះឯង មានប្រមាណតិច ។ បទថា **អញ្ញត្រ មនុស្សេហិ** (កំណើតដទៃពីមនុស្ស) សេចក្តីថា ពួកជនដែលចុតិអំពីមនុស្សលោកហើយ មិនកើតក្នុងមនុស្សលោក ទៅកើតក្នុងអបាយ ៤ មានច្រើនជាង ដូចអាចម៍ដីក្នុងមហាប្រឹថពី ។ ក៏ក្នុងព្រះសូត្រនេះ លោករួមយកសូម្បីទេវតា និងមនុស្សទាំងឡាយចូលជាមួយគ្នា ។ ព្រោះដូច្នោះគប្បីជ្រាបថា អ្នកកើតក្នុងទេវលោកមានប្រមាណតិច ដូចអ្នកដែលកើតក្នុងមនុស្សលោក ដូច្នោះ ។

ចប់អដ្ឋកថា ឆខសិខសូត្រទី ២

# អ ដ្ឋ ក ថា

## កុលសូត្រទី ៣

[៣៣៣] ក្នុង កុលសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា សុប្បធំសិយានិ (ប្លន់បានងាយ) បានដល់ ត្រូវពួកចោរបៀត-បៀនបានងាយ ។ បទថា កុម្ភត្ថេនកេហិ សេចក្តីថា ឈ្មោះថា កុម្ភត្ថេនកា បានដល់ ពួកចោរចូលផ្ទះអ្នកដទៃ ត្រួតមើលដោយពន្លឺប្រទីប ប្រាថ្នានឹងលួចវត្ថុរបស់អ្នកដទៃ អុជប្រទីបដាក់ឆ្នាំងចូលទៅ វត្ថុទាំងនោះដែលចោរប្រើឆ្នាំងនោះលួចបានងាយ ។

បទថា សុបធំសិយោ ហោតិ អមនុស្សេហិ សេចក្តីថា ពិតហើយ បិសាចលេងធូលី រមែងកម្ចាត់អ្នកដែលវៀរមេត្តាភាវនា នឹងចាំបាច់ពោលទៅថ្វីដល់ពួកអមនុស្សដែលជាធំ ។

[៣៣៤] បទថា ភាវិតា បានដល់ ឲ្យចម្រើនទុំះឯង ។ បទថា ពហុ-លីកតា បានដល់ ធ្វើរឿយៗ ។

បទថា យានីកតា បានដល់ ធ្វើឲ្យដូចជាយានដែលទឹមហើយ ។ បទថា វត្ថុកតា បានដល់ ធ្វើឲ្យដូចជាផែនដី ព្រោះអត្ថថា ជាទីតាំងអាស្រ័យ

*បទថា **អនុដ្ឋិតា** បានដល់ តាំងមាំហើយ ។ បទថា **បរិចិត្តា** បានដល់ សន្សំ ដោយជុំវិញ គឺ ចម្រើនល្អហើយ ។ បទថា **សុសមារទ្ធា** បានដល់ មានចិត្តប្រារព្ធសេចក្ដីព្យាយាមដោយល្អ ។*

ចប់អដ្ឋកថា កុលសូត្រទី ៣

# អ ដ្ឋ ក ថា

## ឱក្ខាសូត្រទី ៤

[៣៣៥] ក្នុង *ឱក្ខាសូត្រទី ៤* មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **ឱក្ខាសតំ** (១០០ ខ្ទះ) បានដល់ ខ្ទះមានមាត់ធំ ១០០ ខ្ទះ ។ បទថា **ទានំ ទទេយ្យ** សេចក្តីថា គប្បីឲ្យទានដោយខ្ទះធំ ពេញដោយភោជនប្រណីត ១០០ ខ្ទះ ។ បាលីថា **ឧក្កាសតំ** ដូច្នេះក៏មាន ។ សេចក្តីរបស់បាលីនោះថា ប្រទីបគោម ១០០ ដួង អធិប្បាយថា គប្បីថ្វាយទានពេញដោយរតនៈ ៧ រហូតអស់ស្ថានទីទាំងវាយ ផ្តើមពីស្ថានទីដែលពន្លឺនៃប្រទីបមួយដួងភ្លឺដល់ ។ បទថា **គទ្ទូហនមត្តំ** (ត្រឹមតែការរឹតទឹកដោះគោប៉ុណ្ណោះ) បានដល់ ត្រឹមតែការស្រក់ទឹកដោះនៃមេគោ អធិប្បាយថា ត្រឹមតែការប្រចាប់ក្បាលដោះមេគោតែមួយដង ។ម្យ៉ាងទៀត អធិប្បាយថា ត្រឹមតែលះបង់ក្លិន គឺ ត្រឹមតែប្រើម្រាមដៃ ២ ចាប់ដុំគ្រឿងក្រអូបហិតក្លិនតែមួយដង ។ ក៏អស់កាលសូម្បីត្រឹមនេះ បុគ្គលណាអាចចម្រើនមេត្តាចិត្ត ផ្សាយប្រយោ-ជន៍ទៅក្នុងសព្វសត្វក្នុងលោកធាតុទាំង ៤ ដែលរកប្រមាណមិនបាន ដោយកំណត់យកបរិវេណបន្ទប់ ឬឧបចារវិហារ ឬដោយកំណត់យកចក្រវាឡ

*ការចម្រើនមេត្តាចិត្តរបស់បុគ្គលនោះ នេះមានផលច្រើនជាងនោះ គឺ ជាងទានដែលគេឲ្យមួយថ្ងៃ ៣ ដង ។*

ចប់អដ្ឋកថា ឱក្ខាសូត្រទី ៤

# អ ដ្ឋ ក ថា

## សត្តិសូត្រទី ៥

[៣៣៦] ក្នុង *សត្តិសូត្រទី ៥* មានវិនិច្ឆ័យដូចតទៅនេះ ៖

ក្នុងពាក្យថា *បដិលេណិស្សាមិ* ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា **បដិលេណេ** (កោង) បានដល់ រួបរួមចុងចូលមកដូចកប្បាសរមូរ និងជំពាក់គ្នា ទុកដូចរមូរជ័រឈើ ។ ឈ្មោះថា **បដិកោដ្ដេ** (បត់) បានដល់ រួមត្រង់កណ្ដាលហើយចូលមក ឬរួមចូលមុខគ្នា ហើយយកមុខទាំង ២ រមូរចូលជាមួយគ្នា ។ ឈ្មោះថា **បដិវេដ្ដេ** (ខ្វារ) បានដល់ មូរដូចការរវៃកប្បាស លាតកន្ទេលផែនដែលមូរទុកយូរហើយ ឲ្យមូរត្រឡប់ដូចដើម ។

ចប់អដ្ឋកថា សត្តិសូត្រទី ៥

# អ ដ្ឋ ក ថា

## ធនុគ្គហសូត្រទី ៦

[៣៣៨] ក្នុង ធនុគ្គហសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **ទឡ្ហធម្មា ធនុគ្គហា** (កាន់ធ្នូដ៏មាំ) បានដល់ នាយខ្មាន់ធ្នូជាមេគេ ។ ធ្នូដែលប្រើកម្លាំង ២,០០០ នាក់ លើកឡើង ហៅឈ្មោះថា ទឡ្ហធ្នូ (ធ្នូធ្ងន់) ។ បុគ្គលដែលលើកធ្នូ ចាប់ត្រង់ដងធ្នូ ដែលចងខ្សែធ្នូហើយដ៏ធ្ងន់ ដោយគ្រឿងប្រកបត្រង់ដងធ្នូ មានលោហៈជាដើម ហើយលើកដងធ្នូឡើងឲ្យផុតផែនដី មួយរយៈកូនសរមួយ ឈ្មោះថា ធ្នូដែលប្រើកម្លាំង ២,០០០ នាក់ លើកឡើង ។ បទថា **សុសិក្ខិតា** បានដល់ សិល្បៈដែលរៀនក្នុងសម្នាក់អាចារ្យរហូតអស់ ១២ ឆ្នាំ ។ បទថា **កតហត្ថា** (អ្នកមានជំនាញ) សេចក្តីថា អ្នកដែលរៀនចំពោះតែសិល្បៈប៉ុណ្ណោះ មិនមានការហ្វឹកហាត់ដៃ ។ ចំណែកជនអ្នកហ្វឹកហាត់ដៃទាំងនេះ មានជំនាញដែលបានអប់រំមកហើយ ។ បទថា **កតូបាសនា** (ដែលបានសម្តែងហើយ) បានដល់ អ្នកដែលបានប្រឡងសិល្បៈក្នុងរាជត្រកូលជាដើមហើយ ។

[៣៣៩] បទថា **តស្ស បុរិសស្ស ជវោ** (សន្ទុះនៃបុរសនោះ) សេចក្តី

ថា ដែលឈ្មោះថា បុរសដទៃមានសភាពបែបនេះមិនធ្លាប់មាន ។ ចំណែកព្រះពោធិសត្វប៉ុណ្ណោះ បានឈ្មោះថា **ជវនហំសធំ** (វេលានៃស្តេចហង្សមានសន្ទុះដ៏លឿន ។

ក្នុងគ្រានោះ ព្រះពោធិសត្វបាននាំកូនធ្មុទាំង ៤ មកហើយ ។

បានឮថា ក្នុងគ្រានោះ បងប្អូនប្រុសរបស់ព្រះពោធិសត្វប្រាប់ថា បងប្រុស ពួកយើងនឹងរត់ប្រណាំងជាមួយព្រះអាទិត្យ ។ ព្រះពោធិសត្វពោលថា ព្រះអាទិត្យលឿនណាស់ ពួកយើងមិនអាចរត់ប្រណាំងជាមួយព្រះអាទិត្យបាន ។ បងប្អូនពោលយ៉ាងនោះឯង ២-៣ ដង គិតថា នឹងទៅក្នុងថ្ងៃមួយទើបហើរឡើងទៅទំលើភ្នំយុគន្ធរ ។ ព្រះពោធិសត្វ សួរថា បងប្រុស យើងទៅណា កាលគេឆ្លើយថា ទៅប្រណាំងជាមួយព្រះអាទិត្យ ទើបគិតថា អ្នកមានតបៈនឹងវិនាស អាណិតបងប្រុសទាំងពីរ ខ្លួនឯងទើបទៅនៅក្នុងសម្នាក់របស់បងប្រុសទាំងពីរ ។ គ្រាព្រះអាទិត្យរះឡើង បងប្អូនទាំងពីរក៏ហើរទៅកាន់អាកាស ព្រមពេលដែលព្រះអាទិត្យរះនោះឯង ។ ឯព្រះពោធិសត្វក៏ហើរទៅជាមួយបងប្រុសទាំងពីរដែរ ។ បណ្តាបងប្អូនទាំងពីរនោះ កាលម្នាក់មិនទាន់ដល់វេលាបរិភោគអាហារ ក៏កើតភ្លើងឡើងក្នុងចន្លោះស្លាប ។ ទើបហៅបងប្រុសប្រាប់ថា ខ្ញុំមិនអាច ដូច្នេះ ។ ព្រះពោធិសត្វលួងលោម

បងប្រុសនោះថា កុំខ្លាចឡើយ ឲ្យបងប្រុសចូលទៅនៅក្នុងចន្លោះស្លាប បន្ទា- បង់សេចក្ដីខ្វល់ខ្វាយហើយ ក៏ប្រាប់ទៅថា ទៅចុះ ។ បងប្រុសទីពីរហើរទៅខណៈវេលាបរិភោគអាហារ ក្មេងតាំងឡើងក្នុងចន្លោះស្លាប ទើបពោលយ៉ាងនោះដូចគ្នា សូម្បីព្រះពោធិសត្វក៏បានធ្វើយ៉ាងនោះឯង និងប្រាប់ថាទៅចុះ ។ ចំណែកខ្លួនឯង ហើរទៅដកាបថ្ងៃត្រង់ គិតថា បងប្រុសទាំងពីរនេះល្ងង់ ទើបហើរត្រឡប់ដោយគិតថា យើងមិនគប្បីល្ងង់ បានហើរទៅកាន់ក្រុងពារាណសី ដោយសម្គាល់ថា នឹងគាល់ព្រះរាជាក្រុងពារាណសី ដែលជាអទិដ្ឋសម្លាញ់ (សម្លាញ់ដែលមិនធ្លាប់ឃើញគ្នា) ។ កាលព្រះពោធិសត្វហើរឆ្វេលនៅលើនគរនោះ ។ នគរ ១២ យោជន៍ ដូចជាបាត្រ ដែលគ្របដោយគម្របបាត្រ ។ ខណៈព្រះពោធិសត្វកំពុងហើរឆ្វេល បានប្រាកដជាប្រហោងក្នុងទីនោះៗ សូម្បីព្រះពោធិសត្វឯង ក៏ប្រាកដដូចហង្សច្រើនពាន់ ។ ព្រះពោធិសត្វបន្ថយកម្លាំង ហើរសំដៅព្រះរាជមណ្ឌប ព្រះរាជាទ្រង់ទតឃើញទ្រង់ជ្រាបថា ហង្សមានកម្លាំងរហ័ស ជាសម្លាញ់របស់យើងមកហើយ ទ្រង់បើកព្រះបញ្ជរ ចាត់ចែងតាំងរតនៈប្រថាប់ឈរទត ។ ព្រះពោធិសត្វទំលើតាំងរតនៈ ។

លំដាប់នោះ ព្រះរាជាទ្រង់យកប្រេងដែលបានស្ងួនទាំងពាន់ លាបស្លាប

ទាំងពីររបស់ព្រះពោធិសត្វ ហើយបានព្រះរាជទានបាយលីងមានរសឆ្ងាញ់ និងទឹកមានរសឆ្ងាញ់ ។ តអំពីនោះ ព្រះរាជាបានត្រាស់សួរព្រះពោធិសត្វ ដែលបរិភោគស្រេចហើយថា សម្លាញ់អ្នកបានទៅទីណា ។ ព្រះពោធិសត្វ ប្រាប់រឿងនោះហើយ ទូលថា មហារាជខ្ញុំហើរទៅដរាបថ្ងៃត្រង់ ការហើរ មិនមានប្រយោជន៍ ដូច្នោះ ខ្ញុំទើបត្រឡប់មក ។ ព្រះរាជាត្រាស់ចំពោះ ព្រះពោធិសត្វថា នាយ ខ្ញុំប្រាថ្នានឹងឃើញកម្លាំងដ៏លឿនរហ័សរបស់អ្នក ជាមួយព្រះអាទិត្យ ។ ព្រះពោធិសត្វពោលថា ធ្វើបានលំបាកណាស់ មហារាជ ព្រះអង្គមិនអាចនឹងឃើញបាន ។ ព្រះរាជាត្រាស់ថា នាយ បើដូច្នោះ សូមអ្នកចូរសម្តែងល្មមឲ្យស្រដៀងៗ គ្នា ។ ព្រះពោធិសត្វ ទូលថា ល្អហើយ មហារាជ សូមព្រះអង្គមេត្តាឲ្យពួកខ្មាន់ធ្នូប្រជុំគ្នាចុះ ។ ព្រះរាជាបានត្រាស់ បង្គាប់ឲ្យពួកខ្មាន់ធ្នូប្រជុំគ្នា ។ ស្តេចហង្សនាំពួកខ្មាន់ធ្នូ ៤ នាក់ ឲ្យធ្វើសសរ ខឿនកណ្តាលនគរ ឲ្យប្រដាប់កូនធ្នូត្រង់ករបស់ខ្លួន ហើរឡើងទៅទំលើសសរ ខឿន ពោលថា សូមនាយខ្មាន់ធ្នូ ៤ នាក់ ចូរឈរផ្អែកសសរខឿន បែរមុខ ទៅកាន់ទិសទាំង ៤ បាញ់កូនធ្នូម្តងមួយគ្រាប់ ដូច្នេះ ដំណាលគ្នាទុំះ ខ្លួនឯង ហើរទៅព្រមពេលនឹងកូនធ្នូបាញ់ចេញ មិនចាប់កូនធ្នូនោះ តែចាប់កូនធ្នូ ដែលទៅទិសទក្សិណ ដែលឃ្លាតអំពីធ្នូត្រឹមតែមួយហត្ថ កូនធ្នូទី ២ ឃ្លាត

ត្រឹមតែ ២ ហត្ថ កូនធ្នូទី ៣ ឃ្មាតត្រឹមតែ ៣ ហត្ថ ចាប់កូនធ្នូទី ៤ មិនឲ្យធ្លាក់ដល់ផែនដីឡើយ ។ ខណៈនោះនាយខ្មាន់ធ្នូបានឃើញស្តេចហង្សនោះ ក្នុងវេលាដែលចាប់កូនធ្នូទាំង ៤ គ្រាប់ ហើយហើរមកទំត្រង់សសរខឿនទុំះឯង ។ ស្តេចហង្សក្រាបទូលព្រះរាជាថា មេត្តាទ្រង់ជ្រាបចុះ មហារាជ ភាពលឿនរហ័សរបស់ខ្ញុំ យ៉ាងនេះ ។

គប្បីជ្រាបថា កូនធ្នូទាំងនោះ ព្រះពោធិសត្វនាំមកក្នុងគ្រាសោយព្រះជាតិជា **ជវនហំស:** ដោយប្រការដូច្នេះ ។

បទថា **បុរតោ ធាវន្តិ** សេចក្តីថា ស្ទុះទៅមុនៗ តែទេវតាទាំងនោះ មិនបាននៅខាងមុខរហូតឡើយ ពេលខ្លះនៅខាងមុខ ពេលខ្លះនៅខាងក្រោយ ។ ពិតណាស់ ក្នុងវិមានពួកអាកាសដ្ឋកទេវតា មានទាំងឧទ្យាន មានទាំងស្រះ បោក្ខរណី ។ ទេវតាទាំងនោះ ងូតទឹកលេងកីឡាក្នុងទីនោះ នៅខាងក្រោយខ្លះ ទៅដោយកម្លាំងលឿនរហ័ស រហូតហួសទៅខាងមុខទៀតក៏មាន ។ បទថា **អាយុសង្ខារា** លោកពោលសំដៅរូបជីវិតិន្ទ្រិយ ។ ពិតហើយ រូបជីវិតិន្ទ្រិយនោះ អស់ទៅរហ័សជាងភាពលឿនរហ័សរបស់ទេវតានោះ ។ តែនរណាៗ មិនអាចនឹងដឹងដល់ការបែកធ្លាយរបស់អរូបធម៌បាន ។

ចប់អដ្ឋកថា ធនុគ្គហសូត្រទី ៦

# អ ដ្ឋ ក ថា

## អាណីសូត្រទី ៧

[៣៤០] ក្នុង *អាណីសូត្រទី ៧* មានវិនិច្ឆ័យដូចតទៅនេះ ៖

*បទថា **ទសារហានំ** បានដល់ ពួកក្សត្រិយ៍ដែលមានព្រះនាមយ៉ាងនេះ ។ បានឮថា ក្សត្រិយ៍ទាំងនោះ កាន់យក ១០ ចំណែកអំពីស្រូវសន្ទូងដូច្នោះ ទើបប្រាកដឈ្មោះថា **ទសារហា** ។ បទថា **អានកោ** បានដល់ ស្គរមានឈ្មោះយ៉ាងនេះ ។*

*បានឮថា ក្នុងព្រៃហិមវន្ត មានស្រះក្តាមធំ ។ ក្តាមដ៏ធំ ស៊ីដំរីដែលចុះទៅក្នុងស្រះនោះ ។ គ្រានោះ ពួកដំរីត្រូវក្តាមបៀតបៀន មានសេចក្តីយល់ឃើញរួមគ្នាថា ព្រោះអាស្រ័យកូនរបស់នាងដំរីនេះ ពួកយើងទើបនឹងមានសេចក្តីសួស្តីបាន ទើបបាននាំគ្នាធ្វើសក្ការៈនាងដំរី ។ សូម្បីនាងដំរីនោះក៏បានបង្កើតកូន ជាដំរីមហេសក្ខ ។ ដំរីទាំងឡាយនាំគ្នាធ្វើសក្ការៈសូម្បីកូនដំរីនោះ ។ កូនដំរីចម្រើនវ័យហើយសួរមេថា ហេតុអ្វីដំរីទាំងនេះទើបធ្វើសក្ការៈយើង ។ មេដំរីទើបពោលរឿងឲ្យស្តាប់ ។ កូនដំរីពោលថា ក៏ក្តាមជាអ្វីចំពោះនឹងខ្ញុំ ពួកយើងទៅទីនោះ ហែហមទៅដោយដំរីជាច្រើន*

ទៅទីនោះហើយ ក៏ចុះស្រះមុនតែម្តង ។ ក្តាមមកកៀបកូនដំរីទុក ព្រោះសំឡេងទឹកទុំះឯង ។ ក្តាមមានដង្កៀបដ៏ធំ ។ កូនដំរីមិនអាចធ្វើឲ្យក្តាមឃ្លាតទៅខាងណេះ ខាងណោះបាន ទើបស៊ីកប្រមោយចូលមាត់ ស្រែកលាន់ឡើង ។ ដំរីទាំងឡាយពោលថា កូនដំរីដែលពួកយើងយល់ថា បានអាស្រ័យហើយនឹងមានសេចក្តីសួស្តីនោះ ត្រូវក្តាមកៀបហើយ ទើបនាំគ្នារត់ចេញទៅ ។ លំដាប់នោះ មេរបស់កូនដំរីឈរនៅមិនឆ្ងាយ ពោលនឹងក្តាមដោយពាក្យដែលគួរស្រឡាញ់ថា ពួកយើងឈ្មោះថា ជាអ្នកប្រសើរលើគោក ពួកលោកឈ្មោះថា ជាអ្នកប្រសើរក្នុងទឹក អ្នកប្រសើរមិនគួរបៀតបៀនអ្នកប្រសើរដូច្នេះ ហើយពោលគាថានេះថា

យេ កុឡីរា សមុទ្ទស្មឹ　　គង្គាយ　យមុនាយ
ច　តេសំ　ត្វំ　វារិជោ　　សេដ្ឋោ មុញ្ច រោទន្តិយា បជំ

បណ្តាក្តាមទាំងឡាយក្នុងសមុទ្រ ក្នុងទន្លេគង្គា និងទន្លេយមុនា
ទាំងនោះ លោកជាសត្វទឹកដ៏ប្រសើរបំផុត សូមលោកចូរព្រលែង
កូនរបស់យើងដែលស្រែកយំហើយ ។

ធម្មតាសំឡេងមាតុគ្រាម រមែងធ្វើឲ្យបុរសរំជើបរំជួល ដូច្នោះ ក្តាមទើបបានបន្ធូរដង្កៀប កូនដំរីប្រញាប់លើកជើងទាំងពីរឡើង ជាន់ស្នូកក្តាម ។

ពេលត្រូវជាន់ ស្នូកក្ដាមក៏បែកដូចកាជនៈដី ។ លំដាប់នោះកូនដំរីយកក្ដុក ទាំងពីរចាក់ក្ដាម លើកឡើងបោះទៅលើគោក ហើយបញ្ចេញសំឡេងស្រែក សម្ដែងសេចក្ដីត្រេកអរ ដំរីទាំងឡាយមកពីទីផ្សេងៗ ជាន់ក្ដាមនោះ ។ ដង្កៀប មួយបាក់ធ្លាក់ចុះ សក្កទេវរាជទ្រង់កាន់យកតង្កៀបក្ដាមនោះទៅ ។

ចំណែកដង្កៀបមួយទៀត ត្រូវខ្យល់ និងកំដៅថ្ងៃដុតដរាបស្ងួត មាន ពណ៌ដូចទឹកល័ក្ដរម្ងាស់ ។ កាលភ្លៀងធ្លាក់ ដង្កៀបក្ដាមនោះ ត្រូវក្រសែទឹក បន្សាត់ អណ្ដែតមកជាប់សំណាញ់របស់ព្រះរាជាបងប្អូន ១០ អង្គ ដែល បានរាយសំណាញ់ក្នុងទឹក ហើយក៏លេងទឹកនៅទន្លេគង្គា ។ កាលលេងទឹក ហើយលើកសំណាញ់ឡើង ព្រះរាជាទាំងនោះ ទ្រង់ឃើញដង្កៀបក្ដាមនោះ ត្រាស់សួរថា អ្វីនោះ ។ ដង្កៀបក្ដាម ព្រះអង្គ ។ ព្រះរាជាទាំងឡាយត្រាស់ ថា ដង្កៀបក្ដាមនេះ មិនអាចនាំទៅធ្វើជាគ្រឿងប្រដាប់បាន ពួកយើងនឹង ឲ្យស្រោបដង្កៀបក្ដាមនេះធ្វើស្គរ ត្រាស់បង្គាប់ឲ្យស្រោប ហើយទ្រង់វាយ ។ សំឡេង (ស្គរ) ឮទៅទាំងព្រះនគរប្រមាណ ១២ យោជន៍ ។ តអំពីនោះ ព្រះរាជាទាំងឡាយត្រាស់ថា មិនអាចប្រគំស្គរនេះប្រចាំថ្ងៃ ចូរជាមង្គលភេរី សម្រាប់ថ្ងៃមហោស្រពចុះ ទើបឲ្យធ្វើជាមង្គលភេរី ។ កាលប្រគំស្គរនោះ ប្រជាជនមិនទាន់ផ្ទូតទឹក មិនទាន់តែងខ្លួន ប្រញាប់ឡើងយានដំរីជាដើមទៅ

ប្រជុំ ។ ស្គរនោះបានឈ្មោះថា **អានកៈ** ព្រោះដូចហៅប្រជាជនមក ដោយប្រការដូច្នេះ ។

បទថា **អញ្ញំ អាណឹ ឱទហឹសុ** សេចក្តីថា ស្រោបដោយវត្ថុដទៃ ដែលសម្រេចដោយមាស និងប្រាក់ជាដើម ។ បទថា **អាណិសង្ឃាតោវ អវសិស្សិ** (នៅសល់តែវត្ថុស្រោប) សេចក្តីថា ត្រឹមតែវត្ថុស្រោបដែលសម្រេចដោយមាសជាដើមប៉ុណ្ណោះ ។ លំដាប់នោះ សំឡេងរបស់ស្គរនោះ ដែលឮប្រមាណ ១២ យោជន៍ សូម្បីនៅខាងក្នុងរាំងននក៏លំបាកនឹងឮបាន ។

បទថា **គម្ភីរា** សេចក្តីថា ពោលដោយបាលី ព្រះសូត្រទាំងឡាយដែលជ្រាលជ្រៅ ដូចសល្លសូត្រ ។ បទថា **គម្ភីរត្ថា** សេចក្តីថា ពោលដោយអត្ថ ព្រះសូត្រទាំងឡាយដែលជ្រាលជ្រៅ ដូចមហាវេទល្លសូត្រ ។ បទថា **លោកុត្តរា** បានដល់ សម្តែងអត្ថដែលជាលោកុត្តរៈ ។ បទថា **សុញ្ញត-បដិសុញ្ញុត្តា** សេចក្តីថា ដូចប្រកបសេចក្តីដែលប្រកាសត្រឹមតែសុញ្ញតធម៌ប៉ុណ្ណោះ ។ បទថា **ឧគ្គហេតព្វំ បរិយាបុណិតព្វំ** សេចក្តីថា ដែលគប្បីរៀន និងគប្បីសិក្សា ។ បទថា **កវិកតា** សេចក្តីថា ដែលកវី គឺ អ្នកប្រាជ្ញរចនាទុក ។ ក្រៅពីនោះ ជាវេវចនៈរបស់បទថា **កវិកតា** នុ៎ះឯង ។ បទថា **ចិត្តក្ខរា** បានដល់ មានអក្សរវិចិត្រ ។ ក្រៅពីនោះ ជាវេវចនៈរបស់បទថា

ចិត្តក្ខរា ទុ៎ះឯង ។ បទថា ពាហិរកា បានដល់ មានខាងក្រៅព្រះសាសនា ។ បទថា សាវកភាសិតា សេចក្ដីថា ព្រះសូត្រទាំងសាវកភាសិត ។ បទថា សុស្សូសិស្សំ (ប្រាថ្នានឹងស្ដាប់ដោយល្អ) សេចក្ដីថា សាមណេរ ភិក្ខុកម្លោះ មាតុគ្រាម និងមហាគហបតីជាដើម មានសេចក្ដីពេញចិត្ត ព្រោះព្រះសូត្រទាំងនោះ មានអក្សរវិចិត្រ និងសម្បូរដោយការស្ដាប់ និងជាអ្នកប្រាថ្នានឹងស្ដាប់ ប្រជុំគ្នាដោយគិតថា អ្នកនេះជាធម្មកថិក ។ បទថា តស្មា សេចក្ដីថា ព្រោះហេតុនោះ ព្រះសូត្រទាំងឡាយដែលជាតថាគតភាសិត កាលពួកយើងមិនសិក្សា រមែងអន្តរធានទៅ ។

ចប់អដ្ឋកថា អាណិសូត្រទី ៧

# អ ដ្ឋ ក ថា

## កលិង្គរសូត្រទី ៨

[៣៤៣] ក្នុង *កលិង្គរសូត្រទី ៨* មានវិនិច្ឆ័យដូចតទៅនេះ ៖

*បទថា* **កលិង្គរូបធានា** *បានដល់ ធ្វើកំណាត់ឈើ គឺ កំណាត់ឧស ជាខ្នើយកើយសីសៈ និងកល់ជើង ។ បទថា* **អប្បមត្តា** *បានដល់ មិនប្រមាទ ក្នុងការរៀនសិល្បៈ ។ បទថា* **អាតាបិនោ** *បានដល់ ផ្តើមប្រកបសេចក្តីព្យាយាម គឺ សេចក្តីព្យាយាមដែលជាហេតុធ្វើកិលេសឲ្យក្តៅ ។ បទថា* **ឧបាសនស្មឹ** *បានដល់ ក្នុងការផ្តើមប្រកបសិល្បៈ និងក្នុងការចូលទៅអង្គុយជិតអាចារ្យ ។ បានឮថា ក្នុងកាលនោះ ពួកគេក្រោកឡើងពីព្រឹកព្រលឹមទៅកាន់សាលាសិល្បៈ រៀនសិល្បៈក្នុងសាលាសិល្បៈនោះហើយ ធ្វើការប្រកបសេចក្តីព្យាយាមដោយការរៀន និងការស្វាធ្យាយជាដើម លុបលាងមុខហើយ ទៅបរិភោគបបរ បរិភោគបបរហើយ ទៅកាន់សាលាសិល្បៈទៀត ធ្វើការស្វាធ្យាយ ទៅបរិភោគអាហារពេលព្រឹក បរិភោគអាហារព្រឹកស្រេចហើយ គិតថា សូមពួកយើងកុំដេកលក់យូរដោយសេចក្តីប្រមាទឡើយ ហើយកើយសីសៈ និងជើងនូវកំណាត់ឧស លក់មួយស្របក់ ក៏ទៅកាន់រោង*

សិល្បៈទៀត ផ្ដើមស្វាធ្យាយសិល្បៈ និងវេលាល្ងាចធ្វើការស្វាធ្យាយសិល្បៈ ត្រឡប់ទៅផ្ទះបរិភោគអាហារល្ងាច បឋមយាមធ្វើការស្វាធ្យាយ វេលាល្ងាច ដេកកើយកំណាត់ឈើដូចមុននោះឯង គេទាំងនោះមិនដឹងខណៈ និងមានបញ្ញាទន់ខ្សោយ ដែលលោកសំដៅយកពោលទុកដូច្នេះ ។

បទថា **ឱតារំ** ប្រែថា ប្រហោង ។ បទថា **អារម្មណំ** បានដល់ បច្ច័យ ។ បទថា **បធានស្មឹ** បានដល់ ធ្វើសេចក្ដីព្យាយាមក្នុងទីសម្រាប់ធ្វើសេចក្ដីព្យាយាម ។

បានឮថា ក្នុងបឋមពោធិកាល ភិក្ខុទាំងឡាយធ្វើភត្តកិច្ចស្រេចហើយ មនសិការព្រះកម្មដ្ឋាន កាលភិក្ខុទាំងនោះកំពុងមនសិការនោះឯង ព្រះអាទិត្យក៏អស្តង្គត ។ ភិក្ខុទាំងនោះងូតទឹកហើយ ចុះចង្រ្កមទៀត ចង្រ្កមរហូតអស់បឋមយាម ។ តអំពីនោះគិតថា ពួកយើងកុំដេកលក់យូរ ដេកដើម្បីបន្ទោបង់សេចក្ដីលំបាកផ្លូវកាយ ទើបដេកកើយកំណាត់ឈើ ។ ក៏ភិក្ខុទាំងនោះក្រោកឡើងក្នុងបច្ឆិមយាម ហើយចង្រ្កម ។ លោកសំដៅយកភិក្ខុទាំងនោះទើបពោលទុកដូច្នេះ ។ ក្នុងវដ្ដកាលនៃព្រះរាជដែលគ្រប់គ្រងផែនដីរហូត ៣ វដ្ដកាល កោះនេះ ក៏ជាទីដែលមានសំឡេងរគាំងតែម្យ៉ាង បានជាផ្ទៃដីសម្រាប់បំពេញព្យាយាមតែម្យ៉ាង រគាំងដែលគេវាយនៅវិហារផ្សេងៗ ក៏ដូចបំណង

ទៅកាន់បិលិច្ឆិកោជិនគរ រគាំងដែលគេវាយនៅកល្យាណីវិហារ ក៏ដូចបំណាច់ទៅកាន់នាគទ្វីប ភិក្ខុនេះនឹងត្រូវគេចន្ទុលដោយម្រាមដៃថា ជាបុថុជ្ជន ។ ភិក្ខុទាំងអស់បានសម្រេចព្រះអរហត្តក្នុងថ្ងៃតែមួយ ។ បទថា **តស្មា** សេចក្តីថា ព្រោះមារមិនបានគ្រឿងកើយ គឺ កំណាត់ឈើជាអារម្មណ៍ ។

ចប់អដ្ឋកថា កលិង្គរសូត្រទី ៨

# អ ដ្ឋ ក ថា

## នាគសូត្រទី ៩

ក្នុង នាគសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៨៥] បទថា **អតិវេលំ** សេចក្តីថា កាលដែលកន្លងវេលាទៅ គឺ កាលដែលកន្លងប្រមាណទៅ ។ បទថា **កិមង្គំ បនាហំ** សួរថា ក៏ព្រោះហេតុអ្វី យើងទើបមិនចូលទៅរក ។

[៣៨៦] បទថា **ភិសមុឡាលំ** បានដល់ មើម និងក្រអៅតូចធំ ។ បទថា **អព្ពុគ្គហេត្វា** បានដល់ ដកឡើង ។ បទថា **ភិកច្ឆាបា** បានដល់ កូនដំរី ។ បានឮថា កូនដំរីទាំងនោះស្រែកឮដូចសំឡេងដំរីជំទង់ ព្រោះដូច្នោះ លោកទើបហៅថា កូនដំរី ។

[៣៨៧] បទថា **បសន្នាការំ ករោន្តិ** សេចក្តីថា ធ្វើអាការដែលបុគ្គលជ្រះថ្លាគប្បីធ្វើ គឺ ថ្វាយបច្ច័យ ៤ ។ បទថា **ធម្មំ ភាសន្តិ** សេចក្តីថា រៀន ១-២ ជាតក ឬព្រះសូត្រហើយ សម្តែងធម៌ដោយសំឡេងដែលមិនបែក ។ បទថា **បសន្នាការំ ករោន្តិ** សេចក្តីថា ជ្រះថ្លាក្នុងទេសនារបស់ភិក្ខុទាំងនោះ ហើយថ្វាយបច្ច័យរបស់គ្រហស្ថ ។

*បទថា **នេវ វណ្ណាយ ហោតិ ន ពលាយ** សេចក្តីថា មិនមែនមានដើម្បីសរសើរគុណ មិនមែនសរសើរញាណ និងកាលគុណសាបសូន្យទៅ វណ្ណៈនៃសរីរៈក្តី កំពុងនៃសរីរៈក្តី រមែងសាបសូន្យទៅ ព្រោះដូច្នោះ ទើបឈ្មោះថា មិនប្រព្រឹត្តទៅដើម្បីវណ្ណៈ និងដើម្បីកម្លាំងរបស់សរីរៈ ។*

ចប់អដ្ឋកថា នាគសូត្រទី ៩

# អ ដ្ឋ ក ថា

## ទិឡារសូត្រទី ១០

ក្នុង វិឡារសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៤៩] បទថា *សន្ធិ* ក្នុងពាក្យថា *សន្ធិសមលសង្កតិរេ* បានដល់ ទី.តនៃផ្ទះទាំងពីរ ។ បទថា *សមលា* បានដល់ ផ្លូវជាទីបោលលាមកក្រៅផ្ទះ ។ បទថា *សង្កតិរេ* បានដល់ ទីបោលសម្រាម ។ បទថា *មុទុមូសិ* បានដល់ កូនកណ្ដុរ ។

[៣៥០] បទថា *វុដ្ឋានំ បញ្ញាយតិ* បានដល់ ការសម្ដែងរមែងប្រាកដ ។

ចប់អដ្ឋកថា វិឡារសូត្រទី ១០

# អ ដ្ឋ ក ថា

## បឋមសិគាលសូត្រទី ១១

ក្នុង *បឋមសិគាលសូត្រទី ១១* មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៥១] *ដោយបទថា* **យេន យេន ឥច្ឆតិ** *លោកសម្តែងថា ចចកចាស់មួយក្បាលនោះ រមែងមានចិត្តរីករាយជាខណៈៗ ដោយការផ្លាស់ប្តូរឥរិយាបថ និងដោយខ្យល់ត្រជាក់បក់មកត្រូវឲ្យវា ក្នុងទីដែលវាប្រាថ្នា ។*

[៣៥២] *បទថា* **សក្យបុត្តិយប្បដិញ្ញោ** *នេះ លោកពោលសំដៅដល់ព្រះទេវទត្ត ព្រះទេវទត្តនោះ នឹងមានចិត្តរីករាយសូម្បីត្រឹមតែប៉ុណ្ណោះ ក្នុងអត្តភាពដែលនឹងមកខាងមុខ ។*

ចប់អដ្ឋកថា បឋមសិគាលសូត្រទី ១១

# អ ដ្ឋ ក ថា

## ទុតិយសិគាលសូត្រទី ១២

ក្នុង *ទុតិយសិគាលសូត្រទី ១២* មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៥៣] បទថា **កតញ្ញុតា** បានដល់ ដឹងគុណដែលអ្នកដទៃធ្វើ ។ បទថា **កតវេទិតា** បានដល់ ដឹងគុណដែលផ្សងអំពីគុណដែលគេធ្វើ (តបជំនួស) ក្នុងសេចក្តីនេះ មានរឿងចចកចាស់ដែលមានកតញ្ញូ ដូចតទៅនេះ ៖

បានឮមកថា បងប្អូន ៧ នាក់ ទៅភ្ជួរស្រែ បណ្តាបងប្អូនទាំងនោះ ប្អូនប្រុសពៅ ដឹកគោឲ្យស៊ីឯចុងស្រែ ។ ខណៈនោះ ពស់ថ្លាន់រឹតចចកចាស់មួយ ។ គេឃើញដូច្នោះ ទើបយកឈើវាយពស់ឲ្យព្រលែង ។ ពស់ថ្លាន់ក៏លែងចចកនោះ ហើយមករឹតគេវិញមួយរំពេច ចចកគិតថា បុគ្គលនេះជួយជីវិតយើង សូម្បីយើងក៏នឹងជួយជីវិតបុគ្គលនេះ ទើបពាំកាំបិតដែលដាក់នៅលើថ្នាំងបាយ ទៅរកគេ ។ ពួកបងៗ កំពុងភ្ជួរស្រែឃើញ ក៏ដេញតាម ដោយគិតថា ចចកលួចកាំបិត ។ ចចកដឹងថា ពួកបងៗ ទាំងនោះឃើញហើយ ទើបចោលកាំបិតទុកជិតប្អូនពៅ ហើយគេចចេញទៅ ។ ពួកបងៗ មកឃើញប្អូនប្រុសត្រូវពោះថ្លាន់រឹត ទើបយកកាំបិតកាប់ពោះថ្លាន់ ហើយ

បាននាំប្អូនប្រុសទៅ ។ ភាពកតញ្ញូកតវេទី គប្បីមានក្នុងចចកចាស់ខ្លះ ដោយប្រការដូច្នេះ ។

សូម្បីពាក្យថា សក្យបុត្តិយប្បដិញ្ញោ នេះ លោកពោលសំដៅយកការប្រព្រឹត្តរបស់ព្រះទេវទត្តប៉ុណ្ណោះឯង ។

ចប់អដ្ឋកថា ទុតិយសិគាលសូត្រទី ១២

## ចប់ឱបម្មសំយុត្ត

## រួមក្នុងវគ្គនេះមាន ១២ អដ្ឋកថា


១-អដ្ឋកថា កូដាគារសូត្រ
២-អដ្ឋកថា នខសិខាសូត្រ
៣-អដ្ឋកថា កុលសូត្រ
៤-អដ្ឋកថា ឱក្ខាសូត្រ
៥-អដ្ឋកថា សត្តិសូត្រ
៦-អដ្ឋកថា ធនុគ្គហសូត្រ
៧-អដ្ឋកថា អាណិសូត្រ
៨-អដ្ឋកថា កលិង្គរសូត្រ
៩-អដ្ឋកថា នាគសូត្រ
១០-អដ្ឋកថា វិឡារសូត្រ
១១-អដ្ឋកថា បឋមសិគាលសូត្រ
១២-អដ្ឋកថា ទុតិយសិគាលសូត្រ

# ភិក្ខុសំយុត្ត

## អ ដ្ឋ ក ថា

### កោលិតសូត្រទី ១

*កោលិតសូត្រទី ១ ក្នុងភិក្ខុសំយុត្ត មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៥៤] បទថា **អាវុសោ** ជាពាក្យហៅព្រះសាវក ។ ពិតណាស់ ព្រះមានព្រះភាគជាព្រះពុទ្ធទាំងឡាយ កាលត្រាស់ហៅព្រះសាវក រមែងត្រាស់ហៅថា **ភិក្ខវេ** ចំណែកព្រះសាវកទាំងឡាយគិតគ្នាថា ពួកយើងកុំដូចជាព្រះពុទ្ធទាំងឡាយឡើយ ដែលដំបូងពោលថា **អាវុសោ** ជាខាងក្រោយពោលថា **ភិក្ខវេ** ។ ភិក្ខុសង្ឃដែលព្រះពុទ្ធទាំងឡាយត្រាស់ហៅ រមែងទូលតបព្រះតម្រាស់ថា **ភន្តេ** ។ ភិក្ខុសង្ឃដែលព្រះសាវកទាំងឡាយហៅ រមែងតបថា **អាវុសោ** ។*

*[៣៥៥] ក្នុងពាក្យថា **អយំ វុច្ចតិ** នេះ ប្រកបសេចក្តីដូច្នេះ ព្រោះវិតក្កវិចារៈក្នុងទុតិយជ្ឈានរលត់ សឡាយតនៈរមែងប្រព្រឹត្តទៅមិនបាន ដូច្នោះ ទុតិយជ្ឈាននេះ លោកទើបហៅថា **អរិយោ តុណ្ហីភាវោ** ការស្ងៀមដ៏ប្រសើរ*

តែក្នុងពាក្យថា ធម្មីកថា ឬការស្ងៀមដ៏ប្រសើរនេះ ការមនសិការកម្មដ្ឋានក្តី បឋមជ្ឈានជាដើមក្តី រាប់ថា ជាការស្ងៀមដ៏ប្រសើរទាំងនោះ ។

បទថា **វិតក្កសហគតា** បានដល់ មានវិតក្កជាអារម្មណ៍ ។ បទថា **សញ្ញា មនសិការា** បានដល់ សញ្ញា និងមនសិការ ។ បទថា **សមុទាចរន្តិ** បានដល់ រមែងប្រព្រឹត្តទៅ ។ បានឮថា ទុតិយជ្ឈានរបស់ព្រះថេរៈមិនទាន់ជំនាញ ដូច្នោះ ពេលលោកចេញចាកទុតិយជ្ឈាននោះហើយ វិតក្កវិចារៈមិនតាំងឡើងព្រោះស្ងប់ទៅ ។ ទុតិយជ្ឈានក្តី សញ្ញា និងមនសិការក្តីរបស់ព្រះថេរៈនោះ បានប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្តីវិនាសនោះឯង ។ កាលទ្រង់សម្តែងទុតិយជ្ឈាននោះ ទើបត្រាស់យ៉ាងនេះ ។ បទថា **សណ្ឋបេហិ** បានដល់ តាំងនៅដោយប្រពៃ ។ បទថា **ឯកោទិការំ ករោហិ** បានដល់ ធ្វើឲ្យមានអារម្មណ៍តែមួយ ។ បទថា **សមាទហ** បានដល់ លើកឡើងតាំងទុកដោយប្រពៃ ។ បទថា **មហាភិញ្ញតំ** បានដល់ អភិញ្ញា ៦ ។

បានឮថា ព្រះសាស្តាទ្រង់ផ្សាយសមាធិដែលប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្តីវិនាសរបស់ព្រះថេរៈអស់ ៧ ថ្ងៃ ដោយឧបាយនេះ ឲ្យព្រះថេរៈសម្រេចអភិញ្ញា ៦ ។

ចប់អដ្ឋកថា កោលិតសូត្រទី ១

# អដ្ឋកថា

## ឧបតិស្សសូត្រទី ២

ក្នុង ឧបតិស្សសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៥៧] ពាក្យថា *អត្ថិ នុ ខោ តំ កិញ្ចិ លោកស្មឹ* នេះ លោកពោលសំដៅយកសត្វ ឬសង្ខារដ៏ជំក្រែលែង ។

[៣៥៨] ពាក្យថា *សត្ថុបិ ខោ តេ* នេះ ព្រះអានន្ទសួរដើម្បីនឹងជ្រាបថា សេចក្តីសោកជាដើម មិនគប្បីកើតឡើងដល់ព្រះថេរៈនេះ ព្រោះការប្រែប្រួលនៃព្រះសាស្តាឬ ព្រោះព្រះអានន្ទត្ថេរ មានសេចក្តីពេញចិត្តនិងសេចក្តីស្រឡាញ់ក្នុងព្រះសាស្តានៅហួសប្រមាណ ។ ពាក្យថា **ទីឃរត្តំ** លោកពោលសំដៅយកវេលាដែលកន្លងទៅ តាំងពីថ្ងៃដែលទ្រង់សម្តែងវេទនាបរិគ្គហសូត្រដល់ទីឃនខបរិព្វាជក ត្រង់ទ្វារល្អាងសូករខាតា ។ ក៏ក្នុងថ្ងៃនោះ ព្រះថេរៈដកកិលេសដែលប្រព្រឹត្តទៅតាមវដ្តៈទាំងនេះបានហើយនោះឯង ។

ចប់អដ្ឋកថា ឧបតិស្សសូត្រទី ២

# អដ្ឋកថា

## យជសូត្រទី ៣

ក្នុង យជសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៥៩] បទថា ឯកវិហារេ បានដល់ ក្នុងបន្ទប់មួយ ។ បានឮថា គ្រានោះ ភិក្ខុអាគន្តុកៈប្រជុំគ្នាជាច្រើន ។ ព្រោះដូច្នោះ សេនាសនៈជាយបរិវេណ ឬជាយវិហារមិនគ្រប់គ្រាន់ ព្រះថេរៈពីររូបត្រូវនៅបន្ទប់តែមួយជាមួយគ្នា ព្រះថេរៈទាំងនោះ ពេលថ្ងៃអង្គុយបែកគ្នា តែពេលយប់បាំងវាំងននត្រង់កណ្តាលក្នុងចន្លោះព្រះថេរៈទាំងពីរ ព្រះថេរៈទាំងនោះអង្គុយក្នុងទីជារបស់ខ្លួនប៉ុណ្ណោះ ព្រោះហេតុនោះលោកទើបពោលថា ឯកវិហារេ ។

[៣៦០] ពាក្យថា ឱឡារិកេន លោកពោលសំដៅយកការមានអារម្មណ៍គ្រោតគ្រាត ។ ព្រោះថា ព្រះថេរៈនោះ នៅដោយវិហារធម៌ គឺ ទិព្វចក្ខុនិងទិព្វសោត ។ ពិតណាស់ រូបាយតនៈ និងសទ្ទាយតនៈ ដែលព្រះថេរៈទាំងពីរនោះដឹងហើយ ជាអារម្មណ៍គ្រោតគ្រាត ។ វិហារធម៌នោះឈ្មោះថាគ្រោតគ្រាត ព្រោះឃើញរូបដោយទិព្វចក្ខុ និងឮសំឡេងដោយទិព្វសោត-ធាតុ ។ បទថា ទិព្វចក្ខុំ វិសុជ្ឈិ សេចក្តីថា ទិព្វចក្ខុបរិសុទ្ធិដោយបានឃើញ

ព្រះរូបរបស់ព្រះមានព្រះភាគ ។ បទថា **ទិព្វា ច សោតធាតុ** សេចក្ដីថា ទិព្វសោតធាតុនោះ ឈ្មោះថា បរិសុទ្ធិដោយបានស្ដាប់ព្រះសូរសេងរបស់ព្រះមានព្រះភាគ ទិព្វចក្ខុ និងទិព្វសោតទាំងពីរ សូម្បីរបស់ព្រះមានព្រះ-ភាគក៏បរិសុទ្ធិ ដោយបានទតព្រះនេត្រឃើញរូប និងទ្រង់ស្ដាប់សំឡេងរបស់ព្រះថេរៈ ។ បានឮថា ក្នុងកាលនោះ ព្រះថេរៈគិតថា ឥឡូវនេះ ព្រះ-សាស្ដាប្រថាប់នៅទីណាហ្ន៎ ទើបចម្រើនអាលោកកសិណ ឃើញព្រះសាស្ដាប្រថាប់ក្នុងព្រះគន្ធកុដិ នាព្រះជេតវនវិហារ ដោយទិព្វចក្ខុ បានស្ដាប់ព្រះ-សូរសេងរបស់ព្រះមានព្រះភាគ ដោយទិព្វសោតធាតុ ។ សូម្បីព្រះសាស្ដាក៏ទ្រង់ធ្វើដូច្នោះ ។ ព្រះសាស្ដា និងព្រះថេរៈ បានឃើញ និងបានស្ដាប់សំឡេងគ្នានិងគ្នា ដោយប្រការដូច្នេះ ។

[៣៦១] បទថា **អារទ្ធវីរិយោ** បានដល់ មានសេចក្ដីព្យាយាមបរិ-បូណ៌ គឺ ផ្គងសេចក្ដីព្យាយាមទុកហើយ ។

[៣៦២] បទថា **យាវទេវ ឧបនិក្ខេបនមត្តាយ** សេចក្ដីថា ដុំថ្មទំហំប៉ុនគ្រាប់ស្ពៃ ដែលដាក់ទុកជិតភ្នំហិមវន្តដែលមានទទឹងបីពាន់យោជន៍ ។ លោកអធិប្បាយថា ដុំថ្មក៏ទុកត្រឹមតែដើម្បីនឹងប្រៀបធៀបយ៉ាងនេះថា ភ្នំហិមវន្តធំហ្ន៎ ដុំថ្មប៉ុណ្ណេះហ្ន៎ ។ សូម្បីខាងមុខក៏ន័យនេះឯង ។ បទថា **កប្បំ**

បានដល់ រហូតអស់អាយុកប្ប ។

[៣៦៣] ដោយបទថា លោណយដាយ លោកសម្ដែងប្រៀបដូចជាឆ្នាំងអំបិល ដែលមានទំហំប្រមានប៉ុនកណ្ដាប់មាត់ចក្រវាឡ មានកម្ពស់ទល់ព្រហ្មលោក ។ ក៏ព្រះថេរៈទាំងនោះ កាលនាំឧបមាមកប្រៀបធៀបនឹងវត្ថុដែលធ្លាប់បានឃើញ និងនឹងគុណដែលមានហើយ ។ យ៉ាងណា ។ ពិតណាស់ ធម្មតាថា ឫទ្ធិនេះ ដូចជាភ្នំហិមពាន្ត ព្រោះអត្ថថា ខ្ពស់សន្ធឹម និងព្រោះអត្ថថា ទំហំធំ , ចំណែកបញ្ញា ដូចជារសអំបិល ដែលដាក់ចូលទុកក្នុងបាយគ្រប់ប្រភេទ ព្រោះអត្ថថា ចូលទៅតាំងនៅក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នាំមកប្រៀបធៀបដោយអត្ថថា ឃើញប្រហាក់ប្រហែលគ្នាយ៉ាងនេះមុន ។ ចំណែកលក្ខណៈនៃសមាធិ ប្រាកដជាក់ច្បាស់ដល់ព្រះមហាមោគ្គល្លានត្ថេរ ។ ឈ្មោះថា ឫទ្ធិ ដែលមិនមាន រមែងមិនមានដល់ព្រះសារីបុត្តត្ថេរក៏ពិត សូម្បីយ៉ាងនោះ ព្រះមានព្រះភាគ ក៏ទ្រង់តាំងព្រះមហាមោគ្គល្លានត្ថេរទុកក្នុងឯតទគ្គៈថា ភិក្ខុទាំងឡាយ បណ្ដាភិក្ខុជាសាវករបស់តថាគតដែលមានឫទ្ធិ មហាមោគ្គល្លាននេះជាកំពូល ។ ចំណែកលក្ខណៈវិបស្សនា ប្រាកដច្បាស់ដល់ព្រះសារីបុត្តត្ថេរ ។ បញ្ញាមានហើយសូម្បីដល់ព្រះមហាមោគ្គល្លានត្ថេរក៏ពិត សូម្បីយ៉ាងនោះ ព្រះមានព្រះភាគក៏ទ្រង់តាំង

ព្រះសារីបុត្តត្ថេរទុកក្នុងឯតទគ្គៈថា ភិក្ខុទាំងឡាយ បណ្តាភិក្ខុជាសាវករបស់តថាគតដែលមានបញ្ញាច្រើន សារីបុត្រជាកំពូល ។ ព្រោះដូច្នោះ លោកទាំងពីរទើបទទួលនាទីនៃគ្នានិងគ្នា នាំមកប្រៀបធៀបជាមួយគុណដែលមានហើយ ដោយប្រការដូច្នេះ ។ ពិតណាស់ ព្រះមហាមោគ្គល្លានត្ថេរ សម្រេចក្នុងសមាធិលក្ខណៈ ព្រះសារីបុត្តត្ថេរសម្រេចក្នុងវិបស្សនាលក្ខណៈ ព្រះ-សម្មាសម្ពុទ្ធទ្រង់សម្រេចទាំងពីរលក្ខណៈ ។

ចប់អដ្ឋកថា ឃដសូត្រទី ៣

# អ ដ្ឋ ក ថា

## នវសូត្រទី ៤

ក្នុង **នវសូត្រទី ៤** មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៦៥] បទថា **អប្បោស្សុក្កោ** បានដល់ មិនមានសេចក្ដីខ្វល់ខ្វាយ ។ បទថា **សន្តាយតិ** បានដល់ មានសភាពតោះតើយ ។ បទថា **វេយ្យាវច្ចំ** បានដល់ កិច្ចដែលនឹងគប្បីធ្វើក្នុងចីវរ ។

[៣៦៦] បទថា **អភិចេតសិកានំ** បានដល់ អាស្រ័យអភិចិត្ត គឺ ចិត្តខ្ពង់ខ្ពស់ ។ បទថា **និកាមលាភី** បានដល់ ជាអ្នកបានតាមប្រាថ្នា ព្រោះជាអ្នកអាចចូលសមាបត្តិបានក្នុងខណៈដែលប្រាថ្នា ។ បទថា **អកិច្ឆលាភី** បានដល់ ជាអ្នកបានមិនលំបាក ព្រោះជាអ្នកអាចគ្របសង្កត់អន្តរាយរបស់ឈានចូលសមាបត្តិបានដោយងាយ ។ បទថា **អកសិរលាភី** បានដល់ ជាអ្នកបានយ៉ាងទូលាយ ព្រោះជាអ្នកអាចចេញបានតាមកំណត់ អធិប្បាយថា មានឈានជំនាញហើយ ។

[៣៦៧] បទថា **សិថិលមារព្ភ** បានដល់ ញុាំងសេចក្ដីព្យាយាមធូរថយ ។

ចប់អដ្ឋកថា នវសូត្រទី ៤

# អ ដ្ឋ ក ថា

## សុជាតសូត្រទី ៥

ក្នុង *សុជាតសូត្រទី ៥* មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៦៩] បទថា **អភិរូបោ** បានដល់ មានរូបល្អប្រសើរជាងរូបដទៃៗ ។ បទថា **ទស្សនីយោ** បានដល់ គួរទស្សនា ។ បទថា **បាសាទិកោ** បានដល់ ជាទីជ្រះថ្លានៃចិត្តក្នុងការមើល ។ បទថា **វណ្ណបោក្ខរតាយ** បានដល់ ដោយភាពជាអ្នកមានពណ៌សម្បុរល្អ ។

ចប់អដ្ឋកថា សុជាតសូត្រទី ៥

# អ ដ្ឋ ក ថា

## ភទ្ទិយសូត្រទី ៦

ក្នុង *ភទ្ទិយសូត្រទី ៦* មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៧២] បទថា *ទុព្វណ្ណំ* បានដល់ មានសម្បុរកាយមិនល្អ ។ បទថា *ឱកោដិមកំ* បានដល់ តូចទាប ។ បទថា *បរិភូតរូបំ* បានដល់ ត្រូវមើលងាយអំពីរឿងខ្នាត ។ បានឮថា ពួកភិក្ខុធព្វគ្គិយប្រមាទ លកុណ្ឌកភទ្ទិយ-ភិក្ខុថា អាវុសោភទ្ទិយៈ អាវុសោភទ្ទិយៈ ចំអកបែបផ្សេងៗ ចាប់ទាញមកខ្លះ ចាប់បង្វិលជុំវិញខ្លះ ក្នុងទីនោះៗ ព្រោះហេតុដូច្នេះនោះ លោកទើបពោលថា *បរិភូតរូបំ* ដូច្នេះ ។

ក៏ព្រោះហេតុអ្វី លកុណ្ឌកភទ្ទិយភិក្ខុ ទើបមានរូបយ៉ាងនេះ ។ បានឮមកថា លកុណ្ឌកភទ្ទិយភិក្ខុនេះ ធ្លាប់ជាព្រះរាជាធំមួយអង្គ ព្រះអង្គទ្រង់ស្អប់ដល់ពួកមនុស្សចាស់ និងស្ត្រីចាស់ៗ ប្រសិនបើព្រះអង្គឃើញមនុស្សចាស់ៗ ទ្រង់ត្រាស់ឲ្យប្អូនផ្នួងសក់របស់អ្នកទាំងនោះ ឲ្យចងក្លៀក ហើយឲ្យលេងតាមពេញចិត្ត សូម្បីឃើញស្ត្រីចាស់ៗ ក៏ធ្វើទារុណតាមប្រាថ្នាដល់ស្ត្រីទាំងនោះ ឲ្យលេងតាមពេញចិត្ត ទោសជំរមែងកើតឡើងក្នុងសម្នាក់នៃ

បុត្រ និងធីតាជាដើមរបស់ជនទាំងនោះ ការធ្វើសេចក្ដីអាក្រក់របស់លោក បានធ្វើឲ្យកើតកោលាហលតាំងពីផែនដីរហូតដល់ទេវលោក ៦ ជាន់ ។

លំដាប់នោះ ស្ដេចសក្កៈមានព្រះតម្រិះថា បុគ្គលអន្ធពាល បៀត-បៀនមហាជន យើងនឹងគ្របសង្កត់គេ ។ ស្ដេចសក្កៈទើបប្លែងភេទជាមនុស្សអ្នកស្រុកចំណាស់ម្នាក់ យកពាងពេញដោយតក្កៈ (ទឹកដោះដែលចំអិនលើភ្លើងមួយអំពុះ) ដាក់លើយានតូចមួយ បរយានចូលព្រះនគរ ។ ចំណែកព្រះរាជាទ្រង់ប្រថាប់លើដំរី ស្ដេចចេញចាកព្រះនគរ ទតឃើញគេ ត្រាស់ថា បុរសចាស់នេះ បែរមុខត្ដោះមករកយើង ដោយយានតូចពេញដោយតក្កៈ ឃាត់គេឃាត់គេ ។ ពួកមនុស្សរត់រកខាងនេះខាងនោះ ក៏មិនឃើញ ។ ព្រោះស្ដេចសក្កៈទ្រង់អធិដ្ឋានទុកយ៉ាងនេះថា ព្រះរាជាប៉ុណ្ណោះចូរឃើញយើង អ្នកដទៃចូរកុំឃើញ ។ លំដាប់នោះ កាលពួកមនុស្សទាំងនោះក្រាបទូលថា ទីណាព្រះអង្គទីណាព្រះអង្គ ប៉ុណ្ណោះ ព្រះរាជាព្រមទាំងដំរីស្ដេចចូលទៅក្រោមយាន ដូចកូនគោនៅក្រោមមេគោ ដូច្នោះ ។ ស្ដេចសក្កៈក៏ទ្រង់វាយពាងតក្កៈឲ្យបែកតាំងពីនោះ ព្រះរាជាមានព្រះវរកាយប្រឡាក់ប្រឡូសទៅដោយតក្កៈ ព្រះរាជាឲ្យជូតសម្អាតព្រះវរកាយ ចុះស្រង់ទឹកស្រះបោក្ខរណីក្នុងឧទ្យាន តាក់តែងព្រះវរកាយហើយ ស្ដេចចូលព្រះនគរ បានទតឃើញគេទៀត លុះទតឃើញ

ទើបត្រាស់ថា មនុស្សចាស់ដែលយើងឃើញនេះ ប្រាកដទៀតហើយ ចូរឃាត់គេ ចូរឃាត់គេ ។ ពួកមនុស្សក្រាបទូលថា ទីណាព្រះអង្គ ទីណាព្រះអង្គ ក៏រត់ទៅរត់មក ។ ព្រះអង្គប្រសព្វអាការខុសប្រក្រតីម្តងទៀត ខណៈនោះ ស្តេចសក្កៈឲ្យគោ និងយានបាត់ទៅ ប្រថាប់ឈរក្នុងអាកាស ត្រាស់ថា មនុស្សអន្ធពាល អ្នកសម្គាល់យើងថា ជាឈ្នួញតក្កៈ យើងគឺ ស្តេចសក្កទេវរាជ មកដើម្បីនឹងហាមការធ្វើអាក្រក់របស់អ្នក អ្នកកុំធ្វើយ៉ាងនេះតទៅទៀត ទ្រង់គម្រាមហើយ ក៏ស្តេចយាងទៅ ។ ដោយកម្មយ៉ាងនេះ លោកទើបមានពណ៌សម្បុរអាក្រក់ ។

ក៏ក្នុងសម័យព្រះវិបស្សីសម្មាសម្ពុទ្ធ លកុណ្ឌកភទ្ទិយភិក្ខុនេះ ជាសត្វតាវៅ ឈ្មោះចិត្តបត្ត នៅត្រង់មិគទាយវ័នជាទីឲ្យអភ័យ ថ្ងៃមួយហើរទៅព្រៃហិមវន្ត យកចំពុះពាំផ្លែស្វាយផ្អែមហើរមក ឃើញព្រះសាស្តាមានភិក្ខុសង្ឃហែហម ទើបគិតថា ថ្ងៃមុនៗ ជួបព្រះសាស្តា យើងមិនមានអ្វីតែថ្ងៃនេះ យើងមានផ្លែស្វាយទុំ យើងនឹងថ្វាយផ្លែស្វាយចំពោះព្រះទសពលដូច្នេះ ព្រះសាស្តាទ្រង់ជ្រាបចិត្តរបស់សត្វតាវៅ ទ្រង់ទតមើលឧបដ្ឋាក ។ ឧបដ្ឋាកនាំបាត្រចេញមកដាក់ទុកក្នុងព្រះហស្តរបស់ព្រះសាស្តា ។ សត្វតាវៅដាក់ស្វាយទុំចុះក្នុងបាត្ររបស់ព្រះទសពល ។ ព្រះសាស្តាប្រថាប់គង់សោយ

ស្វាយទុំក្នុងទីនោះឯង ។ សត្វតាវ៉ៅមានចិត្តជ្រះថ្លា រឭកដល់គុណព្រះ-ទសពលរឿយៗ ថ្វាយបង្គំព្រះទសពលហើយ ហើរទៅកាន់សំបុករបស់ខ្លួន ឲ្យវេលាកន្លងទៅដោយសេចក្តីសុខកើតពីបីតិនុ៎ះឯង រហូតអស់ ៧ ថ្ងៃ ។ ដោយកម្មនេះ សត្វតាវ៉ៅនោះ ទើបមានសំឡេងពីរោះ ។

ក្នុងសម័យព្រះកស្សបសម្មាសម្ពុទ្ធ កាលផ្តើមសាងចេតិយ ពួកជាង ប្រឹក្សាគ្នាថា យើងនឹងធ្វើកម្ពស់ណា កម្ពស់ ៧ យោជន៍ នេះខ្ពស់ពេក កម្ពស់ ៦ យោជន៍ សូម្បីនេះក៏ខ្ពស់ពេក កម្ពស់ ៥ យោជន៍ នេះខ្ពស់ពេក កម្ពស់ ៤ យោជន៍ ៣ យោជន៍ ២ យោជន៍ ដូច្នេះ គ្រានោះលកុណ្ឌកភទ្ទិយៈនេះ ជាមេជាង ពោលថា លោកដ៏ចម្រើន ក្នុងអនាគតគួរនឹងផ្តងឡើងសេចក្តី សុខទុក ដោយអាការយ៉ាងនេះ កាន់ខ្សែទាញទៅឈរក្នុងទីបំផុតមួយគាវុត ពោលថា មុខមួយៗ មួយគាវុត ទើបព្រះចេតិយមានទំហំមួយយោជន៍ កម្ពស់ មួយយោជន៍ ។ ជាងទាំងនោះបានធ្វើតាមពាក្យមេជាង ។ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ទើបសាងចេតិយហើយ ។ លោកបានធ្វើប្រមាណរបស់ព្រះពុទ្ធជាម្ចាស់ ដែលរកប្រមាណមិនបានដោយប្រការដូច្នេះ ដូច្នោះ ដោយកម្មនោះ លោក ទើបកើតជាមនុស្សតឿ ។

[៣៧៣] បទថា ហត្ថិយោ បសដមិគា បានដល់ ដំរី និងម្រឹគក្តាន់ ។

បទថា នត្ថិ កាយស្មឹ តុល្យតា សេចក្ដីថា ឈ្មោះថា ការប្រៀបធៀបក្នុងរាងកាយមិនមាន អធិប្បាយថា រាងកាយមិនសំខាន់ ។

ចប់អដ្ឋកថា ភទ្ទិយសូត្រទី ៦

# អ ដ្ឋ ក ថា

## វិសាខសូត្រទី ៧

ក្នុង *វិសាខសូត្រទី ៧* មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៧៥] បទថា *បោរិយា វាចាយ* បានដល់ ដោយវាចាដ៏ពីរោះ មានអក្ខរ និងបទមិនវិនាស ដូចវាចារបស់អ្នកក្រុង គឺ មនុស្សក្នុងក្រុង ។ បទថា *វិស្សដ្ឋាយ* បានដល់ មិនធ្វល់ មិនរវល់ មិនទាក់ទិន អធិប្បាយថា ដែលប្រមាត់ និងស្លេស្មមិនទម្លាយ ។ បទថា *អនេលគឡាយ* សេចក្ដីថា មិននិយាយដោយវាចាដូចវាចារបស់មនុស្សល្ងង់ ប្រើមាត់ដែលកំពុងលេបទឹកមាត់និយាយគ្នា សេចក្ដីពិត និយាយដោយវាចាប្រាសចាកទោស គឺ វាចាស្អាតរៀបរយ ។ បទថា *បរិយាបន្នាយ* បានដល់ វាចាដែលរាប់ចូលក្នុងសច្ចៈ ៤ គឺ វាចាដែលនិយាយមិនផុតអំពីសច្ចៈ ៤ ។ បទថា *អនិស្សិតាយ* បានដល់ មិនពោលវាចាដែលអាស្រ័យវដ្តៈ ។

[៣៧៦] បទថា *ធម្មោ ហិ ឥសិនំ ធជោ* សេចក្ដីថា លោកុត្តរធម៌ ៩ យ៉ាង ឈ្មោះថា ទង់របស់ឥសីទាំងឡាយ ។

ចប់អដ្ឋកថា វិសាខសូត្រទី ៧

# អ ដ្ឋ ក ថា

## នន្ទសូត្រទី ៨

ក្នុង នន្ទសូត្រទី ៨ មានវិច្ឆ័យដូចតទៅនេះ ៖

[៣៧៧] បទថា *អាកោដិតបច្ចាកោដិតានិ* សេចក្តីថា ដែលប្រើបាតដៃឬញញួរជំសងខាង ។ បទថា *អញ្ជិត្វា* បានដល់ ពេញដោយថ្នាំភ្នែក ។ បទថា *អច្ឆំ បត្តំ* បានដល់ បាត្រដីដែលមានពណ៌ថ្លា ។

សួរថា ក៏ព្រោះហេតុអ្វីព្រះថេរៈ ទើបធ្វើយ៉ាងនោះ ។ ឆ្លើយថា ដើម្បីដឹងអធ្យាស្រ័យរបស់ព្រះសាស្តា ។ បានឮថា ព្រះថេរៈនោះមានការគិតយ៉ាងនេះថា បើព្រះសាស្តានឹងត្រាស់ថា ប្អូនប្រុសរបស់យើងនេះ ស្អាតហ្ន៎ យើងនឹងប្រព្រឹត្តតាមអាការនេះឯង បើនឹងឃើញទោសក្នុងប្រការនេះ យើងនឹងលះអាការនេះ កាន់យកសំពត់អំពីគំនរសម្រាម ធ្វើជាចីវរគ្រង នឹងនៅប្រព្រឹត្តក្នុងសេនាសនៈខាងចុង ។

[៣៧៨] បទថា *អទ្ទសំ* ប្រែថា នឹងជា ។

[៣៧៩] បទថា *អញ្ញាកុញ្ចេន* សេចក្តីថា ក៏អាហារការឆាន់របស់ភិក្ខុអ្នកស្វែងរកកោជនដែលមានក្លិនក្រអូប ផ្សំដោយគ្រឿងក្តៅ ក្នុងផ្ទះរបស់

ឥស្សរជន ដែលគេកំណត់ទុក ឈ្មោះថា អញ្ញាកុញ្ចះ ។ តែភោជនលាយគ្នា ដែលភិក្ខុឈរត្រង់ទ្វារផ្ទះតាមលំដាប់ផ្ទះ ឈ្មោះថា អញ្ញាកុញ្ចះ អញ្ញាកុញ្ចៈនេះ លោកបំណងយកក្នុងទីនេះ ។ បទថា **កាមេសុ អនបេក្ខិនំ** បានដល់ ប្រាសចាកសេចក្តីហួងហែង ក្នុងវត្ថុកាម និងកិលេសកាម ។

[៣៨០] បទថា **អារញ្ញិកោ ច** លោកពោលដោយការសមាទានគ្រប់យ៉ាង ។ ពាក្យថា **កាមេសុ ច អនបេក្ខា** សេចក្តីថា ព្រះសូត្រនេះ ព្រះអង្គទ្រង់សម្តែងដល់នាងទេពអប្សរជាដើមក្នុងទេវលោក ស្តេចយាងមកទើបត្រាស់ទុកជាខាងក្រោយ ។ តាំងពីថ្ងៃទីត្រាស់ព្រះសូត្រនេះ ព្រះថេរៈប្រឹងប្រែងព្យាយាមប្រមាណ ២-៣ ថ្ងៃប៉ុណ្ណោះ ក៏តាំងនៅក្នុងព្រះអរហត្តជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរក្នុងលោក ព្រមទាំងទេវលោក ។

ចប់អដ្ឋកថា ឆដ្ឋសូត្រទី ៨

# អ ដ្ឋ ក ថា

## តិស្សសូត្រទី ៩

ក្នុង តិស្សសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៨០] បទថា ទុម្មនោ បានដល់ កើតទោមនស្ស ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះតិស្សៈនេះ ទើបកើតទុក្ខទោមនស្សយ៉ាងនេះ ។ ឆ្លើយថា ក៏ព្រះតិស្សៈនេះជាក្សត្រិយ៍ ហើយចេញបួស ។ ព្រោះដូច្នោះ ភិក្ខុទាំងឡាយឲ្យលោកបួសហើយ ឲ្យស្លៀកសំពត់សាជក ២ ជាន់ ដណ្តប់ចីវរយ៉ាងល្អបន្តក់ក្អែក លាបសីសៈ ដោយប្រេងលាយដោយទឹកពណ៌ក្រហម ។ កាលពួកភិក្ខុទៅកាន់ទីសម្រាកពេលយប់ និងពេលថ្ងៃ លោកមិនដឹងថា ធម្មតាថា ភិក្ខុត្រូវអង្គុយក្នុងឱកាសដែលស្ងាត់ ទើបទៅកាន់រោងឆាន់ ហើយឡើងអង្គុយលើគ្រែធំ ។ ភិក្ខុទាំងឡាយ ដែលសមាទានសំពត់បង្សុកូលជាវត្តដែលត្រាច់ទៅក្នុងទិសជាអាគន្តុកៈមក គិតថា ដោយទំនងនេះ ពួកយើងមានខ្លួនប្រឡាក់ដោយធូលី មិនអាចទៅគាល់ព្រះទសពលបាន យើងនឹងទុកដាក់របស់របរទុកជាមុន ដូច្នេះ ក៏ទៅកាន់រោងឆាន់ ។ កាលព្រះថេរៈកំពុងមក ព្រះតិស្សៈក៏អង្គុយស្ងៀម ។ ភិក្ខុពួកដទៃសួរដោយអើពើ (សូមឱកាស)

ថា ពួកយើងនឹងធ្វើវត្ត គឺ ការលាងជើង បក់ដោយផ្លិតស្ទីកត្នោត ក៏ព្រះតិស្សៈនៅអង្គុយស្ងៀមដដែល សួរថា ពួកលោកមានវស្សាប៉ុន្មាន ។ កាលពួកភិក្ខុនោះឆ្លើយថា ពួកខ្ញុំនៅមិនទាន់មានវស្សា ក៏លោកវិញមានវស្សាប៉ុន្មាន ទើបពោលថា ខ្ញុំទើបតែបួសក្នុងថ្ងៃនេះ ។ លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងលោកថា អាវុសោ លោកចូរកាត់ផ្ចង់សក់ឥឡូវនេះ សូម្បីថ្ងៃនេះ ក្ដិនចៃត្រង់គល់សីសៈរបស់លោក បញ្ចេញក្លិនកាយៗ កាលភិក្ខុចាស់ជាងមានប្រមាណប៉ុណ្ណេះ សូមឱកាសធ្វើវត្ត លោកក៏អង្គុយស្ងៀម សូម្បីសេចក្ដីកោតក្រែងរបស់លោកក៏មិនមាន លោកបួសក្នុងសាសនារបស់អ្នកណា ដូច្នេះ ហើយរួមគ្នាប្រហារព្រះតិស្សៈនោះដោយលំពែង គឺ វាចាពោលថា លោកមិនអាចចិញ្ចឹមជីវិតបានព្រោះមានបំណុល ឬភ័យខ្លាច ទើបបួស ឬលោកក្រឡេកមើលព្រះថេរៈមួយរូប កាលព្រះថេរៈនោះពោលថា លោកសម្លឹងមើលយើងឬលោកតា ទើបក្រឡេកមើលមួយរូបទៀត សូម្បីលោកម្នាក់នោះក៏ពោលយ៉ាងនោះដូចគ្នា ពេលនោះ លោកក៏កើតខត្តិយ-មានះឡើងថា ភិក្ខុទាំងនេះរួមគ្នាប្រើលំពែង គឺ វាចាចាក់ដោតយើង ទឹកភ្នែកពណ៌កែវមណីក្នុងគ្រាប់ភ្នែកក៏ហូរចេញ ។ តពីនោះ លោកក៏ពោលនឹងភិក្ខុទាំងនោះថា លោកមកកាន់សម្នាក់របស់អ្នកណា ។ ភិក្ខុទាំងនោះពោលថា

ក៏លោកសម្គាល់ថាយើង មកកាន់សម្នាក់របស់លោកឬ ពួកយើងមិនមែន នៅក្នុងភេទគ្រហស្ថនេះ ទើបពោលថា ពួកយើងមកកាន់សម្នាក់នៃព្រះសាស្តា ដែលជាអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោក ។ ព្រះតិស្សៈពោលថា ពួកលោកមកក្នុងសម្នាក់បងប្រុសរបស់យើង បើដូច្នោះ យើងនឹងទៅតាម ផ្លូវដែលពួកលោកមកនុ៎ះឯង ហើយក្រោកចេញទៅ បានគិតក្នុងរវាងផ្លូវថា កាលយើងទៅដោយទំនងនេះ ព្រះសាស្តានឹងឲ្យនាំភិក្ខុទាំងនេះចេញទៅ ទើប កើតទុក្ខទោមនស្ស ដើរទាំងទឹកភ្នែកហូរ ដោយហេតុនេះ លោកទើបកើត មានយ៉ាងនេះឯង ។

[៣៨២] បទថា **វាចាយ សន្និតោទកេន** សេចក្តីថា ដោយជន្ទញ គឺ ពាក្យសំដី ។ បទថា **សញ្ជម្ភរី អកំសុ** បានដល់ ធ្វើឲ្យពេញប្រៀប គឺ ឲ្យ ត្រឹមត្រូវមិនមានចន្លោះ ។ លោកអធិប្បាយទុកថា ចាក់ខាងលើ ។ បទថា **វត្តា** សេចក្តីថា លោកនិយាយរឿងដែលប្រាថ្នាចំពោះបុគ្គលពួកដទៃ ។ បទថា **នោ ច វចនក្ខមោ** សេចក្តីថា លោកមិនអាចអត់ទ្រាំពាក្យរបស់ជនពួកដទៃ កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា អ្នកត្រូវសេចក្តីក្រោធនេះចាក់ ព្រោះ ជន្ទញ គឺ វាចាក្នុងបច្ចុប្បន្ននេះ តែក្នុងអតីតអ្នកត្រូវព្រះរាជានេរទេសចេញ អំពីព្រំដែន ។ ភិក្ខុទាំងឡាយទើបទូលអង្វរចំពោះព្រះមានព្រះភាគថា ក្នុង

កាលណាព្រះអង្គ ។

ព្រះសាស្តាត្រាស់ថា ក្នុងអតីតកាល ព្រះបាទពារាណសីសោយរាជ-សម្បត្តិក្នុងក្រុងពារាណសី ។ គ្រានោះ ឥសី ២ នាក់ គឺ ម្នាក់ ឈ្មោះថា **ជាតិមា** ម្នាក់ឈ្មោះថា **មាតង្គ:** ។ បានទៅកាន់ក្រុងពារាណសី ឥសីទាំងពីរនាក់នោះ ឥសីឈ្មោះថា **ជាតិមា** ទៅដល់មុន អង្គុយក្នុងរោងជាងធ្នាំង ។ ក្រោយមកមាតង្គតាបសបានទៅដល់ សូមសម្រាកក្នុងទីនោះ ។ ជាងធ្នាំងពោលថា ក្នុងទីនេះបព្វជិតម្នាក់លោកចូលទៅមុនហើយ លោកម្ចាស់ចូរសួរគេចុះ ។ មាតង្គតាបសនោះ កាន់យកបរិក្ខាររបស់ខ្លួន ឈរជិតទ្វាររោងជាងធ្នាំង ពោលថា លោកអាចារ្យ មេត្តាឲ្យឱកាសខ្ញុំសម្រាកក្នុងទីនេះត្រឹមតែមួយរាត្រីចុះ ។ ជាតិមាឥសី ពោលថា ចូលមកចុះលោក ទើបសួរទៅថា លោកគោត្រអ្វី ។ ឆ្លើយថា ខ្ញុំគោត្រចណ្ឌាល ។ ជាតិមាឥសីពោលថា ខ្ញុំមិនអាចអង្គុយក្នុងកន្លែងតែមួយជាមួយនឹងអ្នកបានទេ ចូរទៅកន្លែងម្ខាងចុះ ។ មាតង្គតាបស ក្រាលកម្រាលស្មៅហើយ ក៏ដេកក្នុងទីនោះឯង ។ ជាតិមាឥសីដេកផ្អែកទ្វារ ។ ចំណែកមាតង្គតាបស ចេញទៅដើម្បីបន្ទោបង់បស្សាវៈ ទើបជាន់ទ្រូងជាតិមាឥសីនោះ ។ កាលជាតិមាឥសីសួរថា អ្នកណាហ្នឹង ។ ទើបពោលថា ខ្ញុំលោកអាចារ្យ ។ ឱ! មនុស្សចណ្ឌាល អ្នក

ឯងមិនឃើញផ្លូវកន្លែងដទៃទេឬ ។ បើដូច្នេះ លោកមិនត្រូវមកជាន់ខ្ញុំទេ ។ លោកអាចារ្យ ព្រោះខ្ញុំមិនឃើញ ទើបជាន់ ។ មេត្តាលើកទោសឲ្យខ្ញុំផង ។ កាលមហាបុរសចេញទៅខាងក្រៅ ជាតិមាតសីនោះគិតថា មនុស្សនេះសូម្បីមកពេលក្រោយ ក៏នឹងមកខាងនេះ ទើបដេកបែរត្រឡប់ទៅខាងនោះវិញ ។ ចំណែកមហាបុរស ចូលទៅដោយគិតថា លោកអាចារ្យដេកបែរក្បាលមកផ្លូវនេះ យើងនឹងទៅផ្លូវដែលជិតជើងរបស់លោក ដូច្នេះ ទើបចូលទៅ ក៏ជាន់ចំទ្រូងទៀត ។ ក៏កាលតសីនោះសួរថា អ្នកណាហ្នឹង ទើបឆ្លើយថា ខ្ញុំលោកអាចារ្យ ។ តសីនោះពោលថា ពីដំបូងជាន់ម្តង អ្នកឯងមិនដឹងឬ ទើបធ្វើ ឥឡូវនេះ អ្នកធ្វើប៉ះពាល់យើង កាលព្រះអាទិត្យរះឡើង សីសៈរបស់អ្នកចូរបែក ៧ ចំរៀក មហាបុរសមិននិយាយអ្វីៗ មុនពេលអរុណរះឡើងនុ៎ះឯង បានចាប់ព្រះអាទិត្យទុក មិនព្រមឲ្យព្រះអាទិត្យរះឡើង ពួកមនុស្ស និងសត្វតិរច្ឆានមានជំរី សេះជាដើម ក៏ភ្ញាក់ផ្អើល ។

ពួកមនុស្សនាំគ្នាទៅកាន់រាជត្រកូល ទូលថា សូមតេជៈ ដែលឈ្មោះថា អ្នកដែលមិនភ្ញាក់ផ្អើលទូទាំងនគរមិនមាន តែមិនប្រាកដថា អរុណនឹងរះឡើង តើមានអ្វីជាហេតុហ្ន៎ ។ សូមព្រះអង្គមេត្តាត្រួតត្រាព្រះនគរ ។ មនុស្សទាំងនោះ កាលត្រួតមើល ក៏ជួបតាបសពីរនាក់នៅក្នុងរោងជាងឆ្នាំង ទើប

គិតថា នេះនឹងជាការធ្វើរបស់តាបសទាំងពីរនេះ ទើបបាននាំគ្នាទៅក្រាបទូលព្រះរាជា ព្រះរាជាត្រាស់ថា ពួកអ្នកឯងចូរ ទៅសួរតាបសនោះមើល ហើយទើបនាំគ្នាមកសួរឥសីឈ្មោះជាតិមានោះថា ពួកលោកធ្វើឲ្យងងឹតឬ ។ ជាតិមាឥសីឆ្លើយថា ខ្ញុំមិនបានធ្វើ តែតាបសកោងខ្លួនអាក្រក់ មានមាយាច្រើននេះធ្វើ ចូរសួរមើលចុះ ។ មនុស្សទាំងនោះ ទើបទៅសួរមហាបុរសថា លោកម្ចាស់ លោកធ្វើឲ្យងងឹតឬ ។ តាបសឆ្លើយថា មែន អាចារ្យម្នាក់នេះបានផ្តាសាខ្ញុំ ព្រោះដូច្នោះ ខ្ញុំទើបធ្វើ ។ មនុស្សទាំងនោះទើបទៅក្រាបទូលព្រះរាជា ។ ចំណែកព្រះរាជាស្តេចមក ត្រាស់សួរមហាបុរសថា លោកម្ចាស់ លោកធ្វើឲ្យងងឹតឬ ។ តាបសទូលថា សូមថ្វាយ ព្រះពរមហាបពិត្រ ។ ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វីលោកម្ចាស់ ។ តាបសទូលថា អាត្មាត្រូវតាបសនេះផ្តាសា បើតាបសនេះសូមខមាទោសអាត្មា អាត្មានឹងលែងព្រះអាទិត្យ ព្រះរាជាត្រាស់ថា លោកម្ចាស់ លោកចូរខមាទោសតាបសនេះចុះ ។ ចំណែកឥសីទូលថា អ្នកមានជាតិដូចយើងនឹងឲ្យខមាទោសមនុស្សចណ្ឌាលដូច្នោះឬ អាត្មាភាពមិនសូមខមាទោសទេ ។

លំដាប់នោះ ពួកមនុស្សពោលនឹងតាបសនោះថា លោកនឹងមិនសូមខមាទោសតាមសេចក្តីពេញចិត្តរបស់ខ្លួនឬ ដូច្នេះ ហើយនាំគ្នាចាប់ដៃ និង

ជើង ហើយឲ្យដេកក្រាបទៀបជើង ហើយពោលថា សូមខមាទោសចុះ ។ តាបសនោះដេកស្ងៀម ។ មនុស្សទាំងនោះ ទើបពោលដដែលចំពោះតាបសនោះថា ចូរសូមខមាទោសក្ខាម ។ លំដាប់នោះ តាបសទើបពោលថា មេត្តាលើកទោសខ្ញុំផង លោកអាចារ្យ ។ មហាបុរសពោលថា ជាដំបូង ខ្ញុំនឹងលើកទោសឲ្យលោក ហើយព្រលែងព្រះអាទិត្យ តែកាលព្រះអាទិត្យរះឡើង សីសៈរបស់លោកនឹងបែក ៧ ចំរៀក ដូច្នេះហើយ ទើបពោលថា លោកចូរយកដុំដីស្អិត ទំហំប៉ុនក្បាល ដាក់លើក្បាលរបស់តាបសនេះ ហើយឲ្យលោកឈរត្រាំទឹកក្នុងទន្លេត្រឹម.ក ។ ពួកមនុស្សក៏បានធ្វើដូចយ៉ាងនោះ ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ វេហ៍ពលរបស់ព្រះរាជាទូទាំងដែនក៏ប្រជុំគ្នា ។ មហាបុរសបានព្រលែងព្រះអាទិត្យហើយ ។ ពន្លឺព្រះអាទិត្យមកប៉ះខ្ទប់នឹងដុំដី ។ ដុំដីនោះក៏បែក ៧ ចំរៀក ។ ក្នុងខណៈនោះឯង តាបសនោះក៏មុជចុះ រួចផុសឡើងត្រង់កំពង់មួយ ហើយក៏គេចចេញទៅ ។ ព្រះសាស្តាទ្រង់នាំរឿងនេះមក ត្រាស់ថា ឥឡូវនេះ គេបានបរិភាស (ពោលទោស) ក្នុងសម្នាក់របស់ភិក្ខុទាំងឡាយមុន ។ សូម្បីក្នុងកាលមុន គេអាស្រ័យសេចក្តីក្រោធនេះ ទើបត្រូវនិរទេសចេញពីព្រំដែន លុះទ្រង់បន្តអនុសន្ធិ កាលនឹងឲ្យឱវាទតាបសនោះ ទើបត្រាស់ថា តិស្សៈ ប្រការនោះមិនសមគួរដល់អ្នក

ផាដើម ៗ

ចប់អដ្ឋកថា តិស្សសូត្រទី៩

# អ ដ្ឋ ក ថា

## ថេរនាមសូត្រទី ១០

ក្នុង *ថេរនាមសូត្រទី ១០* មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៨៤] បទថា *វណ្ណវាទី* ប្រែថា មានប្រក្រតីពោលអានិសង្ស ។

[៣៨៨] បទថា ***យំ អតីតំ បហីនំ*** សេចក្ដីថា ឈ្មោះថា លះសេចក្ដីក្រោធនោះ ដោយការលះបង់ឆន្ទរាគៈក្នុងបញ្ចក្ខន្ធដែលជាអតីត ។ បទថា ***អនាគតំ*** សេចក្ដីថា បញ្ចក្ខន្ធដែលជាអនាគត ដែលឈ្មោះថា រលាស់ចេញបាន ដោយការលះបង់ឆន្ទរាគៈក្នុងបញ្ចក្ខន្ធនោះ ។

[៣៨៩] បទថា ***សព្វាភិភុំ*** សេចក្ដីថា គ្របសង្កត់ខន្ធ អាយតនៈ ធាតុ និងភព ៣ ទាំងអស់ ។ បទថា ***សព្វវិទុំ*** បានដល់ ដឹងច្បាស់បញ្ចក្ខន្ធជាដើម ដែលមានប្រការដូចពោលហើយទាំងអស់នោះ ។ បទថា ***សព្វេសុ ធម្មេសុ*** សេចក្ដីថា ដែលគ្រឿងលាប គឺ តណ្ហា និងទិដ្ឋិ មិនចូលទៅលាបក្នុងធម៌ទាំងពួងនោះឯង ។ បទថា ***សព្វំ ជហំ*** សេចក្ដីថា លះបញ្ចក្ខន្ធទាំងអស់នោះឯង ដោយការលះឆន្ទរាគៈក្នុងបញ្ចក្ខន្ធនោះ ។ បទថា ***តណ្ហក្ខយេ វិមុត្តំ*** បានដល់ បង្អោនទៅក្នុងព្រះនិព្វាន ពោលគឺ ធម៌ជាទីអស់ទៅនៃតណ្ហា

គឺ ក្នុងវិមុត្តិ ដែលមានព្រះនិព្វាននោះជាអារម្មណ៍ ។

ចប់អដ្ឋកថា ជេរធាមសូត្រទី ១០

# អ ដ្ឋ ក ថា

## កប្បិនសូត្រទី ១១

ក្នុង កប្បិនសូត្រទី ១១ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៩០] បទថា មហាកប្បិនោ សេចក្តីថា ព្រះមហាថេរៈដែលនៅក្នុងចំនួនព្រះមហាសាវក ៨០ អង្គ អ្នកសម្រេចកម្លាំងនៃអភិញ្ញា មានឈ្មោះយ៉ាងនេះ ។ បានឮថា ព្រះមហាថេរៈនោះ កាលនៅជាគ្រហស្ថ បានគ្រងរាជសម្បត្តិ មានអាណាខេត្តប្រមាណ ៣០០ យោជន៍ ក្នុងកុក្កុដវតីនគរ តែក្នុងកពចុងក្រោយ បានត្រាច់ផ្ទៀងសោតៈស្តាប់ពាក្យប្រៀនប្រដៅបែបនោះ ។ ត.មកថ្ងៃមួយ ទ្រង់ហែហមទៅដោយអាមាត្រ ១.០០០ នាក់ ទ្រង់បានយាងទៅហាត់ប្រាណក្នុងព្រះរាជឧទ្យាន ។ ក្នុងគ្រានោះ ឈ្មួញធ្វើដំណើរពីមជ្ឈិមប្រទេសទៅកាន់នគរនោះ ទុកដាក់ទំនិញហើយ គិតនឹងគាល់ព្រះរាជា អ្នកខ្លះកាន់គ្រឿងបណ្ណាការទៅកាន់ព្រះរាជទ្វារ បានឮថា ព្រះរាជាស្តេចយាងទៅព្រះរាជឧទ្យាន ទើបទៅកាន់ព្រះរាជឧទ្យាន ឈរត្រង់ទ្វារ បានជីងច្បាស់ដល់អ្នកយាមទ្វារ ក៏ទៅក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប ព្រះរាជាបានត្រាស់បង្គាប់ឲ្យហៅមក ត្រាស់សួរពួកអ្នកថ្វាយគ្រឿងបណ្ណាការដែលថ្វាយ

បន្តឹលឃរថា បាទាំងឡាយ ពួកលោកមកពីណា ។ ឈ្មួញទាំងនោះក្រាបទូលថា មកពីក្រុងសាវត្ថី ព្រះអង្គ ។

ព្រះរាជា. ដែនរបស់ពួកលោក មានកិច្ចាហារបានងាយទេ ។ ព្រះរាជាគ្រប់គ្រងផែនដីទ្រទ្រង់ធម៌ទេ ។

ឈ្មួញ. ករុណា ព្រះអង្គ ។

ព្រះរាជា. ក៏ក្នុងប្រទេសរបស់ពួកលោក មានសាសនាអ្វី ។

ឈ្មួញ. មានព្រះអង្គ តែអ្នកមានមាត់មានអាហារនៅសេសសល់ មិនអាចនឹងនិយាយបាន ។

ព្រះរាជាបានព្រះរាជទានទឹកដោយព្រះកុណ្ឌីមាស ។ ឈ្មួញទាំងនោះខ្ពុរមាត់ហើយ បែរមុខឆ្ពោះព្រះទសពល ផ្គងអញ្ជលី ហើយក្រាបទូលថា មហាបពិត្រ ឈ្មោះថា **ព្រះពុទ្ធរតនៈ** បានកើតឡើងហើយ ក្នុងប្រទេសរបស់ខ្ញុំព្រះអង្គ ។ ពេលព្រះរាជាទ្រង់ស្តាប់ថា **ពុទ្ធោ** បីតិកើតឡើង ផ្សាយទៅទូទាំងព្រះវរកាយរបស់ព្រះរាជា ។ លំដាប់នោះ ព្រះរាជាទើបត្រាស់ថា បា! ទាំងឡាយ លោកចូរពោលថា **ពុទ្ធោ** ចុះ ។ ព្រះរាជាត្រាស់បង្គាប់ឲ្យពួកឈ្មួញពោលឡើង ៣ ដង យ៉ាងនេះថា មហាបពិត្រ ខ្ញុំព្រះអង្គទាំងឡាយពោលថា **ពុទ្ធោ** ដូច្នេះ ទើបត្រាស់ថា បទថា **ពុទ្ធោ** មានគុណរកប្រមាណ

មិនបាន នរណាៗ មិនអាចធ្វើប្រមាណនៃបទថា ពុទ្ធោ នោះបាន ទើបជ្រះថ្លាក្នុងព្រះពុទ្ធនោះឯង ទើបបានប្រទានទ្រព្យមួយសែន ហើយត្រាស់សួរទៀតថា សាសនាដទៃមានទេ ។

ឈ្មួញ. មានព្រះអង្គ គឺ ឈ្មោះ ធម្មរតនៈ កើតឡើងហើយ ។ ព្រះរាជាទ្រង់ស្តាប់សូម្បីដូច្នោះហើយ ទើបទ្រង់ទទួលប្តេជ្ញាដល់ ៣ ដង ដូចយ៉ាងនោះ ហើយព្រះរាជទានទ្រព្យមួយសែនទៀត ត្រាស់សួរទៀតថា សាសនាអ្វីដទៃមានទេ ។

ឈ្មួញ. មានព្រះអង្គ គឺ ព្រះសង្ឃរតនៈ កើតឡើងហើយ ។ ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ទើបទទួលប្តេជ្ញា ៣ ដង ដូចមុន ទ្រង់ព្រះរាជ-ទានទ្រព្យមួយសែនទៀត ទ្រង់លិខិតសេចក្តីដែលព្រះរាជទានទ្រព្យទុកក្នុងព្រះរាជសាសន៍ ហើយបញ្ជូនទៅដោយព្រះតម្រាស់បង្គាប់ថា បា!ទាំងឡាយពួកលោកចូរទៅសម្នាក់របស់ព្រះទេវី ។ កាលពួកឈ្មួញទាំងនោះទៅហើយព្រះរាជាបានត្រាស់សួរអាមាត្រទាំងឡាយថា បា!ទាំងឡាយ ព្រះពុទ្ធទ្រង់ឧប្បត្តិឡើងហើយ ពួកលោកនឹងធ្វើអ្វី ។ អាមាត្រទាំងឡាយក្រាបទូលថា មហាបពិត្រ ព្រះអង្គបំណងនឹងធ្វើអ្វី ។

ព្រះរាជា. យើងនឹងបួស

អាមាត្យ. សូម្បីពួកខ្ញុំព្រះអង្គ ក៏នឹងបួស ។ គេទាំងអស់នោះមិនជាប់ជំពាក់ក្នុងផ្ទះ ឬរណ្ដៅទ្រព្យ ទើបនាំគ្នាចេញបួសព្រមជាមួយអ្នកបរទេះសេះ ។

ពួកឈ្មួញទៅកាន់សម្នាក់ព្រះអនោជាទេវី សម្ដែងព្រះរាជសាសន៍ព្រះទេវីទ្រង់អានហើយ ត្រាស់សាកសួរថា ព្រះរាជាព្រះរាជទានកហាបណៈដល់ពួកលោកជាច្រើន ពួកលោកធ្វើអ្វីដល់ព្រះរាជា ។

ឈ្មួញ. ពួកខ្ញុំព្រះអង្គ នាំព្រះរាជសាសន៍ដែលគួរស្រឡាញ់មក ព្រះនាង ។

ព្រះទេវី. ពួកលោកអាចឲ្យពួកយើងដឹងខ្លះបានទេ ។

ឈ្មួញ. បានព្រះនាង តែអ្នកមានមាត់មានអាហារដែលសេសសល់មិនអាចនឹងពោលបាន ។ ព្រះនាងបានឲ្យប្រទានទឹកដោយព្រះកុណ្ឌីមាសពួកឈ្មួញទាំងនោះខ្ពុរមាត់ហើយ ក្រាបទូលដោយន័យដែលបានក្រាបទូលចំពោះព្រះរាជា ។ សូម្បីព្រះនាងបានស្ដាប់ហើយ ទ្រង់កើតបាមោជ្ជៈ ទ្រង់ទទួលបេ្តជ្ញា ៣ ដង ក្នុងបទមួយៗ ដោយន័យដូចពោលហើយនោះឯងបានព្រះរាជទានទ្រព្យ ៩ សែន បែងចែកជា ៣ ចំណែក តាមចំនួនបេ្តជ្ញា ។ ពួកឈ្មួញ បានទ្រព្យទាំងអស់មួយលានពីរសែន ។

លំដាប់នោះ ព្រះទេវីត្រាស់សួរពួកឈ្នួញថា ព្រះរាជាប្រថាប់នៅទីណា ។ ពួកឈ្នួញទូលថា ព្រះរាជាស្តេចចេញព្រះផ្នួសហើយ ព្រះនាង ។ ព្រះទេវីទ្រង់បញ្ជូនពួកឈ្នួញទាំងនោះទៅ ដោយព្រះតម្រាស់ថា បើដូច្នោះ ពួកលោកចូរទៅចុះ ហើយត្រាស់ឲ្យហៅរកកិរិយារបស់ពួកអាមាត្រ ដែលតាមស្តេច ត្រាស់សួរថា ពួកនាងដឹងទីកន្លែងដែលស្វាមីរបស់ខ្លួនទៅឬទេ ។ កិរិយាទាំងនោះទូលថា ជ្រាប ព្រះនាងម្ចាស់ ពួកគេតាមស្តេចប្រពាតព្រះរាជឧទ្យាន ។ ព្រះទេវីមានព្រះតម្រាស់ថា ពួកគេទៅល្អហើយ នាងទាំងឡាយកាលពួកគេទៅក្នុងសួននោះ បានស្តាប់ថា ព្រះពុទ្ធកើតហើយ ព្រះធម៌កើតហើយ ព្រះសង្ឃកើតហើយ ទើបនាំគ្នាទៅបួសក្នុងសម្នាក់ព្រះទសពល ពួកនាងនឹងធ្វើដូចម្តេច ។ នាងជាកិរិយាអាមាត្យទាំងនោះទូលថា ចំណែកព្រះនាងម្ចាស់ បំណងនឹងធ្វើយ៉ាងណា ។ ព្រះនាងត្រាស់ថា យើងនឹងបួស យើងមិនលិទ្ធកំហាកដែលគេទាំងនោះខាកចោលហើយ ទុកត្រង់អណ្តាត ។ កិរិយាទាំងនោះទូលថា បើដូច្នោះ សូម្បីពួកនាងខ្ញុំក៏នឹងបួស ។ កិរិយាអាមាត្យទាំងអស់នាំគ្នាទឹមរថចេញទៅ ។

ចំណែកព្រះរាជាព្រមដោយអាមាត្រមួយពាន់ ស្តេចយាងដល់ត្រើយទន្លេគង្គា ក្នុងវេលានោះទន្លេគង្គាមានទឹកពេញប្រៀប ។ លំដាប់នោះ ពួកគេ

ឃើញដូច្នោះ ទើបគិតថា ទន្លេគង្គានេះទឹកពេញប្រៀប សម្បូរទៅដោយត្រីកាច ឯពួកទាសៈ ឬមនុស្សដែលមកជាមួយពួកយើង នឹងធ្វើទូក ឬក្បូនឲ្យពួកយើងក៏មិនមាន ដែលឈ្មោះថា គុណរបស់ព្រះសាស្តានេះ ផ្សាយទៅខាងក្រោមដល់អវិចី ខាងលើដល់ភវគ្គព្រហ្ម ប្រសិនបើព្រះសាស្តានេះជាព្រះសម្មាសម្ពុទ្ធ សូមកុំឲ្យសើមសូម្បីក្រចកជើងសេះ ដូច្នេះ ហើយបំបោលសេះលើខ្នងទឹក ។ សូម្បីក្រចកជើងសេះមួយក្បាល ក៏មិនសើម ។ ពួកគេទៅតាមផ្លូវដែលស្តេចយាងទៅ រហូតដល់ត្រើយខាងនោះ និងដល់ទន្លេមួយខ្សែធំដទៃខាងមុខទៀត ។ ក្នុងទីនោះ មិនមានសច្ចកិរិយាយ៉ាងដទៃ ពួកគេឆ្លងទន្លេទទឹងកន្លះយោជន៍នោះ ដោយសច្ចកិរិយានោះឯង ។ លំដាប់នោះ ពួកគេដល់ទន្លេធំ ទី ៣ ឈ្មោះចន្ទភាគា បានឆ្លងទន្លេនោះដោយសច្ចកិរិយានោះឯង ។ ថ្ងៃនោះ វេលាជិតភ្លឺ ព្រះសាស្តាស្តេចយាងចេញចាកមហាករុណាសមាបត្តិ ទ្រង់ត្រួតមើលសត្វលោក ទ្រង់ជ្រាបថា ថ្ងៃនេះព្រះរាជាមហាកប្បិន ទ្រង់លះបង់រាជាណាចក្របីរយយោជន៍ ហែហមទៅដោយពួកអាមាត្រមួយពាន់មក ដើម្បីបួសក្នុងសម្នាក់របស់តថាគត ទ្រង់មានព្រះតម្រិះថា តថាគតគួរទទួលពួកគេ ទ្រង់ជម្រះព្រះសរីរកាយពីព្រឹកព្រលឹម មានភិក្ខុសង្ឃជាបរិវារ ស្តេចបិណ្ឌបាតក្នុងក្រុងសាវត្ថី ក្រោយពីសោយព្រះក្រយា-

ហារហើយ ស្តេចត្រឡប់ចាកបិណ្ឌបាត ព្រះអង្គទ្រង់ប្រដាប់បាត្រ និងចីវរ ស្តេចហោះទៅ ប្រថាប់គង់ពត់ភ្នែនតាំងព្រះសតិ បញ្ចេញព្រះពុទ្ធឆព្វណ្ណរង្សី ក្រោមដើមជ្រៃធំ ដែលដុះត្រង់កំពង់ចូងរបស់ពួកគេទាំងនោះ នាមាត់ច្រាំង ទន្លេចន្ទភាគា ។ ត្រង់កំពង់នោះ ពួកគេក្រឡេកមើលព្រះពុទ្ធឆព្វណ្ណរង្សី ដែលផ្សាយចេញផ្លែលធ្វាត់ ឃើញព្រះភក្ត្ររបស់ព្រះទសពលមានសិរីដូច ព្រះចន្ទពេញវង់ ទើបធ្វើទុកក្នុងចិត្តដោយការឃើញទុំះឯងថា ព្រះសាស្តា ដែលពួកយើងបួសឧទ្ទិសនោះ ជាអង្គនេះពិត ទើបបន្ទោនកាយចុះ ហើយ នាំគ្នាថ្វាយបង្គំព្រះសាស្តាតាំងពីទីឃើញ ។ ព្រះរាជាទ្រង់ចាប់ខ្នងព្រះពុទ្ធ-បាទទាំងពីរថ្វាយបង្គំ ហើយប្រថាប់គង់ក្នុងទីដ៏សមគួរមួយ ព្រមទាំងពួក អាមាត្រមួយពាន់ ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ព្រះរាជា និងអាមាត្រ ទាំងនោះ ។ វេលាចប់ទេសនា ពួកគេទាំងអស់តាំងនៅក្នុងព្រះអរហត្ត ទូល សូមបព្វជ្ជាចំពោះព្រះសាស្តា ។ ព្រះសាស្តាទ្រង់ជ្រាបថា បុគ្គលទាំងនេះ កាន់ចីវររបស់ខ្លួនមកតែម្តង ព្រោះធ្លាប់បានថ្វាយចីវរទាន ទើបទ្រង់ទម្រេត ព្រះហស្តដែលមានវណ្ណៈហាក់ដូចមាស ត្រាស់ថា ចូរជាភិក្ខុចុះ ធម៌តថាគត ពោលល្អហើយ ចូរប្រព្រឹត្តព្រហ្មចរិយៈដើម្បីដល់បំផុតនៃកងទុក្ខដោយប្រពៃ ចុះ ។ លោកដ៏មានអាយុទាំងនោះ បានបព្វជ្ជា និងឧបសម្បទហើយ ។ លោក

ទាំងនោះ ដូចជាព្រះថេរៈមានវស្សា ៦០ បានហែហមព្រះសាស្តាហើយ ។

ចំណែកព្រះនាងអនោជាទេវី មានរថមួយពាន់ជាបរិវារ ស្តេចយាង ដល់ត្រើយទន្លេគង្គា មិនបានឃើញទូក ឬក្បូនដែលមកជាប្រយោជន៍ដល់ ព្រះរាជា តែព្រោះព្រះនាងជាស្ត្រីឆ្លាត ទើបមានព្រះតម្រិះថា ព្រះរាជាទ្រង់ នឹងធ្វើសច្ចកិរិយាទើបស្តេចទៅ ក៏ព្រះសាស្តានោះ ទ្រង់មិនបានកើតដើម្បី ប្រយោជន៍ដល់ព្រះរាជា និងអាមាត្រទាំងនោះតែម្យ៉ាងប៉ុណ្ណោះ ដោយប្រការ ដូច្នេះ បើព្រះសាស្តានោះជាព្រះសម្មាសម្ពុទ្ធ សូមឲ្យរថទាំងឡាយរបស់ពួក យើងកុំបានលិចចុះក្នុងទឹក ដូច្នេះ ហើយឲ្យរថត្រាច់ទៅលើខ្នងទឹក ។ សូម្បី ត្រឹមតែកង់រថក៏មិនសើម ។ សូម្បីទន្លេទី ២ និងទី ៣ ព្រះនាងក៏ឆ្លងបាន ដោយសច្ចកិរិយានោះឯង កាលកំពុងឆ្លងទន្លេនុ៎ះឯង ព្រះនាងបានទតឃើញ ព្រះសាស្តាត្រង់ក្រោមដើមជ្រៃ ។ ព្រះសាស្តាមានព្រះតម្រិះថា កាលស្ត្រី ទាំងនេះឃើញស្វាមីរបស់ខ្លួន ឆន្ទរាគៈនឹងកើតឡើងធ្វើអន្តរាយចំពោះមគ្គ-ផល តែឆន្ទរាគៈនោះនឹងមិនអាចធ្វើអន្តរាយយ៉ាងនេះបាន ទ្រង់បានធ្វើដោយ វិធីដែលពួកគេនឹងឃើញគ្នានិងគ្នាមិនបាន ។ ស្រីទាំងអស់នោះ ឡើងពី កំពង់ អង្គុយថ្វាយបង្គំព្រះទសពល ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ស្ត្រី ទាំងនោះ ។ វេលាចប់ទេសនា ស្ត្រីទាំងនោះ តាំងនៅក្នុងសោតាបត្តិផល

ហើយទើបបានឃើញគ្នានិងគ្នា ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា សូមឧប្បល-វណ្ណាចូរមក ។ ព្រះនាងឧប្បលវណ្ណាថេរីមកហើយ ឲ្យស្ត្រីទាំងនោះបព្វជ្ជា ហើយនាំទៅកាន់សម្នាក់នាងភិក្ខុនី ។ ព្រះសាស្តានាំភិក្ខុ ១.០០០ រូប ហោះទៅវត្តជេតពន ។ លោកសំដៅយកព្រះមហាកប្បិននេះ ទើបបានពោលពាក្យនេះថា **មហាកប្បិនោតិ ឯវំនាមកោ អភិញ្ញាពលប្បត្តោ អសីតិមហាសា-វកានំ អព្ភន្តរោ មហាថេរោ** ដូច្នេះ ។

[៣៩២] បទថា **ជនេតស្មឹ** ប្រែថា ក្នុងជនុំជនអ្នកឲ្យកំណើត អធិ-ប្បាយថា ក្នុងពពួកសត្វ ។ បទថា **យេ គោត្តបដិសារិនោ** សេចក្តីថា បណ្តាអ្នកដែលប្រកាន់ គឺ បដិបត្តិញាណគោត្រថា ពួកយើងជាវាសេដ្ឋគោត្រដូច្នេះជាដើម ក្សត្រិយ៍ជាអ្នកប្រសើរបំផុត ។ បទថា **វិជ្ជាចរណសម្បន្នោ** បានដល់ អ្នកប្រកបដោយវិជ្ជា ៨ ប្រការ និងចរណធម៌ ១៥ ប្រភេទ ។ បទថា **តបតិ** ប្រែថា រមែងរុងរោចន៍ ។ បទថា **ឈាយី តបតិ ព្រាហ្ម-ណោ** សេចក្តីថា ព្រាហ្មណ៍ដែលជាខីណាស្រព សម្ចឹងឈានពីរយ៉ាង រមែងរុងរោចន៍ក្រៃលែង ក៏ខណៈនោះ ព្រះកាឡុទាយីត្ថេរ អង្គុយសម្ចឹងឈានពីរយ៉ាងនៅក្នុងទីមិនឆ្ងាយ ។ បទថា **ពុទ្ធោ តបតិ** សេចក្តីថា ព្រះសព្វញ្ញុពុទ្ធរមែងរុងរោចន៍ ។ បានឮថា នេះជាមង្គលគាថាទាំងអស់ ។

បានឮមកថា ព្រះបាទភាតិករាជឲ្យធ្វើការបូជាយ៉ាងហើយ ត្រាស់ចំពោះអ្នកជាអាចារ្យថា សូមលោកចូរប្រាប់ជ័យមង្គលណាមួយ ដែលមិនផុតពីព្រះរតនត្រ័យ ។ អ្នកជាអាចារ្យពិចារណាដល់ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក កាលនឹងពោលមង្គលគាថានេះ ទើបពោលថា **ទិវា តបតិ អាទិច្ចោ** ព្រះអាទិត្យភ្លឺក្នុងពេលថ្ងៃ ដូច្នេះ ហើយផ្គងអញ្ជលីដល់ព្រះអាទិត្យដែលលិចទៅ ពោលថា **រត្តិមាភាតិ ចន្ទិមា** ព្រះចន្ទរមែងភ្លឺក្នុងពេលយប់ ដូច្នេះ ហើយផ្គងអញ្ជលីដល់ព្រះចន្ទដែលកំពុងរះឡើង ពោលថា **សន្នទ្ធោ ខត្តិយោ តបតិ** ក្សត្រិយ៍ទ្រង់ពាក់គ្រោះ រមែងល្អស្រស់ ដូច្នេះ ហើយផ្គងអញ្ជលីដល់ព្រះរាជា ពោលថា **ឈាយី តបតិ ព្រាហ្មណោ** ព្រាហ្មណ៍អ្នកសម្លឹងឈាន រមែងរុងរឿង ដូច្នេះ ហើយផ្គងអញ្ជលីដល់ភិក្ខុសង្ឃ ពោលថា **ពុទ្ធោ តបតិ តេជសា** ព្រះពុទ្ធជាម្ចាស់ រមែងរុងរឿងដោយតេជៈ ដូច្នេះ ហើយផ្គងអញ្ជលីដល់មហាចេតិយ ។ លំដាប់នោះ ព្រះរាជាត្រាស់នឹងលោកអាចារ្យថា លោកកុំដាក់ដៃចុះ ហើយទ្រង់ប្រគល់ទ្រព្យមួយពាន់ទុកក្នុងដៃដែលលើកឡើងនុ៎ះឯង ។

ចប់អដ្ឋកថា កប្បិនសូត្រទី ១១

# អ ដ្ឋ ក ថា

## សហាយសូត្រទី ១២

ក្នុងសហាយសូត្រទី ១២ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៩៥] បទថា **ចិររត្តំ សមេតិកា** បានដល់ ជាអ្នកមានលទ្ធិតាំងនៅស្មើគ្នា ជាគូគ្នាសូម្បីរហូតអស់កាលយូរ ។ បានឮថា បព្វជិតទាំងនោះបានត្រាច់ទៅរួមគ្នារហូតអស់ ៥ រយជាតិ ។ បទថា **សមេតិ នេសំ សទ្ធម្មោ** សេចក្ដីថា ឥឡូវនេះសាសនធម៌នេះ របស់បព្វជិតទាំងនេះ ប្រៀបធៀបគ្នា ស្មើគ្នា ។ បទថា **ធម្មេ ពុទ្ធប្បវេទិតេ** សេចក្ដីថា ក្នុងធម៌ដែលព្រះមានព្រះភាគទ្រង់ប្រកាសហើយ អធិប្បាយថា សាសនធម៌ រមែងស្អាតដោយធម៌នោះ ។ បទថា **សុវិនីតា កប្បិនេន** សេចក្ដីថា ព្រះឧបជ្ឈាយ៍របស់ខ្លួនណែនាំដោយល្អ ក្នុងធម៌ដែលព្រះអរិយៈប្រកាសហើយ ។ ពាក្យដ៏សេសគ្រប់ៗ បទ ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា សហាយសូត្រទី ១២

## ចប់ភិក្ខុសំយុត្ត

### រួមក្នុងវគ្គនេះមាន ១២ អដ្ឋកថា


១-អដ្ឋកថា កោលិតសូត្រ
២-អដ្ឋកថា ឧបតិស្សសូត្រ
៣-អដ្ឋកថា ឃដសូត្រ
៤-អដ្ឋកថា នវសូត្រ
៥-អដ្ឋកថា សុជាតសូត្រ
៦-អដ្ឋកថា ភទ្ទិយសូត្រ
៧-អដ្ឋកថា វិសាខសូត្រ
៨-អដ្ឋកថា នន្ទសូត្រ
៩-អដ្ឋកថា តិស្សសូត្រ
១០-អដ្ឋកថា នាមសូត្រ
១១-អដ្ឋកថា កប្បិនសូត្រ
១២-អដ្ឋកថា សហាយសូត្រ


# ចប់អដ្ឋកថា

# សំយុត្តនិកាយ និទានវគ្គ

# ចតុត្ថភាគ

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស $ 2.000 US

តាមរយៈភិក្ខុធម្មបញ្ញោ ជុំ សាវឿន វត្តពន្លឺពុទ្ធចក្រ
នៅរដ្ឋមាសាជូសេត សហរដ្ឋអាមេរិក

| | |
|---|---|
| -សមាគមពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | $ 300 US |
| -ភិក្ខុវិជ្ជាសម្បន្នោ ឈួម សំបូរ និងឧបាសិកាគង់ គី | $ 200 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 105 US |
| -ឧបាសិកា ជីវ យួម និងស្វាមី ព្រមទាំងបុត្ត | $ 101 US |
| -ឧបាសក សោម រតនៈ និងភរិយា " ខេត្តព្រៃវែង " | $ 100 US |
| -សីលវត្តី នួន សូនី និងបុត្ត នាងវ៉ង់ | $ 100 US |
| -លោក គ្រី សុភី និងភរិយា ផៃ សុណាំង ព្រមទាំងបុត្ត | $ 100 US |
| -លោក តឹក គ្រី និងភរិយា ព្រមទាំងបុត្ត | $ 100 US |
| -ឧបាសក កែម សាគុណ ឧបាសិកា ជា សុភាព | $ 100 US |
| -ឧបាសក លន ចំរើន ឧបាសិកា ម៉ុក ថានិ | $ 100 US |
| -ឧបាសក ម៉ៅ ប៊ួយ ឧបាសិកា ម៉ៅ លន់<br>-ម៉ៅ ម៉ារ៉ា និងសៀង ថៃបញ្ញារិទ្ធ ព្រមទាំងបុត្ត<br>-ម៉ៅ ម៉ារ៉ង ម៉ៅ គឹមអាន ម៉ៅ គឹមសៀង<br>-ម៉ៅ ប៊ុនសន្ថា ក្លួយស្រី ធន់ សន្ថានី | $ 700 US |
| -ឧបាសិកា ពិន សាមឿន និងបុត្ត | $ 50 US |
| -ឧបាសិកា ពិន សាម៉ុន និងបុត្ត | $ 50 US |
| -ឧបាសិកា ប៊ុន សារ៉ុម និងបុត្ត | $ 50 US |
| -ឧបាសិកា គង់ ជី និងបុត្ត | $ 50 US |

-ឧបាសិកា ឡាច ម៉ាឡៃ និងបុត្ត $ 50 US

-ឧបាសិកា ទូត ច័ន្ទវណ្ណី និងបុត្ត $ 50 US

-ឧបាសិកា ម៉ែន សាវ៉ាត $ 50 US

-ឧបាសិកា ពិន សាត $ 50 US

-ឧបាសិកា អ៊ុំ សាត $ 50 US

-លោក ណៃ សារិន និងឧបាសិកា ជា សូភី $ 50 US

-លោក កែវ ណាត និងឧបាសិកា សឹម គឿន $ 50 US

-ឧបាសក កុក ឆាយ និងកូនប្រុស ឧបាសក តាំង សុផល និងភរិយា ព្រមទាំងបុត្ត នៅខេត្តបាត់ដំបង $ 50 US

-ឧបាសិកា សៀន សេង និងបុត្ត $ 20 US

-ឧបាសក ឡាង ឆរី និងភរិយា ព្រមទាំងបុត្ត $ 20 US

-ឧបាសក ម៉ឺន ប៊ុនហេង និងឧបាសិកា គូវ៉ាញ $ 20 US

-ឧបាសក ប៉ោ ហេង និងឧបាសិកា លន់ ឈុនលី $ 20 US

-ឧបាសិកា ពិន សាម៉ុន $ 20 US

-ឧបាសក កែវ សារិន ឧបាសិកា សំឯម $ 15 US

-ឧបាសិកា ប៊ុន សារុំ $ 10 US

-ឧបាសិកា ហាក់ សៃហេង $ 10 US

-ឧបាសិកា ទេព សុផល $ 10 US

-ឧបាសិកា ទេព ណាម $ 10 US

-ឧបាសក គឹម កក់ និងភរិយា ពិសី $ 10 US

-ឧបាសិកា ទឹម សារី និងបុត្ត $ 10 US

-ឧបាសិកា តាំង ផល្លា ព្រមទាំងស្វាមី និងបុត្ត $ 10 US

-ឧបាសក តាំង សុខឡាយ ភរិយា និងបុត្ត $ 10 US

-អ្នកស្រី បុប្ផអ៊ីវ និងស្វាមី ព្រមទាំងបុត្ត $ 10 US

-ឧបាសក ឃិន ឈួ និងភរិយា ព្រមទាំងបុត្ត $ 6 US

-ឧបាសក តាំង សុខឡាយ ឧបាសិកា សន ស៊ីណែត និងបុត្ត នៅខេត្តបាត់ដំបង $ 5 US

## តាមរយៈភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ប្រទេសអូស្ត្រាលី

| | |
|---|---|
| -ភិក្ខុ ចៅ សៀប " អូស្ត្រាលី " | 100 AUS |
| -ពុទ្ធបរិស័ទច្រើននាក់ " ម៉ែលប៊ន " | 955 AUS |
| -បុណ្យនៅផ្ទះឧបាសិកា លឹម ស៊ូឆេង | 627 AUS |
| -បុណ្យនៅផ្ទះឧបាសិកា ស៊ុយ មន្នា ព្រមទាំងកូនចៅ | 450 AUS |
| -បុណ្យនៅផ្ទះឧបាសិកា អ៊ូច សុផល្លី ព្រមទាំងបុត្ត | 400 AUS |
| -ឧបាសក ឡៅ គីមងួន ឧបាសិកា ដួង លី | 200 AUS |
| -បុណ្យនៅផ្ទះឧបាសិកា តែ យក់ហ៊ុន | 200 AUS |
| -ឧបសិកា គង់ សារឿម | 200 AUS |
| -លោកជំទាវ " ឯកអគ្គរដ្ឋទូតអាឡឺម៉ង់ " | 100 US |
| -ឧបាសិកា កូវ សារី | 100 AUS |
| -ឧបាសិកា ឈ គិមស៊ិន និងបុត្ត សំ ថានី | 100 AUS |
| -លោក ឥន ចាវ៉ាន់ ឧបាសិកា យ៉ុម យ៉ា | 100 AUS |
| -ឧបាសក ឌី មុយ ឧបាសិកា តែ ចាន់ណាវ៉ា | 100 AUS |
| -ឧបាសិកា ឯម ផាយ៉,ឆេង លន់,ម៉ា ឈួអៀ,អាបួយ | 70 AUS |
| -ឧបាសក ឈិត ទ្រី ឧបាសិកា បាន់ ណៃហ៊ាង | 50 AUS |
| -ឧបាសិកា សុឃឿន ប៊ូ | 50 AUS |
| -ឧបាសក ឡុង ហ៊ន ឧបាសិកា លិម យូអេង និងបុត្ត | 50 AUS |
| -ឧបាសិកា ហេង ប៉េគី ព្រមទាំងកូនចៅ | 50 AUS |
| -ឧបាសិកា ស៊ុម គិមហេង | 50 AUS |
| -ឧបាសិកា ឃីម វីឡាត់ | 50 AUS |
| -ឧបាសក តូ សរ៉ឿន ឧបាសិកា មាន សុវត្ថិ និងបុត្ត | 50 AUS |
| -ឧបាសក មង្គល ផន ឧបាសិកា គឹម លាភ ( មាណ) | 50 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 50 AUS |
| -ឧបាសិកា ផ្លោក វណ្ណា | 40 AUS |
| -ឧបាសិកា សំ សុមុន្នា ស្វាមី និងបុត្ត | 30 AUS |
| -ឧបាសិកា រ័ត្ន គីមសាន | 30 AUS |
| -ឧបាសិកា ខូវ ម៉េងលួង ព្រមទាំងស្វាមី និងបុត្ត | 30 AUS |
| -ឧបាសក ហៀក ប៉េងហួរ ឧបាសិកា ផ្លោក ម៉ុង | 30 AUS |
| -ឧបាសិកា ទូច សីណា និងស្វាមី | 20 AUS |

| | |
|---|---|
| -ឧបាសក ស៊ូ ឃីម ឧបាសិកា ស៊ូ សៀងតិច | 20 AUS |
| -ឧបាសក ប៉េង គ្រីគួ ឧបាសិកា គីម សៀងគួ | 20 AUS |
| -ឧបាសិកា គង់ សម្បត្តិ | 20 AUS |
| -ឧបាសិកា ចំរើន វ៉ាក់ជិត | 20 AUS |
| -ឧបាសិកា តែ យក់ហ៊ុន | 20 AUS |
| -ឧបាសិកា យ៉ា យ៉ុម | 20 AUS |
| -ឧបាសិកា លឹម ស៊ូឆេង | 20 AUS |
| -ឧបាសក សន់ ប៊ុនភាវ ឧបាសិកា កាំង គីមហាន | 20 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 20 AUS |
| -ឧបាសិកា យានី | 20 AUS |
| -សេង សៀងឈុន | 20 AUS |
| -ឧបាសក វ៉ាន់ យ៉ាណូរ៉េត ឧបាសិកា វ៉ាន់យ៉ាណូរី | 20 AUS |
| -ឧបាសិកា អ៊ុច សុផល្លី | 20 AUS |
| -ឧបាសិកា ឡាច សារិម | 15 AUS |
| -ចៃស៊ីម,ចៃខេង,អាមួយ | 15 AUS |
| -ឧបាសិកា កូវ សារី | 15 AUS |
| -ឧបាសិកា ទូច ស៊ីណា | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លីសាង | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លាង ហុងប៊ុន | 10 AUS |
| -ឧបាសិកា សៀ ចន្ថា និងគ្រួសារ | 10 AUS |
| -ឧបាសិកា កាំង អ៊ីវហ្គិច | 10 AUS |
| -ឧបាសក ក្រូច សាន | 10 AUS |
| -ឧបាសិកា ស៊ា ចាន់ថា | 10 AUS |
| -ឧបាសក ឃីម វ៉ាន់ ឧបាសិកា អ៊ុំ ខេង | 10 AUS |
| -ឧបាសក សុខ ជួន ឧបាសិកា សុខ ធួក | 10 AUS |
| -ឧបាសិកា អេង ងីមសុខ | 10 AUS |
| -ឧបាសក ឃុត សរ ឧបាសិកា សុខ សច្ចា | 10 AUS |
| -ឧបាសិកា កេសរកូល និងគ្រួសារ | 5 AUS |
| -ឧបាសិកា វ៉ាណ្ណនីសា | 5 AUS |
| -ឧបាសិកា សាន់ ឆាយ, គីម ស្រួន | 5 AUS |

| | |
|---|---|
| -ភិក្ខុ ឆុំ សាវឿន និងពុទ្ធបរិស័ទ វត្តពន្លឺពុទ្ធចក្ក | 620 USA |
| -ឧបាសក សោមរតនៈ ឧបាសិកា ស៊ុប វណ្ណា និងបុត្ត | 200 USA<br>និង 1 លានរៀល |
| -ឧបាសក តាំង សុផល ឧបាសិកា ឡុង កេន និងបុត្ត | 30 USA |
| -ហាង ពិភពកុំព្យូទ័រ | 20 USA |
| -ឧបាសិកា តាំង ផល្លា និងស្វាមី ព្រមទាំងបុត្ត | 10 USA |
| -ឧបាសក ហេង វីរិន្ទ និងភរិយា ព្រមទាំងបុត្ត | 10 USA<br>និង 2 ម៉ឺនរៀល |
| -ឧបាសក តាំង សុខឡាយ និងភរិយា ព្រមទាំងបុត្ត | 10 USA |
| -ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមឃន់ និងកូនចៅ | 5 USA<br>និង 1 ម៉ឺនរៀល |
| -ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ធីតា និងកូនចៅ | 5 USA<br>និង 1 ម៉ឺនរៀល |
| -ឧបាសិកា កំសត់ នៅស្រុកសំឡូត | 30000 រៀល |
| -ឧបាសក ម៉េង ប៊ិច ព្រមទាំងកូនចៅ | 20000 រៀល |
| -ឧបាសិកា ហួន ណេងសឹម | 20000 រៀល |
| -ឧបាសិកា គាត ស៊ីណា | 20000 រៀល |
| -ឧបាសិកា ទេព គឹមហ៊ា | 20000 រៀល |
| -ឧបាសិកា ហេង គួ | 20000 រៀល |
| -ឧបាសិកា គី ពេញ | 20000 រៀល |
| -ម៉ាឧបាសិកា ឆាយ អ៊ីសែង | 20000 រៀល |
| -ឧបាសិកា ជា នាង និងស្វាមី ព្រមទាំងបុត្ត | 20000 រៀល |
| -ឧបាសក ហុង ជ្រិន ឧបាសិកា ឡេង ចំរើន និងកូនចៅ | 20000 រៀល |
| -ឧបាសិកា កែ ថន | 10000 រៀល |
| -ឧបាសិកា អ៊ុយ លឹង | 10000 រៀល |
| -យុវជន ស៊ូ តារា | 10000 រៀល |

